ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

ឆ្នាំ ២០២១ ប្រចាំឆមាសទី១

APSARA AUTHORITY | ANGKOR SITE | OUR WORK | INTERNATIONAL COOPERATION | PROJECTS | EVENTS & NEWS | GALLERY

ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
០៦៣ ៧៦៥ ៥៧៧ ០៦៣ ៧៦៥ ៥៧៦
info@apsaraauthority.gov.kh apsaraautorite
www.apsaraauthority.gov.kh apsara authority

នាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា បានកត់ត្រា និងផ្សព្វផ្សាយជាប្រចាំនូវរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំ និង សកម្មភាពការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈគេហទំព័រ និងបណ្តាញ ទំនាក់ទំនងសង្គមរបស់អាជ្ញាធរជាតិអប្សរា និងចែកចាយទៅតាមបណ្តាញសារព័ត៌មានជាដៃគូជាច្រើនទៀត ។ ឯកសារទាំងនេះ បានជ្រួតជ្រាបដល់មហាជនទាំងក្នុងឧទ្យានអង្គរ និងមហាជនទូទៅ និងបានបង្កើនការយល់ដឹងអំពីអំពីកិច្ចការអភិរក្សបេតិកភណ្ឌ។

រាល់ព្រឹត្តិការណ៍ព័ត៌មានដែលមាននៅក្នុងឯកសារនេះ ត្រូវបានដកស្រង់ទាំងស្រុងចេញពីគេហទំព័ររបស់អាជ្ញាធរជាតិអប្សរា សម្រាប់រក្សាទុកតែប៉ុណ្ណោះ។

មាតិកា

ប្រចាំខែមករា

- សេចក្តីជូនដំណឹងស្តីពីការកែលម្អផ្លូវដើរដោយក្រាលបេតុងមានដាំស្មៅ និងដាំស្មៅ ព្រមទាំងសាងសង់ប្រព័ន្ធដោះទឹកតាមផ្លូវនៅបរិវេណព្រះលានជល់ដំរី ១
- សកម្មភាពកាត់ក្រីមែកឈើដុះលើស្ពានថ្មបុរាណជាប់ស្ពានប្រាសាទតាកែវ ២
- សកម្មភាពថែរក្សាបរិស្ថាននៅរមណីយដ្ឋានអង្គរឱ្យមានភាពបៃតង ៣
- រយៈពេល២ថ្ងៃក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៣៩សំណើ ៤
- អាជ្ញាធរជាតិអប្សរាដំណើរការជួសជុលរួតទី៣នៃប្រាសាទបាយ័ន្ត ៥
- អាជ្ញាធរជាតិអប្សរាបានបញ្ចប់ការដកហូតដើមឈើទាលងាប់មួយដើមក្នុងបរិវេណប្រាសាទបន្ទាយប្រី ៦
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៧
- វេលាយប់វែងជាងថ្ងៃ ជាមួយនឹងអាថ៌កំបាំងលើចម្លាក់ប្រាសាទអង្គរវត្ត ៨
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៩
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១០
- អាជ្ញាធរជាតិអប្សរាបន្តកែលម្អទីធ្លាបរិវេណមុខព្រះលានជល់ដំរី ១១
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១២
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៣
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៤
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅក្នុងបរិវេណប្រាសាទភិមានអាកាស... ១៥
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៦
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អញ្ជើញពិនិត្យវឌ្ឍនភាពការរៀបចំនៅមុខបរិវេណប្រាសាទអង្គរវត្ត ១៧
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អញ្ជើញពិនិត្យការកែលម្អបរិវេណមុខព្រះលានជល់ដំរី ១៨
- សារលៃកព្រះមរណទុក្ខ ១៩
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២១
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះត្រួតពិនិត្យការងារប្រចាំខែនៅក្នុងរមណីយដ្ឋានអង្គរ ២២
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ ២៣
- ស្ពានតាអោងមានអាយុកាលជិត៩០០ឆ្នាំត្រូវបានជួសជុលជាលើកដំបូងដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា...... ២៤

- អាជ្ញាធរជាតិអប្សរា ផ្លាស់ប្តូរកម្រាលឈើផ្លូវចូលប្រាសាទបន្ទាយស្រី ២៥
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៦
- សកម្មភាពកាត់ក្រីមែកឈើ និងដកហូតដើមឈើមានហានិភ័យខ្ពស់ក្នុងបរិវេណវត្តព្រះសិអារ្យមេត្រី និងវត្តតាំងតុក្នុងក្រុងអង្គរធំ ២៧
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៨
- អាជ្ញាធរជាតិអប្សរាកំពុងដំណើរការរៀបចំជួសជុលអតីតអាគារសាលាបារាំងចុងបូព៌ានៅខាងលិចប្រាសាទបាយ័ន្ត. ២៩
- អាជ្ញាធរជាតិអប្សរាអនុវត្តការងារបោះបង្គោលកំណត់ព្រំការពារនៅប្រាសាទបន្ទាយអំពិល ៣០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៣១
- ឯកឧត្តមបណ្ឌិត ហង់ ពៅ ដឹកនាំក្រុមការងារមកដិះកង់សាកល្បងលើផ្លូវកង់ថ្មីនៅរមណីយដ្ឋានអង្គរ ៣២
- អាជ្ញាធរជាតិអប្សរារៀបចំតម្រង់បង្គោលឈើ និងដាក់ខ្សែឡើងវិញនៅតាមដងផ្លូវប្រាសាទបាយ័ន្ត ៣៣
- ភ្នាក់ងារទេសចរណ៍ប្រាសាទបន្ទាយស្រី បន្តចូលរួមកិច្ចការថែទាំ និងអភិរក្សប្រាង្គប្រាសាទដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក ៣៤
- សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ ៣៥
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈអញ្ជើញជាអធិបតីកិច្ចប្រជុំបច្ចេកទេសលើកទី៣៤ និងកិច្ចប្រជុំពេញអង្គលើកទី២៧នៃអាយស៊ីស៊ី-អង្គរ ៣៦
- គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ៖ ការថែរក្សាអភិរក្សរមណីយដ្ឋានអង្គរជាកាតព្វកិច្ចរួមរបស់កម្ពុជា និងសហគមន៍អន្តរជាតិ ៣៧
- គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ចុះត្រួតពិនិត្យនិងជិះសាកល្បងលើផ្លូវកង់ដែលជាសមិទ្ធផលទេសចរណ៍ថ្មីនៅរមណីយដ្ឋានអង្គរ ៣៨
- រយៈពេល៣ថ្ងៃ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ ៣៩
- សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅតាមទីតាំងនានាក្នុងតំបន់រមណីយដ្ឋានអង្គរ ៤០
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៤១
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅខាងកើតប្រាសាទតាព្រហ្ម ៤២

ប្រចាំខែកុម្ភៈ

- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៤៥
- អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការងារជួសជុលផ្លូវដីថ្មើរជើងសម្រាប់ភ្ញៀវទេសចរដើរទស្សនាធម្មជាតិជុំវិញប្រាសាទបន្ទាយស្រី ៤៦
- សម្ភារបរិក្ខារផ្សេងៗសម្រាប់បម្រើការក្នុងឧទ្យានអង្គរតែងទទួលបានការថែទាំជាប្រចាំ ៤៧
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៤៨
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់សម្អាតបរិស្ថាន ៤៩

- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំប្រជុំត្រួតពិនិត្យតាមដានការងារអភិវឌ្ឍន៍
  ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ ៥០
- សកម្មភាពកាត់ដកហូតដើមឈើងាប់មានហានិភ័យខ្ពស់នៅតាមផ្លូវវង់ធំ និងប្រាសាទនាគព័ន្ធ ៥១
- អាជ្ញាធរជាតិអប្សរា កំពុងដាំស្មៅ និងដើមឈើ កែលម្អសោភ័ណភាពនៅផ្លូវចូលកំពង់ទឹកស្រះស្រង់........ ៥២
- អាជ្ញាធរជាតិអប្សរាប្រគល់ប័ណ្ណសរសើរដល់ប្រជាពលរដ្ឋ៧គ្រួសារដែលបានសាងសង់ផ្ទះខ្មែរ
  ត្រឹមត្រូវស្របតាមគំរូប្លង់ស្ថាបត្យកម្ម ៥៣
- សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ កន្លែងផ្តល់ចំណេះដឹងអំពីកិច្ចការស្រាវជ្រាវ
  បុរាណវិទ្យាដ៏សម្បូរបែបនៅខេត្តសៀមរាប ៥៤
- អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាល
  ចំនួន២៤៨សំណើ ក្នុងខែមករា ឆ្នាំ២០២១ .... ៥៥
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យគម្រោងការងារនៅបរិវេណប្រាសាទតាកែវ....... ៥៦
- ទំនៀមចាប់ត្រីរួមគ្នា ត្រៀមឡើងមាយរបស់អ្នកស្រុកអង្គរនៅតែបន្តប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន........ ៥៧
- វត្ថុបុរាណចំនួន៤ត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក.. ៥៨
- ដើមឈើ៤ដើមនឹងត្រូវដកហូតពីលើដងផ្លូវចាប់ពីខាងកើតប្រាសាទអង្គរវត្តដល់ខាងត្បូងប្រាសាទបន្ទាយក្តី ៥៩
- សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅតាមទីតាំងនានាក្នុងតំបន់រមណីយដ្ឋានអង្គរ ៦០
- សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី បង្ហាញពីការអភិរក្សវាយនភណ្ឌ វប្បធម៌
  និងពាណិជ្ជកម្មរបស់ប្រទេសជុំវិញដងទន្លេមេគង្គនិងទន្លេគង្គា ៦១
- អាជ្ញាធរជាតិអប្សរាកំពុងបន្តកិច្ចការអភិរក្សនិងជួសជុលពង្រឹងរចនាសម្ពន្ធឥដ្ឋនៅប្រាសាទគោកចក.................. ៦២
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
  របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៦៣
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងភាគីឥណ្ឌាជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការវប្បធម៌
  ភ្នាក់ងារទេសចរណ៍ចូលរួមសកម្មភាពថែទាំប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ.. ៦៥
- អាជ្ញាធរជាតិអប្សរាជួសជុល ថែទាំស្លាកសញ្ញាចរាចរណ៍ក្នុងតំបន់រមណីយដ្ឋានអង្គរ ៦៦
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ............... ៦៧
- ប្រជាពលរដ្ឋនៅសង្កាត់ក្របីរៀលអញ្ជើញមកទស្សនាប្រាសាទអង្គរវត្តនិងស្វែងយល់ពីសមិទ្ធផល
  ដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន ៦៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
  ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៦៩
- អាជ្ញាធរជាតិអប្សរាប្រុងពលីជួសជុលខ្លោងទ្វារខាងលិចនៃប្រាសាទចៅស្រីវិបុល ៧០
- សេចក្តីជូនដំណឹងស្តីពីការហាមបើកបរទោចក្រយានយន្ត(ម៉ូតូ)លើកំពែងក្រុងអង្គរធំក្នុងរមណីយដ្ឋានអង្គរ......... ៧១
- សាលាបារាំងខេត្តសៀមរាបបណ្តុះគំនិតកុមារស្វែងយល់ពីសមុច្ច័យនៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ........... ៧២
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
  របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៧៣
- មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន៧៥រូប ទទួលការបណ្តុះបណ្តាលលើការរៀបចំរបាយការណ៍តាមទម្រង់ថ្មី .. ៧៤
- អាជ្ញាធរជាតិអប្សរានឹងបើកឱ្យភ្ញៀវទេសចរចូលទស្សនាប្រាសាទកណ្តាលស្រះស្រង់នាសប្តាហ៍ក្រោយ ៧៥
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
  ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៧៦
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅក្នុងបរិវេណ
  វត្តព្រះឥន្ទទេព វត្តគោកធ្លក ប្រាសាទសួព័ត្រ និងប្រាសាទបាយ័ន ៧៧

- មន្ត្រីបុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរាចូលរួមចែករំលែកបទពិសោធន៍ ផ្នែករៀបចំខ្សែសៀគ្វីទេសចរណ៍នៅមេណីយដ្ឋានបេតិកភណ្ឌពិភពលោកសំបូរព្រៃគុក ៧៨
- អាជ្ញាធរជាតិអប្សរានឹងបិទខ្លោងទ្វារតាការបណ្ដោះអាសន្នដើម្បីប្រារព្ធពិធីបើកការដ្ឋានជួសជុល ៧៩
- ប្រជាពលរដ្ឋទាំង១២ភូមិនៃសង្កាត់ក្របីរៀលបានមកទស្សនារមណីយដ្ឋានអង្គរ ៨០
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចុះពិនិត្យផែនការសកម្មភាពអនាគត របស់អាជ្ញាធរជាតិអប្សរា ៨១
- វិស័យឯកជនចាប់ដៃគូសហការជាមួយអាជ្ញាធរជាតិអប្សរាជួសជុលខ្លោងទ្វារតាការ ៨២
- ប្រាសាទស្រះស្រង់សម្ភោធបញ្ចប់ការជួសជុលនៅព្រឹកនេះ ៨៣
- អាជ្ញាធរជាតិអប្សរាដាក់ឱ្យដំណើរការរហាត់ទឹកនៅស្ថានីយបណ្ដុះកូនឈើប្រាសាទតាកែវ........ ៨៤
- និស្សិតនិងសិស្សានុសិស្សចំនួន៤៣នាក់មកទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ........ ៨៥
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៨៦
- និស្សិតសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាបទស្សនកិច្ចសិក្សានៅ សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី ៨៧
- អាជ្ញាធរជាតិអប្សរាចាប់ផ្ដើមអនុវត្តគម្រោងជួសជុលនិងលើកតម្លៃប្រាសាទបាយក្អែក........ ៨៨
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានកំណាយស្រាវជ្រាវនៅមុខព្រះលានជល់ដំរី........ ៨៩
- ដើមឈើហានិភ័យចំនួន១០ដើមត្រូវបានដកហូតនៅប្រាសាទគោកពោធិ៍........ ៩០
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៩១
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៩២

ប្រចាំខែមីនា

- អាជ្ញាធរជាតិអប្សរាបន្តជួសជុលរចនាសម្ពន្ធស្រះខាងជើងនៃប្រាសាទអង្គរវត្តឱ្យរួចរាល់ ៩៥
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេស នៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន ៤៧០គ្រួសារ ៩៦
- ទឹកបារាយណ៍ខាងលិចរួមចំណែកក្នុងការងារកសិកម្មរបស់ប្រជាពលរដ្ឋ........ ៩៧
- អាជ្ញាធរជាតិអប្សរាកំពុងផ្លាស់ប្ដូរផ្ទាំងព័ត៌មាននិងស្លាកសញ្ញាប្រាប់ទិសដៅទស្សនាជុំវិញប្រាសាទបន្ទាយស្រី........ ៩៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ........ ៩៩
- ទស្សនាវដ្ដី "ព្រះនគរ" បំផុសស្មារតីយុវជនយល់ពីតម្លៃវប្បធម៌........ ១០០
- អាជ្ញាធរជាតិអប្សរាបណ្ដុះបណ្ដាលអ្នកបន្តវេនថែរក្សាអង្គរ ១០១
- សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ជាបណ្ដុំចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ សម្រាប់កូនខ្មែរសិក្សាស្វែងយល់........ ១០២
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅ ក្នុងបរិវេណវត្តទេពប្រណម្យ និងក្រុមប្រាសាទព្រះពិធូរនៃក្រុងអង្គរធំ........ ១០៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ........ ១០៤
- អាជ្ញាធរជាតិអប្សរា និងអាជ្ញាធរស្រុកសូទ្រនិគម រួមគ្នាអប់រំផ្សព្វផ្សាយបញ្ឈប់ ការជីកកាយយកអាចម៍ដីពីទំនប់ព្រៃកដីកបុរាណ ១០៥

- អាជ្ញាធរជាតិអប្សរាសហការជាមួយវិស័យឯកជនប្រុងពលីបើកការដ្ឋានកំណាយ
ប្រាសាទវាលធ្មីនៅកណ្តាលបារាយណ៍ប្រាសាទបេងមាលា ១០៦
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១០៧
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលគោរពវិញ្ញាណក្ខន្ធសពលោកស្រី Vann Amberg Gertrude ១០៨
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ ១០៩
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១១០
- អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះពិនិត្យការដ្ឋានជួសជុលស្ពានតាអោង និងប្រាសាទវាលធ្មី ១១១
- អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសកម្មភាពថែទាំតំបន់រមណីយដ្ឋានអង្គរដើម្បីត្រៀមទទួលភ្ញៀវសាជាថ្មី........ ១១២
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់
មកលើរចនាសម្ពន្ធខ្លោងទ្វារតាកាវនៃក្រុងអង្គរធំ ១១៣
- សប្បុរសជនរួមគ្នាស្តារពើកនៅក្នុងកសិន្ទក្រុងអង្គរធំដើម្បីលើកតម្លៃនិងជាប្រយោជន៍ដល់កិច្ចការអភិរក្ស ១១៤
- សកម្មភាពសម្អាតជាប្រចាំរបស់ក្រុមការងារអនាម័យក្នុងរមណីយដ្ឋានអង្គរ ១១៥
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១១៦
- ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ដាំដើមឈើនៅខាងជើងខ្លោងទ្វារដីឆ្នាំង ១១៧
- អាជ្ញាធរជាតិអប្សរាជួសជុសថែទាំស្ពានបណ្តែតទឹកនៅប្រាសាទអង្គរវត្ត ១១៨
- អាជ្ញាធរជាតិអប្សរា កំពុងដកហូតដើមឈើមានហានិភ័យខ្ពស់ចំនួន៤ដើម
នៅប្រាសាទក្រោលរមាស លើភ្នំគូលែន........ ១១៩
- មកទស្សនាអង្គរ កុំភ្លេចគោរពក្រមប្រតិបត្តិអង្គរ និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល........ ១២០
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១២១
- រួមគ្នាដាំកូនឈើដើម្បីអភិរក្សប្រាសាទ និងបង្កើនគម្របបៃតងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ........ ១២២
- សកម្មភាពកាត់ក្រី និងដកហូតដើមឈើហានិភ័យខ្ពស់នៅភ្នំបាខែង ១២៣
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈ បច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន
ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន ៤៦២គ្រួសារ ១២៤
- ស្រះស្រង់អាចនឹងរីងស្ងួតនាចុងរដូវប្រាំងឆ្នាំនេះ ១២៥
- អាជ្ញាធរជាតិអប្សរាកម្ចាត់សត្វកណ្តៀរ ដើម្បីការពារប្រាង្គប្រាសាទក្នុងឧទ្យានអង្គរ........ ១២៦
- ក្រុមអ្នកជំនាញអភិរក្សថ្មរបស់អាជ្ញាធរជាតិអប្សរា កំពុងជួសជុលបង្កាន់ដៃនាគនៅប្រាសាទបន្ទាយសំរែ........ ១២៧
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ........ ១២៨
- ត្រីមាសទី១ ក្នុងឆ្នាំ២០២១ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋ
ក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៦១៦ករណី ១២៩

ប្រចាំខែមេសា

- អាជ្ញាធរជាតិអប្សរាចងរឹតកាបនៅលើរចនាសម្ពន្ធសំណង់ប្រាសាទបាយ័ន្តមួយចំនួន ១៣៣
- អាជ្ញាធរជាតិអប្សរា បន្តដាំដើមឈើបង្កើនគម្របបៃតងដល់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងអភិរក្សប្រាសាទ ១៣៤
- អាជ្ញាធរជាតិអប្សរារៀបចំពិធីប្រុងពាលីជួសជុលប្រាសាទធ្មី........ ១៣៥
- អាជ្ញាធរជាតិអប្សរាបន្តកិច្ចការជួសជុល និងថែទាំស្លាកសញ្ញាផ្សេងៗក្នុងរមណីយដ្ឋានអង្គរ ១៣៦
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ ១៣៧

- ព្រះសិរព្រះនារាយណ៍ធ្វើពីថ្មភក់មួយបំណែករកឃើញនៅប្រាសាទត្រពាំងផុង ១៣៨
- អាជ្ញាធរជាតិអប្សរាកំពុងធ្វើកំណាយសិក្សាពីលទ្ធភាពស្តារនិងលើកតម្លៃត្រពាំងសេសឡើងវិញ........ ១៣៩
- អាជ្ញាធរជាតិអប្សរាបង្កើនសកម្មភាពថែទាំ និងសម្អាតបរិស្ថានតាមទីតាំងប្រាសាទក្នុងរមណីយដ្ឋានអង្គរ ១៤០
- អាជ្ញាធរជាតិអប្សរា គ្រោងចុះកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់
និងបាំងទេសភាពនៅប្រាសាទសួព្រ័ត្រ និងព្រលានជល់ដំរី........ ១៤១
- អាជ្ញាធរជាតិអប្សរាពន្លឿនការជួសជុលខឿនជ្រុងនិរតីនៅរួតទី៣នៃប្រាសាទបាយ័ន្ត
ឱ្យរួចរាល់មុនខែវស្សាមកដល់ ១៤២
- អាជ្ញាធរជាតិអប្សរាចុះបោះបង្គោលព្រំទីតាំងបុរាណដ្ឋានគោកគ្រឹះ និងត្រពាំងឈូក ១៤៣
- អាជ្ញាធរជាតិអប្សរាបន្តជួសជុលបង្កាន់ដៃនាគប្រវែង៣០ម៉ែត្រនៅប្រាសាទបន្ទាយសំរ៉ែ........ ១៤៤
- អាជ្ញាធរជាតិអប្សរា ចុះកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ និងបាំងទេសភាព
នៅប្រាសាទសួព្រ័ត្រ និងព្រះលានជល់ដំរី ១៤៥
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យាន ១៤៦
- កុដិឈើមួយខ្នងនៅប្រាសាទលលៃបញ្ចប់ការសាងសង់ដោយជោគជ័យ ១៤៧
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សា
ភិបាលអាជ្ញាធរជាតិអប្សរា ផ្ញើសារចែករំលែកទុក្ខដល់ក្រុមគ្រួសារលោកសាស្ត្រាចារ្យ Giorgio Croci ១៤៨
- ក្រុមការងារបរិស្ថានរបស់អាជ្ញាធរជាតិអប្សរាបន្តយកចិត្តទុកដាក់ថែរក្សាអនាម័យក្នុងរមណីយដ្ឋានអង្គរ ១៤៩
- អាជ្ញាធរជាតិអប្សរា សហការជាមួយប្រទេសអាល្លឺម៉ង់ ជួសជុលនិងអភិរក្សក្បាច់ចម្លាក់
នៅកំពូលប្រាសាទអង្គរវត្ត........ ១៥០
- អាជ្ញាធរជាតិអប្សរានៅតែបង្កើនសកម្មភាពថែទាំប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ........ ១៥១
- អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះពិនិត្យការដ្ឋានជួសជុលស្ពានឈើនៅប្រាសាទតាកែវ ១៥២
- ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ........ ១៥៣
- យើងនៅញញឹមចាំស្វាគមន៍អ្នកគ្រប់ពេលវេលាកុំភ្លេចអនុវត្តន៍តាមវិធានការណ៍ ៣កុំ ៣ការពារ
ប្រឆាំងជំងឺកូវីដ-១៩ ពេលចូលទស្សនាប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ១៥៥
- ការងារស្តារពើកកំពុងចាប់ផ្តើមអនុវត្តនៅកសិន្ធុខាងលិចក្រុងអង្គរធំ ១៥៦
- អាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់ចំនួន៤ដើម
ដុះជាប់នឹងខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី ១៥៧
- សូមជូនរូបភាពប្រចាំថ្ងៃ៖ ទេសភាពចាប់ពីខ្លោងទ្វារទន្លេអុំទៅប្រាសាទបាយ័ន........ ១៥៨
- ការសម្អាតកូនរុក្ខជាតិតូចៗដែលដុះលើប្រាង្គប្រាសាទជាប្រចាំ ១៥៩
- សូមជូនរូបភាពប្រចាំថ្ងៃ៖ ទិដ្ឋភាពថ្ងៃលិចនៅប្រាសាទភ្នំបាខែង........ ១៦០
- ការរៀបចំកម្រាលថ្មស្ពានហាលប្រាសាទអង្គរវត្តនឹងបញ្ចប់នាពេលឆាប់ៗខាងមុខ........ ១៦១

ប្រចាំខែឧសភា

- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់
លំនៅដ្ឋានជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៣៧៦គ្រួសារ ១៦៥
- ភ្ញៀវទេសចរសប្បាយរីករាយនៅពេលបានឃើញទិដ្ឋភាពដ៏ស្រស់ស្អាតក្នុងតំបន់រមណីយដ្ឋានអង្គរ........ ១៦៦
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ
ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ........ ១៦៧
- ដើមឈើនិងប្រាសាទ រូបពីរជីវិតមួយ ១៦៨

- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៦៩
- ស្នាមញញឹមនៃប្រាសាទបាយ័ន្ត ១៧០
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាកំពុងជួសជុលខឿនរូតទី៣នៃប្រាសាទបាយ័ន្តតាមរបៀបបុរាណ ១៧១
- អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសកម្មភាពថែទាំតំបន់រមណីយដ្ឋានអង្គរដើម្បីត្រៀមទទួលភ្ញៀវសាជាថ្មី ១៧២
- ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបន្តដាំកូនឈើបំពេញចន្លោះនានាក្នុងតំបន់រមណីយដ្ឋានអង្គរ ១៧៣
- រូបភាពប្រចាំថ្ងៃ៖ ប្រាសាទបន្ទាយស្រីនិងចម្លាក់ដ៏អស្ចារ្យ ១៧៤
- រយៈពេល៥ថ្ងៃ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៣១សំណើ ១៧៥
- អាជ្ញាធរជាតិអប្សរារកឃើញទបង្ហូរទឹកបុរាណ នៅព្រះលានដល់ដំរី ១៧៦
- ពន្លឺថ្ងៃលិចចែងចាំងដ៏ស្រស់ស្អាតបន្ថែមសម្រស់មួយកម្រិតទៀតដល់ប្រាសាទអង្គរវត្ត ១៧៧
- សត្វស្លាប៣ប្រភេទផ្សេងទៀត គ្រោងដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ ១៧៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៧៩
- ក្រុមការងារសម្អាតប្រាសាទរួមចំណែកយ៉ាងសំខាន់ក្នុងការលើកតម្លៃបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ ១៨០
- ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរាកំពុងដំណើរការជួសជុលផ្លូវចូលខាងកើតប្រាសាទបន្ទាយស្រី ១៨១
- ក្រុមការងារសម្អាតប្រាសាទរួមចំណែកយ៉ាងសំខាន់ក្នុងការលើកតម្លៃបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ ១៨២
- សោភ័ណភាពព្រះវិហារវត្តរាជបូណ៌ ទីអារាមដ៏ចំណាស់ក្នុងខេត្តសៀមរាប ១៨៣
- ទិដ្ឋភាពប្រាសាទនាគព័ន្ធ៖ ទេសភាពវប្បធម៌នាសតវត្សរ៍ទី១២ រំលេចជាថ្មីនៅសតវត្សរ៍ទី២១ .... ១៨៤
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៨៥
- ទិដ្ឋភាពថ្ងៃរះពណ៌មាសដ៏ស្រស់ត្រកាលនៅប្រាសាទអង្គរវត្ត ១៨៦
- អាជ្ញាធរជាតិអប្សរា គ្រោងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ នៅប្រាសាទលលៃ ១៨៧
- ទិដ្ឋភាពផ្លូវវង់ធំ អមដោយទេសភាពដ៏ស្រស់ត្រកាលកំពុងបញ្ចេញសម្រស់ទាក់ទាញភ្ញៀវទេសចរនារដូវវស្សា ១៨៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៨៩
- កូនឈើចំនួនជាង២០០០ដើម ត្រូវបានចែកជូនដល់ព្រះសង្ឃ និងប្រជាពលរដ្ឋក្នុងខេត្តសៀមរាប ១៩០
- សាលាឆាន់ដ៏ចំណាស់ចំនួន១ខ្នងនៅវត្តរាជបូណ៌ត្រូវបានជួសជុលឡើងវិញដោយអាជ្ញាធរជាតិអប្សរា ១៩១
- ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១២៧សំណើ ១៩២
- សាលាឆាន់ដ៏ចំណាស់ចំនួន១ខ្នងនៅវត្តរាជបូណ៌ត្រូវបានជួសជុលឡើងវិញដោយអាជ្ញាធរជាតិអប្សរា ១៩៣

ប្រចាំខែមិថុនា

- ក្រុមការងារអាជ្ញាធរជាតិអប្សរាបានបញ្ចប់ការងារជួសជុលប្រាសាទធ្មី ១៩៧
- អាជ្ញាធរជាតិអប្សរារួមជាមួយ បញ្ជាការដ្ឋានយោធភូមិភាគទី៤ ដាំកូនឈើប្រមាណ១ម៉ឺនដើមនៅទីបញ្ជាការយោធភូមិភាគទី៤ .... ១៩៨
- អាជ្ញាធរជាតិអប្សរាបន្តអនុវត្តវិធានការការពារ ដើម្បីបង្ការការឆ្លងរាលដាលជំងឺកូវីដ១៩នៅក្នុងរមណីយដ្ឋានអង្គរ ១៩៩
- អាជ្ញាធរជាតិអប្សរាទទួលវត្ថុបុរាណចំនួន៥ ពីបញ្ជាការដ្ឋានយោធភូមិភាគទី៤ .... ២០០

- អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះ និងសាងសង់សំណង់តូចតាចបានចំនួន៩៥គ្រួសារ ២០១
- អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើដល់សាធារណជន ជាង៨ពាន់ដើមទៀត ២០២
- អាជ្ញាធរជាតិអប្សរាកំពុងអនុវត្តន៍ការងារកាត់ក្រី និងដកហូតដើមឈើហានិភ័យនៅប្រាសាទព្រះខ័ន ២០៣
- រូបភាពប្រចាំថ្ងៃ៖ ប្រាសាទទន្លេស្ងួតបង្ហាញរូបរាងឡើងវិញបន្ទាប់ពីអាជ្ញាធរជាតិអប្សរាជួសជុលរួច ២០៤
- អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ចុះពិនិត្យគម្រោងសហការជាមួយអាជ្ញាធរជាតិអប្សរា ២០៥
- រមណីយដ្ឋានប្រាសាទតានៃនារដូវវស្សា ២០៦
- ដើម្បីរមណីយដ្ឋានអង្គរមានភាពស្រស់បំព្រង ២០៧
- អាជ្ញាធរជាតិអប្សរា ចុះពិនិត្យទីតាំងស្នើសុំសាងសង់ផ្លូវលើខ្នងភ្នំគូលែន... ២០៨
- សកម្មភាពដ៏មមាញឹកនៃការស្តារពើកនៅកសិន្ធុខាងលិចនៃក្រុងអង្គរធំរបស់មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា........ ២០៩
- អាជ្ញាធរជាតិអប្សរាបញ្ចប់គម្រោងជួសជុលបណ្ណាល័យខាងត្បូងប្រាសាទព្រះខ័ន ២១០
- អាជ្ញាធរជាតិអប្សរាចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនប្រេងឥន្ធនៈ Total Cambodge
  លើការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ.. ២១១
- អាជ្ញាធរជាតិអប្សរា ចុះពិនិត្យការងារនៅតំបន់ប្រាសាទបេងមាលា.. ២១២
- កូនឈើចម្រុះជាង៦ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយ
  ពីថ្ងៃទី៥ ដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១ .... ២១៣
- អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលស្រុកបន្ទាយស្រីចុះពិនិត្យឡកុលាលភាជន៍បុរាណនៅជើងភ្នំគូលែន.. ២១៤
- អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់
  នៅតាមដងផ្លូវជាតិលេខ៦ ចាប់ពីព្រំប្រទល់ក្រុងសៀមរាប ដល់ឃុំខ្នាត ស្រុកពួក.. ២១៥
- រូបភាពប្រចាំថ្ងៃ៖ ភាពស្រស់ស្អាតនៃប្រាសាទតុបខាងលិច ២១៦
- សោភ័ណភាពពណ៌ខៀវស្រងាត់ចាប់ផ្តើមលេចមុខបណ្តើរៗនៅបរិវេណមុខព្រះលានជល់ដំរី............................ ២១៧
- សកម្មភាពថែទាំ និងសម្អាតប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ ២១៨
- ឆមាសទី១ ឆ្នាំ២០២១ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋ
  ក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៨៦៥ករណី ២១៩
- អាជ្ញាធរជាតិអប្សរាកំពុងចាប់ផ្តើមដំណើរការ គម្រោងជួសជុលខ្លោងទ្វារតាការ ២២០
- លេខាធិការដ្ឋានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ រៀបចំការចុះពិនិត្យការដ្ឋានជួសជុលប្រាសាទ
  ក្នុងរមណីយដ្ឋានអង្គរ ២២១
- កូនឈើចម្រុះជិត៨ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាចែកចាយពីថ្ងៃទី១៤ ដល់ថ្ងៃទី២២ ខែមិថុនា ២២២
- អាជ្ញាធរជាតិអប្សរាដំណើរការលើកថ្មប្រាសាទដែលធ្លាក់រាយប៉ាយក្នុងកសិន្ធុប្រាសាទបាយ័នទៅរក្សាទុក........... ២២៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
  របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ ២២៤
- អាជ្ញាធរជាតិអប្សរាកំពុងស្តារប្រព័ន្ធប្រឡាយបុរាណ២ខ្សែ ប្រវែងជាង៣ពាន់ម៉ែត្រ ២២៥
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
  របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ.. ២២៦
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមកម្មវិធីជិះកង់ បាទីក្រម៉ាជាមួយស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ី ២២៧
- លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរប្រជុំដើម្បីសុំយោបល់បច្ចេកទេសអំពីគម្រោងអភិរក្ស
  និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ.. ២២៨

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមករា

សេចក្តីជូនដំណឹងស្តីពីការកែលម្អផ្លូវដើរដោយក្រាលបេតុងមានដាំស្មៅ និងដាំស្មៅ ព្រមទាំងសាងសង់ប្រព័ន្ធដោះទឹកតាមផ្លូវនៅបរិវេណព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ១០១៣/២០ រដ.សជណ

សេចក្តីជូនដំណឹង
ស្តីពី
ការកែលម្អផ្លូវដើរដោយក្រាលបេតុងមានដាំស្មៅ និងដាំស្មៅ ព្រមទាំងសាងសង់ប្រព័ន្ធដោះទឹកតាមផ្លូវនៅបរិវេណព្រះលានជល់ដំរី

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមរៀបចំគម្រោងកែលម្អផ្លូវដើរ និងដាំស្មៅ ព្រមទាំងសាងសង់ប្រព័ន្ធដោះទឹកតាមផ្លូវនៅបរិវេណព្រះលានជល់ដំរី។ ក្នុងន័យនេះ ដើម្បីសម្រួលដល់ក្រុមការងារបច្ចេកទេស ក៏ដូចជាសុវត្ថិភាព សណ្តាប់ធ្នាប់នៅក្នុងបរិវេណការដ្ឋាន អាជ្ញាធរជាតិអប្សរា នឹងបិទបរិវេណខាងមុខព្រះលានជល់ដំរី ចាប់ពីខាងជើងប្រាសាទបាយ័ន រហូតដល់ចំណុចផ្លូវខាងជើងព្រះពន្លាស្តេចគម្លង់ឆ្ពោះទៅខ្លោងទ្វារដីឆ្នាំង ដូចមានប្លង់ជូនភ្ជាប់មកជាមួយ **ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ នេះតទៅ។**

ដោយឡែកចំពោះភ្ញៀវទេសចរ និងសាធារណជន អាចធ្វើដំណើរតាមផ្លូវថ្មីវាងមុខព្រះលានជល់ដំរីនៅផ្នែកខាងកើតផ្លូវចាស់ដែលអាជ្ញាធរជាតិអប្សរាទើបតែធ្វើការជួសជុលរួចរាល់ ដូចមានប្លង់ជូនភ្ជាប់មកជាមួយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃអង្គារ ១៤ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

Email: info@apsaraauthority.gov.kh
Website: http//www.apsaraauthority.gov.kh

សកម្មភាពកាត់ក្រីមែកឈើដុះលើស្ពានថ្មបុរាណជាប់ស្ពានប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២១

ដោយពិនិត្យឃើញមានហានិភ័យខ្ពស់របស់ដើមឈើ ដែលដុះលើរចនាសម្ព័ន្ធស្ពានថ្មបុរាណនៅចន្លោះប្រាសាទតាកែវ និងប្រាសាទធម្មនន្ទ លើស្ទឹងសៀមរាប ក្រុមជំនាញនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ដោយសហការជាមួយផ្នែកពាក់ព័ន្ធ បានចុះពិនិត្យ និងអនុវត្តន៍វិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ។

ការងារនេះ ធ្វើឡើងដើម្បីបង្ការ និងបញ្ចៀសគ្រោះថ្នាក់ទុកជាមុន កុំឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធរបស់ស្ពានថ្មបុរាណ និងដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រុមការងារអភិរក្សនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការសិក្សាប្លង់ស្ពាន និងរៀបចំជួសជុល

ស្ពាននេះឡើងវិញ។ ដើមឈើដែលប៉ះពាល់រចនាសម្ព័ន្ធមែកចេញបានរួចរាល់មាន ដើមស្រទ្បៅ ដើមស្វាយព្រៃ ដើមចាន់ ដើមបេង និងដើមឈើតូចៗ៤ដើមទៀត៕

សកម្មភាពថែរក្សាបរិស្ថាននៅរមណីយដ្ឋានអង្គរឱ្យមានភាពបៃតង

ផ្សាយនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១

ក្រុមការងារថែរក្សាបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា ជានិច្ចជាកាលបានខិតខំប្រឹងប្រែងថែរក្សា ក្នុងន័យធ្វើយ៉ាងណាឱ្យបរិស្ថានក្នុងរមណីយដ្ឋានអង្គរ ពិសេសមុខប្រាសាទអង្គរវត្ត មានភាពស្រស់ស្អាត មានភាពបៃតង ជាទីទាក់ទាញ និងជាទីគយគន់សម្រាប់ភ្ញៀវទេសចរគ្រប់រូប។ សកម្មភាពទាំងនោះរួមមាន ការស្រោចទឹកដើមឈើនិងសួនច្បារជាប្រចាំ ធ្វើយ៉ាងណា ឱ្យបរិស្ថានជុំវិញមានភាពបៃតងខួបប្រាំងនិងវស្សា។ ជាមួយគ្នានេះ នៅក្នុងបរិវេណខាងក្នុងប្រាសាទអង្គរឯណោះវិញ ថ្មីៗនេះអាជ្ញាធរជាតិអប្សរាទើបនឹងដាក់ឱ្យដំណើរការនូវប្រព័ន្ធស្រោចស្រពស្មៅដោយស្វ័យប្រវត្តិ ដែលក្នុងន័យនេះ ជាផ្នែកមួយសំខាន់ ធានាថាស្មៅក្នុងប្រាសាទលែងមានពណ៌ក្រហមនិងស្វិតក្រៀម នារដូវប្រាំងទៀតហើយ។ ផ្ទុយមកវិញ វាលស្មៅទាំងនោះ នឹងមានភាពបៃតងខួបប្រាំងនិងវស្សា៕

រយៈពេល២ថ្ងៃក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៣៩សំណើ

ផ្សាយនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១

ថ្ងៃទី៤-៥ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៦គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើស្នើសុំជួសជុលតូចតាចរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ។

ជាក់ស្តែង នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក ឡុង កុសល បានចុះពិនិត្យនិងដោះស្រាយនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ហើយអនុញ្ញាតបានចំនួន៥សំណើ។

នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២១ គោលដៅទី២ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យនិងដោះស្រាយស្ថិតនៅក្នុងភូមិបុស្សធំ ភូមិគីរីមានន្ទ ឃុំអំពិល ហើយអនុញ្ញាតបានចំនួន៩សំណើ។ គោលដៅទី៣ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យនិងដោះស្រាយនៅក្នុងភូមិក្លូង់(គោកត្រើល) ភូមិលាងដៃ ឃុំលាងដៃ ហើយអនុញ្ញាតបានចំនួន៩សំណើ។ គោលដៅទី៤ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យនិងដោះស្រាយនៅក្នុងភូមិតាត្រៃ ឃុំព្រះដាក់ ហើយអនុញ្ញាតបានចំនួន៦សំណើ។ គោលដៅទី៥ ក្រុមការងារប្រចាំក្រៅឧទ្យាន ដឹកនាំដោយ លោក សំ សារ៉េត បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិបឹងមាលា ឃុំបឹងមាលា ហើយអនុញ្ញាតបានចំនួន៥សំណើ។ គោលដៅទី៦ ក្រុមការងារប្រចាំក្រៅឧទ្យាន ដឹកនាំដោយ លោក សំ សារ៉េត បានពិនិត្យនិងដោះស្រាយនៅភូមិបឹងមាលា ឃុំបឹងមាលា ហើយអនុញ្ញាតបានចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី៤-៥ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង៦ គោលដៅបានពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន៣៩សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាដំណើរការជួសជុលរួតទី៣នៃប្រាសាទបាយ័ន្ត

ផ្សាយនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរាក្រោមការទទួលបន្ទុករបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ សហការជាមួយស្ថាប័ន JASA ប្រទេសជប៉ុន និងអង្គការយូណេស្កូ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ កន្លងមកនេះ បានរៀបចំសែនព្រេន សុំសេចក្តីសុខចម្រើន ដើម្បីបើកការដ្ឋានជួសជុលប្រាសាទបាយ័ន្តនៅជាន់ទី៣ ឱ្យផុតពីបញ្ហាប្រឈម មុននឹងបើកដំណើរការឱ្យភ្ញៀវចូលទស្សនាជាថ្មី។

តាមការបញ្ជាក់ពី **ឯកឧត្តម តឹម សុផិន** អគ្គនាយករង អាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា ប្រាសាទបាយ័ន្តនៅរួតទី៣ បានទ្រុឌទ្រោមដោយសាររចនាសម្ពន្ធថ្មប្រាសាទក្រៀកចេញពីគ្នា ព្រោះតែអាកាសធាតុ អាយុកាលសំណង់ ការចុះខ្សោយនៃគុណភាពនៃរចនាសម្ពន្ធសំណង់ ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់សំណង់ប្រាសាទទាំងមូល រួមទាំងទេសចរផង បើជួសជុលមិនទាន់ពេលវេលា។

ឯកឧត្តមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរានឹងដំណើរការជួសជុលមានដូចជា៖ ការរើថ្មចេញ ហើយរុញចូលវិញនៅជ្រុងទី៣ទិសខាងត្បូង ការទល់ទ្រកន្លែងដែលមានហានិភ័យរកកលនឹងរលំដួលចំនួន៥៦ចំណុចផ្សេងៗគ្នា។ ក្នុងនោះក៏នឹងមានការរៀបចំបិទភ្ជិតលើថ្មរថ្មដែលវាប្រេះកុំឱ្យវាជ្រាបទឹកចូល និងសម្រួលថ្មរដិបរដុបមិនរាបស្មើ ដើម្បីកុំឱ្យបង្កគ្រោះថ្នាក់ដល់ភ្ញៀវពេលដើរទស្សនាប្រាសាទ។

ក្នុងការអនុវត្តការងារនេះ ធ្វើឡើងដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរាខ្លួនឯង ហើយនឹងចំណាយរយៈពេលមួយឆ្នាំដើម្បីជួសជុលប្រាសាទបាយ័ន្តនៅរួតទី៣នេះឱ្យរួចរាល់ជាស្ថាពរបើពុំមានបញ្ហារាំងស្ទះអ្វីកើតឡើង ទាំងការរៀបចំគូសប្លង់ សិក្សាស្រាវជ្រាវ ចងក្រងឯកសារ និងឆ្លងយោបល់ពីអ្នកជំនាញការអាជហុក៕

អាជ្ញាធរជាតិអប្សរាបានបញ្ចប់ការដកហូតដើមឈើទាលងាប់មួយដើម ក្នុងបរិវេណប្រាសាទបន្ទាយប្រី

ផ្សាយនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២១

ក្រុមអង្កេតហានិភ័យដើមឈើនៃអាជ្ញាធរជាតិអប្សរា ពិនិត្យឃើញមានដើមឈើទាលងាប់មួយដើម ដុះឈរត្រង់កណ្ដាលតួប្រាសាទបន្ទាយប្រី មានជំងឺដំបៅគល់ និងមានហានិភ័យខ្ពស់ ដែលកាលពីឆ្នាំមុនក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានព្យាបាលផ្នែកដែលមានជំងឺ និងកាត់ផ្នែកខាងចុងចេញ ដើម្បីសម្រាលតួដើម និងឲ្យលូតលាស់មែកថ្មី។ ប៉ុន្តែដោយដើមឈើទាលមួយដើមនេះមានអាយុកាលយូរមកហើយ មិនអាចសង្គ្រោះបាន និងដើម្បីធានាសុវត្ថិភាព កុំឲ្យមានគ្រោះថ្នាក់ដល់ភ្ញៀវទេសចរ ដែលតែងតែមកទស្សនាប្រាសាទនេះ ជាពិសេសកុំឲ្យមានការខូចខាតដល់រចនាសម្ព័ន្ធប្រាសាទផងនោះ កាលពីពេលថ្មីៗនេះ អាជ្ញាធរជាតិអប្សរា

បានកាត់ដកហូតដើមឈើទាលងាប់មួយដើមនេះចេញពីក្នុងបរិវេណប្រាសាទបន្ទាយប្រី និងបញ្ចប់ការងាររួចរាល់ជាស្ថាពរ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០២១

ថ្ងៃទី៦ខែមករាឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួកដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយក្នុងភូមិបឹងខ្នារ ភូមិព្រៃក្មេង ភូមិខ្នាត ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ **ឯកឧត្តម ខូយ គីមឆ្នូ** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិសណ្តាន់ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១២ សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

វេលាយប់វែងជាងថ្ងៃ ជាមួយនឹងអាថ៌កំបាំងលើចម្លាក់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ០៧ ខែមករា ឆ្នាំ២០២១

គេតែងដឹងជាទូទៅនូវព្រឹត្តិការណ៍សំខាន់ៗដែលកើតមាននៅប្រាសាទអង្គរវត្ត នោះគឺវេលាយប់និងថ្ងៃស្មើគ្នា ជាមួយនឹងព្រឹត្តិការណ៍ព្រះអាទិត្យរះចំប្រាង្គកណ្តាលប្រាសាទអង្គរវត្ត។ ក្រៅពីព្រឹត្តិការណ៍នេះ មានវេលាពីរសំខាន់ៗទៀត នោះគឺវេលាថ្ងៃវែងជាងយប់ និងវេលាយប់វែងជាងថ្ងៃ។ យ៉ាងណា មានមនុស្សតិចណាស់ដែលបានសង្កេត និងដឹងរឿងរ៉ាវនូវវេលាទាំងនេះ។ អ្នកបុរាណវិទ្យាបង្ហាញពីអាថ៌កំបាំងនូវព្រឹត្តិការណ៍យប់វែងជាងថ្ងៃ និងអាថ៌កំបាំងជាមួយផ្ទាំងចម្លាក់តាមថែវប្រាសាទអង្គរវត្ត។

លោក អ៊ឹម សុខរិទ្ធី បុរាណវិទូ និងជាប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នៃអាជ្ញាធរជាតិអប្សរា បានបង្ហាញនូវតឹកតាងមួយចំនួន នៃវេលាយប់វែងជាងថ្ងៃដែលសាធារណគួរតោងចាប់អារម្មណ៍។ ក្នុងទំនៀមនៃព្រហ្មញ្ញសាសនា វេលាយប់គឺមានន័យថាសភាវៈអាក្រក់មានអំណាច ឬបារមីខ្លាំងជាងសភាវៈល្អ។ តួយ៉ាង ក្នុងវេលាយប់វែងជាងថ្ងៃ ដែលកើតមានចំថ្ងៃទី២១ ខែធ្នូ នោះ គឺពន្លឺនៅពេលព្រឹក បានចាំងលើរូបចម្លាក់ជាសភាវៈអាក្រក់ និងស្រមោលនៃសសរតាមថែវប្រាសាទ បាំងបិទលើចម្លាក់សំខាន់ៗដែលជាតួអង្គនៃសភាវៈល្អឬពពួកទេព។ ជាអ្នកតាមដាន និងយល់ពីសារប្រយោជន៍នៃព្រឹត្តិការណ៍ខាងលើនេះ លោក អ៊ឹម សុខរិទ្ធី បញ្ជាក់ថា ព្រឹត្តិការណ៍នេះគឺកើតមានទាំងនៅថែវខាងកើតនាវេលាថ្ងៃរះ និងថែវខាងលិចនាវេលាពេលថ្ងៃលិច។ ហើយព្រឹត្តិការណ៍នេះនឹងផ្ទុយមកវិញនាថ្ងៃទី២១ ខែមិថុនា ជាព្រឹត្តិការណ៍ប្រចាំឆ្នាំ ដែលវេលាថ្ងៃវែងជាយប់វិញម្តង។

អាថ៌កំបាំងដ៏អស្ចារ្យ ដែលសាធារណជនទូទៅមិនសូវចាប់អារម្មណ៍នេះ គឺជាចំណុចពិសេសមួយទៀតនៃប្រាសាទអង្គរវត្ត ក្រៅពីភាពថ្កុំថ្កើងនៃរចនាបថហើយនោះ។ តាមការយល់ឃើញរបស់លោក អ៊ឹម សុខរិទ្ធី ព្រឹត្តិការណ៍នេះ មិនមែនជារឿងចៃដន្យនោះទេ តែវាជាការគុណគូរដ៏ត្រឹមត្រូវ និងច្បាស់លាស់ពីបុព្វបុរសជំនាន់នោះ ហើយបានរៀបចំត្រឹមត្រូវ មុននឹងឆ្លាក់ចម្លាក់រឿងរ៉ាវនានាតាមទីតាំងនីមួយៗ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៨ ខែមករា ឆ្នាំ២០២១

ថ្ងៃទី៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន ៣គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិដូនឪ ភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិប្រាសាទចារ្យ ភូមិល្បើក ភូមិត្នោតជ្រុំ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយលោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិវាល សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សរុបមក នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង៣ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១១ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១ គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបន្តកែលម្អទីធ្លាបរិវេណមុខព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១

ក្រោយពីទទួលបានការឯកភាពពី ក្រុមអ្នកជំនាញការអាដហុករបស់អាយស៊ីស៊ី-អង្គរ នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរាបានបន្តដំណើរការគម្រោងកែលម្អទីធ្លាបរិវេណមុខព្រះលានជល់ដំរី ដោយមានរៀបចំជាផ្លូវថ្មើរជើងនិងប្រព័ន្ធរំដោះទឹក ព្រមទាំងដាំស្មៅឱ្យមានភាពបៃតងស្រស់បំព្រង ដើម្បីលើកតម្លៃបរិវេណអង្គរធំទាំងមូល។

យោងតាមឯកសារប្រវត្តិសាស្ត្រក្នុងឆ្នាំ ១៩០៩ មុខព្រះលានជល់ដំរីនេះគឺពុំមានស្លាកស្នាមផ្លូវសម្រាប់យានជំនិះចេញចូលនោះទេ។ នៅឆ្នាំ ១៩១២ ទើបឃើញមានផ្លូវមួយស្របក្បែរនឹងប្រាសាទសួរព្រ័ត្រ។ រីឯផ្លូវជាប់នឹងព្រះលានជល់ដំរីទើបមានពេលក្រោយ នៅឆ្នាំ១៩២៨ប៉ុណ្ណោះ។

ឯកឧត្តមយិតចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរាទទួលបន្ទុកក្នុងកិច្ចការនេះ បានឱ្យដឹងថា ដោយមើលឃើញពីហានិភ័យចំពោះប្រាសាទ (រំញ័រនិងការពុកផុយថ្ម) និងភ្ញៀវទេសចរ (គ្រោះថ្នាក់ចរាចរណ៍) ដែលបង្កដោយការបើកបរយានជំនិះគ្រប់ប្រភេទ លើផ្លូវដែលកៀកខ្លាំងនឹងព្រះលានជល់ដំរីនិងក្នុងគោលបំណងលើកតម្លៃបរិវេណនេះឱ្យមានលក្ខណៈដើម និងបង្ក លក្ខណៈងាយស្រួលដល់ការដើរទេស្សនារបស់ភ្ញៀវទេសចរ ទើបអាជ្ញាធរជាតិអប្សរា បានកែលម្អផ្លូវស្របនឹងប្រាសាទសួរព្រ័ត្រសម្រាប់យានយន្ត ហើយផ្លូវមុខព្រះលានជល់ដំរីសម្រាប់ការដើរថ្មើរជើង។

ចំពោះទីតាំងដែលត្រូវកែលម្អទាំងស្រុងគឺចាប់ពីកាច់ជ្រុងខាងជើងប្រាសាទបាយ័ន្ត រហូតដល់ចំណុចមុខព្រះពន្លាស្តេចគម្លង់។ ក្រុមការងារនឹងបិទទីតាំងនេះជា ដំណាក់កាលមិនឱ្យរំខានដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋនិងភ្ញៀវទេសចរឡើយហើយកិច្ចការនេះគ្រោងនឹងបញ្ចប់រយៈពេល៦ខែ។

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១

ថ្ងៃទី ១២ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិត្រាចជុំ ភូមិបង្កោង ភូមិត្រពាំងរុន ឃុំអំពិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិក្ហង់ ភូមិក្លង់(គោកគ្រើល)ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១៥សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅភូមិជ័យ ភូមិស្រែចង្កុត ភូមិតាឯង ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩សំណើ។

សរុបមក នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង៣ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២៩សំណើ។

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៣ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិអំពិលពាម ភូមិប្រឡាយ ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក នង សុវណ្ណារិទ្ធ បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិបឹងដូនប៉ា ភូមិទ្រាំង ភូមិមណ្ឌលបី សង្កាត់ស្លក្រាម។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សរុបមក នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិបន្ទាយស្រី និងភូមិទួលក្រឡាញ់ ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី។

ក្រោយពីចុះពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ នៅក្នុងបរិវេណប្រាសាទភិមានអាកាស

ផ្សាយនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២១

ដើមឈើហានិភ័យចំនួន១៣ដើមស្ថិតក្នុងបរិវេណប្រាសាទភិមានអាកាស បាននិងកំពុងកាត់ក្រី និងខ្លះត្រូវដកហូត។ ការងារនេះធ្វើឡើងបន្ទាប់ពីក្រុមជំនាញព្រៃឈើសង្កេតឃើញថាដើមឈើទាំងនោះខ្លះដុះក្បែររចនាសម្ព័ន្ធប្រាសាទ និងខ្លះតាមបរិវេណផ្លូវទស្សនារបស់ភ្ញៀវទេសចរផង។ គោលបំណងសំខាន់នៃការងារនេះ គឺដើម្បីបញ្ចៀសហានិភ័យនានា ដែលអាចកើតជាយថាហេតុចំពោះមនុស្ស និងប្រាសាទ។

ដើមឈើដែលកំពុងដកហូតរួមមាន ដើមពុទ្រា១ដើម ស្វាយព្រៃ១ដើម ឈើទាល១ដើម ពង្រ១ដើម ស្លង់១ដើម និងពពូល២ដើម ដែលស្ថានភាពដើមឈើទាំងនេះបានងាប់ទាំងស្រុង ដុះជាប់កំពែងប្រាសាទជិតស្រះទឹក និងទ្រេតខ្លាំងទៅលើខ្លោងទ្វារខាងជើងប្រាសាទភិមានអាកាស ព្រមទាំងនៅជាប់ផ្លូវទស្សនាផង។ រីឯដើមឈើដែលកំពុងកាត់ក្រីមានចំនួន៦ដើមមាន ចាមរី១ដើម ព្រីង១ដើម អង្កោល១ដើម ឈើទាល១ដើម ស្លង់១ដើម និងទ្រៀក១ដើមដែលស្ថានភាពដើមឈើទាំងនេះនៅរស់ត្រូវកាត់ក្រី១១មែកចេញ ដើម្បីជួយសម្រាលតួដើមកុំឲ្យដួលរលំ។ ការងារនេះចាប់ផ្ដើមធ្វើពីថ្ងៃទី៤ ហើយគ្រោងនឹងបញ្ចប់នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិតាប្រុក ភូមិដូនឪ ភូមិត្រពាំងស្វាយ ភូមិសំរោង លាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១៦សំណើ។

ដោយឡែកគោលដៅទី២ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិថ្នល់ ភូមិទឹកថ្លា ភូមិប្រិយ៍ចាស់ ភូមិប្រិយ៍ថ្មី ភូមិប្រយុទ្ធ សង្កាត់ស្លក្រាម។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។

សរុបមក នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១៩សំណើ។
សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អញ្ជើញពិនិត្យវឌ្ឍនភាពការរៀបចំនៅមុខបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២១

ឆ្លៀតក្នុងឱកាសអញ្ជើញមកបំពេញភារកិច្ច នៅខេត្តសៀមរាប **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា នារសៀលថ្ងៃសុក្រ ទី១៥ ខែមករា ឆ្នាំ២០២១ បានអញ្ជើញពិនិត្យការរៀបចំមណ្ឌលបដិសណ្ឋារកិច្ច ការរៀបចំកែលម្អសោភ័ណភាពនិងសួនបៃតងនៅមុខបរិវេណប្រាសាទអង្គរវត្ត។

ទន្ទឹមនឹងការសង្កេតឃើញនូវវឌ្ឍនកិច្ចដ៏ល្អប្រសើរ លោកជំទាវបណ្ឌិតសភាចារ្យក៏បានធ្វើការលើកទឹកចិត្ត ដល់អាជ្ញាធរជាតិអប្សរាឲ្យបន្តយ៉ាងសកម្មចំពោះភារកិច្ចរបស់ខ្លួនក្នុងការលើកតម្លៃជាសកលនៃរមណីយដ្ឋានអង្គរតាមរយៈកិច្ចការអភិរក្ស។ ជាពិសេសធ្វើយ៉ាងណារក្សានូវភាពទាក់ទាញនិងភាពអស្ចារ្យរបស់ប្រាង្គប្រាសាទនៃរមណីយដ្ឋានអង្គរក្នុងក្តីសុបិន្តរបស់ភ្ញៀវទេសចរអន្តរជាតិដែលប៉ងប្រាថ្នាមកទស្សនាទីនេះតាមរយៈនៃកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាព៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អញ្ជើញពិនិត្យការកែលម្អបរិវេណមុខព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២១

នៅរសៀលថ្ងៃសុក្រ ទី១៥ ខែមករា ឆ្នាំ២០២១ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ក្នុងគោលបំណងតាមដានការអនុវត្តការងាររបស់អាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះពិនិត្យសកម្មភាពលើកតម្លៃបរិវេណក្រុងអង្គរធំទាំងមូលដែលរួមមានការកែលម្អទីធ្លាបរិវេណមុខព្រះលានជល់ដំរី ការរៀបចំជាផ្លូវថ្មើរជើងនិងប្រព័ន្ធរំដោះទឹក ព្រមទាំងដាំស្មៅឲ្យមានភាពបៃតងស្រស់បំព្រងជាប្រចាំ។

ក្នុងឱកាសនោះ លោកជំទាវបណ្ឌិតសភាចារ្យ បានពិនិត្យមើលរណ្ដៅកំណាយបុរាណវិទ្យាបង្ការនិងលទ្ធផលស្រទាប់ដីដែលអ្នកជំនាញបុរាណវិទ្យាកំពុងតែបំពេញដើម្បីស្វែងយល់អំពីទំនាក់ទំនងប្រវត្តិសាស្ត្រនៃបរិវេណមុខព្រះលានជល់ដំរីជាមួយនឹងប្រាង្គប្រាសាទដែលនៅទីនោះ៕

សារលិខិតរំលែកព្រះមរណទុក្ខ

ផ្សាយនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២១

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទាំនៃអាជ្ញាធរជាតិអប្សរា មានសេចក្តីក្តុកក្តួលរំជួលចិត្តឥតឧបមា ដោយបានទទួលដំណឹងថា **សម្តេចព្រះបរមរាមា នរោត្តម យុវនាថ** ឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានយាងចូលព្រះទិវង្គតនៅថ្ងៃព្រហស្បតិ៍ ០១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ នៅសហរដ្ឋអាមេរិក ក្នុងព្រះជន្មាយុ ៧៨ព្រះវស្សា ដោយព្រះរោគាពាធ។

អាជ្ញាធរជាតិអប្សរា
APSARA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សារលិខិតរំលែកព្រះមរណទុក្ខ

សូមក្រាបបង្គំទូលថ្វាយ
អ្នកម្នាង យិន នរោត្តម យុវនាថ

អ្នកម្នាង ជាទីគោរពរាប់អានដ៏ខ្ពង់ខ្ពស់

តាងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងផ្ទាំនៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្ញុំបាទផ្ទាល់ យើងខ្ញុំមានសេចក្តីក្តុកក្តួលរំជួលចិត្តឥតឧបមា ដោយបានទទួលដំណឹងថា **សម្តេចព្រះបរមរាមា នរោត្តម យុវនាថ ឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានយាងចូលព្រះទិវង្គតនៅថ្ងៃព្រហស្បតិ៍ ០១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ នៅសហរដ្ឋអាមេរិក ក្នុងព្រះជន្មាយុ ៧៨ព្រះវស្សា ដោយព្រះរោគាពាធ។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមចូលរួមរំលែកនូវមរណទុក្ខជាមួយអ្នកម្នាង រួមទាំងបុត្រា បុត្រី ប្រកបដោយអនិច្ចលក្ខណធម៌ សង្វេគ សោកស្តាយ ស្រណោះអាឡោះអាល័យស្ទើររកទីបំផុតគ្មាន ព្រោះថាការបាត់បង់**សម្តេចព្រះបរមរាមា នរោត្តម យុវនាថ** គឺជាការបាត់បង់ព្រះស្វាមីប្រកបដោយសង្គហធម៌ និងការបាត់បង់ព្រះបិតា ប្រកបដោយព្រះព្រហ្មវិហារធម៌ ដ៏ជ្រាលជ្រៅ ពិសេសគឺការបាត់បង់អង្គព្រះរាជវង្សទ្រង់ស្នេហាជាតិ សាសនា ព្រះមហាក្សត្រ មួយអង្គដ៏ល្អឆ្នើមបំផុត។

ជាមួយគ្នានេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់ដួងព្រះវិញ្ញាណក្ខន្ធ **សម្តេចព្រះបរមរាមា នរោត្តម យុវនាថ ឧត្តមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ទ្រង់យាងទៅសោយសុខនាឋានសុគតិភពគ្រប់ៗព្រះជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **អ្នកម្នាង** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃសុក្រ ០២កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្គោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក អ៊ឹម សុខរិទ្ធី បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិគោកបេង នៅភូមិគោកត្នោត សង្កាត់គោកចក ក្រុងសៀមរាប។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិតាប្រុក ភូមិសំពេង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម មុី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិអូរទទឹង ភូមិព្រះដាក់ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះត្រួតពិនិត្យការងារប្រចាំខែនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១

នាព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ដឹកនាំកិច្ចប្រជុំនៅតាមទីតាំងជាក់ស្តែងនៃការងារដើម្បីតាមដានការអនុវត្តការងារផ្សេងៗនាពេលកន្លងមក ព្រមទាំងផ្តល់យោបល់បច្ចេកទេស និងដំណោះស្រាយនានាសម្រាប់កិច្ចការទាំងនោះ។

ក្នុងដំណើរការត្រួតពិនិត្យការងារនេះ អង្គប្រជុំបានចុះពិនិត្យទីតាំងមួយចំនួនដែលចាំបាច់ត្រូវកែសម្រួលប្រព័ន្ធរំដោះទឹក លើកកម្ពស់សោភ័ណភាពទូទៅក្នុងតំបន់ប្រាសាទ ក៏ដូចជាបង្កើនគុណភាពសេវាកម្មទេសចរណ៍រមណីយដ្ឋានអង្គរក្រោយជំងឺកូវីដ-១៩។

ជាចុងបញ្ចប់នៃដំណើរត្រួតពិនិត្យប្រចាំខែមករានេះ ឯកឧត្តមអគ្គនាយក និងអ្នកជំនាញគ្រប់នាយកដ្ឋាន ក៏បានចុះទៅពិនិត្យសំណង់អាគារសាលាបារាំងចុងបូព៌ាដែលមានអាយុជាង១០០ឆ្នាំមកហើយនៅខាងលិចប្រាសាទបាយ័ន្ត ដើម្បីពិនិត្យពីស្ថានភាពសំណង់ និងឱ្យរៀបចំជួសជុលអាគារនេះឡើងវិញ សម្រាប់ទុកជាកន្លែងរក្សាទុកនូវបុរាណវត្ថុផ្សេងៗ ព្រោះកន្លែងនេះក៏ជាទីតាំងរក្សាទុកនិងជួសជុលបុរាណវត្ថុពីសម័យបារាំងមកដែរ៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

រយៈពេលពីរសប្តាហ៍នៃខែមករា ឆ្នាំ២០២១នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌនៃការរស់នៅ និងប្រើ ប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋ បានចំនួន៩៥ករណី រួមមាន៖ ក្រុងសៀមរាប ២៨ករណី ស្រុកបន្ទាយស្រី ២៤ករណី ស្រុកអង្គរធំ១០ករណី ស្រុកប្រាសាទបាគង ២០ករណី ស្រុកពួក ៤ករណី ស្រុកសូទ្រនិគម១ករណី។



ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បី ទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់បាន ចំនួន ២៣ ករណីរួមមាន៖ ស្រុកអង្គរធំ ៥ករណី ក្រុងសៀមរាប ៣ករណី ស្រុកប្រាសាទបាគង ៦ករណី ស្វាយលើ ៤ករណី ស្រុកពួក ១ករណី និងស្រុកបន្ទាយស្រី ៤ករណី។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោល គឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។



សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ស្ពានតាអោងមានអាយុកាលជិត៩០០ឆ្នាំត្រូវបានជួសជុលជាលើកដំបូង ដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

ស្ពានតាអោងឬតាអុង មានទីតាំងស្ថិតនៅក្នុងភូមិចុងស្ពាន ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប គឺជាស្ពានបុរាណវែងជាងគេក្នុងចំណោមស្ពានបុរាណចំនួន២៣លើដងផ្លូវបុរាណពីអង្គរទៅបាកាណ (ព្រះខ័នកំពង់ស្វាយ)។ សព្វថ្ងៃស្ពានបុរាណនេះមានសភាពទ្រុឌទ្រោមខ្លាំងដែលបង្កឡើងពីកត្តាមនុស្សនិងធម្មជាតិ ធ្វើឱ្យផ្នែកជាច្រើនរបស់ស្ពានបុរាណបានប្រេះញែកចេញពីគ្នា ហើយនៅផ្នែកកណ្តាលតួស្ពានសងខាង ថ្មមួយចំនួនបានរលុះធ្លាក់ និងផ្នែកផ្សេងទៀតកំពុងប្រឈមនឹងការរលុះធ្លាក់ដែរ។

តាមការបញ្ជាក់របស់លោកពុទ្ធ សុទ្ធ មន្ត្រីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនិងជាប្រធានគម្រោងជួសជុលស្ពានតាអោងឱ្យដឹងថា៖ អាជ្ញាធរជាតិអប្សរាផ្តើមគម្រោងជួសជុលដំណាក់កាលទី១ នេះចំនួន២ចំណុចសំខាន់ៗ គឺនៅជញ្ជាំងស្ពានផ្នែកខាងជើងដែលបានរលុះធ្លាក់និងមានរហែកធំចេញក្រៅប្រឈមនឹងការរលុះធ្លាក់ ។ក្រុមការងារនឹងធ្វើសម្រង់ប្លង់ ចុះបញ្ជីថ្មការជួសជុលថ្ម ការរៀបចំពង្រឹងជើងសសរថ្មដែលរលុះធ្លាក់ឡើងវិញ ការបង្ហាប់ដីកន្លែងប្រោះនៅតល់ស្ពានខាងលិចនិងការរៀបចំបង្កាន់ដៃនាគដាក់ចូលតាមទីតាំងដើមឡើងវិញ។

ចំពោះប្រវត្តិនិងចំណុចសំខាន់នៃស្ពានបុរាណមួយនេះ លោក ពុទ្ធ សុទ្ធ បានប្រាប់ថា៖ ស្ពានតោអោងឬតាអុង មានបណ្តោយប្រវែង៧០ម៉ែត្រ ទទឹង១៣ម៉ែត្រ និងមានទ្វេត្រដេវចំនួន១៤។ ទ្វេត្រដេវនីមួយៗមានទទឹងប្រវែង ២ម៉ែត្រនិងកម្ពស់៦ម៉ែត្រ។ ស្ពាននេះធ្វើអំពីថ្មបាយក្រៀម លម្អដោយបង្កាន់ដៃនាគក្បាល៩ និងមានព្រះពុទ្ធសមាធិ នៅចំកណ្តាលក្បាលនាគធ្វើអំពីថ្មភក់។ ចំពោះកាលបរិច្ឆេទនៃស្ពាននេះ គេពុំដឹងច្បាស់ថាវាចាប់ផ្តើមកសាងឡើងក្នុងរាជ្យណាទេ គឺគ្រាន់តែដឹងជាទូទៅថាស្ពាននេះសាងឡើងនាសម័យអង្គរ។ ប៉ុន្តែបើមើលលើចម្លាក់បង្កាន់ដៃនាគ គេអាចដឹងថា វាស្ថិតក្នុងរចនាបថបាយ័ន្ត (ឆ្នាំ១១៨១-១២២០នៃគ្រិស្តសករាជ)។

សូមបញ្ជាក់ថា ស្ពានបុរាណដែលមានអាយុកាលជិត៩០០ឆ្នាំនេះ បានប្រារព្ធពិធីប្រុងពលីសែនបួងសួងសុំសេចក្តីសុខចម្រើននិងជោគជ័យក្នុងការជួសជុលលើកដំបូងក្នុងប្រវត្តិសាស្ត្រ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ដែលមាន **ឯកឧត្តម គីម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរានិងសហការីរួមនឹងលោកអភិបាលស្រុក មន្ត្រីសាលាស្រុក មេឃុំ មេភូមិ កងរាជអាវុធហត្ថ និងប្រជាជនដែលរស់នៅក្នុងភូមិជាច្រើននាក់បានចូលរួមឱ្យពរជ័យ។ គម្រោងជួសជុលស្ពានបុរាណនេះ បានប្រើថវិកាមូលនិធិរបស់អាជ្ញាធរជាតិអប្សរា ហើយនឹងបញ្ចប់គម្រោងនៅខែមិថុនា ឆ្នាំ២០២១៕

អាជ្ញាធរជាតិអប្សរា ផ្លាស់ប្តូរកម្រាលឈើផ្លូវចូលប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

ទោះបីបច្ចុប្បន្ន កំណើនភ្ញៀវទេសចរបានធ្លាក់ចុះ ដោយសារជំងឺកូវីដ១៩ក៏ពិតមែន តែកិច្ចការងារជួសជុល អភិរក្ស នៅក្នុងតំបន់រមណីយដ្ឋានអង្គរនៅតែមមាញឹក។

ដាក់ស្ដែង កម្រាលឈើថ្មើជើងនៅក្នុងបរិវេណបន្ទាយស្រី ត្រង់ចំណុចគោបុរៈទី២ ឬច្រកចូលទី៣នៃប្រាសាទ ត្រូវបានក្រុមការងារ របស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ ដែលមានការចូលរួមសហការជាមួយក្រុមភ្នាក់ងារទេសចរ រួមទាំងភ្នាក់ងារសណ្ដាប់ធ្នាប់កំពុងរៀបចំជួសជុលផ្លាស់ប្ដូរកម្រាលឈើថ្មី។

ការជួសជុលនេះ ត្រូវបានអនុវត្តជាប្រចាំដើម្បីលើកតម្លៃរមណីយដ្ឋានអង្គរនិងបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរទស្សនាប្រាសាទ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែមករា ឆ្នាំ២០២១

ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិគោកត្រាច ភូមិជ្រលង ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិខ្វៀន សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សរុបមក នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សកម្មភាពកាត់ក្រីមែកឈើ និងដកហូតដើមឈើមានហានិភ័យខ្ពស់ក្នុងបរិវេណវត្ត ព្រះសិអារ្យមេត្រី និងវត្តតាំងតុក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

ដោយពិនិត្យឃើញមានហានិភ័យខ្ពស់របស់ដើមឈើ ដែលដុះនៅក្នុងបរិវេណវត្តព្រះសិអារ្យមេត្រី និងវត្តតាំងនៃអតីតក្រុងអង្គរធំ ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតអប្សរា បានសហការជាមួយផ្នែកពាក់ព័ន្ធ បានចុះពិនិត្យ និងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ ដើម្បីធានាសុវត្ថិភាពជូនពុទ្ធបរិស័ទ ព្រះសង្ឃ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់

អាយុជិវិត និងជួយសម្រាលតួដើមការពារកុំឲ្យបាក់រលំខូចខាតដល់រចនាសម្ព័ន្ធរបស់ព្រះវិហារ កុដិ និងយានយន្តគ្រប់ប្រភេទ។ ដើមឈើ ដែលបានកាត់ក្រីមែកចំនួន៣៤មែករួមមាន ដើមស្រឡៅ១ដើម ដើមឈើទាល៩ដើម ដើមស្លែង១ដើម។ ចំណែកឯដើមឈើងាប់ដែលបានដកហូតចំនួន៤ដើមរួមមាន ដើមឈើទាល ដើមពង្រ ដើមស្រឡៅ និងដើមស្លែង៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯក ឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិលលៃ ភូមិស្ទឹង ឃុំបាគង។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិទួលក្រឡាញ់ ភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២ គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន១១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកំពុងដំណើរការរៀបចំជួសជុលអតីតអាគារសាលាបារាំងចុងបូព៌ា នៅខាងលិចប្រាសាទបាយ័ន្ត

ផ្សាយនៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា បានរៀបចំដាំបង្គោលឈើនៅតាមដងផ្លូវនៃប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។

គោលបំណងនៃការរៀបចំនេះគឺដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ ធានាជូននូវសុវត្ថិភាពដល់ភ្ញៀវទេសចរក្នុងការធ្វើដំណើរ រក្សាសណ្តាប់ធ្នាប់នៃការចតយានជំនិះឱ្យមានរបៀបរៀបរយ ថែរក្សាសោភ័ណភាពទេសភាពវប្បធម៌អង្គរ ឱ្យមានភាពស្រស់ស្អាតដើម្បីទាក់ទាញទេសចរ។

អាជ្ញាធរជាតិអប្សរា ក៏សូមអំពាវនាវដល់ម្ចាស់យានយន្តមួយចំនួន សូមចូលចតនិងដាក់ភ្ញៀវចុះតាមទីតាំងកំណត់ដែលអាជ្ញាធរជាតិអប្សរាធ្វើទីចំណាត់ឱ្យចត ជៀសវាងឱ្យមានភាពកកស្ទះ និងគ្មានសណ្តាប់ធ្នាប់៕

អាជ្ញាធរជាតិអប្សរាអនុវត្តការងារបោះបង្គោលកំណត់ព្រំការពារនៅប្រាសាទបន្ទាយអំពិល

ផ្សាយនៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០២១

ក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋានអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរា កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១ បានសហការជាមួយអាជ្ញាធរមូលដ្ឋាន នគរបាលបេតិកភណ្ឌ និងភ្នាក់ងារប្រចាំការនៅប្រាសាទបន្ទាយអំពិល បានអនុវត្តការងារបោះបង្គោលកំណត់ព្រំការពារ ក្នុងតំបន់ការពារប្រាសាទបន្ទាយអំពិល ស្ថិតនៅក្នុងភូមិសំរោង ឃុំខ្នារពោធិ៍ ស្រុកសូទ្រនិគម ខេត្តសៀមរាប នៅខាងកើតប្រាសាទចៅស្រីវិបុល១០គីឡូម៉ែត្រ។

ការបោះបង្គោលព្រំការពារក្នុងតំបន់ការពារប្រាសាទបន្ទាយអំពិល មកដល់ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១នេះ បានចំនួន៣០បង្គោលហើយ។ ក្នុងនោះដែរអាជ្ញាធរជាតិអប្សរាក៏បានធ្វើកំណាយស្រាយជ្រាវដែរ ដើម្បីពិនិត្យមើលទីតាំងបុរាណដ្ឋាននិងវត្ថុបុរាណផ្សេងៗដើម្បីសិក្សាស្រាវជ្រាវនិងការពារ។

អត្ថប្រយោជន៍ដ៏សំខាន់នៃការកំណត់បង្គោលព្រំការពារបុរាណដ្ឋាននេះ គឺដើម្បីការពារការរំលោភបំពានដីធ្លី ការបំផ្លាញលើបុរាណដ្ឋាន និងផ្តល់ភាពងាយស្រួលដល់ប្រជាជនក្នុងតំបន់បានយល់ដឹងពីតំបន់ការពារ ចូលរួមការពារបុរាណដ្ឋានក្នុងមូលដ្ឋានរបស់ពួកគាត់ដោយសេចក្តីស្រឡាញ់ជាមួយអ្នកជំនាញ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០២១

ថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ា ន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិតាប្រុក ភូមិក្លង់ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិប្រាសាទចារ្យ ភូមិដូនអុន ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយលោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិគោកតាចាន់ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

គោលដៅទី៤ ក្រុមការងារក្រៅឧទ្យាន ដឹកនាំដោយលោក ឈាន រដ្ឋា បានពិនិត្យ និងដោះស្រាយនៅភូមិបឹងមាលា ឃុំបឹងមាលា។ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ឯកឧត្តមបណ្ឌិត ហង់ ពៅ ដឹកនាំក្រុមការងារមកជិះកង់សាកល្បងលើផ្លូវកង់ថ្មី នៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២១

នៅព្រឹកថ្ងៃអាទិត្យ ១១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ **ឯកឧត្តម បណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារជិះកង់សាកល្បងលើផ្លូវកង់ថ្មី ដែលជាផលិតផលទេសចរណ៍ថ្មីសម្រាប់ឆ្នាំ២០២១នៅក្នុង រមណីយដ្ឋានអង្គរ។

ឯកឧត្តម បណ្ឌិត ហង់ ពៅ មានប្រសាសន៍ថា ថ្ងៃនេះយើងនាំគ្នាមកជិះកង់សាកល្បងលើផ្លូវកង់ថ្មីដែលយើងបានស្ថាបនាឡើងនាឆ្នាំ២០២០កន្លងទៅនេះ ក្នុងគោលបំណងដើម្បីពិនិត្យ សាកល្បង និងត្រៀមទទួលស្វាគមន៍ដល់សហប្រធានគណៈកម្មាធិការIC C ដែលនឹងមកពិនិត្យ និងដកបទពិសោធន៍កម្រិតសប្បាយពេញចិត្តចំពោះគម្រោងនេះយ៉ាងណា ហើយថាតើនៅមានចំណុចណាខ្លះទៀតដែលត្រូវកែសម្រួលដើម្បីឱ្យស្របតាមគោលការណ៍រមណីយដ្ឋាន ដែលជាបេតិកភណ្ឌពិភពលោក។

ឯកឧត្តម បានមានប្រសាសន៍បន្ថែមទៀតថា ការស្ថាបនាផ្លូវកង់នេះឡើងក្រោមទស្សនៈគិតគូរវែង ឆ្ងាយរបស់ **លោកជំទាវបណ្ឌិតសាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ដើម្បីជួយសម្រួលចរាចរណ៍ និងសុខសុវត្ថិភាពដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស ចូលរួមចំណែកថែរក្សាបរិស្ថានក្នុងតំបន់អង្គរ និងទាក់ទាញទេសចរណ៍កីឡាអ្នកជិះកង់កម្សាន្តអ្នកជិះកង់ហាត់ប្រាណដើម្បីសុខភាព ជាដើម។



ឯកឧត្តម បណ្ឌិត អំពាវនាវដល់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ អ្នកជិះកង់កម្សាន្ត អ្នកជិះកង់ហាត់ប្រាណ ទាំងអស់ជួយចូលរួមថែរក្សាបរិស្ថាន អនាម័យ ដោយកុំបោះបង់សម្រាមសំបកដប ម៉ាសប្រើរួចនៅតាមបណ្តោយផ្លូវកង់ថ្មីនេះ និងសូមជួយចូលរួមសម្អាតទាំងអស់គ្នាដើម្បីបង្ហាញពីមោទនភាពជាតិយើង៕

អាជ្ញាធរជាតិអប្សរារៀបចំតម្រង់បង្គោលឈើ និងដាក់ខ្សែឡើងវិញ នៅតាមដងផ្លូវប្រាសាទបាយ័ន្ត

ផ្សាយនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១

ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា បានរៀប ចំតម្រង់បង្គោលឈើឱ្យត្រង់ និងដាក់ខ្សែឡើងវិញនៅតាមដងផ្លូវប្រាសាទបាយ័ន្ត។

គោលបំណងនៃការរៀបចំនេះ គឺដើម្បីធ្វើឱ្យមានសោភ័ណភាពល្អ ធានាជូននូវសុវត្ថិភាពដល់ ភ្ញៀវទេសចរក្នុងការធ្វើដំណើរ រក្សាសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈក្នុងតំបន់ រមណីយដ្ឋានអង្គរ៕

ភ្នាក់ងារទេសចរណ៍ប្រាសាទបន្ទាយស្រី បន្តចូលរួមកិច្ចការថែទាំ និងអភិរក្សប្រាង្គប្រាសាទ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក

ផ្សាយនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១

បើទោះបីជាស្ថានភាពភ្ញៀវទេសចរមានសភាពស្ងប់ស្ងាត់ ក៏ក្រុមការងារផ្សេងៗ របស់អាជ្ញាធរជាតិអប្សរាមិនបាន បន្ថយកិច្ចការប្រចាំថ្ងៃរបស់ខ្លួនដែរ។ ជាក់ស្តែងក្នុងពេលនេះភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទបន្ទាយស្រីបានកំពុងសហការចូលរួមយ៉ាងសកម្មជាមួយនាយកដ្ឋានជំនាញផ្សេងៗក្នុងកិច្ចការអភិរក្សនិងថែទាំជាប្រចាំចំពោះប្រាង្គប្រាសាទដែលជាសម្បត្តិ បេតិកភណ្ឌដ៏មានតម្លៃរបស់ពិភពលោក។

នេះជាគំរូដ៏ល្អមួយក្នុងការចូលរួមសហការបំពេញបន្ថែមលើជំនាញផ្សេងៗ ដែលមានភាពចាំបាច់សម្រាប់ស្ថាប័នអាជ្ញាធរជាតិអប្សរាទាំងមូល។

សេចក្តីជូនដំណឹងស្តីពីការកាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើដែលមានហានិភ័យខ្ពស់នៅតាមបរិវេណប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖៩០/អប. សជណ
២១

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើ ដែលមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ និងសាធារណជនទូទៅក៏ដូចជា ដើម្បីលើកកម្ពស់សោភ័ណភាពនៅតាមដងផ្លូវ និងកុំឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ កាត់ដើមឈើពាក់កណ្តាលដើម និងកាត់ក្រីមែកឈើនៅតាមទីតាំងនានាដូចខាងក្រោម៖

-កាត់ដកហូតដើមឈើចំនួន ០៣ដើម (ដើមដូងងាប់០២ដើម និងដើមស្លែងរស់០១ដើម) និងកាត់ក្រីមែកឈើចំនួន ១០ដើម (ដើមឈើទាល០៨ដើម ដើមបង្គៃដំរី០១ដើម និងដើមស្លែង០១ដើម) ដែលមានហានិភ័យស្ថិតនៅវត្តគោកធ្លក។
-កាត់ដកហូតដើមឈើទាលរស់ចំនួន ០៣ដើម ស្ថិតនៅប្រាសាទសួព្រ័ត ជិតរោងដាក់រន្ទាររបស់JASA។
-កាត់ដកហូតដើមឈើចំនួន ០២ដើម (ដើមបង្គីងាប់០១ដើមនិងដើមអង្គញ់ងាប់០១ដើម) និងកាត់ក្រីមែកចំនួន០៣ដើម(ដើមឈើទាលរស់០២ដើមនិងដើមម្កាក់រស់០១ដើម)ដែលមានហានិភ័យស្ថិតនៅប្រាសាទបាយ័ន កន្លែងការដ្ឋានរបស់JASA។
-កាត់ដកហូតដើមពោធិ៍ចំនួន ០២ដើម និងកាត់ដើមឈើទាលពាក់កណ្តាលដើម ០១ដើម ដែលមានហានិភ័យស្ថិតនៅខាងលិចប្រាសាទអង្គរវត្ត។
-កាត់ដកហូតដើមឈើចំនួន ០៤ដើម (ដើមសំបួររស់០៣ដើម និងដើមអាទិត្យ០១ដើម) ដែលមានហានិភ័យស្ថិតនៅប្រាសាទក្រោលរមាស លើខ្នងភ្នំគូលេន។
-កាត់ដកហូតដើមឈើចំនួន ១៤ដើម (ដើមទ្រៀក០២ដើម ដើមដកព០៤ដើម ដើមល្វស០៣ដើម ដើមស្វាយ០៣ដើម ដើមពន្លា០១ដើម និងដើមសុភី០១ដើម) ដែលមានហានិភ័យ ស្ថិតនៅបរិវេណប្រាសាទគោកពោធិ៍។
-កាត់ដកហូតដើមឈើចំនួន ០៤ដើម (ដើមឈើទាល ដើមដកព ដើមត្រាច និងដើមចំបក់) ដែលមានហានិភ័យចំណុចផ្លូវចូលច្រកខាងកើតប្រាសាទអង្គរវត្ត រហូតដល់ខាងត្បូងប្រាសាទបន្ទាយក្តី។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ តទៅរហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០២១

APSARA National Authority
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
Address: Bang Kong Village, Ampil Commune, Prasat Bakong District, Siem Reap Province

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈអញ្ជើញជាអធិបតីកិច្ចប្រជុំបច្ចេកទេសលើកទី៣៤ និងកិច្ចប្រជុំពេញអង្គលើកទី២៧នៃអាយស៊ីស៊ី-អង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២១

គណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្រ្តអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ (ICC-Angkor) បានសម្រេចរៀបចំកិច្ចប្រជុំបច្ចេកទេសលើកទី៣៤ និងកិច្ចប្រជុំពេញអង្គលើកទី២៧នៃអាយស៊ីស៊ី-អង្គរ នៅថ្ងៃទី២៦-២៧ ខែមករា ឆ្នាំ២០២១ នាសណ្ឋាគារសូហ្វីតែល ខេត្តសៀមរាប បន្ទាប់ពីខកខានដោយសារការរីករាតត្បាតជាសកល នៃជំងឺកូវីដ១៩។

កិច្ចប្រជុំទាំងពីរនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងនាមតំណាងរាជរដ្ឋាភិបាលកម្ពុជា និងលោកជំទាវ Eva Nguyên-Binh ឯកអគ្គរដ្ឋទូតបារាំងប្រចាំនៅកម្ពុជា និងឯកឧត្តម Mikami Masahiro ឯកអគ្គរដ្ឋទូតជប៉ុនប្រចាំនៅកម្ពុជា ក្នុងនាមសហប្រធាននៃកិច្ចប្រជុំពេញអង្គ ។

ទន្ទឹមនឹងនេះ អ្នកជំនាញការអន្តរជាតិ ភ្ញៀវជាតិ និងក្រុមអ្នកជំនាញពាក់ព័ន្ធមួយចំនួនទៀតនឹងចូលរួមកិច្ចប្រជុំទាំងពីរ តាមរយៈ video conference ពីកិច្ចប្រជុំជាក់ស្តែងនាខេត្តសៀមរាប និងក្រៅប្រទេស។ កិច្ចប្រជុំនេះដែរ ក៏មានការចូលរួមពីអ្នកជំនាញអាដហុកថ្មី សម្រាប់ការងារអភិរក្សដែលទើបទទួលបានការតែងតាំងថ្មីគឺ លោកសាស្ត្រាចារ្យ Stefano De Caro អតីតអគ្គនាយកនៃវត្ថុបុរាណរបស់ប្រទេសអ៊ីតាលី និងជាអតីតអគ្គនាយកនៃICCROM ។

ប្រធានបទសំខាន់ៗនៃកិច្ចប្រជុំ គឺផ្តោតលើការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងតំបន់អង្គរ ការតាមដានអំពីការអនុវត្តនូវរាល់អនុសាសន៍ដែលកិច្ចប្រជុំអាយ

ស៊ីស៊ី-អង្គរបានសម្រេចនាពេលកន្លងមក ការពិភាក្សាផ្លាស់ប្តូរយោបល់រវាងអ្នកជំនាញអាដហុកអំពីកិច្ចការផ្សេងៗដែលកំពុងនិងត្រៀមអនុវត្តនាពេលអនាគត។ ក្នុងនោះដែរ កិច្ចប្រជុំក៏នឹងសម្រេចអនុម័តនូវអនុសាសន៍ថ្មីៗបន្ថែមដល់ក្រុមការងារជំនាញដើម្បីអនុវត្តស្របតាមផែនការអនុវត្តគម្រោងនីមួយៗ។

ចំពោះការចូលរួមដោយផ្ទាល់ពីអ្នកជំនាញជាតិ-អន្តរជាតិ នៅសណ្ឋាគារសូហ្វីតែល គឺប្រកាន់ខ្ជាប់នូវវិធានការអនាម័យ និងការរក្សាគម្លាតសង្គមក្នុងនោះបានកំណត់ចំនួនអ្នកចូលរួមផ្ទាល់ចំនួនតែ៧០នាក់ប៉ុណ្ណោះ៕

គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ៖ ការថែរក្សាអភិរក្សរមណីយដ្ឋានអង្គរជាកាតព្វកិច្ចរួមរបស់កម្ពុជា និងសហគមន៍អន្តរជាតិ

ផ្សាយនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់លេខាធិការដ្ឋាន គណៈកម្មាធិការអាយសីសី-អង្គរ អំពីកិច្ចប្រជុំបច្ចេកទេស

លើកទី៣៤ និងកិច្ចប្រជុំពេញអង្គលើកទី២៧ នាថ្ងៃទី២៦-២៧ ខែមករា ឆ្នាំ២០២១ ប្រព្រឹត្តទៅនៅខេត្តសៀមរាប បានឱ្យដឹងថាការអភិរក្សនិងអភិវឌ្ឍន៍ ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរដែលជាសម្បត្តិបេតិកភណ្ឌនៃមនុស្សជាតិរបស់អង្គការយូណេស្កូ រយៈពេល២៥ឆ្នាំមកនេះ គឺមិនមែនជាកាតព្វកិច្ចរបស់កម្ពុជាតែឯងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកាតព្វកិច្ចរបស់អន្តរជាតិដែរ។

ក្នុងន័យនេះ ទោះបីជាក្នុងឆ្នាំ២០២០កន្លងមក ពិភពលោកមានការប្រឈមនឹងការរីករាលដាលជំងឺកូវីដ-១៩ ក៏ក្រុមការងារជំនាញជាតិនិងអន្តរជាតិបន្តអនុវត្តបានយ៉ាងមានប្រសិទ្ធភាពនូវរាល់គម្រោងអភិរក្ស ជួសជុល និងអភិវឌ្ឍន៍ ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។ ក្នុងនេះដែរ ទាំងអ្នកជំនាញជាតិនិងអន្តរជាតិបានជួយសហការអនុវត្ត និងដោះស្រាយបញ្ហាលំបាកជាមួយគ្នា។ ជាលទ្ធផល តម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានអង្គរ ព្រមទាំងការរក្សាបាននូវសភាពដើមនៃប្រាសាទ ក៏ដូចជាតំបន់ការពាររមណីយដ្ឋានអង្គរទាំងមូលត្រូវបានលើកតម្កើងដែលជាគោលបំណងចំបងបំផុតក្នុងការរក្សាតំបន់រមណីយដ្ឋានអង្គរឲ្យស្ថិតក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ។

ដូច្នេះ រាល់សមិទ្ធផលសម្រេចបានពីការជួសជុលប្រាសាទ ការស្រាវជ្រាវ ការបណ្ដុះបណ្ដាលធនធានអ្នកជំនាញនៅអាជ្ញាធរជាតិអប្សរា និងក្រៅប្រទេស គឺសុទ្ធតែបង្ហាញយ៉ាងប្រាកដពីការប្រកៀកស្មាគ្នាយ៉ាងជិតស្និតរវាងកម្ពុជានិងដៃគូអន្តរជាតិក្នុងក្របខណ្ឌគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងអង្គការយូណេស្កូ៕

គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ចុះត្រួតពិនិត្យនិងជិះសាកល្បងលើផ្លូវកង់ដែលជាសមិទ្ធផលទេសចរណ៍ថ្មីនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២១

នាព្រឹកថ្ងៃទី២៧ខែមករាឆ្នាំ២០២១ថ្ងៃទី២នៃកិច្ចប្រជុំពេញអង្គលើកទី២៧ និងកិច្ចប្រជុំបច្ចេកទេសលើកទី៣៤ នៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំសហប្រធានបារាំងនិងជប៉ុន អង្គការយូណេស្កូ អ្នកជំនាញការអាដហុក មន្រ្តីស្ថានទូតមួយចំនួន អ្នកជំនាញអន្តរជាតិ និងសហការីអាជ្ញាធរជាតិអប្សរា ចុះត្រួតពិនិត្យនិងជិះកង់សាកល្បងលើផ្លូវកង់ ដែលជាសមិទ្ធផលទេសចរណ៍ថ្មីនៅរមណីយដ្ឋានអង្គរ។

ឯកឧត្តម ហង់ ពៅ បានសម្តែងសេចក្តីរីករាយចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដែលបានចុះមកត្រួតពិនិត្យ ក៏ដូចជាជិះកង់កម្សាន្តនៅលើផ្លូវកង់ដែលទើបសម្រេចបានថ្មីៗនៅក្នុងរមណីយដ្ឋានអង្គរនាថ្ងៃនេះ ប្រកបដោយភាពសប្បាយរីករាយនិងការពេញចិត្តបំផុត។

ឯកឧត្តមបានអ្នកមានប្រសាសន៍បន្ថែមទៀតថា ការស្ថាបនាផ្លូវកង់នេះឡើងក្រោមទស្សនៈគិតគូរវែងឆ្ងាយរបស់លោក **ជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្រ្តីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា។ គោលបំណងសំខាន់គឺដើម្បីជួយសម្រួលចរាចរណ៍និងធានាសុវត្ថិភាពដល់ប្រជាពលរដ្ឋសិស្សានុសិស្សដែលជិះកង់ក្នុងតំបន់។ ពិសេសផ្លូវកង់នេះ

ក៏បានចូលរួមចំណែកថែរក្សាបរិស្ថានក្នុងតំបន់អង្គរ និងទាក់ទាញទេសចរដែលចូលចិត្តជិះកង់កម្សាន្ត អ្នកជិះកង់ហាត់ប្រាណដើម្បីសុខភាពទទួលបានអារម្មណ៍រីករាយស្រស់ថ្លា មិនភ័យភ័យខ្លាចពីគ្រោះថ្នាក់ឬការរំខានពេលកំពុងជិះកង់។

ផ្លូវកង់នេះមានទទឹង២ម៉ែត្រ និងបណ្តោយ២៣គីឡូម៉ែត្រ ចាប់ពីកន្លែងលក់សំបុត្រចាស់កាត់តាមក្រោយប្រាសាទអង្គរវត្ត បន្តទៅប្រាសាទក្រវ៉ាន់ រួចកាត់ខាងត្បូងប្រាសាទបន្ទាយក្តី បត់ទៅខាងជើងប្រាសាទតាព្រហ្ម ឆ្ពោះទៅស្ពានប្រាសាទកែវ។ ផ្លូវកង់នេះស្ថាបនាឡើងនាឆ្នាំ២០២០ ដោយការបង្ហាប់ដីនិងស្រោចកៅស៊ូពីលើ បត់បែនតាមចន្លោះដើមឈើ ដែលស្ថិតនៅមិនឆ្ងាយ និងស្របនឹងផ្លូវធំដែលអាចមើលគ្នាឃើញ ដើម្បីធានាបាននូវសន្តិសុខនិងសុវត្ថិភាពដល់អ្នកជិះកង់៕

រយៈពេល៣ថ្ងៃ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ

ផ្សាយនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២១

ចាប់ពីថ្ងៃទី២៦ ដល់២៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានបានចុះពិនិត្យ និងដោះស្រាយនៅភូមិលាងដៃ ភូមិត្រពាំងស្វាយ ឃុំលាងដៃ ស្រុកអង្គរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិព្រៃក្មេង ភូមិខ្នាត ភូមិព្រៃធ្លក ឃុំខ្នាត។ ក្រោយពីចុះពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក នង សុវណ្ណារិទ្ធ បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិអញ្ចាញ ឃុំនគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារប្រចាំក្រុងសៀមរាប លោក នង សុវណ្ណារិទ្ធ បានចុះពិនិត្យ និងដោះស្រាយនៅភូមិអញ្ចាញ សង្កាត់នគរធំ ក្រុងសៀមរាប។ ក្រោយពីចុះពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី២៦ ដល់២៨ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅ បានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅតាមទីតាំងនានាក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១

ក្រៅពីបំពេញភារកិច្ចជាប្រចាំ ក្រុមការងារនាយកដ្ឋានសណ្ដាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា និងនគរបាលការពារបេតិកភណ្ឌ ក៏បានឆ្លៀតពេលបោសសម្អាតដី ប្រមូលសំរាម ស្លឹកឈើ និងរៀបចំអនាម័យបរិស្ថាន នៅទីតាំងនានានៅតំបន់រមណីយដ្ឋានអង្គរ។

ការសម្អាតអនាម័យបរិស្ថាននេះ គឺដើម្បីលើកកម្ពស់សោភ័ណភាព អនាម័យ បរិស្ថាន និងសុខុមាលភាពរបស់ភ្ញៀវទេសចរដែលមកកម្សាន្តនៅតាមប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។

បញ្ជាក់ដែរថា ជាទូទៅរមណីយដ្ឋានអង្គរតែងតែធ្វើការសម្អាតជាប្រចាំដោយក្រុមការងារសម្អាតបរិស្ថានដោយភ្នាក់ងារសម្អាតHCC។

សូមទស្សនាកម្រងរូបភាពនៃការអនុវត្តការងារ ដើម្បីភាពស្រស់ស្អាតនៃតំបន់រមណីយដ្ឋានអង្គរ និងសូមចូលរួមថែរក្សាបរិស្ថានឱ្យបានគ្រប់ៗគ្នា!

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែមករា ឆ្នាំ២០២១

ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន៣គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ដាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតក្នុងឃុំលាងដៃ ភូមិ ដូនឪ និងឃុំស្វាយចេក ភូមិព្រះគោថ្មី។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោ ក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិអន្លង្គន់ ភូមិគោកញ្ចៅ ភូមិតាកាំ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១០សំណើ។

គោលដៅទី៣ ក្រុមការងារក្រៅឧទ្យាន ដឹកនាំដោយលោក ឈានរដ្ឋា បានពិនិត្យនិងដោះស្រាយស្ថិតនៅឃុំបឹងមាលា និងឃុំបង្ល័ង។ក្រោយពីពិនិត្យទីតាំងនិងឯកសារដាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។

សរុបមក នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ នៅខាងកើតប្រាសាទតាព្រហ្ម

ផ្សាយនៅថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២១



ក្រោយពីក្រុមអង្កេតដើមឈើហានិភ័យបានពិនិត្យឃើញមានដើមឈើចំនួន១៣ដើមមានហានិភ័យខ្ពស់ ដែលក្នុងនោះមាន៦ដើមងាប់ទាំងស្រុង ស្ថានភាពដើមឈើទាំងនោះដុះទ្រេតជាប់ផ្លូវចូលប្រាសាទ ដុះជាប់ផ្លូវចូលបន្ទប់ទឹក និងក្បែរតូបលក់ដូរក្នុងចំណតខាងកើតប្រាសាទតាព្រហ្ម។



ដើម្បីបង្ការ និងបញ្ចៀសគ្រោះថ្នាក់ទុកជាមុន កុំឲ្យប៉ះពាល់ដល់អាយុជីវិតរបស់ភ្ញៀវទេសចរ និងយានយន្តគ្រប់ប្រភេទ ក្រុមជំនាញ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ដោយសហការជាមួយផ្នែកពាក់ព័ន្ធ កំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ ដោយកាត់ក្រីមែកចំនួន១២មែករួមមាន ដើមអង្កាញ់២ដើម ដើមឈើទាល២ដើម ដើមត្រសេក១ដើម ដើមពពេលខែ១ដើម និងដើមទ្រៀក១ដើម។ ចំណែកឯដើមឈើងាប់ដែលដកហូតចំនួន៦ដើមរួមមាន ដើមឈើទាល២ដើម ដើមត្រសេក២ដើម និងដើមអង្កាញ់២ដើម៕



ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកុម្ភៈ

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យាន អង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិស្រះស្រង់ត្បូង សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរា បានបញ្ចប់ការងារជួសជុលផ្លូវដីថ្មើរជើងសម្រាប់ភ្ញៀវទេសចរ ដើរទស្សនាធម្មជាតិជុំវិញប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២១

បន្ទាប់ពីការទស្សនាប្រាសាទបន្ទាយស្រីភ្ញៀវទេសចរជាតិ និងអន្តរជាតិត្រូវបានលើកទឹកចិត្ត ឱ្យបន្តការដើរទស្សនាធម្មជាតិ ព្រៃព្រឹក្សា ព្រមទាំងសត្វស្លាបដែលមានវត្តមាននៅជុំវិញបរិវេណប្រាសាទបន្ទាយស្រីដោយប្រើប្រាស់ផ្លូវដីដែលអាជ្ញាធរអប្សរាបានរៀបចំតាំងពីឆ្នាំ២០០៨ សម្រាប់តែអ្នកថ្មើរជើងប៉ុណ្ណោះ។

ផ្លូវថ្មើរជើងនេះ ទទួលបន្ទុកជួសជុលដោយនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ ក្នុងន័យរក្សាឱ្យបាននូវសុវត្ថិភាពដល់ភ្ញៀវទេសចរ និង ចូលរួមគ្រប់គ្រងលំហូរភ្ញៀវផងដែរ។

ផ្លូវដីថ្មើរជើងនេះ ត្រូវបានជួសជុលកែលម្អឡើងវិញដោយចាក់បំពេញដី និងកិនបង្ហាប់នៅតាមទីតាំងហូរច្រោះ ព្រមទាំងដាំស្មៅនៅតាមស្មាផ្លូវដើម្បីបង្កើនសោភ័ណភាព និងទប់ស្កាត់ការហូរច្រោះនៃទឹកភ្លៀង។

ការងារជួសជុលផ្លូវដីថ្មើរជើងនេះត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ ហើយក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងបន្តការងារពិនិត្យថែទាំផ្លូវ និងស្មៅដែលបានដាំនៅតាមស្មាផ្លូវនេះ ដើម្បីរក្សាបាននូវសោភ័ណភាព សុវត្ថិភាពដល់ភ្ញៀវទេសចរ និងការប្រើប្រាស់បានយូរ អង្វែងទៅមុខ។

សម្ភារបរិក្ខារផ្សេងៗសម្រាប់បម្រើការក្នុងឧទ្យានអង្គរតែងទទួលបានការថែទាំជាប្រចាំ

ផ្សាយនៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២១

ក្រៅពីការងារអភិរក្សជួសជុលប្រាង្គប្រាសាទដែលជាភារកិច្ចស្នូល អាជ្ញាធរជាតិអប្សរាតែងយកចិត្តទុកដាក់ថែទាំជួសជុលគ្រប់សម្ភារបរិក្ខារទាំងអស់ សំដៅយ៉ាងណាឱ្យរមណីយដ្ឋានអង្គរកាន់តែមានសោភ័ណភាពស្រស់បំព្រងឡើងថែមទៀត។

ជាក់ស្តែងកាលពីព្រឹកថ្ងៃទី១កុម្ភៈ២០២១នេះក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ (TSC) និងភ្នាក់ងារទេសចរណ៍ប្រចាំខ្លោងទ្វារទន្លេអុំបានសហការគ្នាលាងសម្អាត និងលាបថ្នាំបន្ថែមលើរបាំងថ្មស៊ីម៉ង់ត៍តាមចិញ្ចើមផ្លូវ នៅចំណុចខ្លោងទ្វារទន្លេរអុំ ដើម្បីឱ្យទីតាំងមួយនេះមានសោភ័ណភាពកាន់តែប្រសើរឡើង ក៏ដូចជាបង្ករភាពងាយស្រួលក្នុងការធ្វើដំណើរជាដើម៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន៣គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិ សំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន១០សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិបុស្សធំ ភូមិគីរីមានន្ទ ភូមិបឹងរុន ភូមិត្រពាំងរុន ឃុំអំពិល។ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំ ស្រុកបន្ទាយស្រី បានពិនិត្យ និងដោះស្រាយស្ថិតនៅភូមិថ្នល់ទទឹង និងភូមិអូរទទឹង ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់សម្អាតបរិស្ថាន

ផ្សាយនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២១

ក្រុមការងារនាយកដ្ឋានសណ្ដាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការ ភ្នាក់ងារទេសចរណ៍ នគរបាលបេតិកភណ្ឌ ព្រះសង្ឃ និងក្រុមការងារសម្អាតបរិស្ថាន-HCC បានរួមគ្នារើសកាកសំណល់ប្លាស្ទិក និងសំរាមផ្សេងៗនៅក្នុងបរិវេណនៃទីក្រុងអង្គរធំ ដើម្បីឱ្យរមណីយដ្ឋានអង្គររក្សាបាននូវអនាម័យ និងបរិស្ថានស្អាតជាប់ជានិច្ច។

កិច្ចការសម្អាតនៅពេលនេះ មានបីគោលដៅគឺគោលដៅទីមួយ ក្រុមការងារបានសម្អាតបរិស្ថានជុំវិញប្រាសាទបាយ័ន្ត បរិវេណវត្តព្រះឥន្ទទេព និងតាមបណ្ដោយផ្លូវពីប្រាសាទយ័ន្តរហូតដល់ខ្លោងទ្វារតាការ។ រីឯគោលដៅទីពីរ គឺក្រុមការងារបានសម្អាតបរិវេណប្រាសាទបាភួន ប្រាសាទ

ភិមានអាកាស និងជុំវិញវត្តទេពប្រណម្យ។ ចំណែកឯគោលដៅទីបី គឺនៅទីធ្លាមុខប្រាសាទសួរព្រ័ត្រ បរិវេណវត្តវិហារប្រាំពីរល្វែង និងវត្តតាំងតុ។

អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់លើការគ្រប់គ្រងគុណភាពបរិស្ថានជាអាទិភាព ដើម្បីបញ្ចៀសឱ្យបាននូវការបំពុលបរិស្ថាន ដែលជាហេតុបង្កនូវបញ្ហាផ្សេងៗ ដូចជាបញ្ហាសុខភាព និងលើកកម្ពស់សោភ័ណភាពរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំប្រជុំត្រួតពិនិត្យតាមដានការងារអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២១

នារសៀលថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំប្រជុំការងារសំខាន់ៗ មួយចំនួនដើម្បីពិនិត្យតាមដានលើគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលបានទទួលការអនុម័តដោយរាជរដ្ឋាភិបាល និងសិក្សាគម្រោងផ្សេងៗសម្រាប់

អនុវត្តជាបន្តទៀតនាឆ្នាំខាងមុខ។ ឯកឧត្តម អគ្គនាយកអាជ្ញាធរជាតិអប្សរាបានដឹកនាំក្រុមការងារចុះពិនិត្យគម្រោងកែលម្អស្ទឹងសៀមរាប ដែលស្ថិតក្នុងរមណីយដ្ឋានអង្គរ ដើម្បីពិភាក្សា ផ្តល់យោបល់ក្នុងការរក្សាឱ្យបាននូវតម្លៃជាប្រវត្តិសាស្ត្ររបស់ស្ទឹងសម្រាប់កូនខ្មែរជំនាន់ក្រោយ និងឱ្យក្លាយជាទីទាក់ទាញសម្រាប់ភ្ញៀវទេសចរ។

បន្ថែមទៀតនោះ អង្គប្រជុំក៏បានពិនិត្យការអនុវត្តគម្រោងកែលម្អផ្លូវ **សម្តេចឧបុលបញ្ញា សុខ អាន** ព្រមទាំងស្វែងរកដំណោះស្រាយនានាក្នុងន័យពន្លឿនការងារឲ្យកាន់តែមានប្រសិទ្ធភាព។

ទន្ទឹមនឹងនេះដែរ **ឯកឧត្តមហង់ពៅ**ក៏បានផ្តល់អនុសាសន៍ដល់សហការីលើទិសដៅអនាគត ថាគម្រោងអ្វីខ្លះដែលត្រូវធ្វើបន្តទៀត ដែលតម្រូវឱ្យអ្នកបច្ចេកទេសយកទៅសិក្សាលម្អិត ដើម្បីយកមកអភិវឌ្ឍន៍ និងអភិរក្សតំបន់រមណីយដ្ឋានអង្គរប្រកបដោយចីរភាព៕

សកម្មភាពកាត់ដកហូតដើមឈើងាប់មានហានិភ័យខ្ពស់ នៅតាមផ្លូវរង់ធំ និងប្រាសាទនាគព័ន្ធ

ផ្សាយនៅថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២១

ដោយពិនិត្យឃើញមានហានិភ័យខ្ពស់របស់ដើមឈើដែលងាប់ទាំងស្រុង ដុះអមតាមដងផ្លូវរង់ធំ តាមច្រកចូលនិងក្នុងបរិវេណប្រាសាទនាគព័ន្ធ ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយផ្នែកពាក់ព័ន្ធ បានចុះពិនិត្យ និងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ។ តាមអង្កេតជាក់ស្តែង ដើមឈើទាំងនោះងាប់ដោយកត្តាធម្មជាតិ ដុះជាប់ផ្លូវកៅស៊ូ ទ្រេតទៅរកផ្លូវកង់ជាប់ផ្លូវចូលប្រាសាទ និងដុះជាប់រចនាសម្ព័ន្ធរបស់ប្រាសាទ។ ដូច្នេះ ដើម្បីធានាសុវត្ថិភាពជូនអ្នកដំណើរដែលឆ្លងកាត់និងភ្ញៀវទេសចរជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការការខូចខាតដល់ប្រាសាទផង ក្រុមការងារបានសុំគោលការណ៍និងចុះកាត់ដកហូតជាបន្ទាន់។

ដើមឈើងាប់ដែលបានកាត់ដកហូតមានចំនួន១៧ដើមរួមមាន ដើមត្រសេក៣ដើម រំដួល១ដើម សិរមាន់១ដើម ក្រឡាញ់១ដើម ធ្លក១ដើម ធ្លក២ដើម ពពេល២ដើម ចំបក់២ដើម កកោះ១ដើម ព្រីងមួយរយស្រទាប់១ដើម និងឈើទាល២ដើម ៕

អាជ្ញាធរជាតិអប្សរា កំពុងដាំស្មៅ និងដើមឈើ កែលម្អសោភ័ណភាព នៅផ្លូវចូលកំពង់ទឹកស្រះស្រង់

ផ្សាយនៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១

រមណីយដ្ឋានអង្គរជាតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ និងមានភាពល្បីល្បាញជាសកលរហូតដល់បច្ចុប្បន្ននេះ។ ជាបន្តបន្ទាប់ ក្នុងបំណងដើម្បីរៀបចំកែលម្អសោភ័ណភាពបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរឱ្យកាន់តែស្រស់ស្អាតបន្ថែមទៀត ថ្មីៗនេះអាជ្ញាធរជាតិអប្សរា បាននិងកំពុងរៀបចំដាំស្មៅ និងដើមឈើបន្ថែមនៅបរិវេណកំពង់ទឹកស្រះស្រង់។

តាមផែនការការងាររបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន ក្រៅពីការងារដាំស្មៅនិងដើមឈើនៅបរិវេណកំពង់ទឹកស្រះស្រង់នេះ ក្នុងនោះនាយកដ្ឋានក៏គ្រោងរៀបចំការដាំស្មៅ និងដើមឈើធំៗចំនួន១១ទីតាំងបន្ថែមទៀតដូចជា បរិវេណខាងជើងនិងខាងលិចសួនក្រវ៉ាន់ (ខាងមុខប្រាសាទអង្គរវត្ត) ជុំវិញត្រពាំងសេស បរិវេណប្រាសាទព្រហ្មកិល បរិវេណជុំវិញអាងស្នាក់ខ្សាច់(ច្រកសំពៅលូន) ផ្នែកខាងលិចជាប់កសិន្ធុប្រាសាទអង្គរវត្ត ផ្នែកខាងត្បូងក្នុងប្រាសាទអង្គរវត្ត ខាងមុខបរិវេណប្រាសាទព្រះខ័ន នៅមុខប្រាសាទបន្ទាយក្តី និងនៅបរិវេណប្រាសាទលលៃ ព្រមទាំងរៀបចំសួនច្បារនៅរង្វង់មូលអប្សរា និងរង្វង់មូលព្រៃគុយលើវិថីសម្តេចវិបុលបញ្ញា សុខ អាន(ផ្លូវ៦០ម៉ែត្រ)ជាដើម៕

អាជ្ញាធរជាតិអប្សរាប្រគល់ប័ណ្ណសរសើរដល់ប្រជាពលរដ្ឋ៧គ្រួសារ ដែលបានសាងសង់ផ្ទះខ្មែរត្រឹមត្រូវស្របតាមគំរូប្លង់ស្ថាបត្យកម្ម

ផ្សាយនៅថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរា ដោយមានការចូលរួមពីមន្ត្រីរដ្ឋបាលស្រុកបន្ទាយស្រីបានប្រគល់ប័ណ្ណសរសើរជូនប្រជាពលរដ្ឋចំនួន៧គ្រួសារនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលបានសាងសង់ផ្ទះខ្មែរបានត្រឹមត្រូវស្របតាមប្លង់ស្ថាបត្យកម្មដែលអាជ្ញាធរជាតិអប្សរាប្រគល់ជូន។ពិធីនេះត្រូវបានរៀបចំឡើងនៅព្រឹកថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ នៅគេហដ្ឋានរបស់ប្រជាពលរដ្ឋ ដែលស្ថិតនៅភូមិព្រះដាក់ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងនៃ អាជ្ញាធរជាតិអប្សរា ដែលបានអញ្ជើញជាអធិបតីនៅពេលនោះបានមានប្រសាសន៍ថា តាមគោលការណ៍របស់រាជរដ្ឋាភិបាលគឺអាជ្ញាធរជាតិអប្សរាកំពុងប្រឹងប្រែងលើកតម្លៃផ្ទះបែបខ្មែរ ដែលជាសម្បត្តិបេតិកភណ្ឌរូបីនិងបានចូលរួមបង្ហាញតម្លៃវប្បធម៌ដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ និងមនុស្សជំនាន់ក្រោយឱ្យបានដឹងពីកេរដំណែលរបស់ដូនតាខ្មែរយើង។

ឯកឧត្តម បន្ថែមទៀតថារមណីយដ្ឋានអង្គរគឺជាតំបន់វប្បធម៌នៃអត្តសញ្ញាណរបស់ជាតិខ្មែរ ដូច្នេះប្រជាពលរដ្ឋយើងដែលកំពុងរស់នៅក្នុងតំបន់នេះត្រូវចូលរួមថែរក្សា លើកតម្លៃវប្បធម៌របស់យើង ដែលជាបេតិកភណ្ឌវប្បធម៌នៃមនុស្សជាតិ។

ទន្ទឹមនេះដែរ ប្រជាពលរដ្ឋដែលជាម្ចាស់ផ្ទះបានសម្តែងអារម្មណ៍ត្រេកអរ ដោយមិននឹកស្មានថា ផ្ទះរបស់ពួកគាត់ត្រូវបានអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលស្រុកបន្ទាយស្រីចាត់ទុកជាផ្ទះគំរូហើយទទួលបានប័ណ្ណសរសើរថែមទៀតផង។ ពួកគាត់ក៏សូមថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិអប្សរា និងរដ្ឋបាលស្រុកបន្ទាយស្រីដែលបានប្រគល់ប័ណ្ណសរសើរដល់ពួកគាត់នាពេលនេះ និងសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋផ្សេងទៀតដែលកំពុងរស់នៅក្នុងឧទ្យានអង្គរ ប្រសិនបើមានគម្រោងសង់ផ្ទះសូមទៅដាក់ពាក្យស្នើសុំសាងសង់ និងសង់ផ្ទះតាមគំរូផ្ទះខ្មែរស្របតាមការណែនាំរបស់អាជ្ញាធរជាតិអប្សរា។

គួរបញ្ជាក់ផងដែរថា អាជ្ញាធរជាតិអប្សរាមានគម្រោងចុះប្រគល់ជូនប័ណ្ណសរសើរដល់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ នៅស្រុកអង្គរធំ និងស្រុកប្រាសាទបាគង ដែលបានសាងសង់ផ្ទះខ្មែរបានត្រឹមត្រូវនៅពេលឆាប់ៗខាងមុខនេះទៀត៕

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ កន្លែងផ្តល់ចំណេះដឹងអំពីកិច្ចការស្រាវជ្រាវបុរាណវិទ្យាដ៏សម្បូរបែបនៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២១

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ មានអាសយដ្ឋាននៅតាមបណ្តោយផ្លូវ **សម្តេចឧបុលបញ្ញា សុខ អាន** (ផ្លូវ60ម៉ែត្រ) ស្ថិតក្នុងភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ សារមន្ទីរនេះបានកសាងឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសាកលវិទ្យាល័យសូហ្វីយ៉ាដោយទទួលបានការឧបត្ថមថវិកាពីក្រុមហ៊ុនអ៊ីអុង (AEON) របស់ប្រទេសជប៉ុន។

គោលបំណងសំខាន់នៃការកសាងសារមន្ទីរនេះគឺដើម្បីថែរក្សា ក៏ដូចជាបង្ហាញជូនដល់សាធារណជនជាតិ និងអន្តរជាតិនូវវត្ថុបុរាណ ដែលបានធ្វើកំណាយឃើញក្នុងពេលសិក្សាស្រាវជ្រាវនៅប្រាសាទបន្ទាយក្តីកាលពីឆ្នាំ២០០០ និង២០០១។ បន្ទាប់ពីបានបើកដំណើរការចាប់តាំងពីឆ្នាំ២០០៨មក សារមន្ទីរបានពង្រីកការតាំងពិព័រណ៍សមុច្ច័យជាបន្តបន្ទាប់ ដោយបច្ចុប្បន្នសារមន្ទីរមានពិព័រណ៍សំខាន់ៗ ដូចជា៖ ពិព័រណ៍វាលកប់សពគោកតាមាស និងព្រៃក្មេង ពិព័រណ៍ប្រាសាទបន្ទាយក្តី ពិព័រណ៍គោកប៉ាទ្រី និងពិព័រណ៍ស្តីអំពីសមិទ្ធិផលនៃកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងបណ្តាស្ថាប័នអន្តរជាតិក្នុងកិច្ចការគាំពារ និងជួសជុលប្រាសាទនានាក្នុងតំបន់អង្គរ។

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បើកជូនសាធារណជនចូលទស្សនាពីថ្ងៃអង្គារ ដល់ថ្ងៃអាទិត្យ ចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង៤ល្ងាច។ ជាពិសេសមិនគិតថ្លៃចំពោះកងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ ដូនជី តាជី និងកុមារក្រោមអាយុ១២ឆ្នាំ។ សារមន្ទីរក៏មានមគ្គុទ្ទេសក៍ជំនាញនៅចាំពន្យល់បកស្រាយជូនភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដោយឥតគិតថ្លៃផងដែរ។

អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន២៤៨សំណើ ក្នុងខែមករា ឆ្នាំ២០២១

ផ្សាយនៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន២៤៨សំណើ ក្នុងខែមករា ឆ្នាំ២០២១ លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំខែមករា ឆ្នាំ២០២១ បានចុះផ្សព្វផ្សាយអប់រំ និងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសាងសង់តូចតាចទាំង៦គោលដៅស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរចំនួន៣៣៧សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន២៤៨សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងចំនួន៣៣សំណើ ស្រុកអង្គរធំចំនួន៨៨សំណើ ស្រុកពួកចំនួន៣២សំណើ ក្រុងសៀមរាបចំនួន៥៣សំណើ និងស្រុកបន្ទាយស្រីចំនួន៣២សំណើ រួមទាំងក្រុមការងារក្រៅឧទ្យានអង្គរចំនួន១០សំណើ សរុប២៤៨សំណើ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧបត្ថម្ភថវិកាដល់គ្រួសារខ្វះខាតដែលរងគ្រោះដោយសារអគ្គិភ័យ និងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ ថែមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យ គម្រោងការងារនៅបរិវេណប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២១

នារសៀលថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារចុះពិនិត្យ និងសិក្សាគម្រោងការងារមួយចំនួននៅបរិវេណប្រាសាទតាកែវ។ ថ្នាក់ដឹកនាំ បានពិគ្រោះយោបល់ និងស្តាប់រាល់មតិពីអ្នកជំនាញនានា ជុំវិញការងារដែលគ្រោងអនុវត្តន៍នាពេលខាងមុខ ដូចជាការរៀបចំកែលម្អផ្លូវច្រកចូលជាដើម ក្នុងន័យលើកកម្ពស់សោភ័ណភាព និងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមអគ្គនាយកបានណែនាំ និងផ្តល់អនុសាសន៍មួយចំនួនជូនក្រុមការងារ ត្រូវពន្លឿនការងារអនុវត្តឱ្យបានទាន់ពេលវេលា និងរៀបចំផែនការគម្រោងការងារឆ្នាំថ្មី ដើម្បីត្រៀមខ្លួនសម្រាប់ការស្វាគមន៍ភ្ញៀវទេសចរត្រឡប់មកវិញនាពេលឆាប់ៗខាងមុខនេះ៕

ទំនៀមចាប់ត្រីរួមគ្នា ត្រៀមឡើងមាឃរបស់អ្នកស្រុកអង្គរ នៅតែបន្តប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន

ផ្សាយនៅថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០២១

នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ប្រមូលផ្តុំទៅដោយបេតិកភណ្ឌរស់ ដែលសម្បូរទាំងមរតកអរូបី និងរូបីជាច្រើន ហើយត្រូវបានអ្នកស្រុកអង្គរបន្តប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនរហូតមកដល់បច្ចុប្បន្ន។

ជាក់ស្តែងជារៀងរាល់ឆ្នាំ ច្រើនជំនាន់មនុស្សមកហើយ ឱ្យតែដល់ខែមាឃ អ្នកស្រុកភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប មិនដែលខកខាននិងតែងតែនាំគ្នាប្រារព្ធពិធីចាប់ត្រីរួមជាលក្ខណៈសហគមន៍ដើម្បីត្រៀមរៀបចំពិធីឡើងមាឃតាមទំនៀមទម្លាប់ពីបុរាណ។

ការចាប់ត្រីរួមគ្នាធ្វើឡើងនៅត្រពាំងបឹងដែលជាត្រពាំងបុរាណមានទឹកខួបប្រាំងខួបវស្សាអ្នកស្រុកបានអភិរក្សទុកការពារមិនអនុញ្ញាតឱ្យនរណាម្នាក់ចូលមកនេសាទផ្តេសផ្តាស់ខុសពីខែមាឃនេះឡើយ លុះត្រាតែមានការសម្រេចគ្នាពីគណៈកម្មការរៀបចំបុណ្យជាមុន ហើយកំណត់ថ្ងៃនេសាទរួម ទើបអ្នកភូមិអាចទៅរកចាប់បាន។ ប៉ុន្តែត្រូវតែប្រើឧបករណ៍នេសាទបុរាណ រួមមានសំណាញ់ អង្រុត ឈ្នាង ជាដើម។

លោក ពេជ្រ ឃិន មេភូមិភូមិបង្កោងមានប្រសាសន៍ថា ត្រីដែលចាប់បាននោះ មួយផ្នែកសម្រាប់ធ្វើម្ហូបលក្ខណៈគ្រួសាររៀងៗខ្លួន មួយផ្នែកទៀតសម្រាប់ធ្វើទឹកនំបញ្ចុក និងធ្វើម្ហូបអាហាររួម សម្រាប់ពិធីឡើងមាឃ ឬបុណ្យឡើងអ្នកតាតាមទំនៀមបុរាណ។

លោកមេភូមិឱ្យយដឹងទៀតថា ឆ្នាំនេះសម្បូរត្រី។ ប៉ុន្តែដោយសារឆ្នាំនេះ មានភ្លៀងធ្លាក់ចុងឆ្នាំច្រើនទឹកបឹងមិនសូវស្រក ការចាប់ត្រីក៏បានតិច។ ហេតុដូច្នេះ បានជាត្រូវពន្យារការចាប់ត្រីពីថ្ងៃ៣កើត ខែមាឃ ដែលធ្លាប់ធ្វើរាល់ឆ្នាំ មកថ្ងៃ៩រោច ខែមាឃវិញ។ ទោះបី ពិធីនេះមិនបានប្រារព្ធក្នុងថ្ងៃណាមួយច្បាស់លាស់ តែមិនឱ្យហួសពីខែមាឃនេះឡើយ។

ប្រជាជនក្នុងភូមិបង្កោង យុវជន លោក យឿន តារា ដែលក្រោកមកចាំចាប់ត្រីតាំងពីព្រលឹមស្រាងៗ បានសម្តែងចិត្តសប្បាយរីករាយដែលបានមកចាប់ត្រីរួមគ្នា ដែលបង្ហាញការសាមគ្គីរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ ពិសេសរក្សាបាននូវទំនៀមទម្លាប់ដែលមានតាំងពីយូរលង់មកហើយ។

ក្នុងនាមជាយុវជន លោកចង់ឱ្យទំនៀមនេះនៅតែបន្តសម្រាប់ឱ្យកូនចៅជំនាន់ក្រោយស្គាល់រហូតតទៅ។ ការប្រារព្ធពិធីបុណ្យឡើងមាឃឬឡើងអ្នកតានេះ ជាផ្នែកមួយនៃបេតិកភណ្ឌអរូបី ក្រៅពីបង្ហាញឱ្យឃើញតម្លៃវប្បធម៌ ការថែរក្សាមរតកវប្បធម៌ ក៏បានឆ្លុះបញ្ចាំងពីសាមគ្គីភាពនិងភាពរស់រវើកនៅតាមសហគមន៍ និងដើម្បីអបអរដល់ទិន្នផលទទួលបាន ក្រោយពីបានប្រមូលផលស្រូវរួចរាល់ហើយ។ ចំពោះពិធីនេះ ក៏មានការប្រារព្ធប្រហាក់ប្រហែលគ្នានៅតាមស្រុក និងខេត្តមួយចំនួនទៀតទូទាំងប្រទេសកម្ពុជាផងដែរ៕

វត្ថុបុរាណចំនួន៤ត្រូវបានប្រគល់ជូនអាជ្ញាធរជាតិអប្សរាដើម្បីរក្សាទុក

ផ្សាយនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២១

វត្ថុបុរាណធ្វើពីថ្មភក់ចំនួន៤ប្រភេទដែលប្រជាពលរដ្ឋរក្សាទុកនៅភូមិល្វា ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប រួមមាន ថ្មគោលធ្វើពីថ្មភក់ចំនួន១ ព្រះហស្តឆ្វេងទេពស្រី (ប្រាជ្ញាបារមិតា ?)ធ្វើពីថ្មភក់ចំនួន១និងជើងទម្រចំនួន២ ដែលជើងទម្រមួយមានចារជាអក្សរខ្មែរបុរាណចំនួន៤ ជួរនៅផ្ទៃចំហៀង។

វត្ថុទាំងនោះត្រូវបានយកចេញពីទីតាំងដើមដោយប្រជាពលរដ្ឋក្នុងគោលបំណងរក្សាទុកបណ្តោះអាសន្នប៉ុន្តែក្រុមការងារកំណត់បុរាណដ្ឋាននៃអាជ្ញាធរជាតិអប្សរាក្នុងគោលដៅស្រុកវ៉ារិន បានស្នើសុំឱ្យយកមករក្សាទុកនៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ដើម្បីសុវត្ថិភាពដល់វត្ថុទាំងនោះផង ដើម្បីទុកសិក្សាស្រាវជ្រាវ និងចុះបញ្ជីកំណត់អត្តសញ្ញាណវត្ថុទាំងអស់នោះផង។

លោក ឈូក សុម៉ាឡា មន្ត្រីទទួលបន្ទុកការងារចុះបញ្ជីវត្ថុសិល្បៈនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា នេះមិនមែនជាលើកទីមួយទេដែលក្រុមការងារបានចុះទៅទទួលយករូបចម្លាក់ផ្សេងៗដែលប្រជាពលរដ្ឋរស់នៅតាមតំបន់ឆ្ងាយៗ ក្នុងតំបន់រដ្ឋបាលខេត្តសៀមរាបទាំងមូល។ ដូចករណីនេះចម្លាក់ព្រះហស្តឆ្វេងប្រាជ្ញាបារមិតា គឺត្រូវបានយកមកពីប្រាសាទទាវប៉ាត់ ភូមិរលំរុនថ្មី ឃុំស្រែណូយ រីឯជើងទម្រចំនួន២ ដែលមួយមានសិលាចារិក ត្រូវបានគេយកចេញពីប្រាសាទត្រពាំងឈូក ភូមិល្វា ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប។

លោក សុម៉ាឡា បានបន្តថា ការដឹកយកវត្ថុបុរាណដ៏មានតម្លៃទាំងនេះទៅរក្សាទុកឱ្យទាន់ពេលវេលា គឺជាការប្រសើរខ្លាំងណាស់ ដ្បិតវត្ថុមួយចំនួនអាចនឹងត្រូវបែកបាក់ខូចខាតដោយប្រការណាមួយជាយថាហេតុ។ តួយ៉ាងដូចជាជើងទម្រដែលយើងបានដឹកមករក្សាទុកនេះគឺមានសិលាចារិកយ៉ាងសំខាន់ ដែលមានផ្នែកខ្លះត្រូវបានគេយកកាំបិតទៅសំលៀង និងមានផ្នែកខ្លះទៀតមានស្នាមដំបំបែកខូចខាតជាដុំណំ។

តាំងនាមឱ្យអាជ្ញាធរជាតិអប្សរា លោក សុម៉ាឡា ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនប្រជាពលរដ្ឋដែលបានជួយចូលរួមថែរក្សាប្រាសាទបុរាណ និងវត្ថុបុរាណទាំងឡាយនេះ ជាពិសេសអាជ្ញាធរមូលដ្ឋាន ភូមិឃុំ និងស្រុកដែលបានសហការណ៍យ៉ាងកក់ក្តៅដើម្បីដឹករតនវត្ថុទាំងនេះយកមករក្សាទុកឱ្យមានសុវត្ថិភាពសម្រាប់ជាកេរមរតកជូនតាយើងទាំងអស់គ្នា៕

ដើមឈើ៤ដើមនឹងត្រូវដកហូតពីលើដងផ្លូវចាប់ពីខាងកើតប្រាសាទអង្គរវត្ត ដល់ខាងត្បូងប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០២១

មន្ត្រីបច្ចេកទេសនាយកដ្ឋានពាក់ព័ន្ធនៃអាជ្ញាធរជាតិអប្សរា ដោយមានកិច្ចសហការ និងសំណូមពរពីអាជ្ញាធរមូលដ្ឋាន សង្កាត់នគរធំ បានចុះពិនិត្យស្ថានភាពដើមឈើដែលដុះនៅលើដងផ្លូវពីខាងកើតប្រាសាទអង្គរវត្តដល់ខាងត្បូងប្រាសាទបន្ទាយក្តី ស្ថិតក្នុងភូមិក្រវ៉ាន់ និងភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ ក្រុងសៀមរាប។

ក្រោយពីបានពិនិត្យយ៉ាងល្អិតល្អន់ឃើញថា មានដើមឈើចំនួន២៣ដើមត្រូវមានវិធានការ ដែលក្នុងនោះ ដើមឈើចំនួន៤ដើមគួរដកហូតចេញជាបន្ទាន់ រួមមានដើមយាង១ដើម ដកព១ដើម ត្រាច១ដើម និងចំបក់១ដើម ដែលដើមឈើទាំង៤ដើមនេះមានហានិភ័យខ្ពស់ធ្លាប់កើតមានគ្រោះថ្នាក់ចរាចរណ៍ ហើយដុះទ្រេតខ្លាំងជាប់គន្លងផ្លូវកង់ និងនៅជាប់ចំណុចផ្លូវកោងទៀតផង។ វិធានការនេះដើម្បីបង្ការកុំឲ្យមានគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិតអ្នកដំណើរដែលបានឆ្លងកាត់ទីនោះ។ ចំណែកឯដើមឈើចំនួន១៩ដើមទៀតដែលមានហានិភ័យមធ្យមរួមមាន ដើមធ្លក៤ដើម យាង៧ដើម ចំបក់៦ដើម និងត្រាច២ដើម អាជ្ញាធរជាតិអប្សរា នឹងដាក់ផ្លាកសញ្ញាចំណាំងផ្លាតនៅលើដើមឈើទាំងនោះ និងបកកៅស៊ូផ្លូវកង់ដែលវាងដើមឈើចេញ ដែលវិធានការមួយនេះអាចរក្សាទុកដើមឈើទាំង១៩ដើមជាបន្តទៀត។

អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តន៍កិច្ចការខាងលើក្នុងសប្តាហ៍នេះ រហូតដល់បញ្ចប់ការងារ៕

សកម្មភាពនៃការសម្អាតបរិស្ថាន និងអនាម័យនៅតាមទីតាំងនានាក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរាតែងតែយកចិត្តទុកដាក់ ទៅលើ សោភ័ណភាព រួមទាំងសុវត្ថិភាពចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបានមកទស្សនាប្រាសាទនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលជាតំបន់បេតិកភណ្ឌពិភពលោក។

ជាក់ស្តែង ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការ ភ្នាក់ងារទេសចរនៃអាជ្ញាធរជាតិអប្សរា នគរបាលការពារបេតិកភណ្ឌ ភ្នាក់ងារព្រៃឈើ និងHCC ដែលក្រៅពីមានតួនាទីពិនិត្យមើលរបៀប រៀបរយចំពោះភ្ញៀវទេសចរហើយ ក្រុមការ ងារបានសម្អាតដី ប្រមូលសំរាមស្លឹកឈើ និង រៀបចំអនាម័យបរិស្ថាននៅទីតាំងនានានៅតំបន់រមណីយដ្ឋានអង្គរ។

ការសម្អាតបរិស្ថាននេះដើម្បីលើកកម្ពស់សោភ័ណភាពក្នុងប្រាសាទ និងសុខុមាលភាពនៃភ្ញៀវទេសចរ ដែលចូលមកទស្សនាប្រាសាទដ៏ល្បីល្បាញមួយនេះ មិនឱ្យមានផលប៉ះពាល់ដល់សុខភាព និងអារម្មណ៍ក្នុងពេលទស្សនា៕

សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី បង្ហាញពីការអភិរក្សវាយនភណ្ឌ វប្បធម៌ និងពាណិជ្ជកម្មរបស់ប្រទេសជុំវិញដងទន្លេមេគង្គនិងទន្លេគង្គា

ផ្សាយនៅថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២១

សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី មានអាសយដ្ឋាននៅភូមិបឹងដូនប៉ា តាមបណ្តោយផ្លូវ **សម្តេចឧបុលបញ្ញា សុខអាន** (ផ្លូវ៦០ម៉ែត្រ) សង្កាត់ស្លក្រាម ក្រុងសៀមរាប។

សារមន្ទីរនេះបានកសាងឡើងនៅឆ្នាំ២០១០ ដល់ឆ្នាំ២០១១ និងបើកឱ្យដំណើរការក្នុងខែមេសា ឆ្នាំ២០១៤ ក្រោមកិច្ចសហប្រតិបត្តិការទន្លេមេគង្គ-ទន្លេគង្គា ដោយមានប្រទេសចំនួន៦ចូលរួម ដូចជា៖ ប្រទេសកម្ពុជា ឥណ្ឌា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។

គោលបំណងនៃការកសាងសារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី គឺដើម្បីថែរក្សាប្រពៃណីនៃការផលិតវាយនភណ្ឌ ក៏ដូចជាបង្ហាញពីទំនាក់ទំនងរវាងអរិយធម៌ វប្បធម៌ និងពាណិជ្ជកម្មរបស់ប្រទេសជាសមាជិក ដែលមានរយៈពេលជាច្រើនសតវត្សរ៍មកហើយ។

បន្ទាប់ពីបើកដំណើរការ សារមន្ទីរបានធ្វើការតាំងបង្ហាញនូវសម្ភារៈសំខាន់ៗជាច្រើនមកពីប្រទេសជាសមាជិកក្នុងសាលពិព័រណ៍ទាំង៤របស់សារមន្ទីរដូចជា៖ សាលព័ត៌មានពិព័រណ៍ សាលពិព័រណ៍វត្ថុធាតុដើម និងដំណើរការផលិត សាលពិព័រណ៍វាយនភណ្ឌបុរាណ និងសាលពិព័រណ៍វាយនភណ្ឌសហសម័យ។

សារមន្ទីរបើកជូនសាធារណជនចូលទស្សនាពីថ្ងៃពុធ ដល់ថ្ងៃចន្ទ ចាប់ពីម៉ោង៨:៣០នាទីព្រឹក ដល់ម៉ោង៤:០០នាទីល្ងាច ជាពិសេសមិនគិតថ្លៃចំពោះព្រះសង្ឃ ដូនជី តាជី និងកុមារក្រោមអាយុ១២ឆ្នាំ។ សារមន្ទីរក៏មានមគ្គុទ្ទេសក៍ជំនាញនៅចាំពន្យល់ បកស្រាយជូនភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដោយឥតគិតថ្លៃផងដែរ៕

អាជ្ញាធរជាតិអប្សរាកំពុងបន្តកិច្ចការអភិរក្សនិងជួសជុលពង្រឹងរចនាសម្ពន្ធឥដ្ឋនៅប្រាសាទគោកចក

ផ្សាយនៅថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២១

ប្រាសាទគោកចកគឺជាប្រាសាទឥដ្ឋដែលមានចំនួន២ប៉ម សង់ទន្ទឹមគ្នាបែរមុខទៅទិសខាងកើត ក្នុងរាជព្រះបាទជ័យវរ្ម័នទី៣នាចន្លោះឆ្នាំ ៨៥០គ.ស ដល់ ៨៧៧គ.ស. សម្រាប់ឧទ្ទិសដល់ព្រះនារាយណ៍។

ចំណែកសិលាចារិកនៃប្រាសាទគោកចក (K.521) ក៏បានអធិប្បាយផងដែរអំពី កាលបរិច្ឆេទសាងសង់ប្រាសាទគោកចក ក្នុងឆ្នាំ ៨៥០គ.ស។

ភាពដ៏ចំណាស់ផ្នែកសម្ភារសំណង់ ឥដ្ឋនៃប្រាសាទនេះបានទទួលរងនូវការទ្រុឌទ្រោមធ្ងន់ធ្ងរពីសំណាក់រុក្ខជាតិតូចធំគ្រប់ប្រភេទដុះចាក់បំបែកប៉មទាំងពីរបណ្តាលឱ្យស្រទាប់ឥដ្ឋនីមួយៗផ្នែកខាងលើនៅតែបន្តរលុះបាក់ដោយអន្លើៗ។

ប្រាសាទគោកចកត្រូវបានយកចិត្តទុកដាក់លើផ្នែកថែទាំអភិរក្ស និងជួសជុលឡើងវិញច្រើនដំណាក់កាល ទាំងថវិកា និងអ្នកបច្ចេកទេសខ្មែរពីអាជ្ញាធរជាតិអប្សរា។ លោកស្រី ឈុន រតនា ជាមន្ត្រីបច្ចេកទេសអភិរក្សនៃនាយកដ្ឋានអភិរក្សប្រាសាទ ក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរាបានផ្តល់នូវទិន្និន័យមួយចំនួនស្តីអំពីដំណើរប្រព្រឹត្តិទៅលើផ្នែកការងារអភិរក្សនៃប្រាសាទគោកចកចាប់តាំងពីឆ្នាំ ២០១២រហូតដល់បច្ចុប្បន្ន ក្នុងនោះកិច្ចការទល់ទ្រសង្គ្រោះបន្ទាន់បានធ្វើឡើងនៅក្លោងទ្វារខាងកើតនិងជញ្ជាំងខាងលិចនៃប៉មខាងត្បូងនាឆ្នាំ២០១២កន្លងទៅ។

លោកស្រីបានបញ្ជាក់បន្ថែមថា ទោះបីជាមានការទល់ទ្រត្រង់ចំណុចមានហានិភ័យខ្ពស់មួយចំនួនក៏ដោយក៏នៅតែពុំគ្រប់គ្រាន់នៅឡើយសម្រាប់សុវត្ថិភាពប្រាសាទទាំងមូល ព្រោះថា ដុំឥដ្ឋមួយចំនួននៅតែបន្តរលុះធ្លាក់ជាប្រចាំនៅរដូវភ្លៀង ដូចនេះគម្រោងជួសជុលលើរចនាសម្ពន្ធឥដ្ឋបានអនុវត្តឡើងជាផ្នែកៗ នៅប៉មខាងត្បូងចាប់ពីខែ កញ្ញា ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ នាដំណាក់កាលទី១ ហើយរាល់បច្ចេកទេសនៃការជួសជុលប្រាសាទគោកចក គឺមន្ត្រីជំនាញទាំងអស់បានប្រើប្រាស់នូវទ្រឹស្តីនិងទស្សនផ្នែកអភិរក្សលើវិស័យបេតិកភណ្ឌ ដោយគោរពលើបទដ្ឋានអភិក្ស និងច្បាប់ទម្លាប់នានាសម្រាប់ការពារនិងថែរក្សាសំណង់បុរាណ រួមទាំងគិតទៅលើការប្រើប្រាស់សម្ភារថ្មីនិងចាស់បូកបញ្ចូលគ្នាផងដែរដោយរក្សាបានគុណតម្លៃជាប្រវត្តិផ្នែកសិល្បៈ និងប្រវត្តិសំណង់ស្ថាបត្យកម្មនៃប្រាសាទគោកចក។

ជាលទ្ធផលលើគម្រោងអភិរក្សនៃប្រាសាទគោកចកគឺបានបញ្ចប់កិច្ចការជួសជុលពង្រឹងឥដ្ឋដោយផ្នែកៗនៅប៉មទាំងពីរដូចជា ទទួលបាននូវភាពរឹងមាំឡើងវិញត្រង់រចនាសម្ពន្ធខ្លោងទ្វារខាងកើតនិងជញ្ជាំងខាងត្បូងនៃប៉មខាងត្បូង និងបន្តពង្រឹងជញ្ជាំងឥដ្ឋជ្រុងនិរតីនៃប៉មខាងជើង។ ចំណែកសម្រាប់ផែនការនាអនាគត ប្រាសាទគោកចកនឹងគ្រោងបន្តកិច្ចការអភិរក្សនិងជួសជុលបន្ថែមនាដំណាក់កាលទី២ ក្នុងឆ្នាំ២០២២នៅប៉មខាងត្បូងផ្នែកខាងលិច។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក បានពិនិត្យនិងដោះស្រាយស្ថិតក្នុងភូមិគោកស្នួល ភូមិត្រមេង ភូមិស្វាយ ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយលោក ឡុងកុសល បានពិនិត្យ និងដោះស្រាយចំនួន១០សំណើ ស្ថិតក្នុងភូមិទក្សិណត្បូង ភូមិនគរក្រៅ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងភាគីឥណ្ឌា ជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការវប្បធម៌

ផ្សាយនៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២១

កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានទទួលជួបពិភាក្សាតាមរយៈប្រព័ន្ធអ៊ិនធើណិតជាមួយ ឯកឧត្តម Dinesh Patnait អគ្គលេខាធិការនៃក្រុមប្រឹក្សាទំនាក់ទំនងវប្បធម៌ឥណ្ឌា។

កិច្ចប្រជុំនេះធ្វើឡើងដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការវប្បធម៌រវាងកម្ពុជានិងឥណ្ឌាដែលក្នុងនោះក៏មានរួមបញ្ចូលពីការធ្វើឱ្យកាន់តែប្រសើរឡើង នូវសាមន្ទីរវាយនភណ្ឌ

ប្រពៃណីអាស៊ីមេគង្គ-គង្គា (កម្ពុជា ឥណ្ឌា ភូមា ថៃ ឡាវ វៀតណាម) ជាពិសេសពិនិត្យលទ្ធភាពបន្ថែមសម្ភារៈថ្មីៗដើម្បីតាំងបង្ហាញ៕

ភ្នាក់ងារទេសចរណ៍ចូលរួមសកម្មភាពថែទាំប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២១

ប្រាង្គប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ គ្រប់គោលដៅទាំងអស់សុទ្ធតែមានភ្នាក់ទេសចរណ៍ប្រចាំការ ដើម្បីចាំសម្រួលហេតុការណ៍ផ្សេងៗរបស់ភ្ញៀវទេសចរដែលមានបញ្ហាពេលមកទស្សនានៅអង្គរ។

ទោះបីស្ថានភាពភ្ញៀវទេសចរមានភាពស្ងប់ស្ងាត់ ដោយសារជំងឺកូវីដ១៩យ៉ាងណាក៏ដោយ តែភ្នាក់ងារទេសចរណ៍ប្រចាំការតាមប្រាសាទនីមួយៗ ពុំបានឈប់សម្រាកពីការងារប្រចាំថ្ងៃនិងភ្លេចរួមចំណែកថែទាំប្រាសាទនោះឡើយ។

ជាក់ស្ដែង កាលពីថ្ងៃទី១២ខែកុម្ភៈ ឆ្នាំ២០២១ ភ្នាក់ងារទេសចរណ៍ប្រចាំការនៅប្រាសាទសួរព្រ័ត្របានចូលរួមរើសសំរាម ដកកូនរុក្ខជាតិតូចៗដែលដុះលើថ្មប្រាសាទ និងជួយសម្អាតទំនល់ឈើទល់ទ្រថ្មប្រាសាទ ដែលមានសភាពទ្រុឌទ្រោមអាចបង្កជាហានីភ័យដល់រចនាសម្ពន្ធប្រាសាទទាំងមូល។

នេះជាការចូលរួមចំណែកក្នុងកិច្ចការការពារនិងអភិរក្សមរតកដូនតាឱ្យគង់វង្ស ហើយកិច្ចការងារថែរក្សាការពារនេះមិនមែនមានសម្រាប់តែភ្នាក់ងារប្រចាំការតាមប្រាសាទទេ យើងទាំងអស់គ្នាក៏មានចំណែកនិងកាតព្វកិច្ចថែរក្សាដែរ៕

អាជ្ញាធរជាតិអប្សរាជួសជុល ថែទាំស្លាកសញ្ញាចរាចរណ៍ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២១

ក្រុមការងារជួសជុល និងថែទាំផ្លូវ នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ នៃអាជ្ញាធរជាតិអប្សរា តែងតែចុះអនុវត្តការងារថែទាំ និងជួសជុលបង្គោលស្លាកសញ្ញាតាមដងផ្លូវនានាក្នុងតំបន់រមណីយដ្ឋានអង្គរ ជាប្រចាំ ដើម្បីពង្រឹងគុណភាព និងលើកសោភ័ណភាពនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សម្រួលដល់ការធ្វើចរាចរណ៍ និងសុវត្ថិភាពដល់ប្រជាជន ភ្ញៀវទេសចរណ៍ជាតិ -អន្តរជាតិ។

ក្រៅពីកិច្ចការងារអភិរក្ស អាជ្ញាធរជាតិអប្សរា តែងតែយកចិត្តទុកដាក់ស្តារឡើងវិញ ជួសជុល ថែទាំ និងកែលម្អផ្លូវជាប្រចាំដើម្បីឱ្យមានភាពប្រសើរជានិរន្តរ៍ដែលជាសសៃឈាមដ៏សំខាន់ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ ជាបេតិកភណ្ឌពិភពលោក៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

រយៈពេលពីរសប្តាហ៍នៃខែកុម្ភៈ ឆ្នាំ២០២១នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋចំនួន ៦១គ្រួសារ រួមមាន៖ ក្រុងសៀមរាប ២០គ្រួសារ ស្រុកបន្ទាយស្រី ១៣គ្រួសារ ស្រុកអង្គរធំ ១១គ្រួសារ ស្រុកប្រាសាទបាគង ០៨គ្រួសារ ស្រុកពួក ០៧គ្រួសារ និងស្រុកសូទ្រនិគម ០២គ្រួសារ។

ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់ចំនួន ២៦គ្រួសារ រួមមាន៖ ស្រុកអង្គរធំ ០៤ គ្រួសារ ក្រុងសៀមរាប ០៤គ្រួសារ ស្រុកប្រាសាទបាគង ០៥គ្រួសារ ស្រុកពួក ០៤ គ្រួសារ និងស្រុកបន្ទាយស្រី ០៩គ្រួសារ។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតប ទៅកាន់ពលរដ្ឋវិញ ពោល គឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់សាងសង់ គឺពុំមាន ការបង់ប្រាក់ទេ៕

ប្រជាពលរដ្ឋនៅសង្កាត់ក្របីរៀលអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត និងស្វែងយល់ពីសមិទ្ធផលដែលអាជ្ញាធរជាតិអប្សរាសម្រេចបាន

ផ្សាយនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

ប្រជាជនចំនួន៣០នាក់ មកពីភូមិតារស់និងភូមិរកានៃសង្កាត់ក្របីរៀល ក្រុងសៀមរាប នាព្រឹកថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ បានអញ្ជើញមកទស្សនាប្រាសាទអង្គរវត្ត ដើម្បីស្វែងយល់ពីប្រវត្តិខ្លះៗនៃអង្គរវត្ត ពិសេសគឺស្វែងយល់ពីសមិទ្ធផលនៃការអភិវឌ្ឍ ការអភិរក្ស ដែលអាជ្ញាធរជាតិអប្សរាសម្រេចបានកន្លងមក។

តាមការបញ្ជាក់របស់លោក គា រក្សា មន្ត្រីនាយកដ្ឋានផ្សព្វផ្សាយឱ្យដឹងថា អាជ្ញាធរជាតិអប្សរាបានជួយសម្របសម្រួលប្រជាពលរដ្ឋចំនួន១២ ភូមិនៃសង្កាត់ក្របីរៀល មកទស្សនាប្រាសាទអង្គរវត្ត ដើម្បីឱ្យពួកគាត់បានឃើញ បានស្គាល់ប្រាសាទអង្គរវត្ត និងបានដឹងពីការអភិវឌ្ឍ ការរៀបចំសួនច្បារដ៏ស្រស់ស្អាត ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ

នៅមុខប្រាសាទ ការរៀបចំប្រព័ន្ធទឹកនៅក្នុងបរិវេណប្រាសាទអង្គរវត្ត និងការអភិរក្សជាច្រើនដែលអាជ្ញាធរជាតិអប្សរាសម្រេចបានក្នុងការជួសជុលថែទាំប្រាសាទមួយនេះ។

កម្មវិធីនេះមួយថ្ងៃមានប្រជាពលរដ្ឋ២ភូមិមានគ្នា៣០នាក់ចូលរួម ធ្វើឡើងក្នុងរយៈពេល៦ថ្ងៃនៃខែកុម្ភៈ ដោយមានរៀបចំទឹកនិងចំណីអាហារសម្រាប់ពួកគាត់ពេលមកទស្សនាផង៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាប បានពិនិត្យនិងដោះស្រាយស្ថិតក្នុងភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាប្រុងពលីជួសជុលខ្លោងទ្វារខាងលិចនៃប្រាសាទចៅស្រីវិបុល

ផ្សាយនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ បានរៀបចំពិធីប្រុងពលីសែនព្រេន បួងសួងសុំសេចក្ដីសុខចម្រើន ដើម្បីរុះរើខ្លោងទ្វារខាងលិចនៃប្រាសាទចៅស្រីវិបុលមុននឹងជួសជុលឱ្យដំណើរការបានរលូន សុវត្ថិភាព និងជោគជ័យក្នុងការបំពេញការងារអភិរក្សសម្បត្តិដូនតា។

តាមការបញ្ជាក់របស់ **ឯកឧត្តម តឹម សុផិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ខ្លោងទ្វារខាងលិចនេះ គឺរងនូវការខូចខាតដោយសារអាយុកាល ធម្មជាតិ និងការបំផ្លាញរបស់មនុស្សក្នុងសម័យសង្គ្រាមផង ធ្វើឱ្យរលុះរចនាសម្ពន្ធសំណង់ខូចរូបរាងខ្លោងទ្វារ។ កិច្ចការដំបូង ក្រុមការងារនឹងរុះរើសំណង់ខ្លោងទ្វារនេះសិន រួចទើបដំណើរការជួសជុលឱ្យស្របតាមបទដ្ឋានធម្មនុញ្ញអង្គរ។

ក្នុងឱកាសនោះដែរ ឯក ឧត្តមអគ្គនាយករងក៏បានណែនាំដល់ក្រុមការងារ ឆ្មាំ ពលករទាំងអស់ឱ្យខិតខំបំពេញការងារឱ្យបានល្អប្រសើរក្នុងនាមជាអ្នកជំនាញថែរក្សាអង្គរ៕

សេចក្តីជូនដំណឹងស្តីពីការហាមបើកបរទោចក្រយានយន្ត(ម៉ូតូ) លើកំពែងក្រុងអង្គរធំក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១

ក្នុងគោលបំណងថែរក្សា ការពារអភិរក្ស និងលើកតម្លៃជាសកលនៃកំពែងក្រុងអង្គរធំ ក៏ដូចជាដើម្បីចៀសវាងការប៉ះពាល់ជាយថាហេតុដល់រចនាសម្ពន្ធ សំណង់បុរាណពិសេសគឺជួយសម្រួលដល់ការងារជួសជុលកំពែងខ្លោងទ្វារតាការដែលកំពុងអនុវត្តការងារដោយអ្នកជំនាញខ្មែរ អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់សាធារណជនទាំងអស់ថា៖

១. ហាមបើកម៉ូតូឡើងលើកំពែងក្រុងអង្គរធំ លើកលែងតែក្នុងករណីមានការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា។

២. អនុញ្ញាតការធ្វើដំណើរលើកំពែងក្រុងអង្គរធំសម្រាប់តែអ្នកថ្មើរជើងនិងធ្វើដំណើរដោយកង់តែប៉ុណ្ណោះ។

កិច្ចការនេះចាប់អនុវត្តពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នេះតទៅ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ៖ ១៣០/២១ រប.សជ៧

សេចក្តីជូនដំណឹង
ស្តីពី
ការហាមបើកបរទោចក្រយានយន្ត(ម៉ូតូ)លើកំពែងក្រុងអង្គរធំក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា ក្នុងទិសដៅថែរក្សា ការពារអភិរក្ស និងលើកតម្លៃជាសកលនៃកំពែងក្រុងអង្គរធំ ក៏ដូចជាដើម្បីចៀសវាងការប៉ះពាល់ជាយថាហេតុដល់រចនាសម្ព័ន្ធបុរាណ និងជួយសម្រួលដល់ការងារជួសជុលខ្លោងទ្វារតាការ ដែលបាននឹងកំពុងអនុវត្តដោយអ្នកជំនាញ អាជ្ញាធរជាតិអប្សរាសូមធ្វើការណែនាំដូចខាងក្រោម៖

១-ហាមបើកបរម៉ូតូ ឡើងលើកំពែងក្រុងអង្គរធំ លើកលែងតែក្នុងករណីមានការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរា
២-អនុញ្ញាតការធ្វើដំណើរលើកំពែងក្រុងអង្គរធំ សម្រាប់អ្នកថ្មើរជើង និងការធ្វើដំណើរដោយកង់តែប៉ុណ្ណោះ

សេចក្តីណែនាំនេះ នឹងចាប់ផ្តើមអនុវត្តគិតចាប់ពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តដោយសេចក្តីអនុគ្រោះ៕

ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០២១
អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា
ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
អាជ្ញាធរដើម្បីការពារអភិរក្សរមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576
APSARA National Authority
Address: Bang Kong Village, Ampil Commune
Prasat Bakong District, Siem Reap Province

សាលាបារាំងខេត្តសៀមរាបបណ្តុះគំនិតកុមារស្វែងយល់ពីសមុច្ច័យ នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១

ការអប់រំដល់កុមារជាគោលបំណងមួយក្នុងចំណោមគោលបំណងសំខាន់ៗរបស់សារមន្ទីរ។ ជាក់ស្តែងកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១ លោកគ្រូ-អ្នកគ្រូនៃសាលាភាសាបារាំងប្រចាំខេត្តសៀមរាប (École Française de Siem Reap) បានដឹកនាំសិស្សានុសិស្សចំនួន១៩នាក់មកធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។

គោលបំណងនៃទស្សនកិច្ចសិក្សានេះគឺដើម្បីឱ្យកុមារស្វែងយល់អំពីអតីតកាលនៃមនុស្សជំនាន់មុនក៏ដូចជាសមុច្ច័យដែលលកំណាយបានពីស្ថានីយកប់សពកោះតាមាសនិងស្ថានីយព្រៃក្មេង។ ក្រៅអំពីការទស្សនាស្ថានីយខាងលើ កុមារបានទទួលចំណេះដឹងថ្មីៗនិងល្អៗ ក្នុងការប្រើប្រាស់ពាក្យបច្ចេកទេសក្នុងវិស័យបុរាណវិទ្យាជាភាសាបារាំង ព្រមទាំងការអនុវត្តនូវការគូររូបគំនូរជាដើម៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិថ្នល់បាក់ ភូមិត្រពាំងរុន ឃុំអំពិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិត្លង់ ភូមិតាប្រុក ភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩ សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានពិនិត្យ និងដោះស្រាយនៅភូមិកកោះជ្រុំ ភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សរុបមក នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

មន្ត្រី-បុគ្គលិកអាជ្ញាធរជាតិអប្សរាចំនួន៧៥រូប ទទួលការបណ្តុះបណ្តាល លើការរៀបចំរបាយការណ៍តាមទម្រង់ថ្មី

ផ្សាយនៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២១

នៅរសៀលថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាស្តីពី ការរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ តាមទម្រង់របាយការណ៍ថ្មីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ សិក្ខាសាលាដែលរៀបចំនៅសាលសន្និសីទអង្គរ មានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី

រួមនិងបុគ្គលិកមកពីតាមនាយកដ្ឋានជំនាញសរុបចំនួន៧៥រូប ក្រោមបទបង្ហាញពីវាគ្មិនចំនួន២រូប រួមមានលោក អឿន មករា ជាប្រធាន និងលោក ឡុង សំណាង អនុប្រធាននៃនាយកដ្ឋានផែនការ ស្ថិតិ និងសរុប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ជាកិច្ចចាប់ផ្តើមនៃសិក្ខាសាលា កញ្ញា ហ៊ិរ រិទ្ធារី ប្រធានស្តីទីមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ បានរៀបរាប់ពីគោលបំណងសំខាន់នៃសិក្ខាសាលានេះ គឺធ្វើឡើងក្នុងបំណងដើម្បីពង្រឹងចំណេះដឹងបន្ថែមលើការងាររៀបចំរបាយការណ៍ ពិសេសការរៀបចំនិងសរសេររបាយការណ៍ឱ្យស្របតាមកំណែទម្រង់ថ្មីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

លោក ភ័ន ផល្លា ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ បានលើកឡើងថា សិក្ខាសាលានេះមានសារសំខាន់ណាស់សម្រាប់មន្ត្រី-បុគ្គលិកដែលកំពុងកាន់ការងារលើការរៀបចំរបាយការណ៍ ពិសេសគឺការរៀបចំឱ្យស្របតាមទម្រង់ថ្មីរបស់ក្រសួងសាមី។

លោកប្រធាននាយកដ្ឋានលើកទឹកចិត្តឱ្យសិក្ខាកាមទាំងអស់ត្រូវចេះលើកជាសំណួរ និងឆ្លល់រាល់ចំណុចដែលខ្លួនមានចម្ងល់ទៅកាន់វាគ្មិន ដើម្បីឱ្យប្រាកដលើការងារដែលខ្លួនឯងធ្វើ ដែលអាចអនុវត្តន៍កិច្ចការងារទាំងនោះបានដោយរលូន និងឆាប់រហ័ស៕

អាជ្ញាធរជាតិអប្សរានឹងបើកឱ្យភ្ញៀវទេសចរចូលទស្សនាប្រាសាទកណ្ដាលស្រះស្រង់នាសប្ដាហ៍ក្រោយ

ផ្សាយនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១

ដើម្បីអបអរសាទរការបញ្ចប់គម្រោងជួសជុលប្រាសាទកណ្ដាលស្រះស្រង់ជាស្ថាពរ ក្រោមកិច្ចសហការរបស់អាជ្ញាធរជាតិអប្សរាជាមួយវិស័យឯកជន អាជ្ញាធរជាតិអប្សរានឹងរៀបចំប្រារព្ធពិធីសម្ពោធដាក់ភ្ញៀវទេសចរជាតិ-អន្តរជាតិនិងសាធារណជនចូលទស្សនាប្រាសាទកណ្ដាលស្រះស្រង់ជាផ្លូវការ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**។

ក្រោយបញ្ចប់កិច្ចពិធីសាសនា ភ្ញៀវទេសចរជាតិ-អន្តរជាតិ និងសាធារណជនទាំងអស់ អាចអញ្ជើញទៅទស្សនាទិដ្ឋភាពប្រាសាទកណ្ដាលស្រះស្រង់ដើម្បីផ្ដិតយករូបភាព ស្វែងយល់ពីប្រវត្តិ និងសិល្បៈនៃប្រាសាទនេះដោយរីករាយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃពុធ ទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិអំពិលពាម ភូមិគោកត្រាច ភូមិព្រៃឆ្លូក ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៣សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕



អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅក្នុងបរិវេណ វត្តព្រះឥន្ទទេព វត្តគោកធ្លក ប្រាសាទសួព្រ័ត្រ និងប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១

ក្រុមការងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា កំពុងអនុវត្តន៍ការងារចុះកាត់ក្រី និងដកហូតដើមឈើហានិភ័យមួយចំនួនក្នុងបរិវេណវត្តព្រះឥន្ទទេព វត្តគោកធ្លក ប្រាសាទសួព្រ័ត្រ និងប្រាសាទបាយ័ន ក្រោយពិនិត្យឃើញថា ដើមឈើទាំងនោះអាចបង្កហានិភ័យទៅលើមនុស្សនិងសំណង់ប្រាសាទ។ ដើមឈើទាំងនោះ មានសភាពពុកគល់ខ្លាំង មែកងាប់ ទ្រេតជាប់ផ្លូវចូលប្រាសាទ ក្បែរកុដិព្រះសង្ឃ និងខ្លះដុះជាប់ការដ្ឋានជួសជុលជាដើម។



ដូច្នេះ ដើម្បីបង្ការ និងបញ្ចៀសគ្រោះថ្នាក់ទុកជាមុន កុំឲ្យប៉ះពាល់ដល់អាយុជីវិតរបស់ភ្ញៀវទេសចរ ព្រះសង្ឃគង់នៅទីនោះព្រមទាំងប្រជាពលរដ្ឋនិងយានយន្តគ្រប់ប្រភេទដែលឆ្លងកាត់ ក្រុមជំនាញនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ដោយសហការជាមួយផ្នែកពាក់ព័ន្ធ កំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ ដោយកាត់ក្រីមែកឈើចំនួន១៦ដើមដែលមាន៤៦មែករួមមាន ដើមយាង ដើមបង្គៃរជំរី ដើមស្លែង និងដើមម្នាក់ព្រៃ។ ចំណែកឯដើមឈើងាប់ដែលដកហូតចំនួន៥ដើមរួមមាន ដើមដូង ដើមស្លែង ដើមបង្គី និងដើមអង្គាញ់៕

មន្ត្រីបុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរាចូលរួមចែករំលែកបទពិសោធន៍ ផ្នែករៀបចំខ្សែសៀគ្វីទេសចរណ៍នៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកសំបូរព្រៃគុក

ផ្សាយនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១

ក្នុងគោលដៅរៀបចំនិងដាក់ចេញនូវខ្សែសៀគ្វីទស្សនារមណីយដ្ឋានសំបូរព្រៃគុក អាជ្ញាធរជាតិសំបូរព្រៃគុកបានរៀបចំកម្មវិធីកិច្ចពិភាក្សាផ្លាស់ប្ដូរបទពិសោធន៍ស្ដីពីការរៀបចំខ្សែសៀគ្វីទេសចរណ៍រយៈពេល៣ថ្ងៃ និងបានអញ្ជើញមន្ត្រីបុគ្គលិកជំនាញផ្នែករៀបចំខ្សែសៀគ្វីទេសចរណ៍នៃអាជ្ញាធរជាតិអប្សរាចូលរួមដើម្បីចែករំលែកបទពិសោធន៍ការងាររៀបចំខ្សែសៀគ្វីទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរកន្លងមក។

ជាលទ្ធផលនៃកិច្ចពិភាក្សារវាងមន្ត្រីបុគ្គលិកជំនាញទាំងពីរស្ថាប័នដែលបំពេញការងារក្នុងចក្ខុវិស័យរួមគឺ ការអភិរក្សនិងអភិវឌ្ឍន៍រមណីយដ្ឋានបេតិកភណ្ឌពិភពលោក គំនិតរៀបចំខ្សែសៀគ្វីទស្សនាក្រុមប្រាសាទក្នុងរមណីយដ្ឋានសំបូរព្រៃគុកចំនួន៦ត្រូវបានដាក់ចេញដើម្បីបន្តការសិក្សាស៊ីជម្រៅដែលក្នុងនោះមាន៖

១. សិក្សារៀបចំទិសដៅទស្សនាដោយកំណត់ច្រកចេញចូលច្បាស់លាស់សម្រាប់ក្រុមប្រាសាទធំៗចំនួន៣គឺ ក្រុមប្រាសាទយាយព័ន្ធ ក្រុមប្រាសាទតោ និងក្រុមប្រាសាទសំបូរ។

២. សិក្សាដាក់ចេញនូវខ្សែទស្សនាដែលភ្ជាប់ក្រុមប្រាសាទធំៗទាំងបីគឺ ក្រុមប្រាសាទយាយព័ន្ធ ក្រុមប្រាសាទតោ និងក្រុមប្រាសាទសំបូរ ជាមួយនឹងប្រាសាទដើមចាន់ ប្រាសាទអាស្រមមហាឫស្សី និងប្រាសាទជ្រៃ ដោយមានជម្រើសរយៈពេលទស្សនាផ្សេងៗគ្នា (សៀគ្វីរយៈពេលវែង មធ្យម និងខ្លី)។

៣. សិក្សាដាក់ចេញនូវខ្សែសៀគ្វីកង់ និងរទេះគោ ដែលអាចមានជម្រើសខ្សែវែង និងខ្សែខ្លី ក្រោមចំណងជើង «ទស្សនារមណីយដ្ឋានសំបូរព្រៃគុកដោយជិះកង់ ឬរទេះគោ»។

៤. សិក្សាដាក់ចេញនូវខ្សែសៀគ្វីរយៈពេល១ថ្ងៃពេញដើម្បីលើកតម្លៃប្រាសាទតូចៗមួយចំនួន រួមទាំងក្រុងបុរាណ «ឦសានបុរ» ដោយភ្ជាប់ជាមួយក្រុមប្រាសាទធំៗទាំង៣។

៥. សិក្សាស៊ីជម្រៅបន្ថែមដើម្បីដាក់ចេញនូវខ្សែទស្សនាក្រោមប្រធានបទពិសេស « ស្វែងយល់ពីចម្លាក់លើប្រាសាទឥដ្ឋ» ដែលភ្ញៀវទេសចរអាចទទួលបានព័ត៌មានលម្អិតពីចម្លាក់ «ប្រាសាទអណ្ដែត» និងចម្លាក់« មេដៃយ៉ុង» ព្រមទាំង «រចនាសម្ពន្ធប្រាសាទឥដ្ឋរាង៨ជ្រុង» ដែលទាំងនេះជាតម្លៃលេចធ្លោជាសកល (outstanding universal value) របស់រមណីយដ្ឋានសំបូរព្រៃគុកបេតិកភណ្ឌពិភពលោក។

៦. សិក្សារៀបចំខ្សែសៀគ្វីសម្រាប់ទេសចរបែបសមាធិ ដោយក្នុងនោះអាចកំណត់យកប្រាសាទត្រពាំងរពាក់ ឬប្រាសាទគក់ទ្រូងជាទីតាំងបញ្ចប់ខ្សែទស្សនានិងស្នើឱ្យទេសចរអាចធ្វើសមាធិក្នុងឥរិយាបទនិងកាយវិការស្ងប់ស្ងាត់នៅទីនោះបាន។

គំនិតជំហានដំបូងទាំង៦ខាងលើនេះនឹងត្រូវសិក្សាស៊ីជម្រៅលម្អិតបន្ថែមរួមគ្នាបន្តទៀតរវាងមន្ត្រីបុគ្គលិកជំនាញនៃអាជ្ញាធរជាតិអប្សរា និងអាជ្ញាធរជាតិសំបូរព្រៃគុក។

អាជ្ញាធរជាតិអប្សរានឹងបិទខ្លោងទ្វារតាកាវបណ្តោះអាសន្ន ដើម្បីប្រារព្ធពិធីបើកការដ្ឋានជួសជុល

ផ្សាយនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរាសូមជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរានឹងបិទការចេញចូលនៅខ្លោងទ្វារតាកាវបណ្តោះអាសន្ន ដើម្បីប្រារព្ធពិធីបើកការដ្ឋានជួសជុលខ្លោងទ្វារនេះ ក្រោមកិច្ចសហការជាមួយវិស័យឯកជន។

កម្មវិធីនេះប្រារព្ធឡើងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវ កិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**។

អាជ្ញាធរជាតិអប្សរា សង្ឃឹមថាសាធារណជនទាំងអស់នឹងយោគយល់ ហើយចូលរួមសហការបានយ៉ាងល្អប្រសើរ ដើម្បីភាពរលូននៃដំណើរការអភិរក្សសម្បត្តិដូនតាទាំងអស់គ្នា៕

ប្រជាពលរដ្ឋទាំង១២ភូមិនៃសង្កាត់ក្របីរៀលបានមកទស្សនារមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២១

តាមរយៈការសម្របសម្រួល របស់អាជ្ញាធរជាតិអប្សរា ប្រជាពលរដ្ឋទាំង១២ ភូមិនៃសង្កាត់ក្របីរៀលសរុបចំនួន ១៨០នាក់ បានមកទស្សនារមណីយដ្ឋានអង្គរ។

ការអញ្ជើញមកទស្សនារបស់ប្រជាពលរដ្ឋនៃសង្កាត់ក្របីរៀលនេះ បានធ្វើឱ្យពួកគាត់បានស្វែងយល់ពីការរៀបចំ និងរីកចម្រើននៅរមណីយដ្ឋានអង្គរ ជាពិសេសស្ថានភាពប្រទេសដែលមានសុខសន្តិភាពពេញលេញក្នុងផ្ទៃប្រទេស និងមានការអភិវឌ្ឍគ្រប់ទីកន្លែងក្រោមការដឹកនាំដ៏ឈ្លាតវៃនិងកិត្តិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រជាពលរដ្ឋដែលបានមកទស្សនាប្រាសាទអង្គរវត្ត បានសម្តែងនូវទឹកចិត្តសប្បាយរីករាយចំពោះការអភិវឌ្ឍ ការរៀបចំប្រព័ន្ធទឹកនៅក្នុងបរិវេណប្រាសាទអង្គរវត្ត ការរៀបចំបរិវេណបៃតងដ៏ស្រស់ស្អាត ការរៀបចំហេដ្ឋារចនាសម្ព័ន្ធនៅមុខប្រាសាទអង្គរវត្ត ការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយ និងការលើកតម្លៃរមណីយដ្ឋានអង្គរឲ្យកាន់តែប្រសើរ។ កម្មវិធីនេះមានរយៈពេល៦ថ្ងៃ ចាប់ពីថ្ងៃទី១៤ដល់ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ មួយថ្ងៃមានប្រជាពលរដ្ឋ២ភូមិមានគ្នា៣០នាក់ចូលរួម ដោយមានរៀបចំទឹកនិងចំណីអាហារសម្រាប់ពួកគាត់ពេលមកទស្សនាផង៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចុះពិនិត្យផែនការសកម្មភាពអនាគតរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០២១

នៅរសៀលថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា

បានអញ្ជើញចុះពិនិត្យតាមទីតាំងមួយចំនួនដែលស្ថិតក្នុងផែនការសកម្មភាពអនាគតដើម្បីថែរក្សាអភិរក្ស អភិវឌ្ឍន៍ ប្រកបដោយចីរភាពក្នុងការលើកតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានអង្គរ៕

វិស័យឯកជនចាប់ដៃគ្នាសហការជាមួយអាជ្ញាធរជាតិអប្សរាជួសជុលខ្លោងទ្វារតាកាវ

ផ្សាយនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១

ដើម្បីជាការរួមចំណែកអភិរក្សនិងលើកតម្លៃខ្លោងទ្វារតាកាវនេះឡើងវិញ នៅរសៀលថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរាបានសហការជាមួយវិស័យឯកជនប្រារព្ធពិធីប្រុងពលីដើម្បីដំណើរការជួសជុលខ្លោងទ្វារតាកាវក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** អមដោយ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការីរួមនឹងឯកឧត្តម លោកជំទាវ ប្រជាពលរដ្ឋជាង២០០នាក់ចូលរួមជាកិត្តិយស ។

ការជួសជុលខ្លោងទ្វារតាកាវទទួលបានការឧបត្ថម្ភថវិកាទាំងស្រុងពី **លោកជំទាវឧកញ៉ា នាងខសាខា អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ កិត្តបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍។

ក្នុងឱកាសនោះ **លោកជំទាវឧកញ៉ា សៀង ចាន់ហេង** ក៏បានសម្តែងសេចក្តីរីករាយនិងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ព្រមទាំងអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យលោកជំទាវចូលរួមជួសជុលជាថ្មីនៃសំណង់បុរាណក្នុងតំបន់អង្គរ ឱ្យរួចផុតពីការបាក់បែកដោយគ្រោះធម្មជាតិនិងភាពចាស់ទ្រុឌទ្រោមនៃអាយុកាល និងដើម្បីឧទ្ទិសដល់ដួងព្រះវិញ្ញាណក្ខន្ធព្រះមហាវីរក្សត្រនិងមហាបុព្វបុរសខ្មែរ។

បច្ចុប្បន្នខ្លោងទ្វារតាកាវបានរងនូវការទ្រុឌទ្រោមខ្លាំងមិនអាចអនុញ្ញាតឱ្យរថយន្តធ្វើដំណើរឆ្លងកាត់បានឡើយ។ ការទ្រុឌទ្រោមនេះដោយសារអាយុកាល អាកាសធាតុ សង្គ្រាម កង្វះការថែទាំ និងការដុះដាលនៃដើមឈើ បណ្តាលឱ្យរូបចម្លាក់បង្កាន់ដៃយក្សនិងទេវតាជាច្រើនដួលរលំ ហើយក៏បានធ្វើឱ្យរចនាសម្ពន្ធរបស់ខ្លោងទ្វារមួយភាគធំ ពិសេសរូបដំរីទាំង៤បានរងនូវការខូចខាតជាខ្លាំង ដែលតម្រូវឱ្យមានការជួសជុលដើម្បីសង្គ្រោះនិងអភិរក្ស៕

ប្រាសាទស្រះស្រង់សម្ពោធបញ្ចប់ការជួសជុលនៅព្រឹកនេះ

ផ្សាយនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១

ប្រាសាទស្រះស្រង់ត្រូវបានសម្ពោធបញ្ចប់ការជួសជុលក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិ**

ព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន អមដោយ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការី រួមនឹងសម្តេចព្រះសង្ឃរាជ ព្រះសង្ឃ ឯកឧត្តម លោកជំទាវជាច្រើនចូលរួមជាកិត្តិយសនាព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១។

អាជ្ញាធរជាតិអប្សរាសូមសម្តែងសេចក្តីអរគុណយ៉ាងជ្រាវជ្រៅចំពោះវិស័យឯកជន ជាពិសេស **លោកជំទាវឧកញ៉ា នាងខសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀវ ចាន់ហោច** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ដែលបានចំណាយថវិកាផ្ទាល់ខ្លួនឧបត្ថម្ភការជួសជុលនេះ។

ម្យ៉ាងវិញទៀត តាមរយៈនៃការជួសជុលនិងរំលេចរូបរាងជាថ្មីឡើងវិញប្រាសាទស្រះស្រង់បានធ្វើទេសភាពវប្បធម៌នាពេលអតីតកាលបានរស់រានមានជីវិតជាថ្មីឡើងវិញ និងអាចទាក់ទាញភ្ញៀវទេសចរជាតិ - អន្តរជាតិឱ្យចូលមកទស្សនាប្រាសាទនេះ៕

អាជ្ញាធរជាតិអប្សរាដាក់ឱ្យដំណើរការរហាត់ទឹក នៅស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ នេះ អាជ្ញាធរជាតិអប្សរាបានរៀបចំពិធីសម្ពោធ និងដាក់ឱ្យដំណើរការនូវរហាត់ទឹក ស្ថិតនៅស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** អមដោយ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការីរួមនឹងសម្តេចព្រះសង្ឃរាជ ព្រះសង្ឃ ឯកឧត្តម លោកជំទាវជាច្រើនចូលរួមជាកិត្តិយស។

រហាត់ទឹកនេះដែរ ក៏ជាសមិទ្ធផលមួយក្នុងចំណោមសមិទ្ធផលជាច្រើនរបស់ **លោកឧកញ៉ា នាងទិសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ នៅក្នុងតំបន់អង្គរ ដើម្បីរួមចំណែកថែរក្សា លើកតម្លៃមរតកវប្បធម៌ជាតិ។

គួររំឭកថា រហាត់ទឹកស្ថានីយបណ្តុះកូនឈើប្រាសាទតាកែវ មានប្រវត្តិតាំងពីទសវត្សឆ្នាំ៦០ មកម្លេះតែដោយសារអាយុកាលធ្វើឱ្យរហាត់ទឹកនេះ បាត់បង់តួនាទីរបស់ខ្លួន។ នៅដើមឆ្នាំ២០២០ ដោយសារការឧបត្ថម្ភពីវិស័យឯកជន រហាត់ទឹកត្រូវបានជួសជុលឡើងវិញ។ រហាត់ទឹកនេះមានបណ្តោយ១៨ម៉ែត្រ កម្ពស់១២ម៉ែត្រ អង្កត់ផ្ចិត១១,៦ម៉ែត្រ ត្រូវបានជួសជុលដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា ដោយបានរក្សានូវរចនាបថបុរាណទាំងស្រុង និងរួមបញ្ចូលនូវស្ថាបត្យកម្មទំនើប ដើម្បីធានាបាននូវភាពលក្ខណៈដើម និងភាពរឹងមាំធានាបានការប្រើប្រាស់យូរអង្វែង។

និស្សិតនិងសិស្សានុសិស្សចំនួន៤៣នាក់ មកទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

យុវជនជាសសរទ្រូងរបស់ប្រទេសជាតិ ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវនិងអភិរក្សបេតិកភណ្ឌជាតិ។ ដោយមូលហេតុនេះ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១និស្សិតជំនាញស្ថាបត្យកម្មនៃសាកលវិទ្យាល័យបៀលប្រាយខេត្តសៀមរាបចំនួន២២នាក់ និងសិស្សានុសិស្សនៃវិទ្យាល័យឈើតុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ចំនួន២១នាក់ ត្រូវបានលើកទឹកចិត្តឱ្យមកធ្វើទស្សនកិច្ចសិក្សានៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។

ទស្សនកិច្ចសិក្សានេះ គឺដើម្បីស្វែងយល់អំពីតួនាទីរបស់សារមន្ទីរ ប្រវត្តិសាស្ត្រ អរិយធម៌ វត្ថុសិល្បៈ រូបចម្លាក់ និងវត្ថុបុរាណរបស់ជាតិនានាក្រោយការធ្វើកំណាយបាននៅក្នុងតំបន់អង្គរ ព្រមទាំងរបៀបនៃការកប់សពនៅសម័យបុរេប្រវត្តិសាស្ត្រនៅស្ថានីយកោះតាមាស និងព្រៃក្មេង។

តាមរយៈទស្សនកិច្ចសិក្សា ពីសារមន្ទីរសង្ឃឹមថា និស្សិតនិងសិស្សានុសិស្សទាំងអស់បានទទួលនូវចំណេះដឹងជាច្រើនទាក់ទងនឹងសារមន្ទីរដូចជា៖ ការរៀបចំពិព័រណ៌ ការថែរក្សាវត្ថុបុរាណ ប្រវត្តិសាស្ត្រ សាសនា រួមជាមួយចំណេះដឹងទាក់ទងនឹងការរីកចម្រើននៃសិល្បៈខ្មែរក្នុងអំឡុងស.វ.ទី៧ ដល់ស.វទី១៣ នៃគ.ស.។ ទន្ទឹមនឹងនោះ ពួកគេបានយល់ដឹងកាន់តែច្បាស់ពីក្បាច់រចនាយ៉ាងសម្បូរបែបនៃបដិមាដែលកំណាយបានពីប្រាសាទបន្ទាយក្តីរួមមានបីរចនាបថ ដូចជា រចនាបថបាគួន រចនាបថអង្គរវត្ត និងរចនាបថបាយ័ន្ត ដែលបានបញ្ជាក់ពីភាពរុងរឿងនៃសិល្បៈខ្មែរនាសម័យអង្គរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

និស្សិតសាកលវិទ្យាល័យបៀលប្រាយ ខេត្តសៀមរាបទស្សនកិច្ចសិក្សា នៅ សារមន្ទីរវាយនភណ្ឌប្រពៃណីអាស៊ី

ផ្សាយនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

កាលពីរសៀលថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមនិស្សិតនៃសកលវិទ្យាល័យបៀលប្រាយខេត្តសៀមរាបចំនួន១៥នាក់បានមកទស្សនកិច្ចសិក្សានៅសារមន្ទីរវាយកណ្ឌប្រពៃណីអាស៊ីដើម្បីសិក្សាស្វែងយល់អំពី រឿងរ៉ាវពីបុរាណរបស់ទន្លេគង្គានិងសារៈសំខាន់របស់ទន្លេមេគង្គ ក្នុងវិស័យវប្បធម៌និងសង្គម រួមជាមួយនឹងភស្តុតាង បច្ចុប្បន្ននៃទន្លេគង្គាដ៏ពិសិដ្ឋគឺនៅភាគខាងលិចទន្លេមេគង្គ។

មិនតែប៉ុណ្ណោះ ក៏ឱ្យនិស្សិតបានយល់ពីសារៈសំខាន់របស់ទន្លេដ៏អស្ចារ្យទាំងពីរក្នុងទំនាក់ទំនងរវាងគ្នាទៅវិញទៅមក និងឱ្យពួកគេស្វែងយល់ឱ្យកាន់តែច្បាស់ នូវវត្ថុធាតុដើម ដំណើរការផលិត វិធីសាស្ត្រនៃការត្បាញ រចនាបថនៃការតុបតែងលម្អវាយនភណ្ឌបែបសម័យថ្មី និងលក្ខណៈពិសេសនៃវាយនភណ្ឌបែបប្រពៃណី ភាពខុសប្លែកគ្នា និងភាពស្រដៀងគ្នាទៅតាមជាតិសាសន៍និងតំបន់ ដែលផ្តល់ឱ្យនូវប្រភេទវាយនភណ្ឌផ្សេងៗគ្នាជាច្រើន ទៅតាមតំបន់នៃបណ្តាប្រទេសនៅតំបន់ទន្លេមេគង្គ-គង្គា៕

អាជ្ញាធរជាតិអប្សរាចាប់ផ្តើមអនុវត្តគម្រោងជួសជុលនិងលើកតម្លៃប្រាសាទបាយក្អែក

ផ្សាយនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២១

«គម្រោងរៀបចំទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត» ជាគម្រោងដ៏សំខាន់មួយដើម្បីរៀបចំបរិស្ថានប្រាសាទ បង្កើតសោភ័ណភាពប្រាសាទ ទេសភាពវប្បធម៌ សណ្តាប់ធ្នាប់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានអង្គរឱ្យមានភាពល្អប្រសើរ។

នៅក្នុងតំបន់មុខបរិវេណនៃប្រាសាទអង្គរវត្តនេះ ក៏មានគ្រឹះប្រាសាទបាយក្អែក ទួលបុរាណ ថ្នល់បុរាណ និងស្រះទឹកបុរាណជាច្រើន ដែលជាគោលដៅចម្បងរបស់អាជ្ញាធរជាតិអប្សរាក្នុងការសិក្សាស្រាវជ្រាវបុរាណវិទ្យា ដើម្បីលើកតម្លៃបុរាណដ្ឋាន ហើយស្វែងយល់ឱ្យច្បាស់អំពីសំណល់បុរាណ និងវិសាលភាពមត៌កវប្បធម៌បុរាណ។

ជាក់ស្តែងនៅខែកុម្ភៈ ឆ្នាំ២០២១ អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមដំណើរការជួសជុលពង្រឹងគ្រឹះប្រាសាទបាយក្អែក ដែលរងការខូចខាតដោយសារអាយុកាល កង្វះការថែទាំ សល់តែគ្រឹះ គ្មានរូបរាងច្បាស់លាស់ និងផ្ទាំងថ្មរាយប៉ាយ ឱ្យមានរូបរាងល្អប្រសើរឡើងវិញ តាមសំណល់សំណង់បុរាណដែលនៅសេសសល់ ដើម្បីទុកជាស្នាដៃសម្រាប់ការគោរពបូជានិងកិច្ចការស្រាវជ្រាវដល់កូនខ្មែរជំនាន់ក្រោយ ក៏ដូចជាសម្រាប់បម្រើវិស័យទេសចរណ៍ផង។

លោក ស្រ៊ុន តិច បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទបាយក្អែកនិងជាប្រធានគម្រោងជួសជុលបានឱ្យដឹងថា យើងប្រើពលករជំនាញ៦នាក់និងរយៈពេល៥ឬ៦ខែអាចនឹងជួសជុលប្រាសាទនេះរួចរាល់ ព្រោះបានធ្វើកំណាយស្រាវជ្រាវរួចហើយកាលពីឆ្នាំ២០២០។

តាមលទ្ធផលស្រាវជ្រាវ គឺឃើញប្រាសាទមានទំហំ៣ម៉ែត្របួនជ្រុង ឃើញកម្រាលឥដ្ឋ ដែលមានវន្ធសរសេរបញ្ឈរទំហំអង្កត់ផ្ចិត២០សង់ទីម៉ែត្រក្បឿងនិងនាងប្រាលមួយចំនួន។ ដូច្នេះតាមការសន្និដ្ឋានបឋម គឺប្រាសាទនេះមានរោងទោងឈើ បែរមុខទៅទិសខាងជើងដែលខុសពីប្រាសាទដទៃសំដៅទៅរកអ័ក្សផ្លូវចូលទៅប្រាសាទអង្គរវត្ត។ ចំពោះរូបរាងប្រាសាទទាំងមូល យើងមិនអាចរៀបចំបានពេញលេញទេ ព្រោះគ្មានជញ្ជាំង បានត្រឹមរៀបចំខឿន ស៊ុមទ្វារ ហោរជាងពីលើ ហើយនឹងយកជើងទម្រលិង្គដាក់ក្នុងប្រាសាទឡើងវិញ។

លោក ស្រ៊ុន តិច បន្តថា យោងតាមតាមការតម្កល់ជើងទម្រលិង្គ គឺប្រាសាទនេះឧទ្ទិសដល់ព្រហ្មញ្ញសាសនា ប៉ុន្តែមិនអាចកំណត់ថាប្រាសាទនេះកសាងឡើងក្នុងសតវត្សរ៍ណា មានអាយុកាលប៉ុន្មាន រចនាបថអ្វីឡើយ ដោយសារពុំមានក្បាច់ចម្លាក់អ្វីទាំងអស់អាចកត់សម្គាល់បាន សូម្បីសរសរពេជ្រក៏គ្មានក្បាច់ចម្លាក់សម្គាល់ដែរ។

អាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់លើកតម្លៃដល់បុរាណដ្ឋានជាច្រើននៅក្នុងរមណីយដ្ឋានអង្គរ មិនមែនតែប្រាសាទគ្រឹះប្រាសាទបាយក្អែកប៉ុណ្ណោះទេ គឺមានបុរាណដ្ឋានដទៃទៀតដូចជា ត្រពាំងសេស ទួលបុរាណ និងផ្លូវបុរាណចេញពីអ័ក្សភ្នំបាខែងក៏ត្រូវបានជួសជុលនិងលើកតម្លៃដែរ ព្រោះវាជាចំណុចសំខាន់ក្នុងការទាក់ទាញទេសចរ ក៏ដូចជាកេរមត៌កដូនតាខ្មែរនិងជាបេតិកភណ្ឌពិភពលោកឱ្យនៅគង់វង្សយូរអង្វែង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានកំណាយស្រាវជ្រាវនៅមុខព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

នារសៀលថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានចុះទៅពិនិត្យការដ្ឋានកំណាយស្រាវជ្រាវបុរាណវិទ្យានៅមុខព្រះលានជល់ដំរី មុននឹងដំណើរការរៀបចំហេដ្ឋារចនាសម្ពន្ធផ្លូវថ្មើជើង សួនស្មៅ ដាំដើមឈើ និងប្រព័ន្ធបង្ហូរទឹក។

ក្នុងឱកាសនោះ **លោកជំទាវឧកញ៉ា នាងឧសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀវ ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ ក៏បានអញ្ជើញទៅទស្សនានិងស្វែងយល់ពីកំណាយស្រាវជ្រាវនេះពីអ្នកជំនាញអាជ្ញាធរជាតិអប្សរាផង ព្រមទាំងកោតសរសើរចំពោះកិច្ចការរបស់ក្រុមអ្នកជំនាញនិងការដឹកនាំរបស់ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាដែលខិតខំបំពេញការងារអភិរក្ស អភិវឌ្ឍន៍បានយ៉ាងល្អប្រសើរ។ ពិសេស លោកជំទាវក៏សម្តែងសេចក្តីរីករាយដែលរាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអាជ្ញាធរជាតិអប្សរា ផ្តល់ឱកាសឱ្យលោកជំទាវបានចូលរួមចំណែកថែរក្សាសម្បត្តិដូនតាលើទឹកដីអង្គរបានយ៉ាងច្រើន។

ឯកឧត្តម ហង់ ពៅ ក៏បានកោតសរសើរនិងថ្លែងអំណរគុណចំពោះលោកជំទាវដែលបានចំណាយធនធានចូលរួមក្នុងកិច្ចការអភិរក្សនៅក្នុងតំបន់រមណីយដ្ឋានអង្គរនិងលើកតម្លៃបេតិកភណ្ឌពិភពលោក ដែលជាដួងព្រលឹងតំណាងជាតិខ្មែរ។

ក្នុងនោះដែរ ឯកឧត្តមអគ្គនាយក ក៏ស្តាប់បទបង្ហាញពីអ្នកជំនាញចំពោះលទ្ធផលកំណាយនៅក្នុងការដ្ឋាននេះ ហើយលើកទឹកចិត្តចំពោះកិច្ចការស្រាវជ្រាវដើម្បីបង្ហាញរបើកគំហើញថ្មីៗនៅតំបន់អង្គរផង៕

ដើមឈើហានិភ័យចំនួន១០ដើមត្រូវបានដកហូតនៅប្រាសាទគោកពោធិ៍

ផ្សាយនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងអនុវត្តន៍វិធានការបន្ទាន់ចំពោះដើមឈើដែលកំពុងបង្កហានិភ័យខ្ពស់មកលើប្រាសាទគោកពោធិ៍ ស្ថិតក្នុងភូមិគោកពោធិ៍ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប។

ដើមឈើដែលបានដកហូតរួចរាល់មានចំនួន១០ដើមរួមមាន ដើមដកព៦ដើម កញ្ជើបាយដាច៣ដើម និងចង្កត្នាត១ដើមដែលស្ថានភាពដើមឈើទាំងនោះដុះទ្រេតជាប់ខឿនប្រាសាទ ដុះនៅលើតួប្រាសាទ និងមានឫសចាក់ចូលក្នុងថ្មតួប្រាសាទផង ដែលអាចបង្កឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធប្រាសាទកាន់តែធ្ងន់ធ្ងរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃពុធ ទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍ចំនួននៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការសហការចូលរួមអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងនៅភូមិព្រៃក្មេង ភូមិបឹងខ្នារ ភូមិជ្រលង ឃុំខ្នាត និងភូមិកំភែម ឃុំកែវពណ៌។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិក្រវ៉ាន់ ភូមិរហាល ភូមិស្រះស្រង់ខាងជើង សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៣ សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០២១

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរ បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិលាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិគោកថ្មី ភូមិពាម ភូមិគោកពោធិ៍ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិថ្នល់ សង្កាត់ស្រង៉ែ ភូមិសណ្តាន់ សង្កាត់ទឹកវិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី៤ ក្រុមការងារប្រចាំក្រៅឧទ្យាន បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិ បឹងមាលា ឃុំបឹងមាលា។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន២សំណើ។

សរុបមក នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៤គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមីនា

អាជ្ញាធរជាតិអប្សរាបន្តជួសជុលរចនាសម្ពន្ធស្រះខាងជើងនៃប្រាសាទអង្គរវត្តឱ្យរួចរាល់

ផ្សាយនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២១

ក្រុមអ្នកជំនាញជួសជុលស្រះខាងជើងនៃប្រាសាទអង្គរវត្ត មកដល់ពេលនេះបានបញ្ចប់កិច្ចការស្រាវជ្រាវបុរាណវិទ្យា រួចរាល់ហើយ ព្រមទាំងបានជួសជុលប្រាំងស្រះបានចំនួន ៥៦ម៉ែត្រ និងបញ្ចូលទឹកក្នុងស្រះចំនួន៦០០០០ម៉ែត្រគូប។ ទោះជាយ៉ាងនេះក្តី ទីនេះនៅតែបន្តបិទស្បៃខ្មៅមិនទាន់ អនុញ្ញាតឱ្យភ្ញៀវទេសចរចូលទៅផ្តិតរូបភាពប្រាសាទអង្គរ វត្តពីស្រះនេះនៅឡើយ ព្រោះគម្រោងជួសជុលនិងលើក តម្លៃរចនាសម្ពន្ធស្រះនៅតែបន្ត អាចនឹងរួចរាល់ទាំងស្រុង នៅ២ឆ្នាំក្រោយ។

លោក ស្រ៊ុន តិច បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទ ក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការនិងជាប្រធានគម្រោង ជួសជុលរចនាសម្ពន្ធស្រះខាងជើងឱ្យដឹងថា ការងារទាំង នេះបានចាប់ផ្តើមកិច្ចការស្រាវជ្រាវតាំងពីឆ្នាំ២០១៨ និង អនុវត្តការជួសជុលនៅឆ្នាំ២០២០។ បច្ចុប្បន្នមិនទាន់បើក ឱ្យភ្ញៀវចូលផ្តិតរូបភាពទេ ព្រោះរចនាសម្ពន្ធស្រះខាងជើង ខូចខាតខ្លាំង មិនទាន់ជួសជុលរួចរាល់ទាំងស្រុង។ ស្រប នឹងពេលនេះ ការរីករាតត្បាតនៃជំងឺកូវីដ១៩ក៏មិនមានភ្ញៀវ មកទស្សនាដែរ។ម្យ៉ាងវិញទៀតក៏ទុកឱកាសឱ្យអ្នកជំនាញ ស្រាវជ្រាវនិងអ្នកជួសជុលងាយស្រួលបំពេញការងារបាន ល្អផង។

នាឆ្នាំ២០២១នេះ អាជ្ញាធរជាតិអប្សរានៅសល់កាំជណ្តើរ ស្រះ៣ជ្រុងទៀតដែលត្រូវពង្រឹងនិងកំពុងតែកំណាយមើល ស្ថានភាពខូចខាតជាក់ស្តែងដើម្បីលើកគម្រោងជួសជុល បន្ថែមចំនួន៦៥ម៉ែត្រឱ្យរួចរាល់ក្នុងរយៈពេល២ឆ្នាំទៀត តែបើជួបនឹងករណីស្រាវជ្រាវ វានឹងអាចពន្យារពេលយូរ ជាងនេះ។ រចនាសម្ពន្ធស្រះខាងជើងខូចខាតទ្រុឌទ្រោម ដោយសារថ្មភក់មានប្រតិកម្មខ្លាំងនឹងកម្តៅថ្ងៃជាមួយនឹង ទឹកធ្វើឱ្យក្តៅសើមៗ បណ្តាលឱ្យថ្មភក់ងាយសឹករិចរិល ងាយ នឹងបាក់បែកហើយកន្លែងខ្លះបាត់ថ្មដែលធ្វើឱ្យមានចន្លោះ ប្រហោងបណ្តាលឱ្យទឹកហូរនាំដីច្រោះចូលទៅក្នុងស្រះ។ ដូច្នេះក្រុមការងារត្រូវការសិក្សាស្រាវជ្រាវពីវិធីសាស្ត្រពង្រឹង ការបិទចន្លោះប្រហោងយ៉ាងម៉េចដើម្បីកុំឱ្យវាច្រោះទៀត។

លោក ស្រ៊ុន តិច បញ្ជាក់ថា ការអភិរក្សសំណង់បុរាណ យើងអត់អាចកំណត់បានដូចសំណង់សម័យទំនើបទេ យើង ត្រូវការពេលវេលាយូរដើម្បីកុំឱ្យបាត់បង់នូវទម្រង់ដើមរបស់ ស្រះ។ យើងមិនអាចធ្វើលឿនពេក ដោយមិនគិតគូរអំពី កិច្ចការស្រាវជ្រាវ បច្ចេកទេសបុរាណ វិស្វកម្មបុរាណ ការប្រើ ប្រាស់វត្ថុធាតុដើមនោះឡើយ។ ដូច្នេះមុននឹងយើងធ្វើពី កន្លែងមួយទៅកន្លែងមួយ យើងត្រូវកំណាយបើកដីមើល ឱ្យអស់ពីស្ថានភាពដើមរបស់វា រួចសម្រង់ប្លង់គ្រប់ជ្រុង ជ្រោយ រួចសិក្សាប្លង់ តើត្រូវរៀបម៉េចឱ្យដូចទម្រង់ដើម ដែល សំខាន់សម្រាប់កិច្ចការអភិរក្សមិនអាចកែប្រែវាបានទេ។ ចំពោះស្រះខាងជើងនៃប្រាសាទអង្គរវត្ត ក៏ធ្លាប់មានប្រវត្តិ ជួសជុលកាលពីឆ្នាំ១៩២២ ដោយលោក ហង់រី ម៉ាកហ្សាល់។ គាត់បានរៀបផ្នែកខាងជើងម្តងរួចមកហើយ ដោ យលោក បានកែលម្អលើកថ្មឱ្យមានទម្រង់ចេញជារូបរាងស្រះ៕

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេស នៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន ៤៧០គ្រួសារ

ផ្សាយនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២១

នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងអំឡុង ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារបានចុះពិនិត្យនិងជួយ សម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាននិងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពល រដ្ឋដែលរស់នៅក្នុងឧទ្យាន និងក្រៅឧទ្យានអង្គរបានចំនួន ៤៧០គ្រួសារ។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរចំនួន ៤៦០គ្រួសារ៖ក្រុងសៀមរាប១៣៦គ្រួសារស្រុកប្រាសាទបាគង ១១៧គ្រួសារ ស្រុកបន្ទាយស្រី ៨៩គ្រួសារ ស្រុកពួក ៤៣គ្រួសារ និងស្រុកអង្គរធំ ៦៦គ្រួសារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្រៅឧទ្យានអង្គរចំនួន១០គ្រួសារ៖ គឺនៅក្រុងសៀមរាប០៣គ្រួសារ និងស្រុកស្វាយលើចំនួន០៧គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាតនិងដាក់ពាក្យសាងសង់ស្នើសុំ គឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

ទឹកបារាយណ៍ខាងលិចរួមចំណែកក្នុងការងារកសិកម្មរបស់ប្រជាពលរដ្ឋ

ផ្សាយនៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២១

ប្រជាកសិករនៃសហគមន៍កសិករ ប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្របារាយណ៍ខាងលិច កំពុងរីករាយជាមួយនឹងទិន្នផលស្រូវនៅក្នុងរដូវនេះ ដែលតាមការអះអាង ឆ្នាំនេះមានការកើនឡើងជាងឆ្នាំទៅ។ ប្រជាកសិករទាំងនោះអះអាងថា កំណើនទិន្នផលស្រូវឆ្នាំនេះក៏ដោយសារការទទួលទឹកពីបារាយណ៍ខាងលិចដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរាបានទាន់ពេលវេលា និងក្នុងបរិវេណគ្រប់គ្រាន់សម្រាប់បំពេញស្រែរបស់សិបហិកតារបស់ពួកគេ។

ប្រធានសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្របារាយណ៍ខាងលិច លោក សុខ មក់ ឱ្យដឹងថា ទិន្នផលរបស់ប្រជាកសិករដែលទទួលទឹកបារាយណ៍ខាងលិចនៅឆ្នាំនេះ ទទួលបានផលល្អប្រសើរ។ លោកបន្ថែមថា លទ្ធផលដែលទទួលបាននេះក៏ដោយសារការទទួលទឹកពីប៉ែកខាងលើដែលទម្លាក់មក មានភាពងាយស្រួល និងឆាប់រហ័យទាន់ពេលវេលា។ ប្រធានសហគមន៍ លោក សុខ មក់ បានបង្ហាញអារម្មណ៍រីករាយជាខ្លាំងចំពោះអាជ្ញាធរជាតិអប្សរាដែលជានិច្ចកាលបានសហការផ្តល់ទឹកដល់កសិករសម្រាប់ស្រោចស្រពស្រូវតាមតម្រូវការជាក់ស្តែង។

កសិករក្នុងភូមិតាជេត ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប លោក ជា ម៉ោញ រៀបរាប់ថា ស្រែចំនួន៥ហិកតារបស់លោកនៅឆ្នាំ ទទួលផលគិតជាទឹកប្រាក់ប្រមាណ ១៥លាន។ លោកបន្ថែមថា ទឹកបារាយណ៍ជាផ្នែកមួយយ៉ាងសំខាន់ដែលជួយឱ្យផលស្រូវរបស់លោកបានផលល្អ។ លោកបញ្ជាក់ថា៖ បើគ្មានទឹកនោះទេ ស្រូវមិនកើតទេ ព្រោះវាលនេះតាំងពីដើម ពឹងលើទឹកបារាយណ៍តាំងពីសង្គមមក»។

មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹក លោក ទឹម ឆោម បារាយណ៍ខាងលិចមានតួនាទីស្នូលចំនួន៤សំខាន់ៗ រួមមាន ទី១សម្រាប់បញ្ចៀសជំនន់ទឹកភ្លៀងមិនឱ្យលិចក្រុង ទី២ផ្គត់ផ្គង់សម្រាប់ប្រជាកសិករដែលសព្វថ្ងៃមានចំនួន២ស្រុក-ក្រុង គឺ៥សង្កាត់ក្នុងក្រុងសៀមរាប និង៤ឃុំនៃស្រុកពួក។ តួនាទីទី៣ គឺផ្គត់ផ្គង់ទឹកស្អាតដល់រដ្ឋាករទឹកស្វយ័តសៀមរាប និងទី៤ ផ្គត់ផ្គង់ទឹកក្រោមដីដើម្បីឱ្យមានស្ថេរភាពជួយការពារគ្រឹះប្រាសាទ និងជួយសម្រួលចរន្តទឹកក្រោមដីដល់ពលរដ្ឋនៅជុំវិញតំបន់ផងដែរ។

សម្រាប់សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាស្ត្របារាយណ៍ខាងលិចនេះដែរ លោក ទឹម ឆោម ពន្យល់ថា សហគមន៍នេះបានបង្កើតយូរមកហើយ តែនៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលក៏ប្រគល់ការគ្រប់គ្រងមកឱ្យអាជ្ញាធរជាតិអប្សរា ហើយបានបន្តរៀបចំកិច្ចការងារបែងចែកដល់ប្រជាកសិករឱ្យកាន់តែល្អប្រសើរ។

យ៉ាងណា មន្ត្រីនៃនាយកដ្ឋានគ្រប់គ្រងទឹករៀបរាប់ថា នៅក្រោយការផ្គត់ផ្គង់ទឹកបានគ្រប់តម្រូវការ ប្រជាកសិករបានពង្រីកផ្ទៃដីស្រែ ដែលធ្វើឱ្យការផ្គត់ផ្គង់ទឹកមានការកើនឡើងជាលំដាប់។ លោក ទឹម ឆោម ពន្យល់ថា មុនការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា ផ្ទៃដីស្រែសរុបទាំងមូលរបស់កសិករមានត្រឹម១៣,០០០ហិកតា តែក្រោយមកមានការបង្កើនផ្ទៃដីស្រែប្រាំងរហូត២ដង។ ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់ប្រជាកសិករទាំងអស់ សូមធ្វើស្រែតែម្តងក្នុងមួយឆ្នាំ ហើយត្រូវដាំដំណាំរួមផ្សំផ្សេងៗជំនួសដើម្បីកាត់បន្ថយហានិភ័យពីការពឹងលើទឹកបារាយណ៍ ព្រោះបច្ចុប្បន្ននេះ ទឹកបារាយណ៍មានតួនាទីច្រើនច្រើន ដែលធ្វើឱ្យការបញ្ជូនទឹកដល់ប្រជាពលរដ្ឋមិនតាមតម្រូវការនៅពេលខ្លះ។លោកទឹមឆោមប្រាប់ថា៖«ការបើកទឹកទម្លាក់លើសពីមួយដង អាស្រ័យលើទឹក យើងក៏ព្យាយាមពន្យល់ឱ្យគាត់ធ្វើស្រែដំណាលគ្នា ដើម្បីឱ្យការទម្លាក់ទឹកមកម្តងរួច ជៀសវាងទម្លាក់ច្រើនដង វាខាតទឹក»៕

អាជ្ញាធរជាតិអប្សរាកំពុងផ្លាស់ប្ដូរផ្ទាំងព័ត៌មាននិងស្លាកសញ្ញាប្រាប់ទិសដៅទស្សនាជុំវិញប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២១

ក្នុងន័យបង្កើនគុណភាពសេវាទេសចរណ៍ក្នុងរមណីយដ្ឋានអង្គរ ព្រមទាំងផ្ដល់ជូនភ្ញៀវទេសចរនូវបទពិសោធន៍ល្អៗពីការទស្សនាប្រាសាទបន្ទាយស្រី នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរជាតិអប្សរា បានផ្លាស់ប្ដូរផ្ទាំងព័ត៌មាន និងស្លាកសញ្ញាប្រាប់ទិសដែលចាស់ទ្រុឌទ្រោម រលុបអក្សរចេញ ដោយជំនួសមកវិញនូវផ្ទាំងព័ត៌មាននិងស្លាកសញ្ញាថ្មី ដែលមានបន្ថែមនូវព័ត៌មានអំពីរយៈចម្ងាយពីទីតាំងមួយទៅទីតាំងមួយទៀត។

ការផ្លាស់ប្ដូរនេះ គឺដើម្បីឱ្យភ្ញៀវទេសចរ កាន់តែងាយស្រួល និងទទួលបានព័ត៌មានគ្រប់គ្រាន់ពីការទស្សនាប្រាសាទបន្ទាយស្រី។ ជាមួយគ្នាដែរ អាជ្ញាធរជាតិអប្សរាក៏បានរៀបចំដាក់កន្លែងអង្គុយសម្រាកក្រោមម្លប់ឈើនៅតាមបណ្ដោយផ្លូវដើរចេញពីប្រាសាទត្រឡប់ទៅចំណតយានយន្តវិញ ដើម្បីសម្រួលដល់ទេសចរដែលមានអាយុច្រើន និងឆ្លើយតបចំពោះភ្ញៀវទេសចរដែលត្រូវការទីតាំងអង្គុយអានសៀវភៅ ព្រមទាំងអាចមើលឃើញប្រាសាទពីចម្ងាយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០២ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន ៣គោលដៅ ដែលមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិស្ពានក្អែក ឃុំកណ្តែក ភូមិថ្នល់ត្រង់ ឃុំបាគង។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិដូនឪ ភូមិគោកគ្រើល ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិបន្ទាយស្រី ភូមិទួលក្រឡាញ់ ឃុំខ្នារសណ្តាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សរុបមក នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕



ទស្សនាវដ្តី "ព្រះនគរ" បំផុសស្មារតីយុវជនយល់ពីតម្លៃវប្បធម៌

ផ្សាយនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២១

ជាស្មារតីរួមចំណែកអបអរសាទរខួបលើកទី២៣នៃទិវាវប្បធម៌ជាតិ ដែលធ្វើឡើងក្រោមប្រធានបទ «យុវជនដើម្បីវប្បធម៌ជាតិ» នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១នេះ អាជ្ញាធរជាតិអប្សរា កន្លងមកក៏បានចេញផ្សាយទស្សនាវដ្តី «ព្រះនគរ» ដែលបរិយាយលម្អិតពីទិដ្ឋភាពទំនៀមទម្លាប់ប្រពៃណី ក៏ដូចជាលទ្ធផលស្រាវជ្រាវនានានៅក្នុងតំបន់អង្គរ។

តាមរយៈខ្លឹមសារថ្មីនៃទស្សនាវដ្តីនេះ អាជ្ញាធរជាតិអប្សរា រំពឹងទុកថា វានឹងក្លាយជាឯកសារមួយដើម្បីជំរុញបំផុសស្មារតីឱ្យស្រឡាញ់វប្បធម៌ជាតិ និងមនសិការស្នេហាជាតិដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសស្រទាប់យុវជនដែលជាទំពាំងស្នងឫស្សី ដែលមានកាតព្វកិច្ចថែរក្សា ការពារឱ្យស្ថិតស្ថេរគង់វង្សនូវសម្បត្តិវប្បធម៌ជាតិនិងវប្បធម៌ចម្រុះនៃសហគមន៍ជាតិនៅកម្ពុជា សំដៅរក្សាបាននូវឯកភាពជាតិ សាមគ្គីភាព សន្តិភាព និងការអភិវឌ្ឍ។



សូមបញ្ជាក់ថា ការចេញផ្សាយនូវទស្សនាវដ្តីឈ្មោះ «ព្រះនគរ លេខ១នេះ គឺបានផ្តោតសំខាន់ទៅលើបុរាណវត្ថុរកឃើញថ្មីៗនៅអង្គរ ការអភិរក្សជួសជុលប៉មឥដ្ឋលេខ ៨នៅប្រាសាទបាគង ទំនៀមទម្លាប់ពិធីបុណ្យតាមបែបសាសនា និងការគោរពតៗគ្នារបស់ពលរដ្ឋក្នុងតំបន់អង្គរ ដូចជា ពិធីឡើងអ្នកតាខែពិសាខនៅវត្តអធ្វា ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ និងប្រព័ន្ធធារាសាស្ត្រនៃប្រាសាទព្រះវិហារជាដើម។

អាជ្ញាធរជាតិអប្សរាបណ្តុះបណ្តាលអ្នកបន្តវេនថែរក្សាអង្គរ

ផ្សាយនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២១

អង្គរ ជាដួងព្រលឹងនិងអត្តសញ្ញាណជាតិ បានក្លាយជាសម្បត្តិបេតិកភណ្ឌវប្បធម៌នៃមនុស្សជាតិរបស់អង្គការយូណេស្កូនៅឆ្នាំ១៩៩២។ តាំងពីពេលនោះមករហូតដល់បច្ចុប្បន្ន ក្រៅតែពីកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពតំបន់អង្គរ ការបណ្តុះបណ្តាលអ្នកបន្តវេនថែរក្សាអង្គរត្រូវបានចាត់ទុកជាកិច្ចការអាទិភាពយ៉ាងសំខាន់។

ក្នុងន័យនេះ ស្របនឹងការអបអរសាទរទិវាវប្បធម៌ជាតិ ៣ មីនា លើកទី២៣ ក្រោមប្រធានបទយុវជនដើម្បីវប្បធម៌ជាតិ អាជ្ញាធរជាតិអប្សរាសូមរំលេចនូវការងាររបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ដែលជាផ្នែកមួយដើរតួយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាល ពង្រឹងចំណេះដឹងដល់ធនធានយុវជនជំនាន់ក្រោយ ទាក់ទងនឹងកិច្ចការអភិរក្ស ការអភិវឌ្ឍន៍ ទំនៀមទម្លាប់ ប្រពៃណី សាសនា របកគំហើញថ្មីៗ ដែលស្ថិតក្នុងតំបន់រមណីយដ្ឋានអង្គរ។ ជាក់ស្តែង ក្នុងឆ្នាំ ២០២០ មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន១៨វគ្គក្នុងន័យចែករំលែកបទពិសោធន៍ ក៏ដូចជាផ្ទេរចំណេះដឹងពីអ្នកចេះច្រើន ដល់អ្នកចេះតិច ដើម្បីនិរន្តរភាពអ្នកបន្តវេន។

វគ្គបណ្តុះបណ្តាលទាំងនោះរួមមានប្រធានបទទាក់ទងនឹងវិស័យបេតិកភណ្ឌ ការអភិរក្ស ប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ សាសនា ក៏ដូចជាការរកឃើញរបកគំហើយថ្មីៗដែលមាននៅក្នុងតំបន់រមណីយដ្ឋានអង្គរដោយការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក និងសាធារណៈជនជាសិក្ខាកាមសរុបប្រមាណ ៧១៥នាក់។

បន្ថែមពីនោះ មជ្ឈមណ្ឌលនេះបានរៀបចំបាឋកថា ដែលមានវាគ្មិនជាច្រើនរូបចូលរួម និងបានចែករំលែកចំណេះដឹងបទពិសោធន៍ដល់មន្ត្រី បុគ្គលិកអាជ្ញាធរជាតិអប្សរា មគ្គុទ្ទេសក៍ សាធារណៈជន និងអ្នកស្រាវជ្រាវដែលកំពុងបំពេញភារកិច្ចក្នុងតំបន់អង្គរបានចំនួន ៤បាឋកថា សរុបមានសិក្ខាកាមចំនួន ២០០នាក់៕

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ជាបណ្តុំចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ សម្រាប់កូនខ្មែរសិក្សាស្វែងយល់

ផ្សាយនៅថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០២១

សារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ មានពិព័រណ៍អចិន្ត្រៃយ៍ចំនួន៣ សុទ្ធសឹងជាលទ្ធផលកំណាយស្រាវជ្រាវបុរាណវិទ្យានៅក្នុងតំបន់អង្គរ។ ពិព័រណ៍វត្ថុបុរាណដែលបានមកពីកំណាយស្រាវជ្រាវទាំងនោះ នឹងផ្តល់ចំណេះដឹងដល់អ្នកទស្សនាឱ្យយល់បានកាន់តែច្បាស់អំពីបុរាណវិទ្យាលើដីនិងក្រោមដី រួមទាំងប្រវត្តិសិល្បៈជាច្រើនទៀត។

មានទីតាំងស្ថិតនៅភូមិបឹងដូនប៉ា ឃុំស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប សារមន្ទីរព្រះនរោត្តមសីហនុអង្គរមិនត្រឹមតែជាទីកន្លែងពិព័រណ៍នូវកុលាលភាជន៍ ផ្នូរសពបុរាណ សាកសពឬឆ្អឹងខ្មោចមនុស្សសម័យបុរាណរួមទាំងបដិមាជាច្រើនសម្រាប់ទស្សនាប៉ុណ្ណោះទេ តែក៏ជាកន្លែងដែលផ្ទុំនូវចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ ប្រវត្តិសិល្បៈ និងបម្រែបម្រួលនៃសាសនាខ្មែរនាអតីតកាល។

លោក ប៉ែន ចំរ៉ុង នាយកស្តីទីនៃសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ បានលើកឡើងថា អ្នកទស្សនាអាចទទួលបាននូវចំណេះដឹងដ៏កម្រ តាមរយៈការចូលមកទស្សនាពិព័រណ៍នៅសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ។ ជាពិសេសសម្រាប់យុវជន កុលបុត្រខ្មែរដែលចំណេះដឹងទាំងនេះគឺមានតម្លៃជាទីបំផុត។ លោកសង្កត់ធ្ងន់ថា យុវជនជា សសរទ្រូងរបស់ប្រទេសជាតិហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវ និងចូលរួមក្នុងកិច្ចការថែរក្សា ការពារ និងអភិរក្សបេតិកភណ្ឌ។ ដូច្នេះ សារមន្ទីរព្រះនរោត្តម

សីហនុ-អង្គរ លើកទឹកចិត្ត និងបើកទូលាយដល់គ្រឹះស្ថានអប់រំផ្សេងៗដឹកនាំសិស្សានុសិស្សឱ្យមកធ្វើទស្សនកិច្ចសិក្សាស្វែងយល់យល់ពីតួនាទីរបស់សារមន្ទីរ និងបានឃើញបុរាណវត្ថុផ្ទាល់ភ្នែក ដែលបានមកពីការស្រាវជ្រាវរបស់អាជ្ញាធរជាតិអប្សរា អង្គការស្ថាប័នអន្តរជាតិធ្វើការងារជួសជុល អភិរក្ស និងស្រាវជ្រាវនៅក្នុងតំបន់អង្គរ។

លោក ប៉ែន ចំរ៉ុង បន្ថែមថា ក្រោយពេលមានការអប់រំបេតិកភណ្ឌបានទូលំទូលាយ មានប្រជាពរដ្ឋ និងសប្បុរសជនបានចូលរួមផ្តល់នូវបុរាណវត្ថុដូចជាបដិមា និងកុលាលភាជន៍មកសារមន្ទីរជាហូរហែរ។ សកម្មភាពនេះ សបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើន រួមទាំងបានចូលរួមចំណែកថែរក្សា ការពារ អភិរក្សជាមួយអាជ្ញាធរជាតិអប្សរា និងសម្រាប់ប្រជាជាតិខ្មែរទាំងមូល៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់នៅក្នុងបរិវេណវត្តទេពប្រណម្យ និងក្រុមប្រាសាទព្រះពិធូរនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ និងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើម

ឈើដែលបង្កហានិភ័យខ្ពស់ក្នុងបរិវេណវត្តទេពប្រណម្យ និងក្រុមប្រាសាទព្រះពិធូរនៃក្រុងអង្គរធំ។ ការងារនេះ ធ្វើឡើងដើម្បីធានាសុវត្ថិភាពជូនពុទ្ធបរិស័ទ និងព្រះសង្ឃ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងជួយសម្រាលដល់តួដើម បង្ការកុំឲ្យបាក់ដួលរលំខូចខាតដល់សាលាឆាន់ កុដិ និងយានយន្តគ្រប់ប្រភេទ ព្រមទាំងបង្កឲ្យប៉ះពាល់ដល់រចនាសម្ព័ន្ធប្រាសាទកាន់តែធ្ងន់ធ្ងរ។ លើសពីនេះ ការចុះកាត់ក្រី និងដកហូតដើមឈើទាំងនោះ ក្នុងបំណងសម្រួលកិច្ចការអភិរក្សនិងជួសជុលប្រាសាទផងដែរ។

ដើមឈើដែលបាននិងកំពុងកាត់ដកហូតមានចំនួន៥ដើម រួមមាន ដើមអង្កោល១ដើម ដូនកាយ២ដើម ស្លង់១ដើម និងឈើយាង១ដើម ដែលស្ថានភាពដើមឈើទាំងនោះ ដុះទ្រេតមកលើសាលាឆាន់ និងកុដិ ដួលមួយផ្នែកចំពីមុខប្រាសាទ ដុះជាប់ខឿនប្រាសាទផ្នែកខាងត្បូង មានជំងឺពុកគល់ ប្រព័ន្ធឫសខ្សោយចាក់ចូលក្នុងរចនាសម្ព័ន្ធប្រាសាទ។ ចំណែកឯដើមឈើដែលកំពុងកាត់ក្រីមែកមានចំនួន៥ដើម រួមមាន ដើមឈើយាង២ដើម ស្លង់២ដើម និងចាមរី១ដើម ដុះជាប់ផ្លូវចូលវត្ត និងដុះជាប់ខឿនប្រាសាទផ្នែកខាងជើងឈៀងខាងលិចមានមែកសាខាច្រើនគ្របពីលើប្រាសាទ។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន ២គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិស្ទឹងភូមិឪឡោក ឃុំបាគង។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិ រំចេក ឃុំរំចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរា និងអាជ្ញាធរស្រុកសូទ្រនិគម រួមគ្នាអប់រំផ្សព្វផ្សាយបញ្ឈប់ការជីកកាយយកអាចម៍ដីពីទំនប់ព្រែកជីកបុរាណ

ផ្សាយនៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ **ឯកឧត្តម តឹម សុធិន** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា រួមទាំងសហការី និងមន្ត្រីនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តសៀមរាប អាជ្ញាធរមូលដ្ឋាន បានចូលរួមប្រជុំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋប្រកបអាជីវកម្មដុតឥដ្ឋនិងក្បឿង កុំជីកការជីកកាយយកអាចម៍ដីពីទំនប់ព្រែក។

កិច្ចប្រជុំបានប្រព្រឹតទៅនៅសាលាឃុំដានរុន ស្រុកសូទ្រនិគម មានគោលបំណងអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចំនួន១១គ្រួសារ ដែលមានអាជីវកម្មដុតឥដ្ឋនៅលើខ្នងទំនប់ព្រែកស្រមោច ឬហៅថាផ្លូវសំពៅ ដែលជាទំនប់បុរាណមានប្រភពពីជើងភ្នំគូលែនដល់បឹងទន្លេសាប ដើម្បីសុំកុំឲ្យមានការជីកកាយយកអាចម៍ដីពីខ្នងទំនប់នៅក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាបជាបន្តទៀត។

ឯកឧត្តម តឹម សុធិន លើកឡើងថា ដើម្បីចូលរួមថែរក្សាកេរដំណែលរបស់ដូនតាក៏ដូចជាសម្បត្តិបេតិកភណ្ឌជាតិ សូមបងប្អូនអាជីវករផលិតឥដ្ឋនិងក្បឿងអាចប្រើប្រាស់ទីតាំងរបស់ខ្លួនដូចដើម ប៉ុន្តែត្រូវយកអាចម៍ដីពីកន្លែងផ្សេងមកធ្វើ ជៀសវាងការខូចខាត ឬធ្វើឲ្យបាត់បង់ស្លាកស្នាមប្រវត្តិសាស្ត្រ។ ឯកឧត្តមក៏បានស្នើសុំឲ្យជួយថែរក្សាបុរាណដ្ឋានមួយចំនួនផ្សេងៗទៀត មានដូចជាប្រាសាទ បឹងបុរាណ ទួលបុរាណ សម្រាប់កូនចៅជំនាន់ក្រោយ។

សូមបញ្ជាក់ថា ព្រែកជីកខាងលើនេះមានប្រភពពីជើងភ្នំគូលែន រហូតដល់បឹងទន្លេសាប។ ថ្វីត្បិតសព្វថ្ងៃបានបាត់ដានខ្លះៗនៅជិតភ្នំ ប៉ុន្តែផ្នែកខាងក្រោម មានដានកាន់តែច្បាស់មានទឹកប្រើប្រាស់ជាព្រែកនៅឡើយ។

កាលពីសម័យបុរាណ ព្រែកជីកនេះមានតួនាទីសំខាន់ ក្រៅពីផ្តល់ទឹកសម្រាប់កសិកម្មដល់សហគមន៍ជុំវិញ គឺជាផ្លូវដឹកជញ្ជូនថ្មពីភ្នំគូលែនមកតំបន់អង្គរ និងសម្រាប់ធ្វើជំនួញផង។ល។

អាជ្ញាធរជាតិអប្សរាសហការជាមួយវិស័យឯកជនប្រុងពលីបើកការដ្ឋានកំណាយ ប្រាសាទវាលផ្ទីនៅកណ្ដាលបារាយណ៍ប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១

ពិធីប្រុងពលីកំណាយប្រាសាទវាលផ្ទីនៅចំកណ្ដាលបារាយណ៍ប្រាសាទបេងមាលា ត្រូវបានប្រារព្ធឡើងនៅរសៀលថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ ក្រោមវត្តមាន **ឯកឧត្តម តឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងលោក ម៉ៅ ស៊ី ប្រធានសហគមន៍ទេសចរណ៍បន្ទាយឆ្មារ តំណាងលោកជំទាវ ម៉ៅ ម៉ាល័យ កែ គឹមយ៉ាន ហេមចិត្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភនិងជាប្រធានកិត្តិយស សមាគមន៍នារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ នៃខេត្តបន្ទាយមានជ័យ រួមទាំងសហការីអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋានចូលរួមផង។

ពិធីប្រុងពលីនេះធ្វើឡើងដើម្បីបួងសួងសុំការអនុញ្ញាតពីម្ចាស់ទឹកម្ចាស់ដី និងវត្ថុស័ក្តិសិទ្ធិដែលនៅថែរក្សាប្រាសាទនេះ ឱ្យក្រុមការងារកំណាយនិងជួសជុលប្រាសាទបានប្រកបដោយសុខសុវត្ថិភាពនិងជោគជ័យ។

ឯកឧត្តម តឹម សុធិន អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា ក្រុមការងារបើកការដ្ឋាន កំណាយនិងជួសជុលប្រាសាទវាលផ្ទីដែលស្ថិតនៅចំកណ្ដាលបារាយណ៍ប្រាសាទបេងមាលា មានទីតាំងស្ថិតនៅភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប ក្រោមការឧបត្ថម្ភរបស់ **លោកជំទាវ ម៉ៅ ម៉ាល័យ កែ គឹម យាន**។ ប្រាសាទនេះជាសំណង់មានគ្រឹះថ្មបាយក្រៀមរាងការ៉េ និងមានសំណល់ដុំថ្មភក់មានរូបប្រហែលជា ព្រះពុទ្ធប្រក់នាគ ឬក៏ព្រះវិស្ណុផ្ទុំលើនាគ អាចសាងសង់ឡើងគោរពដល់ព្រហ្មញ្ញសាសនាក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ឬជាព្រះពុទ្ធសាសនាក្នុងរាជព្រះបាទជ័យវរ្ម័នទី៧។ តែយើងពុំទាន់ដឹងថាវាជារូបអ្វីពិតប្រាកដទេ ដូច្នេះទើបអាជ្ញាធរជាតិអប្សរាធ្វើកំណាយស្រាវជ្រាវនេះដើម្បីរក និងផ្គុំដុំថ្មទាំងអស់នេះ ដើម្បីដឹងថាជារូបអ្វីពិតប្រាកដ។ ឯកឧត្តម ក៏បានសំណូមពរឱ្យប្រជាពលរដ្ឋជួយការពារប្រាសាទបុរាណនិងសុំអង្វរប្រជាពលរដ្ឋមេត្តាកុំកាប់ព្រៃក្នុងបរិវេណប្រាសាទដែលនាំឱ្យប្រាសាទងាយរលំបាក់បែកខូចខាត។

លោក ម៉ៅ ស៊ី តំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ម៉ៅ ម៉ាល័យ កែ គឹមយ៉ាន** មានប្រសាសន៍ថា ជានិច្ចកាលលោកជំទាវតែងតែចូលចិត្តការថែរក្សាមរតកដូនតាជាពិសេសប្រាសាទបុរាណ។កន្លងមកលោកជំទាវបានចំណាយថវិការាប់លានដុល្លារក្នុងការជួសជុលប្រាសាទបន្ទាយឆ្មារ និងរចនាសម្ពន្ធនានារបស់ប្រាសាទនេះហើយជួយជួសជុលប្រាសាទបន្ទាយទ័ព និងកំពុង បន្តជួសជុលព្រះពន្លាជ័យ ឬហៅថា បារាយណ៍មេបុណ្យ។ ពេលនេះលោកជំទាវបានចំណាយថវិកាផ្ទាល់ខ្លួនបន្ថែមទៀតដើម្បីធ្វើកំណាយប្រាសាទវាលផ្ទី ដែលស្ថិតនៅជិតប្រាសាទបេងមាលា ក្នុងស្រុកស្វាយលើ ខេត្តសៀមរាប។

លោក ម៉ៅ ស៊ី បានបន្ថែមទៀតថា ដរាបណាលោកជំទាវនៅមានជីវិត លោកជំទាវនឹងបន្តធ្វើការជួសជុលប្រាសាទបុរាណបន្ថែមទៀត ដើម្បីចូលរួមចំណែកថែរក្សាមរតកបុរាណដែលមាន តម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់ ទុកឱ្យកូនចៅជំនាន់ក្រោយៗទៀត។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២១

ថ្ងៃសុក្រ ទី៥ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន៣គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិ ត្រពាំងស្វាយ ឃុំលាងដៃ។ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨ សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិតាស្នេហ៍ ភូមិប្រាសាទចារ្យ ភូមិល្បើក ភូមិត្នោតជ្រុំ ឃុំជូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រៅឧទ្យាន បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិបឹងមាលា ឃុំបឹងមាលា។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១សំណើ។

សរុបមក នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៥ សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលគោរពវិញ្ញាណក្ខន្ធ សពលោកស្រី Vann Amberg Gertrude

ផ្សាយនៅថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី៧ខែមីនាឆ្នាំ២០២១ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដឹកនាំដោយ **ឯកឧត្តម តឹម សុធិន** អគ្គនាយករងទីប្រឹក្សា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការមួយចំនួនបានអញ្ជើញចូលគោរពវិញ្ញាណក្ខន្ធសពលោកស្រី Vann Amberg Gertrude នៅគេហដ្ឋានសពស្ថិតក្នុងភូមិទ្រាំងសង្កាត់ស្លក្រាម ក្រុងសៀមរាប។

លោកស្រី Vann Amberg Gertrude ហៅ Trudy ជាភរិយា **ឯកឧត្តមវណ្ណម៉ូលីវណ្ណ** អតីតប្រធានអាជ្ញាធរជាតិអប្សរា បានទទួលមរណភាពក្នុងអាយុ៨៨ឆ្នាំ ដោយរោគាពាធ វេលាម៉ោង៧និង៤០នាទី យប់ថ្ងៃទី៥ មីនា ឆ្នាំ២០២១។

យើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមសម្តែងនូវសេចក្តីក្រៀមក្រំ និងសោកស្តាយជាពន់ពេកជាមួយគ្រួសារសព និងសូមគោរពលំឱនកាយបួងសួងដល់វិញ្ញាណក្ខន្ធលោកស្រី បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ៕

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួន បានចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ។ ការចុះពិនិត្យនៅពេលនោះ រួមមានការងារស្តារនិងរៀបចំស្ទឹងសៀមរាប ការដ្ឋានជួសជុលស្ពានប្រាសាទតាកែវ ការដ្ឋាននៅព្រះលានជល់ដំរី និងគម្រោងលើកតម្លៃប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

គួរបញ្ជាក់ថា ការចុះពិនិត្យការដ្ឋានការងារនៅពេលនោះ ក៏មានការកាត់បន្ថយបុគ្គលិកបច្ចេកទេសចូលរួមមួយចំនួនផងដែរ ក្នុងបំណងចូលរួមរក្សាគំលាតសង្គម ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្ការជំងឺកូវីដ១៩៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិក្លង់ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយ ស្ថិតនៅភូមិព្រះដាក់ ភូមិអូរទទឹង ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន២៩សំណើ។

សរុបមក នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៣៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះពិនិត្យការដ្ឋានជួសជុល ស្ពានតាអោង និងប្រាសាទវាលផ្ទី

ផ្សាយនៅថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានជួសជុលស្ពានតាអោង ដែលជាស្ពានបុរាណ ស្ថិតនៅភូមិចុងស្ពាន ឃុំខ្វាវ ស្រុកជីក្រែង។

ស្ថានភាពមុនការជួសជុលស្ពាននេះមានសភាពទ្រុឌទ្រោមខ្លាំង និងផ្នែកខ្លះបានប្រេះ និងរលុះធ្លាក់ ដែលប្រឈមនឹងហានិភ័យខ្ពស់ ទាមទារឱ្យមានការជួសជុលជាបន្ទាន់។

បន្ទាប់ពីនោះ ឯកឧត្តមអគ្គនាយក ក៏បានអញ្ជើញចុះទៅពិនិត្យការដ្ឋានកំណាយស្រាវជ្រាវនិងជួសជុលនៅប្រាសាទវាលផ្ទី ស្ថិតនៅចំកណ្តាលបារាយណ៍ប្រាសាទបេងមាលា ដែលបានបើកការដ្ឋាននាដើមខែមីនា កន្លងទៅផងដែរ។

ប្រាសាទនេះ ទទួលបានការឧបត្ថម្ភជាថវិកាសម្រាប់ជួសជុលដោយសប្បុរសជនខ្មែរ ដែលបច្ចុប្បន្នក្រុមការងារជំនាញរបស់អាជ្ញាធរជាតិអប្សរា កំពុងធ្វើកំណាយស្រាវជ្រាវ មុននឹងចាប់ផ្តើមជួសជុលនាពេលឆាប់ៗខាងមុខនេះ៕

អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសកម្មភាពថែទាំតំបន់រមណីយដ្ឋានអង្គរ ដើម្បីត្រៀមទទួលភ្ញៀវសារជាថ្មី

ផ្សាយនៅថ្ងៃទី ១១ ខែមីនា ឆ្នាំ២០២១

ការរីករាលដាលជាសាកលនៃជំងឺកូវីដ ១៩ ធ្វើឲ្យភ្ញៀវទេសចរនៅតំបន់អង្គរ មានភាពស្ងប់ស្ងាត់ខ្លាំង។ ភ្ញៀវស្ងាត់ តែការងារនៅអង្គរមិនស្ងាត់នោះទេ។ ការរៀបចំសណ្តាប់ធ្នាប់តូបលក់ដូរ ការស្តារហេដ្ឋារចនាសម្ពន្ធ ដាំស្មួន ដាំកូនឈើ ថែទាំ ទល់ទ្រ និងជួសជុលប្រាសាទជាដើម គឺជាសកម្មភាពដែលមានជាប្រចាំនៅអង្គរ។

ដោយឡែកភ្នាក់ងារទេសចរណ៍ ដែលនៅជាប្រចាំតាមប្រាសាទក្នុងការណែនាំភ្ញៀវ សម្របសម្រួលបញ្ហាផ្សេងៗ និងទប់ស្កាត់ភាពឆ្គាំឆ្គងភ្ញៀវទេសចរដែលផ្ទុយនឹងក្រមប្រតិបត្តិអង្គរ នៅបន្តបំពេញការងាររបស់ខ្លួនតាមប្រក្រតី។ ពិតហើយ ភ្ញៀវទេសចរនៅសល់តិចតួច តែមិនមែនអត់នោះទេ ហើយបញ្ហាអាចនឹងកើតមានឡើង សូម្បីតែភ្ញៀវទេសចរម្នាក់ឬពីរនាក់ បើយើងមើលមិនដិតដល់ទេនោះ។

ក្រៅពីភារកិច្ចរបស់ខ្លួនជាមួយភ្ញៀវទេសចរ ភ្នាក់ងារក៏បានចូលរួមយ៉ាងសកម្មក្នុងការងារផ្សេងៗជាមួយផ្នែកពាក់ព័ន្ធដទៃទៀតក្នុងតំបន់អង្គរ ដូចជា ការចូលរួមសម្អាតបរិស្ថាន ការតាមដានស្ថានភាពហានិភ័យនៃថ្មប្រាសាទ និងកិច្ចការអភិរក្ស ជួសជុលប្រាសាទជាដើម។

សកម្មភាពជាប្រចាំនេះហើយ ដែលធ្វើឱ្យរមណីយដ្ឋានអង្គរនៅតែរក្សាបាននូវភាពស្អាត គង់វង្សយូរអង្វែង។ ជាពិសេសតាមរយៈការស្តារហេដ្ឋារចនាសម្ពន្ធ និងការរៀបចំស្មួនជាដើម កាន់តែបន្ថែមសម្រស់ដល់រមណីយដ្ឋានអង្គរ។ នេះជាការទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត ក្រោយស្ថានភាពកូវីដ_១៩បានធូរស្បើយ៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ មកលើរចនាសម្ពន្ធខ្លោងទ្វារតាកាវនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា រួមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យនិងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើហានិភ័យខ្ពស់មកលើរចនាសម្ពន្ធខ្លោងទ្វារតាកាវនៃក្រុងអង្គរធំ។ ការងារនេះធ្វើឡើង ដើម្បីធានាសុវត្ថិភាពអ្នកដំណើរដែលឆ្លងកាត់ទីនោះ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទកាន់តែធ្ងន់ធ្ងរ ដែលការងារនេះនឹងជួយសម្រួលដល់កិច្ចការអភិរក្ស និងជួសជុលខ្លោងទ្វារតាកាវ ដែលគ្រោងនឹងអនុវត្តក្នុងពេលឆាប់ៗនេះ។

ដើមឈើដែលបាន និងកំពុងកាត់ដកហូតចេញមានចំនួន ៨ដើមរួមមាន ដើមចាន់៣ដើម ដើមយាង១ដើម ស្វាយ ២ដើម អង្កោល១ដើម និងស្លែង១ដើម ដែលស្ថានភាពដើមឈើទាំងនោះ ដុះទ្រេតនៅលើខឿនថ្មបាយក្រៀម មានជំងឺ និងប្រព័ន្ធឫសខ្សោយចាក់ចូលក្នុងរចនាសម្ព័ន្ធខ្លោងទ្វារ។ ចំណែកឯដើមឈើដែលកំពុងកាត់ក្រីមែកមានចំនួន ៤ដើមរួមមាន ដើមចាន់៣ដើម និងស្លែង១ដើម ដុះទ្រេតលើកំពែង ដែលត្រូវកាត់ក្រីចំនួន៩មែកចេញ ដើម្បីសម្រាលតួដើមឈើទាំងនោះ និងជួយសម្រួលដល់ការងារជួសជុលឲ្យបានលឿនផង៕

សប្បុរសជនរួមគ្នាស្តារពើកនៅក្នុងកសិន្ធុក្រុងអង្គរធំដើម្បីលើកតម្លៃ និងជាប្រយោជន៍ដល់កិច្ចការអភិរក្ស

ផ្សាយនៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២១

កុម្ភៈ ឆ្នាំ២០២១កន្លងមក ក្រោមអធិបតីភាព **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដោយមើលឃើញពីស្ថានភាពក្រាស់ឃ្មឹកនៃពើកដុះក្នុងកសិន្ធុអង្គរធំ លោកជំទាវកិត្តិសង្គហបណ្ឌិតនិង**លោកជំទាវឧកញ៉ា នាងទិសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ បានបរិច្ចាគថវិកាផ្ទាល់ខ្លួន និងគៀងគរសប្បុរសជននានាដើម្បីរួមចំណែកស្តារពើកនៅក្នុងកសិន្ធុអង្គរធំ ទុកជាប្រយោជន៍ដល់កិច្ចការអភិរក្ស។

ក្នុងឱកាសនោះនិងជាបន្តបន្ទាប់មកទៀត ក៏មានការចូលរួមបរិច្ចាគបន្ថែមពីសម្តេចព្រះសង្ឃរាជ ព្រះគ្រូចៅអធិការវត្ត ឯកឧត្តម លោកជំទាវ និងសប្បុរសជនជាច្រើនអង្គ/នាក់បានចូលរួមយ៉ាងផុសផុល។

ដំណើរការស្តារពើកនេះ នឹងចាប់ផ្តើមឡើងនាពេលឆាប់ៗខាងមុខ។ អាជ្ញាធរជាតិអប្សរាក៏សូមថ្លែងអំណរគុណព្រះគុណនិងអរគុណចំពោះសម្តេចព្រះសង្ឃរាជ ព្រះចៅអធិការវត្តគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ និងសប្បុរសជនទាំងអស់ដែលបានគិតគូរលះបង់ធនធានខ្លួនដោយសេចក្តីរីករាយ ជ្រះថ្លា ដើម្បីរួមចំណែកស្តារពើកក្នុងកសិន្ធុអង្គរធំជាមួយអាជ្ញាធរជាតិអប្សរា ក្នុងការលើកតម្លៃនិងជាប្រយោជន៍ដល់កិច្ចការអភិរក្សផង ពិសេស គឺសម្រួលចរន្តទឹកក្នុងកសិន្ធុអង្គរធំបានល្អប្រសើរ៕

សកម្មភាពសម្អាតជាប្រចាំរបស់ក្រុមការងារអនាម័យក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២១

ក្រុមការងារសម្អាតអនាម័យក្នុងតំបន់រមណីយដ្ឋានអង្គរ តែងធ្វើសកម្មភាពជាប្រចាំ ក្នុងន័យដើម្បីថែរក្សាសោភណ្ឌភាព បរិស្ថាន អនាម័យក្នុងតំបន់អង្គរឱ្យកាន់តែមានភាពស្រស់ស្អាត ស័ក្តិសមជាបេតិកភណ្ឌរបស់មនុស្សជាតិ។

កិច្ចការងារទាំងនោះរាប់ទាំងការសម្អាតក្នុងបរិវេណប្រាសាទ លើកគោក និងក្នុងទឹក៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិតាឯក ឃុំរុនតាឯក ស្រុកបន្ទាយស្រី។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ដាំដើមឈើនៅខាងជើងខ្លោងទ្វារដីឆ្នាំង

ផ្សាយនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១

នៅថ្ងៃទី១៧ខែមីនាឆ្នាំ២០២១ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរាបានសហការចូលរួមដាំកូនឈើជាមួយអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់រមណីយដ្ឋានអង្គរ ស្ថិតនៅចំណុចប៉ុស្តិ៍ការពារខ្លោងទ្វារដីឆ្នាំង ខាងស្តាំដៃផ្លូវបំបែកទៅអង្គរក្រៅ។

កូនឈើទាំងនោះត្រូវបានដាំឡើងវិញដើម្បីបំពេញចន្លោះព្រៃឈើនៅតាមដងផ្លូវ និងចូលរួមចំណែកក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាបណ្តុះកូនឈើ និងដាំកូនឈើជាច្រើនម៉ឺនរៀងរាល់ឆ្នាំ។ ក្រៅពីនោះ ក៏បានចែកជូនដល់ប្រជាពលរដ្ឋ ព្រះសង្ឃ រួមទាំងស្ថាប័នផ្សេងៗក្នុង និងក្រៅខេត្តសៀមរាបសម្រាប់ដាំដើម្បីបង្កើនគម្របឈើ៕

អាជ្ញាធរជាតិអប្សរាជួសជុលថែទាំស្ពានបណ្ដែតទឹកនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១

នាយកដ្ឋានទ្រទ្រង់បច្ចេកទេសនិងគម្រោងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរា ជួសជុលថែទាំស្ពានបណ្ដែតទឹកនៅកសិន្ធុមុខប្រាសាទអង្គរវត្ត ដើម្បីលើកកម្ពស់សោភ័ណភាព ធានាសុវត្ថិភាព និងសម្រួលដល់ការធ្វើដំណើរចូលទស្សនាទៅកាន់ប្រាសាទអង្គរវត្តរបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។

ក្នុងកិច្ចការជួសជុល ក្រុមការងារបានផ្លាស់ប្ដូរពោងបណ្ដែតដែលបានខូច ពោងសង្គ្រោះបន្ទាន់ លាបថ្នាំការពារ ផ្លាស់ប្ដូរស្លាកសញ្ញា និងបង្កាន់ដៃជាដើម៕

អាជ្ញាធរជាតិអប្សរា កំពុងដកហូតដើមឈើមានហានិភ័យខ្ពស់ចំនួន៤ដើម នៅប្រាសាទក្រោលរមាស លើភ្នំគូលែន

ផ្សាយនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា រួមជាមួយផ្នែកពាក់ព័ន្ធ បានចុះពិនិត្យ និងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើចំនួន៤ដើមបន្ថែមទៀតដែលបង្កហានិភ័យខ្ពស់មកលើរចនាសម្ពន្ធប្រាសាទក្រោលរមាស លើភ្នំគូលែន។ ការងារនេះធ្វើឡើងដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ និងប្រជាពលរដ្ឋ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទនេះកាន់តែធ្ងន់ធ្ងរ។

ដើមឈើដែលកំពុងកាត់ដកហូតរួមមាន ដើមសំបួរ៣ដើម និងដើមអាទិត្យ១ដើម ដែលស្ថានភាពដើមឈើទាំងនោះដុះទ្រេតជាប់រចនាសម្ពន្ធប្រាសាទ មានប្រព័ន្ធឫស និងតួដើមមិនរឹងមាំ៕

មកទស្សនាអង្គរ កុំភ្លេចគោរពក្រមប្រតិបត្តិអង្គរ និងអនុវត្តតាមការណែនាំ របស់ក្រសួងសុខាភិបាល

ផ្សាយនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១

ចាប់តាំងសតវត្សរ៍ទី៩ដល់សតវត្សរ៍ទី១៥ អង្គរ គឺជាអតីតរាជធានីខ្មែរដ៏ល្បីល្បាញ ដែលត្រូវគេប្រសិទ្ធនាមឈ្មោះថា អាណាចក្រខ្មែរ។ មកដល់បច្ចុប្បន្ននេះ អង្គរ មិនត្រឹមតែជាបូជនីយដ្ឋានសម្រាប់ពុទ្ធសាសនិក និងប្រជាពលរដ្ឋខ្មែរទូទៅគោរពបូជា សំពះបន់ស្រន់បួងសួងប៉ុណ្ណោះទេ ថែមទាំងជាសម្បត្តិវប្បធម៌ដ៏ល្អឯករបស់មនុស្សជាតិក្នុងពិភពលោកទាំងមូលទៀតផង។

អាជ្ញាធរជាតិអប្សរា ដែលជាស្ថាប័នទទួលខុសត្រូវក្នុងការអភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានអង្គរ បានសហការជាមួយអ្នកស្រុកអង្គរ ភ្ញៀវទេសចរ មគ្គុទ្ទេសក៍ទេសចរណ៍ និងក្រុមការងារជួសជុលប្រាសាទជាដើម បានបង្កើតក្រមមួយឈ្មោះថា ក្រមប្រតិបត្តិអង្គរ ដើម្បីឱ្យភ្ញៀវទេសចរមកទស្សនារមណីយដ្ឋានអង្គរអនុវត្តតាម ក្នុងគោលដៅធ្វើយ៉ាងណាធានាឱ្យបាននូវសុវត្ថិភាព ក៏ដូចជាបទពិសោធន៍ល្អៗ ការគោរពលើកតម្លៃ និងរបៀបរៀបរយសម្រាប់តំបន់មណីយដ្ឋានអង្គរ។ ឯខ្លឹមសារសំខាន់ៗនៃក្រមប្រតិបត្តិនោះរួមមាន៖ ហាមស្លៀកខើចលើខើចក្រោម ហាមប៉ះក្បាច់ចម្លាក់ឬអង្គុយលើថ្មទ្រុឌទ្រោម ហាមស្រែកឡូឡា ហាមឡើងលើគំនរថ្ម ត្រូវគោរពស្លាកសញ្ញា ហាមដក់បារី និង ចោលសំរាមជាដើម។

ដោយឡែកស្ថិតនៅក្នុងដំណាក់កាល ដែលមេរោគកូវីដ១៩កំពុងរីករាលដាលយ៉ាងខ្លាំងនេះ អាជ្ញាធរជាតិអប្សរា សូម

អំពាវនាវចំពោះភ្ញៀវទេសចរជាតិ និងអន្តរជាតិទាំងអស់ដែលមកទស្សនាតំបន់រមណីយដ្ឋានអង្គរ ត្រូវគោរពក្រមប្រតិបត្តិអង្គរផង អនុវត្តន៍តាមណែនាំរបស់ក្រសួងសុខាភិបាលផងដូចជាពាក់ម៉ាស់រក្សាគម្លាត ឧស្សាហ៍លាងសម្អាតដៃ និងមិនត្រូវជួបជុំមនុស្សច្រើន ឬចូលរួមក្នុងទីកន្លែងងងឹត ចង្អៀតជាដើម...។ល។

ដូចនេះ ការគោរពក្រមប្រតិបត្តិអង្គរផងនិងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលផង គឺជាការជួយខ្លួនឯងឱ្យមានសុវត្ថិភាព ក៏ដូចជារួមចំណែកក្នុងការអភិរក្ស និងលើកតម្លៃតំបន់រមណីយដ្ឋានអង្គរផង៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិថ្នល់ទទឹង ភូមិថ្នល់បណ្តោយ ឃុំរុនព្រះដាក់។ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន១៧សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

រួមគ្នាដាំកូនឈើដើម្បីអភិរក្សប្រាសាទ និងបង្កើនគម្របបៃតងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ក្រុមភ្នាក់ងារសណ្ដាប់ធ្នាប់ប្រចាំការតាមប្រាសាទ និងអង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អង្គរ បានរួមគ្នាដាំកូនឈើស្ថិតនៅគោលដៅការពារខាងកើតខ្លោងទ្វារជ័យ។

កូនឈើដែលយកមកដាំនៅទីតាំងនេះ ជាប្រភេទឈើប្រណីតរួមមាន អង្កាញ់៧៥ដើម និងឈើទាល៧៥ដើម សរុបចំនួន១៥០ដើម។

ការដាំដើមឈើ គឺដើម្បីរួមគ្នាថែរក្សាទេសភាពវប្បធម៌ បង្កើតគម្របបៃតងដល់បរិស្ថាននៅក្នុងតំបន់អង្គរ បង្កើនជម្រកសត្វព្រៃ និងជួយដល់ការអភិរក្សប្រាសាទផង។ កូនឈើទាំងនោះត្រូវបានដាំឡើងវិញដើម្បីបំពេញចន្លោះព្រៃឈើនៅតាមដងផ្លូវ និងចូលរួមចំណែកក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាបណ្ដុះកូនឈើ និងដាំកូនឈើជាច្រើនម៉ឺនរៀងរាល់ឆ្នាំ។ ក្រៅពីនោះ ក៏បានចែកជូនដល់ប្រជាពលរដ្ឋ ព្រះសង្ឃ រួមទាំងស្ថាប័នផ្សេងៗក្នុង និងក្រៅខេត្តសៀមរាបសម្រាប់ដាំដើម្បីបង្កើនភាពបៃតងនៃបរិស្ថានបានកាន់តែច្រើនបន្ថែមទៀត៕

សកម្មភាពកាត់ក្រី និងដកហូតដើមឈើហានិភ័យខ្ពស់នៅភ្នំបាខែង

ផ្សាយនៅថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២១



ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន រួមមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យ និងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើចំនួន២៥ដើមដែលមានហានិភ័យខ្ពស់ ដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្កលក្ខណៈងាយស្រួលសម្រាប់ការទស្សនាទេសភាពជុំវិញភ្នំបាខែង។

ដើមឈើងាប់ដែលបានកាត់ដកហូតរួមមាន ដើមបំពីងរាជ១ដើម ផ្ទៀវ១ដើម ព្រីង១០០ស្រទាប់១ដើម ល្វៀង៣ដើម រកា១ដើម ចំបក់១ដើម សិរមាន់១ដើម ជន្លូស២ដើម ក្រឡាញ់១ដើម និងឈើទាល១ដើម ដែលស្ថានភាពដើមឈើងាប់ទាំងនោះ ជុះជាប់ផ្លូវដើរឡើងលើភ្នំ និងជុះក្បែរប្រាសាទ។ ចំណែកឯដើមឈើដែលបានកាត់ក្រីមែករួមមាន ដើមល្វៀង៦ដើម ស្ពួល៣ដើម ក្រឡាញ់១ដើម និងដើមយាង២ដើម មានមែកសាខាច្រើន ជុះបាំងទេសភាពសម្រាប់ការទស្សនាពីលើភ្នំបាខែងទៅបារាយណ៍ខាងលិច និងទៅប្រាសាទអង្គរវត្ត៕

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈ បច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន ៤៦២គ្រួសារ

ផ្សាយនៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២១

នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងអំឡុងខែមីនា ឆ្នាំ២០២១ ក្រុមការងារបានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាននិងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យាន និងក្រៅឧទ្យានអង្គរបានចំនួន ៤៦២គ្រួសារ។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរចំនួន ៤៤៧ គ្រួសារ៖ ក្រុងសៀមរាប ១១៨គ្រួសារ ស្រុកប្រាសាទបាគង ១០០គ្រួសារ ស្រុកបន្ទាយស្រី ១០០គ្រួសារ ស្រុកពួក ៥២ គ្រួសារ និងស្រុកអង្គរធំ ៧៧គ្រួសារ។

ចំណែកប្រជាពលរដ្ឋរស់នៅក្រៅឧទ្យានអង្គរចំនួន១៥ គ្រួសារ៖ គឺនៅក្រុងសៀមរាប ០៤គ្រួសារ ស្រុកសូទ្រនិគម ០៣គ្រួសារ ស្រុកប្រាសាទបាគង ០១ គ្រួសារនិងស្រុកស្វាយលើ ០៧គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាតនិងដាក់ពាក្យសាងសង់ស្នើសុំគឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

ស្រះស្រង់អាចនឹងរីងស្ងួតនាចុងរដូវប្រាំងឆ្នាំនេះ

ផ្សាយនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២១

នាចុងរដូវប្រាំងខាងមុខនេះ ស្រះស្រង់អាចនឹងរីងស្ងួត ព្រោះកន្លងមកនេះពុំមានការបញ្ចូលទឹកក្នុងស្រះស្រង់ដោយមូលហេតុទុកលទ្ធភាពគ្រប់គ្រាន់ឲ្យអ្នកជំនាញធ្វើការជួសជុល និងលើកតម្លៃឡើងវិញនៅប្រាសាទកណ្តាលស្រះស្រង់។

អ្នកជំនាញលើការគ្រប់គ្រងទឹកបានបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាមិនបានបង្ហូរទឹកចូលបន្ថែមក្នុងស្រះស្រង់ទេ ខណៈដែលក្រុមអ្នកជួសជុលប្រាសាទ ប្រញាប់ប្រួសរាន់ក្នុងការបង្ហើយការងារជួសជុលប្រាសាទស្រះស្រង់ឲ្យទាន់ពេលវេលា។

ស្ថានភាពបច្ចុប្បន្ន គិតត្រឹមថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១នេះ កម្រិតបរិមាណទឹកក្នុងស្រះស្រង់ ស្ថិតក្នុងកម្រិតទាបបំផុត ហើយកំដៅថ្ងៃនឹងបន្តហួតទឹកដែលនៅសេសសល់បន្តិចបន្តួចនេះ យ៉ាងឆាប់រហ័យបំផុត បើគិតតាមរយៈអាកាសធាតុសព្វថ្ងៃ៕

អាជ្ញាធរជាតិអប្សរាកម្ចាត់សត្វកណ្ដៀរ ដើម្បីការពារប្រាង្គប្រាសាទក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២១

ក្រៅពីអាកាសធាតុ អាយុកាលសំណង់ រុក្ខជាតិ សត្វកណ្ដៀរ ក៏ជាបញ្ហាមួយ ដែលបង្កហានិភ័យយ៉ាងខ្លាំងដល់ប្រាង្គប្រាសាទនិងបរិក្ខារមួយចំនួនទៀតធ្វើពីឈើសម្រាប់ប្រើប្រាស់ដូចជាជណ្ដើរ បង្កោលរបា ទ្រនល់ទល់ទ្រ និងរោងសម្រាប់បម្រើក្នុងកិច្ចការអភិរក្សនៅក្នុងឧទ្យានអង្គរដែរ។

លោកស្រី នេត ស៊ីមន មន្ត្រីអភិរក្សនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការបានឱ្យដឹងថា៖ នៅតាមប្រាង្គប្រាសាទសត្វកណ្ដៀរបានពូនដីធ្វើជាដំបូក ចំណែកដីគឺបានពាំចេញពីក្នុងគ្រឹះឬបរិវេណជុំវិញប្រាសាទ។ កត្តានេះយូរៗទៅធ្វើឱ្យមានរន្ធឬប្រហោងដោយសារអស់ដី។ ពេលរដូវភ្លៀង ទឹកក៏បានហូរចូលក្នុងរន្ធទាំងនោះ ដែលបណ្ដាលឱ្យគ្រឹះប្រាសាទស្រុត ហើយថ្មក៏ចាប់ផ្ដើមរលុះធ្លាក់និងឈានដល់ការបាក់រលំប្រាសាទតែម្ដង។

លើសពីនេះទៀត សត្វកណ្ដៀរបានបំផ្លាញសម្ភារមួយចំនួនដែលយើងបានប្រើប្រាស់នៅតាមប្រាសាទដូចជា៖ កម្រាលក្ដារជណ្ដើរទ្រនល់ទល់ទ្ររោងប្រើប្រាស់ធ្វើពីឈើជាដើម។

មិនតែប៉ុណ្ណោះ សត្វកណ្ដៀរបានស៊ីបំផ្លាញដើមឈើដែលភាគច្រើនដុះនៅតាមប្រាសាទមានអាយុច្រើន ដើមមួយចំនួនមានសភាពពុកផុយដោយសារតែសត្វកណ្ដៀរស៊ីបំផ្លាញ ក៏បណ្ដាលឱ្យបាក់រលំសង្កត់មកលើប្រាង្គប្រាសាទផងដែរ។

ជាការឆ្លើយតបចំពោះការបំផ្លាញពីសំណាក់សត្វកណ្ដៀរ នាយកដ្ឋានជំនាញបានណែនាំការងារដល់ភ្នាក់ងារទេសចរណ៍កំពុងបំពេញការងារតាមប្រាង្គប្រាសាទឱ្យយកចិត្តទុកដាក់ជួយថែទាំជាប្រចាំតាមរយៈការសម្អាតសម្ភារបរិក្ខារផ្សេងៗធ្វើពីឈើ ការកម្ចាត់សត្វកណ្ដៀរតាមរយៈការលាបថ្នាំ និងការតាមដានពីដំបូកនិងរន្ធផ្សេងៗទៀតដែលសត្វកណ្ដៀរកំពុងកពូនដើម្បីកាយចេញដាក់ថ្នាំកម្ចាត់ជាដើម៕

ក្រុមអ្នកជំនាញអភិរក្សថ្មរបស់អាជ្ញាធរជាតិអប្សរា កំពុងជួសជុលបង្កាន់ដៃនាគ នៅប្រាសាទបន្ទាយសំរ៉ែ

ផ្សាយនៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២១

ក្រុមអ្នកជំនាញអភិរក្សថ្ម របស់អាជ្ញាធរជាតិអប្សរា កំពុងមមាញឹកជួសជុលបង្កាន់ដៃនាគ នៅប្រាសាទបន្ទាយសំរ៉ែ។ សកម្មភាពទាំងនោះរួមមាន ការស្វានដាក់ស្នួលតភ្ជាប់បំណែក ដងខ្លួននាគ និងដាប់ថ្មថ្មីបំពេញកម្រាស់ជើងទម្របង្កាន់ដៃនាគជាដើម។

កិច្ចការងារនេះ ធ្វើឡើងដើម្បីលើកតម្លៃឡើងវិញនៅប្រាសាទ បន្ទាយសំរ៉ែ ក៏ដូចជាធ្វើឲ្យមាននិរន្តរភាពសម្រាប់ការអភិរក្សប្រាសាទខ្មែរ៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋ នៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០២១

សម្រាប់ខែមីនា ឆ្នាំ២០២១នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋបានចំនួន១២៩ គ្រួសារ រួមមាន៖ ក្រុងសៀមរាប ៣២គ្រួសារ ស្រុកបន្ទាយស្រី ២២ គ្រួសារ ស្រុកអង្គរធំ ១៣គ្រួសារ ស្រុកប្រាសាទបាគង ៣៨ គ្រួសារ ស្រុកពួក ១០គ្រួសារ ស្រុកសូទ្រនិគម ០៦គ្រួសារ និងស្រុកស្វាយលើ ០៨គ្រួសារ។

ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់បានចំនួន ៥០គ្រួសាររួមមាន៖ ស្រុកអង្គរធំ ០៦គ្រួសារ ក្រុងសៀមរាប ១០គ្រួសារ ស្រុកប្រាសាទបាគង ០៨គ្រួសារ ស្វាយលើ ០៤គ្រួសារ ស្រុកពួក ១១គ្រួសារ និងស្រុកបន្ទាយស្រី ១១ គ្រួសារ។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោល គឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ត្រីមាសទី១ ក្នុងឆ្នាំ២០២១ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៦១៦ករណី

ផ្សាយនៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២១

លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំត្រីមាសទី១ក្នុងឆ្នាំ២០២១ បានចុះផ្សព្វផ្សាយអប់រំនិងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសាងសង់តូចតាចទាំង៥គោលដៅស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរបានចំនួន៩៣៤សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន៦១៦សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន៧៩ករណី ស្រុកអង្គរធំបានចំនួន១៧៥ករណី ស្រុកពួកបានចំនួន៩៧ករណី ក្រុងសៀមរាបបានចំនួន១២០ករណី និងស្រុកបន្ទាយស្រីបានចំនួន១២៧ករណី រួមទាំងក្រុមការងារក្រៅឧទ្យានអង្គរចំនួន១៨សំណើ សរុបចំនួន៦១៦សំណើ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧបត្ថម្ភថវិកាដល់ចាស់ជរា កុមារមានជំងឺ ជនពិការ គ្រួសារខ្វះខាតមួយចំនួន ចូលរួមក្នុងកិច្ចការសាសនា និងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ ថែមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ខែមីនា ឆ្នាំ២០២១

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមេសា

អាជ្ញាធរជាតិអប្សរាចងរឹតកាបនៅលើរចនាសម្ព័ន្ធសំណង់ប្រាសាទបាយ័ន្តមួយចំនួន

ផ្សាយនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២១



ដោយហេតុថា នៅតាមថែវចម្លាក់ខាងក្រៅនៃប្រាសាទបាយ័ន្ត មានចំនុចហានិភ័យភាគច្រើនបណ្ដាលមកពីសសរធ្នឹមស៊ុមទ្វារជញ្ជាំងថ្មដំបូល។ល។ដែលអាចនឹងរអិលធ្លាក់បាក់បែក ឬដួលរលំ។ ហេតុនេះទើបឱ្យក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ធ្វើការទប់ស្កាត់ជាបន្ទាន់ដោយអនុវត្តន៍និតិវិធីពង្រឹងឱ្យមានលំនឹងតាមរយៈការចងរឹតកាបនិងរំកិលថ្មចូលទីតាំងដើមវិញ។

គោលបំណងនៃការចងរឹតកាបនេះ គឺទប់ស្កាត់កុំឱ្យរចនាសម្ព័ន្ធប្រាសាទមួយចំនួនត្រូវបានដួលរលំ និងដើម្បីរក្សាទ្រង់ទ្រាយដើមរបស់ប្រាសាទឱ្យនៅគង់វង្សបានយូរអង្វែង ហើយត្រូវរង់ចាំឱកាសសមស្រប ដើម្បីធ្វើការជួសជុលឡើងវិញ។ ការចងរឹតកាបស្ថិតនៅថែវខាងជើង ត្បូង និងលិច។

ការងារអនុវត្តន៍គម្រោងចងរឹតកាបនេះបានចាប់ផ្ដើមតាំងពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ហើយរហូតមកទល់នឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ នេះបានសម្រេចលទ្ធផលចំនួន ២០ចំណុចហើយ៕

អាជ្ញាធរជាតិអប្សរា បន្តដាំដើមឈើបង្កើនគម្របបៃតងដល់ក្នុងតំបន់រមណីយដ្ឋានអង្គរ និងអភិរក្សប្រាសាទ

ផ្សាយនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២១

ថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ប្រចាំការតាមប្រាសាទនៃអាជ្ញាធរជាតិអប្សរា ដាំកូនឈើនៅចំណុចខាងលិចផ្លូវត្រពាំងសេស។ កូនឈើទាំងនោះត្រូវបានដាំឡើងវិញបំពេញចន្លោះព្រៃឈើនៅតាមដងផ្លូវ ដើម្បីបង្កើនសោភ័ណភាព និងរក្សាបាននូវសណ្តាប់ធ្នាប់កាន់តែល្អប្រសើរ។ ជាពិសេស បង្កើតគម្របបៃតងដល់បរិស្ថាននៅក្នុងតំបន់អង្គរ និងជួយដល់ការអភិរក្សប្រាសាទ។

សូមបញ្ជាក់ថា អាជ្ញាធរជាតិអប្សរាបន្តបណ្តុះកូនឈើ និងដាំកូនឈើជាច្រើនម៉ឺនដើមរៀងរាល់ឆ្នាំ។ ម្យ៉ាងទៀតអាជ្ញាធរជាតិអប្សរាចែកជូនដល់ប្រជាពលរដ្ឋ ព្រះសង្ឃ រួមទាំងស្ថាប័នផ្សេងៗក្នុងនិងក្រៅខេត្តសៀមរាបដោយឥតគិតថ្លៃសម្រាប់ដាំដើម្បីបង្កើនភាពបៃតងនៃបរិស្ថាន។

សម្រាប់បងប្អូនដែលមានបំណងចង់ដាំកូនឈើឬត្រូវការកូនឈើយកទៅដាំនោះ សូមទំនាក់ទំនងមកអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរារៀបចំពិធីប្រុងពាលីជួសជុលប្រាសាទផ្ទី

ផ្សាយនៅថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា រួមមាន **ឯកឧត្តម តឹម សុផិន ឯកឧត្តម ឡុង ក្ដុសល** អគ្គនាយករង ព្រមទាំងមន្ត្រី-បុគ្គលិក ពលករ នៃអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីប្រុងពាលីបែបសាសនា ដើម្បីជួសជុលប្រាសាទផ្ទីដែលស្ថិតនៅកណ្ដាលបារាយណ៍ប្រាសាទបេងមាលា។

ពិធីសាសនាមួយត្រូវបានរៀបចំឡើងនៅព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ នៅបរិវេណការដ្ឋានកំណាយប្រាសាទផ្ទី ក្នុងបំណងសុំម្ចាស់ទឹកម្ចាស់ដី ដើម្បីរៀបចំដំណើរការការដ្ឋានជួសជុលប្រាសាទ។ ក្នុងពិធីនេះ ក៏មានការចូលរួមពីមន្ត្រីបុគ្គលិក និងពលករនៃអាជ្ញាធរជាតិអប្សរា ដែលត្រៀមការងារជួសជុល និងលើកតម្លៃប្រាសាទនេះឲ្យល្អប្រសើរឡើងវិញផងដែរ។

គួរបញ្ជាក់ថាអាជ្ញាធរជាតិអប្សរាបានចាប់ផ្ដើមធ្វើកំណាយស្រាវជ្រាវ សិក្សានៅប្រាសាទផ្ទីឡើងវិញនៅដើមខែ មីនា ដើម្បីលម្អិតពីរចនាសម្ពន្ធប្រាសាទនេះក្រោយសប្បុរសជនមួយរូប គឺលោកជំទាវហេមចិន្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ ម៉ៅ ម៉ាល័យ កែ គឹមយាន បានប្រកាសពីកិច្ចសហការឧបត្ថម្ភដើម្បីជួសជុលប្រាសាទនេះឡើងវិញ៕

អាជ្ញាធរជាតិអប្សរាបន្តកិច្ចការជួសជុល និងថែទាំស្លាកសញ្ញាផ្សេងៗក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២១

ក្នុងគោលបំណងលើកកម្ពស់សេវាកម្មទេសចរណ៍ ក៏ដូចជាការយកចិត្តទុកដាក់ថែទាំសម្ភារបរិក្ខានៅក្នុងតំបន់អង្គរ អាជ្ញាធរជាតិអប្សរាតែងយកចិត្តទុកដាក់ថែទាំជួសជុលគ្រប់សម្ភារបរិក្ខារប្រើប្រាស់ទាំងអស់ សំដៅធ្វើយ៉ាងណាឱ្យរមណីយដ្ឋានអង្គរកាន់តែមានសោភ័ណភាពនិងរបៀបរៀបរយល្អជានិច្ច។

ជាក់ស្តែងនាពីថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ ក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍(TSC) បានមកសម្អាត លាបថ្នាំកណ្តៀរ និងជួសជុលសម្ភារបរិក្ខារប្រើប្រាស់មួយចំនួនដូចជា ផ្ទាំងប៉ាណូព័ត៌មាន និងរនាំងឈើជាដើម នៅបរិវេណប្រាសាទតានៃ ដើម្បីឱ្យសម្ភារទាំងអស់នោះរឹងមាំគង់វង្សបានយូរ ក៏ដូចជាដើម្បីថែរក្សាសុវត្ថិភាពភ្ញៀវទេសចរដែលមកទស្សនាប្រាសាទផង៕

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០២ ខែមេសា ឆ្នាំ២០២១

នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួន បានចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ។ ការចុះពិនិត្យនៅពេលនោះរួមមាន ការដ្ឋានកំណាយស្រាវជ្រាវបុរាណវិទ្យានៅមុខព្រះលានជល់ដំរីមុននឹងដំណើរការរៀបចំហេដ្ឋារចនាសម្ពន្ធផ្លូវថ្មើជើង សួនស្មៅ ដាំដើមឈើ។

ការដ្ឋានជួសជុលប្រាសាទបាយ័ន្ត និងគម្រោងកែលម្អត្រពាំងសេស ព្រមទាំងការដ្ឋានជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ក្នុងន័យអភិរក្ស និងលើក តម្លៃប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

ព្រះសិរព្រះនារាយណ៍ធ្វើពីថ្មភក់មួយបំណែករកឃើញនៅប្រាសាទត្រពាំងផុង

ផ្សាយនៅថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០២១

ព្រះសិរព្រះនារាយណ៍មួយបំណែកខាងស្តាំត្រូវបានក្រុមការងារជួសជុលប្រាសាទត្រពាំងផុងប្រទះឃើញនៅខាងក្នុងតួប៉មកណ្តាលនៃប្រាសាទនេះ។

បំណែកព្រះសិរធ្វើពីថ្មភក់ដែលមានកម្ពស់៣៨ស.ម ទទឹង ២០ស.មនិងកម្រាស់១៨ស.មនេះមានព្រះភក្ត្រមួយចំហៀងខាងស្តាំដែលនៅលើព្រះភក្ត្រនោះមានសល់ទ្រនុងចិញ្ចើម ព្រះនេត្រ ចុងច្រមុះ បបូរមាត់បន្តិច និងស្លឹកត្រចៀកមួយចំហៀង។ រីឯនៅផ្នែកខាងលើ មានម្កុដរាងស៊ីឡាំងដែលគ្របត្រឹមថ្ងាសទៅតាមជើងសក់នៅជុំវិញពីផ្នែកខាងមុខដល់ខាងក្រោយ។

លោក ឈូក សុម៉ាឡា មន្ត្រីក្រុមចុះបញ្ជីវត្ថុសិល្បៈនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអជ្ញាធរជាតិអប្សរាបានឱ្យដឹងថា បំណែកព្រះសិរនៃបដិមានេះនៅសល់ផ្នែកខ្លះដែលអាចឱ្យយើងធ្វើការកំណត់សម្គាល់បានថាជាព្រះសិររបស់បដិមាព្រះនារាយណ៍ ពោលគឺពុំមែនជាព្រះសិវៈ រឺព្រះហរិហរៈឡើយ។

លោកបានបន្ថែមទៀតថា បើតាមលោកយល់ បដិមានេះទំនងជាស្ថិតក្នុងរចនាបថគូលែន ដោយព្រះភក្ត្រនៃបដិមារាងធំខ្លី ចិញ្ចើមដាច់មិនជាប់គ្នាទេ រីឯលក្ខណៈសម្គាល់ពិសេសជាងនេះទៅទៀតគឺ ម្កុដរាងជាស៊ីឡាំងខ្ពស់ទៅលើដែលនេះហើយជាលក្ខណៈនៃបដិមាសាស្ត្រក្នុងរចនាបថគូលែន។

ម្យ៉ាងវិញទៀត បើយើងគិតទៅលើសំណង់ប្រាសាទត្រពាំងផុងនោះទៀតសោត ក៏មានអ្នកស្រាវជ្រាវបានអះអាងរួចមកហើយថា ប្រាសាទនេះគឺមានរចនាបថគូលែន ដែលសង់ឡើងនៅពាក់កណ្តាលសតវត្សទី៩ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៣ (៨៥០?-៨៧៧) ដែលត្រូវជាបុត្ររបស់មហាក្សត្រដ៏ល្បីមួយអង្គគឺព្រះបាទ ជ័យវរ្ម័នទី២ (៨០២-៨៥០?)។ បើដូច្នេះមែន នោះគឺគ្មានអ្វីចម្លែកទេ ពោលគឺបំណែកបដិមាដែលបានរកឃើញនេះគឺប្រហែលជាបដិមាដើម ដែលបានសាងសង់ក្នុងពេលដំណាលគ្នាជាមួយប្រាសាទត្រពាំងផុងនោះតែម្តងមានន័យថាពុំមែនជាបដិមាដែលយកមកតម្កល់នាសម័យក្រោយៗមកទៀតនោះទេ។

ក្រោយពីធ្វើកំណត់ហេតុប្រគល់ទទួលបំណែកចម្លាក់ខាងលើ ដោយមានស្ថាបន័នគរបាលការពារបេតិកភណ្ឌ ព្រមទាំងភ្នាក់ងារទេសចរណ៍រួចមក បំណែកចម្លាក់នោះបានដឹកយកទៅរក្សាទុកជាបណ្តោះអាសន្ននៅមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា ដើម្បីធ្វើការចុះបញ្ជីទុកជាឯកសារផង និងបន្តស្វែងរកទិន្នន័យបំណែកផ្សេងៗទៀតផង ក្រែងលោមាន និងធ្វើការជួសជុលនៅថ្ងៃខាងមុខ៕

អាជ្ញាធរជាតិអប្សរាកំពុងធ្វើកំណាយសិក្សាពីលទ្ធភាពស្តារនិងលើកតម្លៃត្រពាំងសេសឡើងវិញ

ផ្សាយនៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២១

ត្រពាំងសេស ដែលស្ថិតនៅបរិវេណមុខប្រាសាទអង្គរវត្ត បានចាប់ផ្តើមប្រែរូបរាងបន្តិចៗម្តង ក្រោយពេលដែលអាជ្ញាធរជាតិអប្សរា សម្របសម្រួលឲ្យមានការផ្លាស់ទីតូបលក់ដូរ ចេញពីបរិវេណត្រពាំងនេះ នៅចុងឆ្នាំ២០២០។

បច្ចុប្បន្ននេះ គម្រោងអភិវឌ្ឍន៍ និងកែលម្អត្រពាំងសេស កំពុងដំណើរការ ហើយអ្នកបុរាណវិទ្យាកំពុងធ្វើកំណាយស្រាវជ្រាវ ដើម្បីសិក្សាពីលទ្ធភាពបន្ថែមទៀតក្នុងការស្តារ និងលើកតម្លៃត្រពាំងបុរាណនេះឡើងវិញ។

លោក ធឿន សុខុន មន្ត្រីបុរាណវិទ្យានៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ឲ្យដឹងថា ក្រុមការងារកំណាយរបស់លោក បានរកឃើញសណ្ឋាននៃទំនប់ត្រពាំងសេស ដូចជាមានស្រទាប់ច្រើនថ្នាក់ដែលរៀបចំក្នុងរចនាសម្ពន្ធរបស់ទំនប់។ ក្រុមការងាររបស់ លោក សុខុន បានបើករណ្តៅកំណាយចំនួន១១ទីតាំង និងបានប្រទះឃើញកុលាលភាជន៍មួយចំនួន ក៏ដូចជាបានឃើញនូវរចនាសម្ពន្ធទំនប់ជុំវិញត្រពាំងកាន់តែច្បាស់។ លោករៀបរាប់ថា ទំនប់នេះត្រូវបានគេលើកដីព័ទ្ធជុំវិញ បន្ទាប់មកយកដីឥដ្ឋចេញ រួចចាក់ដីខ្សាច់លាយគ្រួសបាយក្រៀម បន្ទាប់មកប្រើដីឥដ្ឋជាស្នូលដើម្បីឲ្យទំនប់នៅយូរអង្វែងហើយ ក្រោយមកទៀតប្រើខ្សាច់មួយស្រទាប់និងបុកបង្ហាប់ដោយប្រើកម្ទេចកថ្មបាយក្រៀមលាយដីឥដ្ឋ។

តាមការបញ្ជាក់របស់លោក ធឿន សុខុន អាជ្ញាធរជាតិអប្សរាមានគម្រោងស្តារត្រពាំងសេសឡើងវិញនាពេលឆាប់ៗខាងមុខនេះ ដើម្បីស្តុកទឹកបានច្រើនជាងពេលមុន ទុកជាប្រយោជន៍ទាំងការងារអភិរក្សប្រាសាទ និងប្រយោជន៍ប្រជាពលរដ្ឋជុំវិញតំបន់។

លោក ជូ រ៉ាឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌និងបរិស្ថាន និយាយថា ក្រុមការងាររបស់លោកកំពុងមមាញឹករៀបចំដាំស្មៅ និងដើមឈើជាបណ្តើរៗជុំវិញត្រពាំងសេសនេះ ដែលតាមគម្រោងគឺរៀបចំលើផ្ទៃដីសរុបជាង៣ម៉ឺនម៉ែត្រការ៉េ។ បច្ចុប្បន្ននេះ ការងារបានដំណើរការបានប្រមាណ៤០ភាគរយហើយ។

គម្រោងដែលចាប់ផ្តើមពីដើមខែ កុម្ភៈមកនេះ រៀងយឺតយ៉ាវបន្តិច ដ្បិតថាការងារនៅជុំវិញត្រពាំងសេសដែលជាអតីតតូបលក់ដូរ និងធ្លាប់មានរថយន្តបើកបរបណ្តាលឲ្យដីរឹង មានថ្មច្រើន ធ្វើឲ្យក្រុមការងាររៀបចំសួនត្រូវប្រើពេលយូរ និងលំបាកក្នុងការធ្វើដី។ លោក ជូ រ៉ាឌីណា បន្ថែមថា មួយវិញទៀតបរិវេណត្រពាំងសេសជាបុរាណដ្ឋាន ដែលត្រូវធ្វើកំណាយសិក្សាជាមុន ទើបអាចរៀបចំអ្វីផ្សេងៗបាន ដូច្នេះក្រុមការងាររបស់លោកនឹងពន្លឿនការងាររៀបចំសួន ក្រោយពេលក្រុមបុរាណវិទូសិក្សារួច។

គួរបន្ថែមថា ក្នុងផែនការការងារឆ្នាំ២០២១នេះ ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ គ្រោងរៀបចំនិងកែលម្អបរិស្ថាននៅតំបន់មួយចំនួនទៀតក្នុងតំបន់រមណីយដ្ឋានអង្គរ ដែលក្នុងនោះរួមមាន នៅប្រាសាទអង្គរវត្ត ប្រាសាទព្រហ្មកិលច្រកសំពៅលូនប្រាសាទព្រះខ័នប្រាសាទបន្ទាយក្តី ប្រាសាទបាគង និងទីតាំងមួយចំនួនទៀត ក្នុងន័យលើកតម្លៃបរិស្ថាន សោភ័ណភាពក្នុងតំបន់ប្រាសាទឲ្យកាន់តែល្អប្រសើរ៕

អាជ្ញាធរជាតិអប្សរាបង្កើនសកម្មភាពថែទាំ និងសម្អាតបរិស្ថានតាមទីតាំងប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១

ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ ការទស្សនាប្រាសាទក្នុងឧទ្យានអង្គរត្រូវបានបិទក្នុងគោលបំណងចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩។

ក្នុងកំលុងពេលដែលគ្មានភ្ញៀវទេសចរនេះគឺជាឱកាសល្អសម្រាប់អាជ្ញាធរជាតិអប្សរាបង្កើនសកម្មភាពថែទាំ និងសម្អាតតាមទីតាំងប្រាសាទផ្សេងៗក្នុងរមណីយដ្ឋានអង្គរ។

ជាក់ស្តែងនៅព្រឹកថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ នេះ មន្ត្រីបុគ្គលិកដែលប្រចាំការនៅតាមប្រាសាទរួមមាន ភ្នាក់ងារទេសចរណ៍ និងភ្នាក់ងារសណ្តាប់ធ្នាប់បានរួមគ្នាសម្អាតតាមទីតាំងផ្សេងៗជាច្រើនក្នុងរមណីយដ្ឋានអង្គរ។

សកម្មភាពការងារនេះនឹងបន្តរហូតក្នុងកំលុងពេលដែលរមណីយដ្ឋានអង្គរត្រូវបានបិទការទស្សនារហូតដល់ពេលបើកធម្មតាវិញ៕

អាជ្ញាធរជាតិអប្សរា គ្រោងចុះកាត់ក្រី និងដកហូតដើមឈើ មានហានិភ័យខ្ពស់ និងបាំងទេសភាពនៅប្រាសាទសួព្រ័ត្រ និងព្រលានជល់ដំរី

ផ្សាយនៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាព វប្បធម៌ និងបរិស្ថាន រួមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យ និងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើដែលកំពុងមានហានិភ័យខ្ពស់ និងបាំងទេសភាពនៅសួព្រ័ត្រ និងព្រលាន

ដល់ដំរី នាពេលឆាប់ៗខាងមុខនេះ។ ការងារនេះធ្វើឡើងដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទ ព្រមទាំងលើកតម្លៃទេសភាពនៅបរិវេណនោះផង។

ដើមឈើដែលនឹងត្រូវកាត់ក្រីរួមមាន ដើមសង្កែ៣ដើម ស្នាយ៤ដើម ចាមរី៩ដើម ដើមយាង (ឈើទាល) ១៧ដើម ល្ហ៤ដើម ត្នោត១ដើម ថ្កូវ១ដើម ដូនកាយ១ដើម និងដើមច្រឹង១ដើម។ ចំណែកឯដើមឈើដែលនឹងកាត់ដកហូតរួមមាន ដើមស្នាយ១៧ដើម សង្កែ៦ដើម ពុទ្រា៩ដើម ស្លែង៣ដើម ខ្វារ៣ដើម ផ្អឹងត្រី១គុម្ព និងគុម្ពឃ្លែង២គុម្ព ។

អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារនេះចាប់ពីថ្ងៃចន្ទ ទី១២ ខែមេសា ឆ្នាំ២០២១ រហូតដល់បញ្ចប់ការងារ៕

អាជ្ញាធរជាតិអប្សរាពន្លឿនការជួសជុលខឿនជ្រុងនិរតីនៅរួតទី៣ នៃប្រាសាទបាយ័ន្តឱ្យរួចរាល់មុនខែវស្សាមកដល់

ផ្សាយនៅថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២១

ទិសនិរតី រួតទី៣នៃប្រាសាទបាយ័ន្ត ដែលប្រឈមនឹងហានិភ័យខ្ពស់ បានចាប់ផ្តើមជួសជុលតាំងពីខែមករា ដើមឆ្នាំ២០២១ រហូតមកដល់ពេលនេះសម្រេចបាន៣០ភាគរយហើយ។

កញ្ញា ម៉េង សុវណ្ណលីលីន ស្ថាបត្យករនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ និងជាក្រុមការងារជួសជុលរួតទី៣នៃប្រាសាទបាយ័ន្ត បានឱ្យដឹងថា ការងារជួសជុលនៅប្រាសាទបាយ័ន្ត មាន៤គម្រោងធំៗ ក្នុងនោះរួមមាន ទី១ ជួសជុលជ្រុងនិរតី រួតទី៣នៃប្រាសាទបាយ័ន្តបាន៣០ភាគរយ។ ទី២ ទល់ទ្រផ្តែរហោរជាងដែលពុំមានសរសរពេជ្រសម្រាប់ទ្រលំនឹង ដំបូល និងធ្នឹមរលុះធ្លាក់បាន៩០ភាគរយ។ ទី៣ រៀបចំបិទភ្ជិតតាមប្រហោងថ្ម និងសម្រួលថ្មរដិបរដុបមិនរាបស្មើបាន៨០ភាគរយ និងទី៤ តម្លើងជណ្តើរគ្រោងដែកដើម្បីសម្រួលដល់សៀគ្វីទស្សនាប្រាសាទសម្រេចបាន១០០%ហើយ។

អ្នកជំនាញរូបនេះបញ្ជាក់ថា ដោយកៀកនឹងខែវស្សាខិតចូលជិតមកដល់ ដូចនេះ ក្រុមការងារនឹងខិតខំពន្លឿនការរើថ្ម និងរៀបទៅវិញ យ៉ាងយូរឱ្យរួចរាល់នៅខែមិថុនាខាងមុខ។ ដោយឡែកការជួសជុលកម្រាលអាចបន្តក្នុងរយៈពេលប្រមាណ៣ខែបន្តទៀតនឹងបញ្ចប់ទាំងស្រុង។

កញ្ញា លីលីន បានដឹងទៀតថាផលលំបាកចំពោះការងារជួសជុលនេះគឺទីធ្លាមានភាពតូចចង្អៀត ពិបាកក្នុងការរើថ្ម និងត្រូវការប្រើកម្លាំងពលកម្មមនុស្សទាំងស្រុងក្នុងការរើថ្ម។ ដូច្នេះ ក្រុមការងារបានប្រើបន្ទះកៅស៊ូក្រាលលើកម្រាលថ្ម ដើម្បីធ្វើដាក់ថ្មដែលរើ ចៀសវាងការប៉ះថ្មនឹងថ្មដោយផ្ទាល់ អាចបណ្តាលឱ្យខូចផ្ទៃថ្ម។ ម្យ៉ាងទៀតបើមានភ្លៀងធ្លាក់ ឬរដូវវស្សាមកដល់ គឺពិបាកក្នុងការជួសជុល។

រចនាសម្ពន្ធខឿននៅរួតទី៣នៃប្រាសាទបាយ័ន្តនេះ រងការខូចខាតដោយសារកត្តាអាកាសធាតុ ដើមឈើ ជាពិសេសកត្តាទឹកបានហូរជ្រោះចូលរចនាសម្ពន្ធដែលនាំយកល្បាយខ្សាច់ចេញនាំអោយមានបញ្ហានៅតាមជ្រុងកែងក្រៀកចេញពីគ្នា ដែលអាចប៉ះពាល់ដល់ខឿនរួតទី៣ និងសំណង់ប្រាសាទទាំងមូលផងដែរ។

សូមបញ្ជាក់ថា គម្រោងជួសជុលនេះជាអនុវត្តផ្ទាល់ដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា ដោយមានការសហការលើបច្ចេកទេសរវាងអាជ្ញាធរជាតិអប្សរា និងស្ថាប័ន JASA ប្រទេសជប៉ុន។ បន្ទាប់ពីបញ្ចប់គម្រោងជួសជុលខឿនជ្រុងនិរតីនេះ ក្រុមការងារនឹងបន្តធ្វើការជួសជុលតាមខឿនដែលមានហានិភ័យផ្សេងទៀត និងបន្តសិក្សាជួសជុលទីតាំងផ្សេងៗទៀត ដើម្បីរក្សា និងពង្រឹងរចនាសម្ពន្ធប្រាសាទអោយបានរឹងមាំ យូរអង្វែង។

អាជ្ញាធរជាតិអប្សរាចុះបោះបង្គោលព្រំទីតាំងបុរាណដ្ឋានគោកគ្រើះ និងត្រពាំងឈូក

ផ្សាយនៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២១

នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ ក្រុមការងារបច្ចេកទេសទី៣នៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយរដ្ឋបាលស្រុកបន្ទាយស្រី និងម្ចាស់ដីជាប់ព្រំបុរាណដ្ឋានបានចុះបោះបង្គោលព្រំទីតាំងបុរាណដ្ឋានចំនួនពីរទីតាំងដោយជោគជ័យ គឺ បុរាណដ្ឋានទួលគោកគ្រើះ និងបុរាណដ្ឋានត្រពាំងឈូក ដែលមានទីតាំងស្ថិតនៅភូមិប្រិយ៍ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។

ការបោះបង្គោលព្រំការពារបុរាណដ្ឋានទាំងនេះ គឺដើម្បីជាប្រយោជន៍ក្នុងការកំណត់ព្រំដីបុរាណដ្ឋានត្រូវការពារឱ្យបានត្រឹមត្រូវ ជៀសវាងការកាន់កាប់ដីបុរាណដ្ឋានដោយខុសច្បាប់ពីសំណាក់ឈ្មួញទិញលក់ដីធ្លី និងដើម្បីបង្ហាញប្រាប់ដល់ប្រជាពលរដ្ឋក៏ដូចសាធារណជនទូទៅឱ្យងាយស្រួលកត់សម្គាល់ទីតាំងបុរាណដ្ឋានដែលរួមមាន៖ តួប្រាសាទ ស្រះទឹក និងរចនាសម្ពន្ធនៃសំណង់បុរាណដ្ឋាន កុំឱ្យមានការរំលោភបំពានគ្រប់រូបភាព និងដើម្បីងាយស្រួលរៀបចំបុរាណដ្ឋានទាំងនេះឱ្យបានល្អប្រសើរឡើងវិញ។

គួរបញ្ជាក់ទៀតថា សកម្មភាពចុះបោះបង្គោលព្រំទីតាំងបុរាណដ្ឋាននេះ ក្រុមការងារនឹងបន្តធ្វើជាបន្តបន្ទាប់ទៀតនៅទីតាំងផ្សេងៗទៀតតាមផែនការដែលបានកំណត់។

អាជ្ញាធរជាតិអប្សរាបន្តជួសជុលបង្កាន់ដៃនាគប្រវែង៣០ម៉ែត្រនៅប្រាសាទបន្ទាយសំរែ

ផ្សាយនៅថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០២១

ចាប់តាំងពីដើមខែមីនា ឆ្នាំ២០២១ ក្រុមការងារអភិរក្សថ្មនៃអាជ្ញាធរជាតិអប្សរា សហការជាមួយស្ថាប័ន GIZ ប្រទេសអាល្លឺម៉ង់ បានជួសជុល អភិរក្សលើកតម្លៃបង្កាន់ដៃនាគ ស្ថិតនៅជ្រុងនិរតីនៃប្រាសាទបន្ទាយសំរែប្រវែង៣០ម៉ែត្រ ដែលគ្រោងនឹងបញ្ចប់នៅចុងខែកញ្ញា ឆ្នាំ២០២១ ខាងមុខ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ក្រុមការងារជួសជុលបានប្រមាណ៣៥ភាគរយហើយ។

លោក ឡុង ណារី ប្រធានក្រុមការងារអភិរក្សថ្មនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ លើកឡើងថា បង្កាន់ដៃនាគនៅប្រាសាទបន្ទាយសំរែ បានរងការខូចខាត និងបាក់បែកជាច្រើនអន្លើរ ខ្លះបាត់ជើងទម្រ ខ្លះទៀតបាក់ជាកំណាត់។ បំណែកខ្លួន និងក្បាលនាគមួយចំនួនត្រូវកប់នៅក្នុងពេងទង និងព្រៃជុំវិញប្រាសាទ បណ្ដាលមកពីកម្សោយរចនាសម្ពន្ធគ្រឹះមិនអាចទ្រទម្ងន់សង្កត់ ការបំផ្លាញដោយបរិស្ថានធម្មជាតិ ស្លែ ទឹក សីតុណ្ហភាព អាកាសធាតុ និងកង្វះការថែទាំជាដើម។

លោកបញ្ជាក់ថា ក្រុមការងារបានប្រមូលបំណែកតូចធំរបស់ចម្លាក់បង្កាន់ដៃនាគមកពីទីផ្សេងៗតាមដែលអាចធ្វើបាន ដោយព្យាយាមមិនយកថ្មថ្មីមកជំនួស។ ការប្រើថ្មថ្មីត្រូវធ្វើឡើងនៅត្រង់ចំណុចណាដែលសំខាន់ខ្វះមិនបាន ហើយពុំអាចស្វែងរកបំណែកដើមឃើញប៉ុណ្ណោះ។

លោកបន្តទៀតថា ការជួសជុល និងព្យាបាលថ្ម តភ្ជាប់បំណែកថ្មឡើងវិញ គឺប្រើប្រាស់ស្នូលប្រភេទ Fiber GLass និងការតថ្មប្រភេទ Skiadure។ ក្រុមការងារបានពង្រឹងផ្ទៃថ្មដែលពុកផុយឱ្យរឹងមាំឡើងវិញ ចាក់បំពេញបាយអរចូលក្នុងប្រហោងនឹងតំណបិទភ្ជិតរន្ធតូចធ្មារ ស្នាមប្រេះ និងប្រហោងតូចៗនៅលើផ្ទៃថ្មចម្លាក់ សម្អាតស្លែ និងបន្សាបយកជាតិអំបិលចេញពីផ្ទៃថ្ម ដាប់យកចេញនូវដែកទាមចាស់ៗ និងស៊ីម៉ង់ត៍អស់គុណភាព រៀបដំឡើងបង្កាន់ដៃនាគឡើងវិញស្របតាមទីតាំងដើម។

អ្នកជំនាញរូបនេះបន្តថា ចំពោះផលលំបាកក្នុងការងារជួសជុល គឺទីធ្លាមានភាពតូចចង្អៀត ពិបាកក្នុងដឹកជញ្ជូនថ្មមកក្នុងប្រាសាទ ត្រូវប្រើកម្លាំងពលកម្មទាំងស្រុង ដូច្នេះត្រូវចំណាយពេលវេលាយូរបន្តិច។

ក្រោយពីបញ្ចប់ការជួសជុលនៅទីនេះ ក្រុមការងារនឹងបន្តជួសជុលកន្លែងខូចខាតផ្សេងៗទៀតដូចជា ហោរជាង ផ្ដែរ កំពូលព្រហ្ម និងធ្នឹមជាដើម៕

អាជ្ញាធរជាតិអប្សរា ចុះកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ និងបាំងទេសភាព នៅប្រាសាទសួព្រ័ត្រ និងព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បាននិងកំពុងចាក់កាត់ក្រី និងដកហូតដើមឈើហានិភ័យ ដែលបាំងទេសភាពនៅប្រាសាទសួព្រ័ត្រ និងព្រះលានជល់ដំរី។ ការងារនេះធ្វើឡើងដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទ ព្រមទាំងលើកតម្លៃទេសភាពនៅបរិវេណនោះផង។

ដើមឈើដែលត្រូវកាត់ក្រីរួមមាន ដើមសង្កែ៣ដើម ស្វាយ៤ដើម ចាមរី៩ដើម ដើមយាង (ឈើទាល) ១៧ដើម ល្វា៤ដើម ត្នោត១ដើម ប្ញស្សី១ដើម ដូនកាយ១ដើម និងដើមច្រឹង១ដើម។ ចំណែកឯដើមឈើដែលនឹងកាត់ដកហូតរួមមាន ដើមស្វាយ១៧ដើម សង្កែ៦ដើម ពុទ្រា៩ដើម ស្លែង៣ដើម ខ្វាវ៣ដើម ឆ្អឹងត្រី១គុម្ព និងគុម្ពឃ្លែង២គុម្ព។ ការងារនេះ គ្រោងនឹងបញ្ចប់រួចរាល់នៅចុងសប្តាហ៍នេះ៕

ខែមេសា ឆ្នាំ២០២១

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យាន

ផ្សាយនៅថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួម សហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិសំរោង ភូមិតាប្រុក ភូមិជូនឪ ឃុំលាងដៃ ស្រុកអង្គរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

កុដិឈើមួយខ្នងនៅប្រាសាទលលៃបញ្ចប់ការសាងសង់ដោយជោគជ័យ

ផ្សាយនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២១

កុដិឈើប្រក់ក្បឿងមួយខ្នង ជាសំណង់ស្ថាបត្យកម្មរចនាប័ទ្មខ្មែរបែបពុទ្ធសាសនា មានទំហំបណ្ដោយ១៧ម x ទទឹង ៧,៦ម មានបន្ទប់សិងសរុបចំនួន៥បន្ទប់ និងបន្ទប់ទឹកចំនួន៤ បានបញ្ចប់ការសាងសង់កាលពីខែមីនា ឆ្នាំ២០២១ ក្រោមកិច្ចប្រឹងប្រែង និងសហការគ្នារវាងព្រះសង្ឃគង់នៅវត្តប្រាសាទលលៃ ក្រុមប្រឹក្សាកិច្ចការវត្តអារាមក្នុងតំបន់អង្គរ និងអាជ្ញាធរជាតិអប្សរា។

ការសាងសង់កុដិនេះក្នុងគោលបំណង សម្រួលដល់ការគង់នៅរបស់ព្រះសង្ឃដែលបានរំកិលប្ដូរទីតាំងចុះពីលើខឿនប្រាសាទលលៃកាលពីពេលកន្លងមកឱ្យបានសមរម្យ និងមានភាពងាយស្រួលមួយកម្រិតទៀត។
អាជ្ញាធរជាតិអប្សរាសូមថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅ ប្រគេន និងជូនចំពោះព្រះសង្ឃ គណៈកម្មការអាចារ្យវត្ត និងពុទ្ធបរិស័ទទាំងអស់ដែលបានចូលរួមចំណែកក្នុងកិច្ចការថែរក្សា និងអភិរក្សសម្បត្តិបេតិកភណ្ឌដែលជាកេរតំណែលដូនតាឱ្យបានគង់វង្ស៕

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា ផ្ញើសារចែករំលែកទុក្ខ ដល់ក្រុមគ្រួសារលោកសាស្ត្រាចារ្យ Giorgio Croci

ផ្សាយនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ២០២១

លោកសាស្ត្រាចារ្យ Giorgio Croci ដែលបានធ្វើមរណភាពកាលពីថ្ងៃព្រហស្បត្តិ៍ ទី១៦ ខែមេសា ឆ្នាំ២០២១ ដោយរោគាពាធ ជាអតីតអ្នកជំនាញចំពោះកិច្ចលើផ្នែកអភិរក្សនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ និងជាបុគ្គលផ្ដើមនាំមុខ

ក្នុងកិច្ចការពារថែរក្សា ជួសជុលប្រាសាទបុរាណខ្មែរក្នុងរមណីយដ្ឋានអង្គរ។ ក្នុងតួនាទីជាអ្នកជំនាញចំពោះកិច្ច លោកសាស្ត្រាចារ្យ Giorgio Croci មិនត្រឹមតែជាសសរទ្រូងនៃកិច្ចការពារ ថែរក្សា ជួសជុលប្រាសាទប៉ុណ្ណោះទេ តែលោកសាស្ត្រាចារ្យក៏បានផ្ទេរនិងចែករំលែកនូវចំណេះដឹងយ៉ាងច្រើនដល់អ្នកជំនាញខ្មែរផងដែរ។

ក្នុងកាយវិការចូលរួមចែករំលែកទុក្ខដល់ក្រុមគ្រួសាររបស់លោកសាស្ត្រាចារ្យ Giorgio Croci លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានផ្ញើនូវសារចែករំលែកទុក្ខសម្តែងនូវការសោកស្តាយជាពន់ពេកចំពោះការបាត់បង់លោកសាស្ត្រាចារ្យ Giorgio Croci នាពេលនេះ។ ជាមួយគ្នានេះដែរ លោកជំទាវបណ្ឌិតសភាចារ្យក៏បានសម្តែងនូវការដឹងគុណជាអនេកប្បការចំពោះការលះបង់របស់លោកសាស្ត្រាចារ្យ Giorgio Croci ក្នុងបុព្វហេតុលើកស្ទួយតម្លៃរមណីយដ្ឋានអង្គរ សម្បត្តិបេតិកភណ្ឌវប្បធម៌ខ្មែរនិងជាសម្បត្តិបេតិកភណ្ឌវប្បធម៌នៃមនុស្សជាតិរបស់អង្គការយូណេស្កូ៕

ក្រុមការងារបរិស្ថានរបស់អាជ្ញាធរជាតិអប្សរាបន្តយកចិត្តទុកដាក់ថែរក្សាអនាម័យក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២១

ទោះស្ថានភាពនៅក្នុងរមណីយដ្ឋានអង្គរមានការបិទមិនឲ្យចូលទស្សនាក៏ដោយ តែក្រុមការងារបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា នៅតែបន្តការងាររបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួន ក្នុងន័យថែរក្សាបរិស្ថានតំបន់រមណីយដ្ឋានអង្គរ ឲ្យកាន់តែស្រស់បំព្រងជានិច្ច។ សកម្មភាពការងារសម្អាតទាំងនោះគឺទាំងក្នុងប្រាសាទ តាមដងផ្លូវ និងក្នុងកសិន្ធុទឹក។ល។

អាជ្ញាធរជាតិអប្សរា សហការជាមួយប្រទេសអាល្លឺម៉ង់ ជួសជុល និងអភិរក្សក្បាច់ចម្លាក់នៅកំពូលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរា ទទួលបន្ទុកដោយនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ក្រោមកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន GARCP (German Apsara Restoration Conservation Project) ប្រទេសអាល្លឺម៉ង់ ជួសជុល អភិរក្សក្បាច់ចម្លាក់នៅជ្រុងខាងជើងឈៀងខាងកើត រួតទី២នៃកំពូលប្រាសាទអង្គរវត្ត និងសង្គ្រោះបន្ទាន់នូវផ្នែកមួយចំនួនទៀតរបស់ប្រាសាទនេះ។

ការជួសជុលអភិរក្សក្បាច់ចម្លាក់នៅកំពូលប្រាសាទអង្គរវត្តនេះ បានចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ២០១៩ មកដល់ពេលបច្ចុប្បន្នអនុវត្តបានប្រមាណ៤០ភាគរយ និងគ្រោងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០២៣ខាងមុខ៕

អាជ្ញាធរជាតិអប្សរានៅតែបង្កើនសកម្មភាពថែទាំប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០២១

គ្រប់គោលដៅទាំងអស់សុទ្ធតែមាន ភ្នាក់ទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ និងក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ប្រចាំការ ដើម្បីចាំសម្រួលហេតុការណ៍ផ្សេងៗរបស់ភ្ញៀវទេសចរដែលមានបញ្ហាពេលមកទស្សនានៅអង្គរ។

ទោះបីស្ថានភាពភ្ញៀវទេសចរមានភាពស្ងប់ស្ងាត់ ដោយសារជំងឺកូវីដ១៩យ៉ាងណាក៏ដោយ តែក្រុមការងារដែលប្រចាំការតាមប្រាសាទនីមួយៗ ពុំបានឈប់សម្រាកពីការងារប្រចាំថ្ងៃនិងមិនភ្លេចរួមចំណែកថែទាំប្រាង្គប្រាសាទ ក្នុងរមណីយដ្ឋានអង្គរឡើយ។ ផ្ទុយទៅវិញ ក្រុមការងារបានយកឱកាសនេះបង្កើនសកម្មភាពថែទាំ និងសម្អាតតាមទីតាំងប្រាសាទផ្សេងៗក្នុងរមណីយដ្ឋានអង្គរជាប្រចាំ។

ជាក់ស្តែង ក្រុមការងារដែលប្រចាំការនៅតាមប្រាសាទរួមមានភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ និងក្រុមការងារត្រួតពិនិត្យសេវាកម្មទេសចរណ៍ បានជួសជុលរនាំងឈើ រនាំងថ្មបាំងទ្រូងផ្លូវ និងស្លាកសញ្ញាផ្សេងៗ ព្រមទាំងបានរួមគ្នាសម្អាតបរិវេណប្រាសាទនិងទីតាំងផ្សេងៗជាច្រើនកន្លែងទៀតក្នុងតំបន់អង្គរ ក្នុងគោលបំណងថែទាំអភិរក្សប្រាសាទលើកតម្លៃមរតកដូនតានិងលើកកម្ពស់បរិស្ថាន៕

អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះពិនិត្យការដ្ឋានជួសជុលស្ពានឈើនៅប្រាសាទតាកែវ

ផ្សាយនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២១

ព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងសហការី ចុះពិនិត្យការដ្ឋានជួសជុលស្ពានឈើដែលឆ្លងកាត់ស្ទឹងសៀមរាប ស្ថិតនៅខាងលិចប្រាសាទតាកែវ លើកំណាត់ផ្លូវវង់តូច ក្នុងតំបន់រមណីយដ្ឋានអង្គរ។

ស្ពាននេះរងនូវការទ្រុឌទ្រោម ដោយកត្តាអាកាសធាតុ និងអាយុកាល បណ្ដាលឲ្យសំណង់ប្រឈមនឹងហានិភ័យខ្ពស់ ទាមទារឱ្យមានការជួសជុលជាបន្ទាន់។អាជ្ញាធរជាតិអប្សរាបានចាប់ផ្ដើមតាំងពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១។

ការជួសជុលស្ពានឈើនេះ ក្រុមការងារបានសុំយោបល់ និងអនុម័តយល់ព្រមពីគណៈកម្មាធិការ អាយ ស៊ីស៊ី-អង្គរ។ កំលុងពេលជួសជុលស្ពានឈើនេះអាជ្ញាធរជាតិអប្សរាបានសាងសង់ស្ពានសម្រាប់ឆ្លងកាត់ជាបណ្ដោះអាសន្ន និងសូមការអធ្យាស្រ័យចំពោះប្រជាពរដ្ឋ និងភ្ញៀវទេសចរ ចំពោះមានការរំខានក្នុងការធ្វើដំណើរអំឡុងពេលជួសជុល៕

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២១

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីមួយចំនួន បានចុះពិនិត្យការដ្ឋានការងារក្នុងតំបន់រមណីយដ្ឋានអង្គរ។

បន្ទាប់ពីបានពិនិត្យការជួសជុលស្ពានឈើតាកែវ **ឯកឧត្តម ហង់ ពៅ** បានបន្តទៅពិនិត្យការដ្ឋានកំណាយស្រាវជ្រាវបុរាណវិទ្យានៅមុខព្រះលានជល់ដំរី។ ការដ្ឋានជួសជុលប្រាសាទបាយ័ន្ត។ ការដ្ឋានជួសជុលប្រាសាទអង្គរវត្ត ក្នុងន័យអភិរក្ស និងលើកតម្លៃប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា ទោះបីក្នុងបរិបទជំងឺកូវីដ១៩ ឆ្លងរាលដាលក្នុងសហគមន៍ ក៏តំបន់រមណីយដ្ឋានអង្គរ នៅតែបន្តការងារជួសជុល អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព ព្រមទាំងចូលរួមគោរពតាម ៣កុំ ៣ការពារដែលដាក់ចេញដោយរាជរដ្ឋាភិបាល។

យើងនៅញញឹមចាំស្វាគមន៍អ្នកគ្រប់ពេលវេលា

ផ្សាយនៅថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០២១

ខ្ញុំនៅបង្ហាញស្នាមញញឹមជាប់ជានិច្ច និងរង់ចាំអ្នកមកទស្សនាខ្ញុំគ្រប់ពេលវេលា។ ក្រោមការមើលថែទាំអភិរក្សយ៉ាងល្អប្រពៃពីអាជ្ញាធរជាតិអប្សរា ធ្វើឲ្យខ្ញុំនៅតែរឹងមាំ ស្រស់ស្អាត ស័ក្តិសមនូវគុណតម្លៃនៃប្រាង្គប្រាសាទដ៏អច្ឆរិយជាសាកលសម្រាប់មនុស្សជាតិ។ សូមកូនខ្មែរគ្រប់រូប ចូលរួមថែរក្សាគុណតម្លៃបេតិកភណ្ឌនេះជាដរាបតរៀងទៅ។ កិច្ចការអភិរក្សបេតិកភណ្ឌ ជាភារកិច្ចកូនខ្មែរគ្រប់ៗរូប៕

កុំភ្លេចអនុវត្តន៍តាមវិធានការណ៍ ៣កុំ ៣ការពារប្រឆាំងជំងឺកូវីដ១៩ ពេលចូលទស្សនាប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២១

ក្នុងកំលុងពេលដែលជំងឺកូវីដ១៩កំពុងរាតត្បាតយ៉ាងខ្លាំងក្នុងពិភពលោក ក៏ដូចជានៅកម្ពុជា អាជ្ញាធរជាតិអប្សរាក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះការបង្ការធ្វើយ៉ាងណាទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺឆ្លងនេះ។

ជានិច្ចកាលអាជ្ញាធរជាតិអប្សរា បានដាក់ចេញនូវវិធានការណ៍សម្រាប់មន្ត្រី ភ្នាក់ងារបំពេញកិច្ចការតាមប្រាង្គប្រាសាទទាំងអស់ត្រូវអនុវត្តន៍ជាប្រចាំនូវវិធានការ ៣កុំ ៣ការពារឱ្យបានជាប់ជាប្រចាំ។

ចំពោះប្រជាពលរដ្ឋនិងភ្ញៀវទេសចរមុនពេលចូលទស្សនាប្រាសាទគឺ តម្រូវឱ្យពាក់ម៉ាស់ លាងសម្អាតដៃជាមួយអាល់កុល និងស្កេនកម្មវិធីQR Codeចុះឈ្មោះដើម្បីទប់ស្កាត់មេរោគកូវីដ១៩។ ជាពិសេសមិនឱ្យមានភាពប្រមូលផ្តុំ ឬការឈរកៀកៗគ្នាឡើយ។

អាជ្ញាធរជាតិអប្សរាសង្ឃឹមជឿជាក់ថា បងប្អូនប្រជាពលរដ្ឋនិងភ្ញៀវទេសចរទាំងអស់ ពិតជាមានការយោគយល់និងចូលរួមអនុវត្តន៍ឱ្យបានល្អប្រសើរទាំងអស់គ្នា៕

ការងារស្តារពើកកំពុងចាប់ផ្តើមអនុវត្តនៅកសិន្ធុខាងលិចក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២១

ក្រុមការងារនៃនាយកដ្ឋានគ្រប់គ្រងទឹក នៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងអនុវត្តសកម្មភាពស្តារពើកនៅក្នុងកសិន្ធុក្រុងអង្គរធំ។ ការអនុវត្តជំហានដំបូងនេះធ្វើឡើងនៅកសិន្ធុខាងលិច ឬជាប់ខ្លោងទ្វារតាការ នៃក្រុងអង្គរធំ។

ក្រុមការងារស្តារពើក បានបង្ហាញសកម្មភាពដ៏មមាញឹក ក្នុងការអូស ទាញ និងលើកពើកដ៏ក្រាស់ ចេញពីទឹក មកទម្លាក់លើគោកជាប់ច្រាំងកសិន្ធុ។ ស្មៅនិងរុក្ខជាតិតូចៗ ដែលកកក្លាយជាពើកនោះ មានសភាពក្រាស់ និងកន្លែងខ្លះស្ទើរមើលទឹកមិនឃើញ ហើយនៅផ្នែកខាងក្រោម មានកំណកដីប្រមាណ៦តឹក។

លោក ញ៉ែម រស្មី មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹកបានឲ្យដឹងថា ការងារនេះនាយកដ្ឋានបានប្រើប្រាស់កម្លាំងជិត៤០នាក់ ដែលចាប់ផ្តើមស្តារពើកពីថ្ងៃទី២៤ ខែមេសាមក។ លោកបន្ថែមថាការងារមានជួបបញ្ហាប្រឈមខ្លះៗ ដូចជាសត្វអាសិរពិស ដែលរស់នៅក្នុងពើក ដែលជាហានិភ័យសម្រាប់កម្មករដែលចុះកាត់ពើក។ មួយទៀតដែលជាការលំបាក និងធ្វើឲ្យការងារមិនអាចធ្វើលឿនទៅបាន គឺពើកដែលមានសភាពក្រាស់ ធ្ងន់ ដូច្នេះត្រូវមានបច្ចេកទេសកាត់ច្រៀកចំណិតតូចៗ ដើម្បីងាយស្រួលលើកចេញ។ យ៉ាងណា លោក ញ៉ែម រស្មី បញ្ជាក់ថា ក្រុមការងារកំពុងរកវិធីសាស្ត្រផ្សេងទៀត ដើម្បីជំរុញឲ្យការងារបានទៅមុខលឿន ដូចជាការប្រើឧបករណ៍ជំនួយដើម្បីអូសពើក ដែលបច្ចុប្បន្នប្រើតែកម្លាំងមនុស្សអូសផ្ទាល់។

ការងារស្តារពើកជាជំហានដំបូងនេះ ធ្វើឡើងដោយអាជ្ញាធរជាតិអប្សរា ដោយមានការឧបត្ថម្ភដោយវិស័យឯកជន ក្នុងនោះរួមមាន **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច **លោកជំទាវ ភឿង សកុណា** ប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **លោកជំទាវ ឧកញ៉ា នាងទសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ និងសប្បុរសជនមួយចំនួនទៀត។ ការស្តារនេះមានប្រវែង ទទឹង១០០ម៉ែត្រ បណ្តោយ ១៥០០ ម៉ែត្រ។ ការស្តារពើកនេះ គឺដើម្បីចូលរួមអភិរក្ស និងលើកតម្លៃឡើងវិញនៃរមណីយដ្ឋានអង្គរ។

សូមបញ្ជាក់ថា ពើកស្មៅដ៏ក្រាស់នេះ កកើតឡើងដោយសាររុក្ខជាតិតូចៗក្នុងទឹកដូចជាកំប្លោក ស្លែរ នៅក្នុងទឹករយៈពេលយូរ កង្វះការសម្អាតគ្រប់គ្រាន់ ទើបបណ្តាលឲ្យកកក្រាស់កើតជាពើកដូច្នេះ។ គេរំពឹងថា បរិស្ថាននៅកសិន្ធុខាងលិចនៃក្រុងអង្គរធំ នឹងប្រែជាស្រស់ស្អាត និងទាក់ទាញឡើងវិញ បន្ទាប់ពីការងារស្តារពើកនេះបានបញ្ចប់ទៅតាមការគ្រោងទុក ហើយក៏ងាយស្រួលក្នុងការផ្ទុកទឹកបានច្រើនជាងពេលមុនផងដែរ៕

អាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់ចំនួន៤ដើម ដុះជាប់នឹងខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា រួមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យ និងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើចំនួន៤ដើម ដែលកំពុងមានហានិភ័យខ្ពស់មកលើរចនាសម្ពន្ធខ្លោងទ្វារខាងលិចប្រាសាទបន្ទាយក្តី។ កិច្ចការងារនេះធ្វើឡើងក្នុងបំណងដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធខ្លោងទ្វារប្រាសាទនេះកាន់តែធ្ងន់ធ្ងរ ព្រមទាំងជួយសម្រួលដល់ការងារជួសជុលខ្លោងទ្វារនេះឡើងវិញក្នុងពេលឆាប់ៗនេះផង។

ដើមឈើដែលនឹងត្រូវកាត់ដកហូតរួមមាន ដើមពង្រ៣ដើម និងដើមចាន់១ដើម ដែលស្ថានភាពដើមឈើទាំងនេះ ដុះទ្រេតជាប់ខឿនខ្លោងទ្វារ មានជំងឺពុកគល់ និងតួដើម ប្រព័ន្ធឫសខ្សោយដុះគ្របលើថ្ម និងចាក់ចូលក្នុងរចនាសម្ពន្ធគ្រឹះរបស់ខ្លោងទ្វារ បណ្តាលឲ្យថ្មរបើកឡើង និងរំកិលចេញពីទីតាំងដើម។

អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារនេះចាប់ពីសប្តាហ៍ទី១នៃខែឧសភា ឆ្នាំ២០២១ រហូតដល់បញ្ចប់ការងារ។ អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន៕

សូមជូនរូបភាពប្រចាំថ្ងៃ៖ ទេសភាពចាប់ពីខ្លោងទ្វារទន្លេអុំទៅប្រាសាទបាយ័ន

ផ្សាយនៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២១

ទិដ្ឋភាពស្រស់បំព្រងកំពុងគ្របដណ្តប់នៅតាមដងផ្លូវនានាក្នុងរមណីយដ្ឋានអង្គរ ជាពិសេសតាមដងផ្លូវពីខ្លោងទ្វារទន្លេអុំឆ្ពោះទៅប្រាសាទបាយ័ន ដើមឈើតូចធំជាច្រើន ឈរអមសងខាងផ្លូវ បង្កើនភាពទាក់ទាញដល់អ្នកដំណើរ និងធ្វើឲ្យអ្នកទេសចរជិតឆ្ងាយនឹករឮកដល់រមណីយដ្ឋាន



ការសម្អាតកូនរុក្ខជាតិតូចៗដែលដុះលើប្រាង្គប្រាសាទជាប្រចាំ

ផ្សាយនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១

ការកាត់សម្អាតកូនរុក្ខជាតិតូចៗ ដែលដុះលើតួប្រាសាទបុរាណ គឺជាកាងារដ៏សំខាន់មួយទៀតរបស់អាជ្ញាធរអប្សរា ក្នុងកិច្ចការថែរក្សានិងការពារប្រាសាទបុរាណដែលមិនអាចមើលរំលងបាន។ ការយកចិត្តទុកដាក់សម្អាតកូនរុក្ខជាតិតូចៗ ចេញពីប្រាសាទបុរាណ ក៏ព្រោះតែកូនរុក្ខជាតិទាំងនោះ នឹងដុះរីកធំឡើងបង្កឱ្យប៉ះពាល់ដល់ប្រាង្គប្រាសាទ ចំណែកឯឫសរបស់វាក៏បង្កឱ្យខូចខាតដល់ថ្ម និងរចនាសម្ពន្ធផ្សេងៗជាច្រើនទៀតរបស់ប្រាសាទដែរ។

អ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា បានរកឃើញថា បើទោះបីជាមានការកាត់ ឬដកចេញនូវកូនរុក្ខជាតិ ជាប្រចាំក៏ដោយ គឺវានៅតែមិនទាន់មានសុវត្ថិភាពទាំងស្រុងចំពោះប្រាសាទបរាណនៅឡើយទេ ពីព្រោះឫសរបស់រុក្ខជាតិទាំងនោះនៅតែបន្តលូតលាស់ ចាក់ជ្រៅទៅក្នុងរចនាសម្ពន្ធរបស់ប្រាសាទទៅហើយ ដូចជារុក្ខជាតិដើមពោធិជាដើម។

ដូច្នេះហើយ បានជារៀងរាល់ថ្ងៃ អាជ្ញាធរជាតិអប្សរាក្រៅតែពីមានក្រុមការងារជាច្រើនផ្នែកក៏មានក្រុមជំនាញសម្រាប់ណែនាំដល់មន្ត្រី បុគ្គលិកដែលប្រចាំការតាមប្រាង្គប្រាសាទឱ្យចេះពីរបៀបកាត់ដករុក្ខជាតិ ដែលដុះនៅលើប្រាសាទ ដើម្បីកម្ចាត់ឱ្យសមស្របតាមបទដ្ឋានបច្ចេកទេសផងដែរ៕

ខែមេសា ឆ្នាំ២០២១

សូមជូនរូបភាពប្រចាំថ្ងៃ៖ ទិដ្ឋភាពថ្ងៃលិចនៅប្រាសាទភ្នំបាខែង

ផ្សាយនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១

ប្រាសាទភ្នំបាខែងជាគោលដៅទេសចរណ៍មួយដ៏ទាក់ទាញសម្រាប់ការទស្សនាថ្ងៃលិចក្នុងតំបន់រមណីយដ្ឋានអង្គរ។ ដ្បិតមិនមានទេសចរបរទេស តែទេសចរក្នុងស្រុក ក៏ដូចជាប្រជាពលរដ្ឋក្នុងខេត្តសៀមរាបនៅតែបន្តការឡើងទៅទស្សនាថ្ងៃលិចនៅទីនេះជាប្រចាំ ហើយខ្លះទៀតដើរឡើងចុះសម្រាប់ការហាត់ប្រាណផង៕



ការរៀបចំកម្រាលថ្មស្ពានហាលប្រាសាទអង្គរវត្តនឹងបញ្ចប់នាពេលឆាប់ៗខាងមុខ

ផ្សាយនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១

កម្រាលថ្មភក់ប្រវែង៩ ០ម៉ែត្រដែលជាស្រទាប់ខាងលើនៃស្ពានហាលប្រាសាទអង្គរវត្តសម្រាប់ដើរនឹងរៀបរួចរាល់នាពេលខាងមុខដ៏ខ្លី។

លោក សយ ច័ន្ទនោឫទ្ធិ ស្ថាបត្យករ បាននិយាយថាមកដល់បច្ចុប្បន្ននេះ ការងារពង្រឹងគ្រឹះសម្រេចបានស្ទើរ១០០ភាគរយ។ រីឯការងាររៀបចំកម្រាលផ្លូវដើរទៅភ្ជាប់នឹងកម្រាលដែលខាងសាកលវិទ្យាល័យសូហ្វីយ៉ាជួសជុលរួចរាល់នោះបានសម្រេចបាន៩០ភាគរយហើយ។ ក្រៅពីនេះ ក្រុមការងារកំពុងបន្តការងារពង្រឹងគ្រឹះផ្នែកខាងក្នុង និងខាងក្រៅ នៃស្ពានហាល និងកំពុងបន្តស្រាវជ្រាវនៅផ្នែកកំពង់ទឹក។



គួរបញ្ជាក់ថា ស្ពានហាលខាងលិចអង្គរវត្ត បានចាប់ផ្តើមដំណើរការជួសជុលនៅពាក់កណ្តាលឆ្នាំ២០១៦ ស្ថិតក្នុងជំហានទី២ នៃកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន។ កន្លងមកស្ពានហាលប្រាសាទអង្គរវត្ត ត្រូវបានជួសជុលបានប្រវែង១០០ម៉ែត្រ ដែលអនុវត្តក្នុងជំហានទី១នៅឆ្នាំ១៩៩៦ រហូតដល់ឆ្នាំ២០០៧៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែឧសភា

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋានជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៣៧៦គ្រួសារ

ផ្សាយនៅថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០២១

នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងខែមេសា ឆ្នាំ២០២១ ក្រុមការងារបានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាននិងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យាន និងក្រៅឧទ្យានអង្គរបានចំនួន ៣៧៦គ្រួសារ។

ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរចំនួន ៣៦០ គ្រួសារមាន ក្រុងសៀមរាប ៨៣គ្រួសារ ស្រុកប្រាសាទបាគង ៧៩គ្រួសារ ស្រុកបន្ទាយស្រី ៨៨គ្រួសារ ស្រុកពួក ៤៤គ្រួសារ និងស្រុកអង្គរធំ ៦៦គ្រួសារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្រៅឧទ្យានអង្គរចំនួន ១៦គ្រួសារ គឺនៅក្រុងសៀមរាប ០៣គ្រួសារ ស្រុកសូទ្រនិគម ០២គ្រួសារ ស្រុកប្រាសាទបាគង ០១គ្រួសារ និងស្រុកស្វាយលើ ១០គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាតនិងដាក់ពាក្យសាងសង់ស្នើសុំគឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

ភ្ញៀវទេសចរសប្បាយរីករាយនៅពេលបានឃើញទិដ្ឋភាពដ៏ស្រស់ស្អាត ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២១

នៅពេលធ្វើដំណើរមកដល់តំបន់អង្គរ ភ្ញៀវទេសចរពិតជាបានឃើញអំពីទិដ្ឋភាពដ៏មមាញឹក នៃមន្ត្រីអាជ្ញាធរជាតិអប្សរា និងភ្នាក់ងារទេសចរណ៍ចាំទទួលស្វាគមន៍អ្នកទេសចរ ព្រមទាំងសម្រស់ធម្មជាតិខៀវខ្ចីមានសួនច្បារអមសងខាងបរិវេណផ្លូវចូល ជាមួយក្លិនផ្កាយ៉ាងក្រអូបឈ្ងុយឈ្ងប ក្រោមការថែទាំយ៉ាងយកចិត្តទុកដាក់ពីអាជ្ញាធរជាតិអប្សរា។

កញ្ញា ស្រីរ័ត្ន អាយុ៣២ឆ្នាំ ប្រជាពលរដ្ឋរស់នៅស្រុកពួក ខេត្តសៀមរាបបានឱ្យដឹងថា នៅពេលបានមកទស្សនារមណីយដ្ឋានអង្គរក្រោយការប្រកាសបើកដំណើរការទទួលស្វាគមន៍ភ្ញៀវទេសចរឡើងវិញ ធ្វើឱ្យកញ្ញាបំភ្លេចអស់រាល់ក្តីកង្វល់នានា ដោយនឹកឃើញតែភាពបៃតងស្រស់ស្អាតនៅក្នុងរមណីយដ្ឋានអង្គរ។ កញ្ញាបន្តទៀតថា តំបន់រមណីយដ្ឋានអង្គរពិតជាមានភាពស្រស់ស្អាត នៅពេលដែលអាជ្ញាធរជាតិអប្សរាបានអភិវឌ្ឍនិងអភិរក្ស ដោយមានការរៀបចំជាសួន និងមានដាំដើមផ្កា ដាំស្មៅ និងដាំដើមឈើបន្ថែម ដែលធ្វើឱ្យបរិវេណខាងមុខប្រាសាទអង្គរវត្ត និងតាមបណ្តាប្រាសាទនានាមានភាពបៃតងស្រស់ស្អាត។

ចំណែកលោក ឌី រស្មី រស់នៅក្នុងក្រុងសៀមរាប បានរៀបរាប់ដោយក្តីរំភើប ក្រោយពេលដែលរាជរដ្ឋាភិបាលបានប្រកាសបើករមណីយដ្ឋានទេសចរណ៍នៅទូទាំងប្រទេសឡើងវិញនេះ ព្រោះក្រោយពេលសម្រាកពីការងារលោកតែងតែទៅលម្ហែអារម្មណ៍នៅរមណីយដ្ឋានអង្គរ ដោយសារទីនោះប្រជុំទៅដោយទេសភាពបៃតងនៅពេលដែលអាជ្ញាធរជាតិអប្សរាបានធ្វើការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅក្នុងតំបន់អង្គរទាំងមូល។ លោកបន្តថានៅពេលដែលបញ្ចប់វិបត្តិនៃជំងឺកូវីដនេះ ភ្ញៀវទេសចរដែលមកកម្សាន្តនៅក្នុងរមណីយដ្ឋានអង្គរ នឹងកាន់តែទទួលបានភាពរីករាយជាមួយសម្រស់ធម្មជាតិដ៏ស្រស់បំព្រងដែលអាជ្ញាធរបានរៀបចំនេះ។

ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជាសាកលនៃជំងឺកូវីដ១៩ ជានិច្ចកាល អាជ្ញាធរជាតិអប្សរាបានដាក់ចេញវិធានការសម្រាប់មន្ត្រី ភ្នាក់ងារបំពេញកិច្ចការតាមប្រាង្គប្រាសាទទាំងអស់ ត្រូវអនុវត្តន៍ជាប្រចាំនូវវិធានការ៣កុំ និង៣ការពារឱ្យបានជាប់ជាប្រចាំ។ ចំពោះប្រជាពលរដ្ឋនិងភ្ញៀវទេសចរមុនពេលចូលទស្សនាប្រាសាទគឺ តម្រូវឱ្យពាក់ម៉ាស់ លាងសម្អាតដៃជាមួយអាល់កុល និងស្កេនកម្មវិធីQR Code ដើម្បីចូលរួមតាមដាននិងទប់ស្កាត់ការចម្លងមេរោគកូវីដ-១៩។ ជាពិសេសមិនឱ្យមានការប្រមូលផ្តុំ និងត្រូវដើរឬក៏ឈរដោយរក្សាគម្លាតឆ្ងាយៗពីគ្នា៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុក អង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិតាប្រុក ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ដើមឈើនិងប្រាសាទ រូបពីរជីវិតមួយ

ផ្សាយនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២១

ប្រាសាទតាព្រហ្ម ជាប្រាសាទមួយដែលទាក់ទាញភ្ញៀវទេសចរ ដ្បិតថាប្រាសាទនេះមានលម្អដោយដើមឈើធំៗជាច្រើន ហើយដើមឈើទាំងនោះបានដុះចាក់ឫសទៅលើថ្មប្រាសាទ ដែលជាទិដ្ឋភាពដ៏អស្ចារ្យ។ ដើមឈើមានតួនាទីជាច្រើនសម្រាប់ការពារប្រាសាទដូចជាបង្កើតសំណើម

ដែលជួយកាត់បន្ថយកម្តៅនៅតាមប្រាសាទ ផ្តល់ជាម្លប់ដល់ប្រាសាទដែលបង្កើតសំណើមក្នុងតំបន់ប្រាសាទ ដែលសំណើមនោះនឹងជួយរក្សាលំនឹងគ្រឹះប្រាសាទដែលជាដីខ្សាច់ និងសារប្រយោជន៍មួយទៀត គឺជួយទប់ខ្យល់ ដែលខ្យល់ទាំងនោះអាចធ្វើឱ្យថ្មប្រាសាទរលុះ និងបាក់បែកបានដោយងាយ។ ជារួមដើមឈើ និងប្រាសាទ ប្រៀបដូចជារូបពីរមានជីវិតតែមួយ ដែលមានន័យថា ដើមឈើនិងប្រាសាទ បំពេញតម្លៃឱ្យគ្នាទៅវិញទៅមកដោយមិនអាចខ្វះតួអង្គមួយណាបានឡើយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។ ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ស្នាមញញឹមនៃប្រាសាទបាយ័ន្ត

ផ្សាយនៅថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២១

អតីតរាជធានីអង្គរធំ មានទំហំ៩គីឡូម៉ែត្រក្រឡាដែលស្ថាបនាឡើងជាបន្តបន្ទាប់ក្នុងរាជ្យនៃព្រះមហាក្សត្រជាច្រើនតំណ និងបន្តរហូតដល់ព្រះបាទជ័យវរ្ម័នទី៧។





នៅចំកណ្តាលនៃអតីតរាជធានីអង្គរធំមានប្រាសាទបាយ័ន្តដ៏ល្អឯក កសាងឡើងដោយព្រះបាទជ័យវរ្ម័នទី៧។ កំពូលប្រាសាទបាយ័ន្តមានចម្លាក់ព្រហ្មមុខបួនបែរព្រះភក្ត្រទៅទិសធំៗចម្បងទាំងបួន និង បានបង្ហាញស្នាមញញឹមមិនចេះរីងស្ងួតទៅកាន់អ្នកទេសចរគ្រប់ជាតិសាសន៍ ព្រមទាំងបានលើកតម្លៃវប្បធម៌ជាតិឱ្យ កាន់តែវិសេសវិសាលជានិរន្តតរៀងទៅ៕

អតីតរាជធានីនេះមានកំពែងបួនជ្រុងព័ទ្ធជុំវិញ ដែលជ្រុងនីមួយៗមានប្រវែង៣គីឡូម៉ែត្រ។ កំពែងទាំងបួនជ្រុងក៏មានខ្លោងទ្វារសំខាន់ៗចំនួន៥ បែរទៅរកទិសធំៗចម្បងទាំងបួនដូចជា ខាងកើតមានខ្លោងទ្វារជ័យ និងខ្លោងទ្វារខ្មោច ខាងលិចមានខ្លោងទ្វារតាកាវ ខាងត្បូងមានខ្លោងទ្វារទន្លេអុំ និងខាងជើងមានខ្លោងទ្វារដីឆ្នាំង។ បន្ទាប់ពីកំពែង ផ្នែកខាងក្រៅបន្ទាប់ទៀតនោះគឺកសិន្ធុទឹកព័ទ្ធជុំវិញផងដែរ។

អ្នកជំនាញអាជ្ញាធរជាតិអប្សរាកំពុងជួសជុលខឿនរូតទី៣ នៃប្រាសាទបាយ័ន្តតាមរបៀបបុរាណ

ផ្សាយនៅថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០២១

ក្រុមអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរា ដែលសហការជាមួយស្ថាប័JASAប្រទេសជប៉ុនកំពុងជួសជុលនិងពង្រឹងរចនាសម្ពន្ធខឿននៅរូតទី៣នៃប្រាសាទបាយ័ន្តឡើងវិញ បន្ទាប់ពីពិនិត្យឃើញថារូតទី៣នៃប្រាសាទ មានការទ្រុឌទ្រោមជាច្រើនកន្លែង។

ដំណើរការជួសជួលបានចាប់ផ្តើម តាំងពីដើមខែមីនា ឆ្នាំ២០២១ មកដល់ពេលនេះ ដោយការងារសម្រេចបាន ៦៥ភាគរយ ហើយ គ្រោងនឹងបញ្ចប់នៅចុងខែកក្កដា ឆ្នាំ ២០២១ ខាងមុខ។ តាមការបញ្ជាក់របស់លោក យាម មុនី មន្ត្រីបច្ចេកទេសនៃការជួសជុលខឿនរូតទី៣ នៃប្រាសាទបាយ័ន្ត ឱ្យដឹងថា ការជួសជុលខឿនរូតទី៣នេះ ក្រុមការងារបានយកតាមលំនាំបច្ចេកទេសបុរាណទាំងស្រុង។

លោកបញ្ជាក់ទៀតថា បន្ទាប់ពីរើថ្មភក់ និងថ្មបាយក្រៀមនៅកន្លែងដែលក្រៀកហែកចេញពីគ្នារួចហើយ អ្នកជំនាញបានយកទៅរៀបឡើងវិញតាមលក្ខណៈដើម និងបានធ្វើតេស្តពិនិត្យលើគុណភាពដីរបស់គ្រឹះបុរាណ ព្រមទាំងបានរក្សាដីដែលមានគុណភាពយកមកប្រើឡើងវិញផង។

លោក មុនី ពន្យល់ថា ក្រុមការងារបានបុកបង្ហាប់ដីឥដ្ឋកម្ទេចថ្មបាយក្រៀម ខ្សាច់ ដីដំបូកកណ្តៀរ កំបោរ នៅតាមស្រទាប់នីមួយៗនៃរចនាសម្ពន្ធរបស់ប្រាសាទ ប្រយោជន៍ដើម្បីឱ្យរូតប្រាសាទ មានគុណភាពអាចទ្រទម្ងន់បានយូរអង្វែង និងបញ្ចៀសការជ្រាបទឹកដែលធ្វើឱ្យខូចខាតដល់គ្រឹះប្រាសាទបន្ថែមទៀត។

រចនាសម្ពន្ធខឿននៅរូតទី៣ នៃប្រាសាទបាយ័ន្ត រងការខូចខាតដោយសារកត្តាជាច្រើនយ៉ាងដូចជា កត្តាអាកាសធាតុ ដើមឈើ ជាពិសេសកត្តាទឹកបានហូរច្រោះចូលរចនាសម្ពន្ធដែលនាំល្បាយខ្សាច់ចេញ បង្កឱ្យមានបញ្ហានៅតាមជ្រុងនិងកែងក្រៀកចេញពីគ្នាដែលអាចប៉ះពាល់ដល់ខឿនរូតទី៣ ហើយគំរាមកំហែងដល់សំណង់ប្រាសាទទាំងមូល ៕

អាជ្ញាធរជាតិអប្សរាកំពុងបង្កើនសកម្មភាពថែទាំតំបន់រមណីយដ្ឋានអង្គរ ដើម្បីត្រៀមទទួលភ្ញៀវសាជាថ្មី

ផ្សាយនៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០២១

ដើម្បីត្រៀមទទួលរួចជាស្រេចក្នុងការស្វាគមន៍ភ្ញៀវទេសចរសាជាថ្មីម្តងទៀត ក្រុមការងារភ្នាក់ងារទេសចរណ៍នៃអាជ្ញាធរជាតិអប្សរា កំពុងតែមមាញឹកក្នុងការរៀបចំសណ្តាប់ធ្នាប់ ការស្តារហេដ្ឋារចនាសម្ពន្ធ ដាំស្មួន ដាំកូនឈើ ការសម្អាតបរិស្ថាន គឺជាសកម្មភាពដែលមានជាប្រចាំនៅអង្គរ ដើម្បីត្រៀមបើកទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិនាពេលខាងមុខ។

ដោយឡែក ក្រុមការងារភ្នាក់ងារទេសចរណ៍ដែលនៅប្រចាំការតាមប្រាសាទក្នុងការណែនាំភ្ញៀវ សម្របសម្រួលបញ្ហាផ្សេងៗនៅបន្តបំពេញការងាររបស់ខ្លួនតាមប្រក្រតី។ ក្រៅពីភារកិច្ចរបស់ខ្លួនជាមួយភ្ញៀវទេសចរ ភ្នាក់ងារក៏បានចូលរួមយ៉ាងសកម្មក្នុងការងារផ្សេងៗជាមួយផ្នែកពាក់ព័ន្ធដទៃទៀតក្នុងតំបន់អង្គរ ដូចជា ការចូលរួមសម្អាតបរិស្ថាន ការតាមដានស្ថានភាពហានិភ័យនៃថ្មប្រាសាទ រនាំងថ្មបាំងទ្រូងផ្លូវ និងស្លាកសញ្ញាផ្សេងៗជាច្រើនកន្លែងទៀតក្នុងតំបន់អង្គរក្នុងគោលបំណងដើម្បីលើកកម្ពស់សោភ័ណភាពអនាម័យបរិស្ថាននិងសុខុមាលភាពរបស់ភ្ញៀវទេសចរដែលមកកម្សាន្ត។

សកម្មភាពជាប្រចាំនេះហើយ ដែលធ្វើឱ្យរមណីយ ដ្ឋានអង្គរនៅតែរក្សាបាននូវភាពស្អាត គង់វង្សយូរអង្វែង។ ជាពិសេសតាមរយៈការស្តារហេដ្ឋារចនាសម្ពន្ធ និងការរៀបចំស្មួនជាដើម កាន់តែបន្ថែមសម្រស់ដល់រមណីយដ្ឋានអង្គរ៕

ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរាបន្តដាំកូនឈើបំពេញចន្លោះនានា ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០២១

ក្រុមការងារនាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ សហការជាមួយភ្នាក់ងារទេសចរណ៍ កម្លាំងនគរបាលបេតិកភណ្ឌ រួមនិងក្រុមការងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា បានដាំកូនឈើឡើងវិញ ក៏ដូចជាបំពេញចន្លោះខ្វះខាតនៅតាមតំបន់ប្រាសាទមួយចំនួន ក្នុងតំបន់រមណីយដ្ឋានអង្គរ។

ដើមឈើដែលក្រុមការងារបានរៀបចំដាំឡើងវិញកាលពីពេលថ្មីៗនេះ រួមមាន នៅមុខប្រាសាទភ្នំបាខែង បានដើមកូនឈើចំនួន ៣១០ដើម មានដើមច្រេស១០០ដើម ដើមបេង៨០ដើម ដើមធ្នង់៨០ដើម និងដើមរំដួល៥០ដើម។

បន្ថែមពីនេះ ក្រុមការងារក៏បានសហការដឹករណ្តៅដាំកូនឈើនៅចំណុចកសិន្ធុខាងត្បូងអង្គរវត្ត និងបានដាំកូនឈើសរុប ២៦០ដើម មានដើមយាង ១០០ដើម ដើមគគីរ ១០០ដើម និងដើមរំដួល៦០ដើម។

អាជ្ញាធរជាតិអប្សរានៅបន្តដាំដើមឈើដើម្បីបំពេញនៅទីកន្លែងមួយចំនួនទៀតនៅរមណីយដ្ឋានអង្គរ ក្នុងន័យដើម្បីបង្កើនគម្របព្រៃឈើ និងសោភ័ណភាពក្នុងតំបន់កាន់តែល្អប្រសើរ។

រូបភាពប្រចាំថ្ងៃ៖ ប្រាសាទបន្ទាយស្រីនិងចម្លាក់ដ៏អស្ចារ្យ

ផ្សាយនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២១

នៅពេលគេនិយាយពីប្រាសាទបន្ទាយស្រី នោះគេនឹងនឹកឃើញនូវក្បូរក្បាច់ចម្លាក់ដ៏អស្ចារ្យ ដែលផុសពីផ្ទាំងថ្មភក់ពណ៌ផ្កាឈូកកម្រមាន ដែលទស្សនីយភាពនេះបានជិតជាប់ក្នុងក្រអៅបេះដូងភ្ញៀវទេសចរគ្រប់ៗរូប។ ដ្បិតថា មានចម្ងាយឆ្ងាយពីទីរួមខេត្តប្រមាណ៣០គីឡូម៉ែត្រក៏ពិតមែន តែភ្ញៀវទេសចរដែលបានមកកម្សាន្តខេត្តសៀមរាប កម្រចោលការទស្សនានៅប្រាសាទបន្ទាយស្រីនេះណាស់។

ប្រាសាទបន្ទាយស្រីកសាងឡើងនៅឆ្នាំ ៩៦៧ នៃគ.ស ក្នុងរាជ្យព្រះបាទរាជេន្ទ្រវរ្ម័នទី២ គឺមុនប្រាសាទអង្គរវត្ត និងប្រាសាទអង្គរធំ (បាយ័ន្ត) ទៅទៀត។ ប្រាសាទនេះកសាងឡើងដោយព្រហ្មណ៍ម្នាក់ឈ្មោះ យជ្ញវរាហ ដែលជាព្រះគ្រូរបស់ព្រះបាទជ័យវរ្ម័នទី៥ដើម្បីឧទ្ទិសថ្វាយដល់ព្រហ្មញ្ញសាសនា។ ឈ្មោះដើមនៃប្រាសាទនេះ គឺឥស្វរបុរ ដែលមានន័យថា បុរីនៃឥស្វរ លុះក្រោយមកក៏ហៅថាបន្ទាយស្រីវិញ៕

រយៈពេល៥ថ្ងៃ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៣១សំណើ

ផ្សាយនៅថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០២១

ចាប់ពីថ្ងៃទី៦ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤ គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិសាលាក្រវ៉ាន់ ឃុំរំចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិអារក្សស្វាយ សង្កាត់នគរធំ ភូមិបឹងដូចប៉ា សង្កាត់ស្លក្រាម។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិស្រះស្រង់ជើង និងស្រះស្រង់ត្បូង សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

ក្រុមការងារសហគមន៍ប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅភូមិព្រៃធ្លក ភូមិគោកត្រាច ភូមិគោកស្នួល ភូមិស្វាយ ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង អនុញ្ញាតបាន៧សំណើ។

ក្រុមការងារប្រចាំស្រុក អង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិត្រពាំងស្វាយ និងភូមិលាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំស្រុក បន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិតាត្រៃ ភូមិព្រះដាក់ ភូមិថ្នល់បណ្តោយ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក ចាប់ពី៦ ដល់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤គោលដៅបានអនុញ្ញាតជួសជុលផ្ទះបានចំនួន៣១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកឃើញទបង្ហូរទឹកបុរាណ នៅព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០២១

ក្នុងការអនុវត្តគម្រោងកែលម្អផ្លូវដើរ ដាំស្មៅ និងប្រព័ន្ធរំដោះទឹកនៅបរិវេណព្រះលានជល់ដំរីក្នុងក្រុងអង្គរធំ ការសិក្សាអំពីផលប៉ះពាល់បុរាណវិទ្យា គឺជាផ្នែកមួយយ៉ាងសំខាន់ដើម្បីស្វែងយល់ពីពីរចនាសម្ព័ន្ធ និងដំណាក់កាលនៃការរៀបចំទីធ្លាដែលប្រើប្រាស់នៅមុខព្រះបរមរាជវាំង និងការវិវឌ្ឍរបស់រចនាសម្ព័ន្ធបុរាណផ្សេងៗ ដែលនៅក្រោមដីទៅតាមយុគសម័យនីមួយៗ។

ជាលទ្ធផលក្រុមបុរាណវិទូបានប្រទះឃើញនូវរចនាសម្ព័ន្ធបុរាណជាច្រើនដូចជាប្រព័ន្ធផ្លូវប្រព័ន្ធចង្អូរទឹកនៅអមផ្លូវពីមុខព្រះបរមរាជវាំងទៅខ្លោងទ្វារជ័យព្រមទាំងរចនាសម្ព័ន្ធសំណង់ផ្សេងៗជាច្រើនទៀត។

ពិសេសជាងនេះទៀត គឺក្រុមបុរាណវិទូបានរកឃើញទបង្ហូរ (លូបង្ហូរទឹក) បុរាណមួយបន្ថែមទៀត នៅខាងជើងផ្លូវចុះកណ្តាលនៃខឿនព្រះលានជល់ដំរីបន្តិច ដែលបុព្វបុរសស្ថាបនាឆ្លងកាត់ផ្លូវទទឹងថ្ងៃ (ផ្លូវចេញពីប្រាសាទបាយ័ន្តទៅខ្លោងទ្វារដើផ្ទាំង) នៃក្រុងអង្គរធំ។ ព្រមទាំងមានស្នាមដានជើងសសរឈើដែលបញ្ជាក់ថាមានសំណង់អំពីឈើឬហៅថារោងទោងអំពីឈើប្រក់ក្បឿងនៅតាមបណ្តោយផ្លូវប្រវែងជិត៨០ម៉ែត្រ។

លោក ខៀវ ច័ន្ទ បុរាណវិទូនិងជាអ្នកទទួលខុសត្រូវការដ្ឋានកំណាយបានសន្និដ្ឋានថានេះជាដំណាក់កាលដំបូងនៃព្រះបរមរាជវាំង ប្រហែលជារាជព្រះបាទយសោវរ្ម័ន (ទី១) ពេលដែលផ្លាស់រាជធានីពីរលួសមកអង្គរដែលយកភ្នំបាខែងជាចំណុចកណ្តាលនៃក្រុងយសោធរបុរី។

ចំពោះទបង្ហូរទឹក (លូបង្ហូរទឹក) បុរាណដែលទើបរកឃើញថ្មីនេះ លោក ខៀវ ច័ន្ទ បញ្ជាក់ថា បានស្ថាបនាឡើងដោយយកថ្មបាយក្រៀមធ្វើជាជញ្ជាំងសងខាង និងថ្មភក់ធ្វើជាគម្របពីលើ មានកម្ពស់ជិតកន្លះម៉ែត្រនិងទទឹងមុខសម្រាប់ទឹកហូរ០,២ម៉ែត្រនិងមានបណ្តោយ៦ម៉ែត្រ ដើម្បីរំដោះទឹកចេញពីមុខព្រះបរមរាជវាំង ចូលទៅក្នុងប្រព័ន្ធប្រឡាយធំខាងកើតដែលនៅបែផ្លូវទៅខ្លោងទ្វារជ័យ ហើយហូចូលទៅបឹងធំដែលស្ថិតនៅទិសនិរតីនិងធ្លាក់ទៅក្នុងសិន្ធុអង្គរធំតាមរន្ធត្រដេវ។

លោកបញ្ជាក់ទៀតថា បើផ្អែកលើសមុច្ច័យដែលបានរកឃើញនៅក្នុងស្រទាប់ដីនីមួយៗ គេអាចសន្និដ្ឋានជាបឋមបានថា ទបង្ហូរទឹកបុរាណនេះអាចស្ថាបនាឡើងនៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៧ ក្នុងពេលដែលព្រះអង្គបានរៀបចំក្រុងអង្គរធំឱ្យមានប្រព័ន្ធផ្លូវនិងប្រព័ន្ធប្រឡាយទឹកខ្វាត់ខ្វែងជាក្រឡាចត្រង្គពាសពេញក្រុង។ ដោយមានរន្ធត្រដេវនៅទិសឦសានសម្រាប់បញ្ចូលទឹកមកក្នុងក្រុង និងរន្ធត្រដេវនៅទិសនិរតីសម្រាប់បង្ហូរទឹកចេញពីក្រុងទៅសិន្ធុខាងក្រៅធ្លាក់ទៅបឹងទន្លេសាប។

ក្រៅពីនេះព្រះអង្គក៏បានស្ថាបនាកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញក្រុងដែលមានទំហំ៣គីឡូម៉ែត្របួនជ្រុងផងដែរ។

ព្រះលាននេះ ត្រូវបានសាងឡើងនៅចុងសតវត្សទី១២ដោយព្រះបាទជ័យវរ្ម័នទី៧ ក្នុងរចនាបទបាយ័ន្ត។ នៅទីនេះ បុព្វបុរសខ្មែរបានសាងខឿនខ្ពស់ផុតពីដីមួយជួរវែង លាតសន្ធឹងតាមបណ្តោយកំពែងរាជវាំងខាងកើត លយហួសទៅជើងនិងហួសទៅត្បូង ដែលមានរានហាលចំនួនបីនិងមានពីរជាន់។ នៅលើខឿននេះដើមឡើយមានអគារសាងពីឈើប្រក់ក្បឿង តែសព្វថ្ងៃយើងមើលមិនឃើញទេ ឃើញតែស្លាកស្នាមថ្មនៅខាងក្រោមប៉ុណ្ណោះ។

គួរបញ្ជាក់ដែរថា នៅក្នុងក្រុងអង្គរធំមានអាងស្តុកទឹកចំនួន៣គឺ បឹងតាត្រួតនៅទិសឦសាន្ត បឹងដូនមានៅខាងលិចព្រះបរមរាជវាំង និងបឹងធំនៅទិសនិរតី៕



ពន្លឺថ្ងៃលិចចែងចាំងដ៏ស្រស់ស្អាតបន្ថែមសម្រស់មួយកម្រិតទៀតដល់ប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០២១

ពន្លឺព្រះអាទិត្យពណ៌មាស បានចែងចាំងមកលើប្រាសាទអង្គរវត្ត ពិសេសឆ្លុះស្រមោលតាមចម្រឹងបង្អួចប្រាសាទ បង្កើតជាភាពស្រស់ស្អាត និងទាក់ទាញថែមមួយកម្រិតទៀត។ ទិដ្ឋភាពថ្ងៃរះនិងថ្ងៃលិចនៅប្រាសាទអង្គរវត្ត គឺជាផ្ទាំងទស្សនីយភាពដ៏ទាក់ទាញមួយសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ហើយកាន់តែពិសេសនិងទាក់ទាញទៀតនោះ គឺព្រឹត្តិការណ៍ថ្ងៃរះលើកំពូលប្រាង្គកណ្តាលនៃប្រាសាទអង្គរវត្ត ដែលតែងកើតមានពីរដងក្នុងមួយឆ្នាំ៕

សត្វស្លាប៣ប្រភេទផ្សេងទៀត ត្រៀមដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២១

កាលពីចុងសប្តាហ៍កន្លងទៅ គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការ Wildlife Alliance បានដឹកជញ្ជូនសត្វស្លាប៣ប្រភេទផ្សេងទៀត សរុបចំនួន ១១ក្បាល មកកាន់ព្រៃរមណីយដ្ឋានអង្គរ។ សត្វស្លាបទាំងនោះរួមមាន សត្វក្ងោក (Peafowl) ចំនួន៥ក្បាល សត្វកេងកងធំ (Great Hornbill) ចំនួន៣ក្បាល និងសត្វញ៉ាំង (Wreathed Hornbill) ចំនួន៣ក្បាល ដែលទទួលបានជាអំណោយពីអង្គការអភិរក្សសត្វព្រៃនានា និងប្រជាពលរដ្ឋយកមកផ្សាំនៅក្នុងព្រៃរមណីយដ្ឋានអង្គរ ដែលក្រុមការងារគម្រោងនឹងធ្វើការដោះលែងសត្វស្លាបទាំងនេះចេញពីទ្រុងចូលទៅក្នុងព្រៃនាពេលខាងមុខ។

កន្លងមកគម្រោងទទួលបានជោគជ័យក្នុងការដោះលែងសត្វព្រៃជាច្រើនប្រភេទចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ មានដូចជា សត្វទោចមកុដ (Pileated gibbon) ចំនួន១១ក្បាល (កើតកូនបានចំនួន៤ក្បាល) សត្វឈ្លូស (Red muntjac) ចំនួន៤ក្បាល សត្វស្វាព្រាម (Silvered langurs) ចំនួន១២ក្បាល សត្វសំពោចក្រអូប (Common palm civets) ចំនួន៥ក្បាល សត្វភេខ្លួនរលោង (Smooth-coated otter) ចំនួន៤ក្បាល (កើតកូនបានចំនួន២ក្បាល) សត្វឆ្មាដាវ (Leopard Cat) ចំនួន២ក្បាល និងសត្វកេងកងតូច (Oriental Pied Hornbill) ចំនួន២ក្បាល និងសត្វផ្សេងៗមួយចំនួនទៀត។ មកដល់សព្វថ្ងៃ សត្វទាំងអស់នេះនៅតែមានវត្តមាននៅទីនោះនៅឡើយក្រោមការយកចិត្តទុកដាក់តាមដាន និងថែទាំជាប្រចាំពីក្រុមការងារ។

ដើម្បីឱ្យសត្វព្រៃទាំងអស់បន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ចូលរួមថែរក្សាសត្វព្រៃទាំងនោះទាំងអស់គ្នា ចៀសវាងពេលប្រទះឃើញមានបំណងមិនល្អ និងមេត្តាកុំផ្តល់ចំណីឱ្យសត្វទាំងនោះ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិត្រពាំងសេះ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសម្អាតប្រាសាទរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកតម្លៃបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០២១

ប្រសិនបើគ្មានការថែទាំ និងសម្អាតអនាម័យជាទៀងទាត់ពីសំណាក់ក្រុមការងារសម្អាតប្រាសាទ ម្លេះតំបន់រមណីយដ្ឋានអង្គរ នឹងមិនស្រស់ស្អាតដូចដែលសាធារណជនបានឃើញនោះទេ។ ជារៀងរាល់ថ្ងៃ ពួកគេបានបែងចែកជាក្រុមៗ ខ្លះបោសស្លឹកឈើ បោសដី ស្រោចស្មៅ កាត់រុក្ខជាតិទាំងតូចទាំងធំ ក្នុងនិងក្រៅប្រាសាទ មួយទៀតនោះគឺបារស្លៃ និងរុក្ខជាតិក្នុងទឹក។ល។

សកម្មភាពទាំងនេះ គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យតំបន់ប្រាសាទមានសោភ័ណភាពស្អាត ក្រៅពីកិច្ចការអភិរក្សដែលអាជ្ញាធរជាតិអប្សរា បាននិងកំពុងធ្វើជាប្រចាំហើយនោះ។

យ៉ាងណាកិច្ចការទាំងអស់នេះមិនអាចខ្វះការចូលរួមពីសាធារណជន ក៏ដូចជាភ្ញៀវទេសចរបានទេ។ យើងទាំងអស់គ្នា ត្រូវមានស្មារតីតែមួយក្នុងការធ្វើឱ្យបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរមានភាពស្រស់ស្អាត ទាក់ទាញភ្ញៀវទេសចរ ពិសេសស័ក្តិសមជាមួយគុណតម្លៃមិនអាចកាត់ថ្លៃបាន នៃរមណីយដ្ឋានរបស់មនុស្សជាតិ៕

ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរា កំពុងដំណើរការជួសជុលផ្លូវចូលខាងកើតប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១

ដោយសារអាយុកាល ការប្រែប្រួលនៃធម្មជាតិ រួមផ្សំនឹងកត្តាផ្សេងៗទៀត បានធ្វើឱ្យប្រាសាទដ៏ អស្ចារ្យមួយនេះទទួលរងនូវការខូចខាតនិងមានសភាពទ្រុឌទ្រោមយ៉ាងខ្លាំង។ ដើម្បីសង្គ្រោះប្រាសាទនេះ ឱ្យរួចផុតពីគ្រោះថ្នាក់ អាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុល ទល់ទ្រ នៅតាមបណ្តាចំណុចខូចខាតដែលប្រឈមនឹងគ្រោះថ្នាក់ជាច្រើនកន្លែងរួចមកហើយ។

បច្ចុប្បន្ននេះ ក្រុមអ្នកបច្ចេកទេសអាជ្ញាធរជាតិអប្សរាកំពុងបន្តធ្វើការជួសជុលផ្លូវចូលពីខាងកើតដែលក្រាលដោយថ្មបាយក្រៀម ចន្លោះខ្លោងទ្វារទី៣និងទី៤មានសភាពទ្រុឌទ្រោមខ្លាំង ។

បើតាមការបញ្ជាក់របស់លោក សារ៉ាយ គឹមហួល ជាមន្ត្រីបច្ចេកទេសនិងជាអ្នកទទួលខុសត្រូវកិច្ចការអភិរក្សប្រាសាទបន្ទាយស្រីបានឱ្យដឹងថា៖ ផ្លូវចូលប្រាសាទពីខាងកើតនេះមានប្រវែង៥៧ម៉ែត្រ ទទឹង៣,៣ម៉ែត្រ ក្រាលដោយថ្មបាយក្រៀម។

ការជួសជុលនេះ គឺយើងធ្វើទៅតាមបច្ចេកទេសបុរាណទាំងអស់។ ចំពោះថ្មដែលបាត់បង់ បែកបាក់ និងពុកផុយ ក្រុមការងារមិនបានប្រើប្រាស់ថ្មបាយក្រៀមថ្មីមកជំនួសទេ គឺប្រើប្រាស់កំបោរបាយអរពិសេសម្យ៉ាង ដែលផ្សំឡើងតាមរបៀបបុរាណរួមមាន កំបោរលៀស ម្សៅឥដ្ឋ ម្សៅថ្មបាយក្រៀមហ្មត់ ម្សៅថ្មបាយក្រៀមគ្រើម ខ្សាច់ និងស្ករត្នោត មកបំពេញជំនួសថ្មបាយក្រៀមដែលបានបាត់ឬខូច ធ្វើយ៉ាងណាឱ្យមានលក្ខណៈស្រដៀងថ្មបាយក្រៀម។មកដល់ពេលនេះក្រុមការងារបានធ្វើការជួសជុលបានជិត៥០% ភាគរយហើយ។

គួរបញ្ជាក់ដែរថា ប្រាសាទបន្ទាយស្រីដែលមានឈ្មោះដើម ស្រីត្រិភុវនមហេស្វរៈ នេះត្រូវបានចាប់ផ្តើមសាងឡើងដោយព្រះរាជគ្រូព្រាហ្មណ៍ម្នាក់ឈ្មោះថា យជ្ញវរាហ នាអំឡុងសតវត្សរ៍ទី១០ ក្រោមរជ្ជកាលរបស់ព្រះបាទ រាជេន្ទ្រវរ្ម័នទី២ (រវាង គ.ស. ឆ្នាំ៩៤៤ដល់៩៦៨) និងកសាង រួចរាល់ជាស្ថាពរនៅក្រោមរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥ (គ.សឆ្នាំ៩៦៨-១០០១)ដើម្បីឧទ្ទិសដល់ព្រះសិវៈ៕

ក្រុមការងារសម្អាតប្រាសាទរួមចំណែកយ៉ាងសំខាន់ ក្នុងការលើកតម្លៃបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិគោព្នៅ ភូមិតាកាំ ភូមិអន្លង់គ្គន់ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិវាល សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន២សំណើ។

សរុបមក នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង២គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៩សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សោភ័ណភាពព្រះវិហារវត្តរាជបូណ៌ ទីអារាមដ៏ចំណាស់ក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២១

វត្តរាជបូណ៌ ស្ថិតនៅទិសខាងកើតនៃក្រុងសៀមរាប ជាវត្តដ៏ធំ និងជាទីចាប់អារម្មណ៍បំផុតក្នុងក្រុងសៀមរាប ហើយក៏ជាវត្តមួយក្នុងចំណោមវត្តដែលមានវ័យចំណាស់បំផុតក្នុងខេត្តទាំងមូល។ តាមឯកសារប្រវត្តិរបស់វត្តនេះ គឺសាងសង់ឡើង ក្នុងរវាងឆ្នាំ១៦៥០។

ព្រះវិហារបុរាណមួយនៃវត្តរាជបូណ៌ ត្រូវបានជួសជួលអភិរក្សដោយអាជ្ញាធរជាតិអប្សរាដែលរក្សាបាននូវទម្រង់ដើមទាំងស្រុង។សំណង់ដែលមានអាយុកាល៣៧១ឆ្នាំនេះ មានលក្ខណៈស្ថាបត្យកម្មដ៏ល្អឯករចនាដោយក្បូរក្បាច់បង្ហាញនូវស្នាដៃសិល្បៈខ្មែរពិតៗទាំងដំបូល តួព្រះវិហារ គ្រឹះ ហោជាង សន្លឹកទ្វារ សន្លឹកបង្អួច ព្រះពុទ្ធបដិមា បល្ល័ង្ក សសរ រូបគំនូរ ពណ៌ ព្រមទាំងក្នុងបរិវេណវត្តអារាមនេះ មានដើមឈើតូចធំ ផ្តល់ជាម្លប់ត្រឈឹងត្រឈៃក្រៃលែង៕

ទិដ្ឋភាពប្រាសាទនាគព័ន្ធ៖ ទេសភាពវប្បធម៌នាសតវត្សរ៍ទី១២ រំលេចជាថ្មីនៅសតវត្សរ៍ទី២១

ផ្សាយនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០២១

នៅឆ្នាំ២០០៧បារាយណ៍ជ័យតាដាក(បារាយណ៍ខាងជើង) ត្រូវបានអាជ្ញាធរជាតិអប្សរាធ្វើការលើកតម្លៃនិងបន្តតួនាទីដើមរបស់ខ្លួនឡើងវិញតាមរយៈការជួសជុលប្រព័ន្ធបង្ហូរទឹកបុរាណឡើងវិញ ហើយអាងទឹកទាំងប្រាំនៃប្រាសាទនាគព័ន្ធអាចរក្សាទឹកបានខួបប្រាំងខួបវស្សា។ កិច្ចការនេះ ត្រូវបានចាប់ផ្ដើមបន្ទាប់ពីអ្នកជំនាញខាងផ្នែកគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានរកឃើញប្រព័ន្ធបង្ហូរទឹកបុរាណកាលពីឆ្នាំ២០០៥។

ការណ៍នេះធ្វើឱ្យបារាយណ៍មានទេសភាពនាដើមរដូវវស្សាដែលភ្លៀងចាប់ផ្ដើមធ្លាក់មករុក្ខជាតិជុំវិញចាប់ផ្ដើមបញ្ចេញពណ៌បៃតងខៀវខ្ចី ដ៏ស្រស់បំព្រង គួរជាទីគយគន់ ដែលអាចអន្ទងអារម្មណ៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិ នៅពេលដែលបានទៅទស្សនាប្រាសាទនាគព័ន្ធ។

គួររំឭកថា បារាយណ៍ជ័យតាដាក (បារាយណ៍ខាងជើង) ស្ថាបនាឡើងក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ អស់រយៈកាលជិតមួយពាន់ឆ្នាំមកហើយ និងមានបណ្ដោយ ៣៦០០ម ទទឹង ៩៣០ម។ បច្ចុប្បន្ន បារាយណ៍នេះកំពុងដើរតួយ៉ាងសំខាន់ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់ប្រើប្រាស់ ក្នុងវិស័យកសិកម្ម ដល់មនុស្សសត្វ និងទ្រទ្រង់កិច្ចការអភិរក្សក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្ដែង ក្រុមការងារប្រចាំស្រុកអង្គរធំ បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិលាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

ក្រុមការងារប្រចាំពួក បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិត្នោតជ្រុំ ភូមិដូនកែវ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន២សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាបបានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិវាល និង ភូមិទក្សិណត្បូង សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ទិដ្ឋភាពថ្ងៃរះពណ៌មាសដ៏ស្រស់ត្រកាលនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២១

ប្រាសាទអង្គរវត្ត គឺជាសំណង់អច្ឆរិយៈដ៏អស្ចារ្យនៅលើលោក ដែលកសាងដោយដៃរបស់បុព្វបុរសខ្មែរ។ មិនត្រឹមតែមានអាយុកាលជាងមួយពាន់ឆ្នាំមកនោះទេ ប្រាសាទអង្គរវត្តត្រូវបានរចនាដោយក្បាច់ចម្លាក់យ៉ាងរស់រវើកលើជញ្ជាំងប្រាសាទ។ រីឯ ធម្មជាតិ និងទេសភាពជុំវិញក៏សុទ្ធតែបានចូលរួមចំណែកលើកតម្លៃប្រាសាទនិងទាក់ទាញទេសចរណ៍គ្រប់ជាតិសាសន៍មកទស្សនា។

ទិដ្ឋភាពដ៏អស្ចារ្យ ដែលមនុស្សគ្រប់គ្នាប្រាថ្នាចង់ឃើញនោះ គឺប្រាសាទអង្គរវត្តនាពេលថ្ងៃរះនាព្រឹកព្រលឹមស្រាងៗ ដែលបានបង្កើតជាទិដ្ឋភាពដ៏ស្រស់ឆើតឆាយជាមួយរស្មីពណ៌មាសពីទិសបូព៌ គួរជាទីទស្សនាមិនជិនណាយដែរ។

សូមអញ្ជើញទស្សនារូបភាពថ្ងៃរះនៅប្រាសាទអង្គរវត្តនាព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ដូចតទៅ៖

អាជ្ញាធរជាតិអប្សរា គ្រោងកាត់ក្រី និងដកហូតដើមឈើ មានហានិភ័យខ្ពស់ នៅប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន និងនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា រួមជាមួយផ្នែកពាក់ព័ន្ធបានចុះពិនិត្យនិងគ្រោងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើដែលកំពុងមានហានិភ័យខ្ពស់ និងបាំងទេសភាពនៅប្រាសាទលលៃ។

កិច្ចការនេះធ្វើឡើងក្នុងបំណង ដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យ ប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទកាន់តែធ្ងន់ធ្ងរ និងលើកតម្លៃទេសភាពនៅបរិវេណនោះផង ព្រមទាំងជួយសម្រួលដល់គម្រោងជួសជុលនិងអភិរក្សប្រាសាទលលៃ ដែលកំពុងដំណើរការអនុវត្តឲ្យទាន់ពេលវេលាតាមផែនការដែលបានគ្រោងទុក។

ដើមឈើដែលនឹងត្រូវកាត់ក្រីរួមមាន ដើមពោធិ៍១ដើម ត្រចៀកដំរី១ដើមនិងជ្រៃ១ដើមត្រូវក្រីមែកចេញចំនួន១២មែក ដើម្បីជួយសម្រាលតួដើម និងបើកទេសភាពប្រាសាទឡើងវិញផង។ ចំណែកឯដើមឈើដែលនឹងកាត់ដកហូត និងគាស់ចេញទុកដាំនៅទីតាំងផ្សេងរួមមាន ដើមស្តៅ១ដើម ស្វាយ១ដើម ដូង២ដើម ខ្នុរ១ដើម ជ្រៃ២ដើម គ១ដើម ថ្កូវ១ដើម ពោធិ៍១ដើម រំដួល១០ដើម ព្រីង១ដើម ចំប៉ី២ដើម និងត្របែកព្រៃ១ដើម។

អាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារនេះចាប់ពីថ្ងៃអង្គារ ទី២៥ ខែឧសភា ឆ្នាំ២០២១ រហូតដល់បញ្ចប់ការងារ៕

ទិដ្ឋភាពផ្លូវវង់ធំ អមដោយទេសភាពដ៏ស្រស់ត្រកាលកំពុងបញ្ចេញ សម្រស់ទាក់ទាញភ្ញៀវទេសចរនារដូវវស្សា

ផ្សាយនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២១

ក្រោមការខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា ក្នុងការកែលម្អផ្លូវវង់ធំរហូតទទួលបានការកោតសរសើរ និងទាក់ទាញភ្ញៀវទេសចរ ដែលកំពុងធ្វើចរាចរកម្សាន្តលើដងផ្លូវជាលក្ខណៈគ្រួសារ ជាពិសេសគឺ ភ្ញៀវទេសចរជិះកង់កម្សាន្តនាពេលល្ងាចក្នុងរមណីយដ្ឋានអង្គរ។

ផ្លូវនេះទៀតសោត គឺអមដោយដើមឈើតូចធំដែលមានពណ៌ខៀវដ៏ស្រស់ត្រកាលគ្របដណ្តប់លើដងផ្លូវលាយឡំដោយសម្លេងសត្វយំពិរោះរណ្តំ ធ្វើឱ្យភ្ញៀវទេសចររំសាយភាពតានតឹងក្នុងចិត្ត និងទុក្ខកង្វល់ផងដែរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន៣គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបាគង បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិគោកចាន់ ឃុំអំពិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។

ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិត្លង់ និងភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិរំចេក និងភូមិសាលាក្រវ៉ាន់ ឃុំរំចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៣គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

កូនឈើចំនួនជាង២០០០ដើម ត្រូវបានចែកជូនដល់ព្រះសង្ឃ និងប្រជាពលរដ្ឋក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១

ព្រះសង្ឃ ព្រមទាំងប្រជាពលរដ្ឋជិតឆ្ងាយ បានបន្តដាក់ពាក្យស្នើសុំកូនឈើ ដើម្បីយកទៅដាំនៅតាមដីចម្ការ និងដីភូមិ ទៅតាមតម្រូវការជាក់ស្តែង។ ក្នុងសប្តាហ៍នេះ អាជ្ញាធរជាតិអប្សរា បានផ្តល់កូនឈើសរុបចំនួន ២,០៦០ដើម ជូនព្រះសង្ឃ និងប្រជាពលរដ្ឋ ដែលរស់នៅបណ្តាភូមិស្រុកនានាជុំវិញខេត្តសៀមរាប។

ព្រះសង្ឃ និងប្រជាពលរដ្ឋដែលទទួលបានដើមឈើពីអាជ្ញាធរជាតិអប្សរា ក្នុងនោះរួមមាន៖

ទី១. ផ្តល់កូនឈើជូនលោក ម៉ោល អ៊ី នាយកសាលាបឋមសិក្សាអំពិលពាម ចំនួន២០០ដើម ដើម្បីយកទៅដាំជុំវិញបរិវេណសាលារៀន ស្ថិតនៅភូមិអំពិលពាម ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គគីរចំនួន៥០ដើម ធ្នង់ចំនួន៥០ដើម គ្រញូងចំនួន៥០ដើម និងរំដួលចំនួន៥០ដើម។

ទី២. ផ្តល់កូនឈើជូនលោក ប្រាក់ សុជេត តំណាងរដ្ឋបាលឃុំល្វា ចំនួន៨០០ដើម ដើម្បីយកទៅដាំនៅជុំវិញស្រះសហគមន៍ ស្ថិតនៅភូមិជ្រាស់ ឃុំល្វា ស្រុកពួក ខេត្តសៀមរាប ។ កូនឈើទាំងនោះរួមមាន គ្រញូងចំនួន២០០ដើម បេងចំនួន១០០ដើម ធ្នង់ចំនួន១០០ដើម ច្រេសចំនួន២០០ដើម និងគគីរចំនួន២០០ដើម។

ទី៣. ផ្តល់កូនឈើជូនតំណាងព្រះតេជគុណ ឡាច លាង ព្រះអនុគណក្រុងសៀមរាប ចំនួន១,០០០ដើម ដើម្បីយកទៅដាំនៅតាមទីវត្តអារាម និងសាលារៀននានាក្នុងខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ត្របែកព្រៃ៥០ដើម រំដួល១០០ដើម គ្រញូង២០០ដើម ធ្នង់១០០ដើម ច្រេសចំនួន៥០ដើម ឈើទាល២០០ដើម គគីរចំនួន២០០ដើម និងកកោះ១០០ដើម។

ទី៤. ផ្តល់កូនឈើជូនតំណាងព្រះតេជគុណ ហែម គឹមសាន ព្រះគ្រូចៅអធិការវត្តប្រាសាទគោកចក ចំនួន៦០ដើម ដើម្បីយកទៅដាំនៅក្នុងទីធ្លាវត្តមាន គ្រញូង១០ដើម ធ្នង់២០ដើម បេង១០ដើម និងច្រេស២០ដើម៕

សាលាឆាន់ដ៏ចំណាស់ចំនួន១ខ្នងនៅវត្តរាជបូណ៌ត្រូវបានជួសជុលឡើងវិញដោយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១

សំណង់សាលាឆាន់ចំនួន១ខ្នង ស្ថិតនៅក្នុងវត្តរាជបូណ៌ ដែលជាសម្បត្តិបេតិកភណ្ឌព្រះពុទ្ធសាសនាខ្មែរត្រូវបាន ជួសជុល និងអភិរក្សឡើងវិញដោយអ្នកជំនាញបច្ចេកទេស នៃអាជ្ញាធរជាតិអប្សរា ក្រោមការផ្តួចផ្តើមរបស់ព្រះមហាវិមលធម្ម ពិន សែម សិរីសុវណ្ណោ ព្រះរាជាគណៈថ្នាក់ទោ និងជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌។

ព្រះអង្គតែងតែមានព្រះទ័យយកចិត្តទុកដាក់ក្នុងការងារថែរក្សា អភិរក្សនូវសំណង់បេតិកភណ្ឌព្រះពុទ្ធសាសនាក្នុងខេត្តសៀមរាប ដើម្បីចូលរួមចំណែកថែរក្សាមរតកវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនា ព្រមទាំងអភិរក្ស និងលើកតម្លៃវប្បធម៌នៃសិល្បៈរបស់ខ្មែរពីបុរាណកាលដ៏រស់រវើក ឱ្យនៅឋិតថេរទៅមុខទៀតសម្រាប់ទុកជាកេរដំណែលដល់កូនចៅជំនាន់ក្រោយ។

បច្ចុប្បន្ន សំណង់អគារសាលាឆាន់នៅវត្តរាជបូណ៌នេះមានបណ្តោយប្រវែង២២.៨ម៉ែត្រ ទទឹង ២១.២៥ម៉ែត្រ និងកម្ពស់១០.៩២ម៉ែត្រ កំពុងស្ថិតក្នុងសភាពចាស់ទ្រុឌទ្រោម ដោយសារអាយុកាល ហើយគ្រោងនឹងបញ្ចប់ការជួសជុលនៅខែកញ្ញា ឆ្នាំ២០២១ ខាងមុខនេះក្រោមការប្រឹក្សាបច្ចេកទេស និងថវិកាទាំងស្រុងពីអាជ្ញាធរជាតិអប្សរា។

គួរបញ្ជាក់ដែរថា នេះជាលើកទី២ហើយដែលអាជ្ញាធរជាតិអប្សរាបានធ្វើការជួសជុលសំណង់បុរាណនៅក្នុងវត្តរាជបូណ៌បន្ទាប់ពីបានជួសជុលព្រះវិហារក្នុងវត្តនេះរួចរាល់កាលពីឆ្នាំ២០២០កន្លងមក៕

ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១២៧សំណើ

ផ្សាយនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១

លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំខែឧសភា ក្នុងឆ្នាំ២០២១ បានចុះផ្សព្វផ្សាយអប់រំ និងពិនិត្យការស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចទាំង៥ស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរបានចំនួន២៣៦សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន១២៧សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន១៩សំណើ ស្រុកអង្គរធំបានចំនួន២៤សំណើ ស្រុកពួកបានចំនួន១៦សំណើ ក្រុងសៀមរាបបានចំនួន៣៥សំណើ និងស្រុកបន្ទាយស្រីបានចំនួន៣៣សំណើ សរុបចំនួន១២៧សំណើ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧបត្ថម្ភជាសម្ភារៈប្រើប្រាស់ រួមទាំងថវិកាជូនគ្រួសារដែលរងគ្រោះធម្មជាតិ ចាស់ជរា កុមារមានជំងឺ ជនពិការ គ្រួសារខ្វះខាតមួយចំនួន កិច្ចការសាសនា និងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ថែមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង ១១២ភូមិក្នុងតំបន់អង្គរ។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើ

ប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សាលាឆាន់ដ៏ចំណាស់ចំនួន១ខ្នងនៅវត្តរាជបុណ្យត្រូវបានជួសជុល ឡើងវិញដោយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០២១

ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន៤គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិសំរោង និងភូមិជួនឪ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំស្រុកពួកបានពិនិត្យនិងដោះស្រាយស្ថិតក្នុងភូមិគោកស្នួល ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាប បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

ក្រុមការងារប្រចាំក្រៅឧទ្យានអង្គរ បានពិនិត្យនិងដោះស្រាយស្ថិតនៅក្នុងឃុំបឹងមាលា។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សរុបមក នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៤គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២០សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែមិថុនា

ក្រុមការងារអាជ្ញាធរជាតិអប្សរាបានបញ្ចប់ការងារជួសជុលប្រាសាទផ្ទី

ផ្សាយនៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១

ក្រុមការងារនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅនិងក្នុងឧទ្យានអង្គរ នៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ការងារជួសជុលប្រាសាទផ្ទី ដែលស្ថិតនៅកណ្តាលបារាយណ៍នៃប្រាសាទបេងមាលា។គម្រោងជួសជុលនេះគឺធ្វើឡើងដោយមានការចូលរួមពីវិស័យឯកជន។

ឯកឧត្តម គឹម សុធិន អគ្គនាយករងអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា គម្រោងជួសជុលប្រាសាទផ្ទីបានសម្រេចរួចរាល់ហើយនៅចុងខែ ឧសភា នេះ បន្ទាប់ពីចាប់ផ្តើមដំណើរការនៅដើមខែ មេសា។ នៅដើមខែ មីនា ការធ្វើកំណាយពិនិត្យរចនាសម្ពន្ធប្រាសាទនេះ បានចាប់ផ្តើមនិងឈានដល់ការជួសជុលលើកតម្លៃឡើងវិញ ក្រោមការចូលរួមពីវិស័យឯកជន គឺលោកជំទាវហេមចិត្តាមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភ ម៉ៅ ម៉ាល័យ កែ គឹមយ៉ាន ក្នុងបំណងដើម្បីចូលរួមអភិរក្សមរតកសម្បត្តិបេតិកភណ្ឌជាតិ។

បើតាមការបញ្ជាក់ពីឯកឧត្តម គឹម សុធិន គម្រោងជួសជុលនេះមានការលំបាកបន្តិចដែរ ព្រោះការដ្ឋានស្ថិតនៅកណ្តាលបារាយណ៍ ក្នុងព្រៃ ហើយផ្លូវធ្វើដំណើរមានភាពតូចបន្តិចដែលពិបាកក្នុងការដឹកជញ្ជូនថ្មតាមរថយន្តធុនធ្ងន់។ យ៉ាងណា **ឯកឧត្តម គឹម សុធិន** បានបង្ហាញសុទិដ្ឋិនិយម និងអារម្មណ៍រីករាយជាខ្លាំងជាមួយសមិទ្ធផលថ្មីមួយបន្ថែមទៀតនេះ ពិសេសប្រាសាទដែលបានដួលរលំឃើញតែគំនរដុំថ្មហើយបានខិតខំរកផ្គុំឱ្យមានរូបរាងឡើងវិញ។

ប្រាសាទផ្ទីដែលស្ថិតនៅចំកណ្តាលបារាយណ៍ប្រាសាទបេងមាលា មានទីតាំងស្ថិតនៅភូមិបេងមាលា ឃុំបេងមាលា ស្រុកស្វាយលើ ខេត្តសៀមរាប។ ប្រាសាទនេះមានលក្ខណៈជាសំណង់ថ្មបាយក្រៀម រាងការេ ប្រវែង១៥ម៉ែត្របួនជ្រុង និងមានជញ្ជាំងព័ទ្ធជុំវិញកម្ពស់១ម៉ែត្រ ។ នៅចំកណ្តាលគេតម្កល់រូបព្រះពុទ្ធប្រក់នាគសរុបទាំងខឿនកម្ពស់ ៦,៥ម៉ែត្រ អំពីថ្មភក់ ដែលទំនងជាត្រូវបានសាងសង់ឡើងរវាងពាក់កណ្តាលសតវត្សទី១២ ទៅចុងសតវត្សទី១២៕

អាជ្ញាធរជាតិអប្សរារួមជាមួយ បញ្ជាការដ្ឋានយោធភូមិភាគទី៤ ដាំកូនឈើប្រមាណ១ម៉ឺនដើម នៅទីបញ្ជាការយោធភូមិភាគទី៤

ផ្សាយនៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរានិងសហការី បានអញ្ជើញចូលរួមពិធីប្រគល់និងដាំកូនឈើចម្រុះចំនួន១ម៉ឺនដើម នៅទីបញ្ជាការយោធភូមិភាគទី៤។

ពិធីនេះប្រារព្ធឡើងក្រោមអធិបតីភាព **ឯកឧត្តម ឧត្តមសេនីយឯក ពៅ ហេង** មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការដ្ឋានយោធភូមិភាគទី៤ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ពិន ប្រាកដ**

អភិបាលរងខេត្តសៀមរាប មេបញ្ជាការរង ខណ្ឌរដ្ឋបាលព្រៃឈើនៃមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទ តំណាងសហភាពសហព័ន្ធយុវជនកម្ពុជា ប្រធានចលនាយុវជន១៥៧ប្រចាំខេត្តសៀមរាប មន្ត្រីអាជ្ញាធរជាតិអប្សរា និងស្ថាប័នពាក់ព័ន្ធជាច្រើនទៀតចូលរួម។

ការដាំកូន ឈើចម្រុះ ប្រភេទបេង ធ្នង់ គ្រញូង និងនាងនួន លើផ្ទៃដី ទំហំ ជាង ២.៥ហិកតារនេះ ដើម្បីចូលរួមចំណែកក្នុងការថែរក្សា និងអភិរក្ស បរិស្ថានធម្មជាតិឱ្យកាន់តែមានភាពស្រស់បំព្រង នៅក្នុងបរិវេនយោធភូមិភាគទី៤ ជាពិសេសនៅក្នុងតំបន់រមណីដ្ឋានអង្គរទាំងមូល។

សូមជម្រាបជូនថា នេះជាឆ្នាំទីពីរហើយ ដែលអាជ្ញាធរជាតិអប្សរា សហការណ៍ជាមួយបញ្ជាការដ្ឋានយោធភូមិភាគទី៤ ដើម្បីដាំកូនឈើចម្រុះឡើងវិញ នៅបរិវេនទីបញ្ជាការដ្ឋានយោធភូមិភាគទី៤ ដែលលើកទី១បានដាំកាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ចំនួនមួយម៉ឺនដើម និងលើកទីពីរប្រារព្ធឡើងក្នុងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១នេះចំនួនមួយម៉ឺនដើម៕

អាជ្ញាធរជាតិអប្សរាបន្តអនុវត្តវិធានការការពារ ដើម្បីបង្ការការឆ្លងរាលដាលជំងឺកូវីត១៩ នៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២១

ស្របពេលរមណីយដ្ឋានអង្គរមានភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទស្សនាឡើងវិញ អាជ្ញាធរជាតិអប្សរាបានចាត់នូវវិធានការការពារទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩នេះ ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការ ៣កុំ ៣ការពារ ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល នៅតាមច្រកត្រួតពិនិត្យនីមួយៗ ដើម្បីសម្រួលដល់ភ្ញៀវទេសចរដែលចូលទស្សនាប្រាសាទនានា។

វិធានការ៣កុំ ៣ការពារ ដែលកំពុងអនុវត្តគឺចាំបាច់ត្រូវតែពាក់ម៉ាស់ លាងសម្អាតដៃជាមួយអាល់កុល ស្កេនQR Code វាស់កម្តៅ និងរក្សាគម្លាតក្នុងពេលដើរទស្សនា៕

អាជ្ញាធរជាតិអប្សរាទទួលវត្ថុបុរាណចំនួន៥ ពីបញ្ជាការដ្ឋានយោធភូមិភាគទី៤

ផ្សាយនៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២១

វត្ថុបុរាណចំនួន៥ ដែលបញ្ជាការដ្ឋានយោធភូមិភាគទី៤ បានរកឃើញនាពេលកន្លងមក បានសម្រេចប្រគល់ជូនដល់អាជ្ញាធរជាតិអប្សរា ដើម្បីយកមកថែរក្សា និងអភិរក្សបន្តទៀត។

ពិធីប្រគល់ទទួលវត្ថុបុរាណទាំង៥ប្រភេទនេះ ត្រូវបានទទួលដោយផ្ទាល់ពីសំណាក់ **ឯកឧត្តមហង់ ពៅ**អគ្គនាយកអាជ្ញាធរជាតិអប្សរា និងសហការី ក្នុងឱកាសអញ្ជើញចូលរួមពិធីប្រគល់និងដាំកូនឈើនាបញ្ជាការដ្ឋានយោធភូមិភាគទី៤ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១។

វត្ថុបុរាណដែលអាជ្ញាធរជាតិអប្សរា បានទទួលក្នុងឱកាសនោះរួមមាន៖

១.សសរពេជ្យមួយកំណាត់តូច
២.កំពូលប្រាសាទតាមជ្រុងនៃប្រាសាទធំ
៣.ផ្ទាំងថ្មមួយ
៤.ដុំហោជាងផ្នែកខាងលើ មានកំណាត់ព្រះសិរូបព្រះមួយផ្នែក
៥.បង្គោលព្រះទិស មួយដុំ។

សូមជម្រាបជូនថា នេះមិនមែនជាលើកទី១ទេ ដែលអាជ្ញាធរជាតិអប្សរា បានទទួលវត្ថុបុរាណពីស្ថាប័នពាក់ព័ន្ធ និងបងប្អូនប្រជាពលរដ្ឋនានាដែលបានប្រទះឃើញនិងស្ម័គ្រប្រគល់ជូនអាជ្ញាធរជាតិអប្សរា ធ្វើការថែរក្សា និងអភិរក្សដើម្បីសម្រាប់កូនចៅជំនាន់ក្រោយបានឃើញ។

អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះ និងសាងសង់សំណង់តូចតាច បានចំនួន៩៥គ្រួសារ

ផ្សាយនៅថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២១

ខែឧសភាឆ្នាំ២០២១នេះក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅ ដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ ប្រជាពលរដ្ឋបានចំនួន៩៥ករណី រួមមាន៖ ក្រុងសៀមរាប ៣០ករណី ស្រុកបន្ទាយស្រី ២០ករណី ស្រុកអង្គរធំ ០៨ករណី ស្រុកប្រាសាទបាគង ១៨ករណី ស្រុកពួក ០៨ករណី ស្រុកសូទ្រនិគម ០៧ករណី និងស្រុកស្វាយលើ ០៤ករណី។



ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បី ទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់បានចំនួន ២៥ ករណីរួមមាន៖ ស្រុកអង្គរធំ ០៣ករណី ក្រុងសៀមរាប ០៧ករណី ស្រុកប្រាសាទបាគង ០៦ករណី ស្រុកពួក ០២ករណី និងស្រុកបន្ទាយស្រី ០៧ករណី។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើរហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោល គឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើដល់សាធារណជន ជាង៨ពាន់ដើមទៀត

ផ្សាយនៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២១

ព្រះសង្ឃ ព្រមទាំងសាធារណជនបានដាក់ពាក្យស្នើសុំកូនឈើជាបន្តបន្ទាប់មកកាន់អាជ្ញាធរជាតិអប្សរា ដើម្បីយកទៅដាំនៅលើដីលំនៅឋាន ដីចម្ការ សាលារៀន វត្តអារាម និងដីតំបន់ជុំវិញ ទៅតាមតម្រូវការដាក់ស្នែង។ នៅចុងខែឧសភា កន្លងទៅនេះ កូនឈើសរុប ៨,៧០០ ដើម បានចែកជូនទៅសាធារណជន។ ដើមឈើដែលផ្តល់ជូនទាំងនោះរួមមាន៖

- ផ្តល់កូនឈើជូនតំណាង **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន ចំនួន៦០០ដើម ដើម្បីយកទៅដាំតាមបណ្តោយផ្លូវសំខាន់ៗក្នុងក្រុងសួង ខេត្តត្បូងឃ្មុំ។ កូនឈើទាំងនោះរួមមានគ្រញូង៤០០ដើមនិងធ្នង់២០០ដើម។
- ផ្តល់កូនថ្កូវជូនលោក ស៊ុន គង់ ប្រធានមន្ទីរបរិស្ថានខេត្តសៀមរាប ចំនួន២០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន។
- ផ្តល់កូនឈើជូនតំណាងក្រុមហ៊ុន គូឡារ៉ា វ៉ធើរ(KULARA Water Co.,Ltd.) ចំនួន១,១៥០ដើមដើម្បីយកទៅដាំស្តារព្រៃឈើវិចរិលឡើងវិញតាមជើងភ្នំគូលែនខាងក្រោមព្រះអង្គជប់ ស្ថិតក្នុងភូមិត្បែងកើត ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម ធ្នង់២០០ដើម បេង១០០ដើម ប្រេស២០០ដើម ឈើទាល១០០ដើម ផ្ចឹក១០០ដើម គគីរ១៥០ដើម ត្រយឹង៥០ដើម និងកកោះ៥០ដើម។
- ផ្តល់កូនឈើជូនតំណាង **ឧត្តមសេនីយ៍ឯក ពៅ ហេង** មេបញ្ជាការយោធភូមិភាគទី៤ ចំនួន៥,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីបញ្ជាការដ្ឋានយោធភូមិភាគទី៤ ស្ថិតក្នុងភូមិស្ពានក្អែក ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ កូនឈើទាំងនោះរួមមាន គ្រញូង១,០០០ដើម ធ្នង់៣០០ដើម បេង២០០ដើម ប្រេស៥០០ដើម ឈើទាល១,០០០ដើម គគីរ១,០០០ដើម រំដួល៥០០ដើម និងលឿងរាជ៥០០ដើម។
- ផ្តល់កូនឈើជូនលោក គឹម រស្មី ចំនួន១២០ដើម ដើម្បីយកទៅដាំលើដីផ្ទាល់ខ្លួន។ កូនឈើទាំងនោះរួមមាន គ្រញូង៣០ដើម ធ្នង់៣០ដើម កកោះ៣០ដើម និងគគីរ៣០ដើម។
-ប្រគេនកូនឈើជូនព្រះអង្គ តាត មហាទី ព្រះគ្រូចៅអធិការវត្តព្រះឥន្ទកោសា ចំនួន១,១៣០ដើម ដើម្បីយកទៅដាំ និងចែកចាយនៅតាមសាលារៀន និងវត្តអារាមក្នុងខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង២០០ដើម បេង២០០ដើម សិរមាន់២២០ដើម គុយ២០ដើម ផ្ទៀវ ២២០ដើម និងរំដួល២៧០ដើម។
-ផ្តល់កូនឈើជូនលោក ស៊ិន កាន់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំតាមជើងភ្នំគូលែន ស្ថិតក្នុងភូមិថ្មដល់ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម ធ្នង់១០០ដើម បេង៥០ដើម ប្រេស៥០ដើម ផ្ចឹក ១០០ដើម និងគគីរ១០០ដើម៕

អាជ្ញាធរជាតិអប្សរាកំពុងអនុវត្តន៍ការងារកាត់ក្រី និងដកហូតដើមឈើហានិភ័យ នៅប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២១

ក្រុមជំនាញនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងចុះអនុវត្តការងារកាត់ក្រី និងដកហូតដើមឈើហានិភ័យនៅបរិវេណប្រាសាទព្រះខ័ន។ ការងារនេះធ្វើឡើងដើម្បីធានាសុវត្ថិភាពជូនភ្ញៀវទេសចរ ជៀសវាងគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិត និងបង្ការកុំឲ្យប៉ះពាល់ដល់រចនាសម្ពន្ធប្រាសាទកាន់តែធ្ងន់ធ្ងរ ដែលការងារនេះនឹងជួយសម្រួលដល់កិច្ចការអភិរក្ស និងការជួសជុលពង្រឹងប្រាសាទនេះឡើងវិញផង។

ដើមឈើដែលក្រុមការងារកំពុងកាត់ដកហូតចេញរួមមាន ដើមស្រឡៅ២ដើម ពភ្លាប្រើស២ដើម ស្លង់២ដើម ផ្ដៀក១ដើម គគីរ១ដើម ឈើទាល៣ដើម និងស្លែង១ដើម ដែលស្ថានភាពដើមឈើទាំងនោះ ដុះទ្រេតខ្លាំងគងលើកំពែងប្រាសាទ ដុះលើរានហាលខាងជើង មានជំងឺ ប្រព័ន្ធឫសខ្សោយខ្លាំង និងតួដើមងាប់ទាំងស្រុង។

ចំណែកឯដើមឈើដែលត្រូវកាត់ក្រីមែករួមមាន ដើមស្រឡៅ១ដើម ស្លង់១ដើម ខ្នុរព្រៃ២ដើម ត្រាង២ដើម និងឈើទាល៣ដើម ស្ថានភាពដើមដុះទ្រេតខ្លាំងក្បែរកំពែងប្រាសាទ ដុះជាប់រោងទងរានហាលខាងលិច និងខាងត្បូងសាលរបាំ ប្រព័ន្ធឫសនិងតួដើមរឹងមាំសណ្ឋានដីជ្រាយមានមែកសាខាច្រើន ដែលត្រូវកាត់ក្រីមែករស់ចំនួន២២មែក និងមែកងាប់ចំនួន៥មែកយកចេញ ដើម្បីជួយសម្រាលតួដើមឈើទាំងនេះ បញ្ចៀសការបាក់រលំ ឬធ្លាក់មែកមកលើប្រាសាទ៕

រូបភាពប្រចាំថ្ងៃ៖ ប្រាសាទទន្លេស្ងួតបង្ហាញរូបរាងឡើងវិញបន្ទាប់ពីអាជ្ញាធរជាតិអប្សរាជួសជុលរួច

ផ្សាយនៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០២១

អាជ្ញាធរជាតិអប្សរាបានចាប់ផ្ដើមគម្រោងជួសជុលប្រាសាទនេះឡើងវិញ និងទើបបញ្ចប់គម្រោងជួសជុល ដែលធ្វើឱ្យប្រាសាទនេះ អាចឈរ និងបង្ហាញរូបរាងដ៏ស្រស់ស្អាតរបស់ខ្លួនឡើងវិញ និងក្លាយជាគោលដៅថ្មីសម្រាប់ភ្ញៀវទេសចរ។ ក្នុងគម្រោងជួសជុលនេះ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា បានប្រទះឃើញទ្វារបាលកម្ពស់ជិត២ម៉ែត្រ ព្រះពុទ្ធស្ដេចថ្នាំ បដិមាជាច្រើនអង្គ បំណែកជើងទ្វារបាល និងស្លាកស្នាមរស់នៅរបស់ប្រជាជននាអតីតកាលជាច្រើន។ល។



ប្រាសាទទន្លេស្ងួត ស្ថិតនៅក្នុងភូមិអង្គរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប ខាងជើងខ្លោងទ្វារជីផ្នាំងប្រមាណ៥០០ម៉ែត្រ។ ដោយសារអាយុកាល ធ្វើឱ្យប្រាសាទដែលជាអតីតមន្ទីរពេទ្យក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧នេះ ទ្រុឌទ្រោម និងដួលរលំ៕

អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ចុះពិនិត្យគម្រោងសហការជាមួយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០២១

នៅថ្ងៃអាទិត្យ ទី០៦ ខែមិថុនា ឆ្នាំ២០២១ **លោកជំទាវឧកញ៉ានាងទសាខាអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភកិត្តិបណ្ឌិត សៀង ចាន់ហេង** អមដំណើរដោយឯកឧត្តម អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានអញ្ជើញចុះពិនិត្យវឌ្ឍនភាពគម្រោងមួយចំនួន ដែលកំពុងសហការជាមួយអាជ្ញាធរជាតិអប្សរារួមមាន ការងារជួសជុលខ្លោងទ្វារតាការ ការស្តារបារពើកកសិន្ធុអង្គរធំខាងលិចជាដើម។

សូមបញ្ជាក់ថា កន្លងមកលោកជំទាវឧកញ៉ាកិត្តិបណ្ឌិតក៏ធ្លាប់បានជួយរួមចំណែកជាមួយអាជ្ញាធរជាតិអប្សរាក្នុងការជួសជុលរហាត់ទឹក និងប្រាសាទស្រះស្រង់រួចហើយដែរ៕

ក្នុងឱកាសនោះ លោកជំទាវឧកញ៉ាក៏បានឆ្លៀតពេលទៅទស្សនាសិក្សានូវគម្រោងមួយចំនួនទៀត ដូចជាការរៀបចំបរិវេណមុខព្រះលានជល់ដំរីនិងការរៀបចំបរិវេណប្រាសាទតាកែវ ដើម្បីពិនិត្យលទ្ធភាពសហការជាបន្តទៀតផងដែរ។

រមណីយដ្ឋានប្រាសាទតានៃនារដូវវស្សា

ផ្សាយនៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០២១

ប្រាសាទតានៃ មានរចនាប័ទ្មដ៏ល្អឯក អមដោយទេសភាពវប្បធម៌ដ៏ស្រស់បំព្រង ដុះដុំជិត និងព័ន្ធព័ទ្ធដោយដើមរុក្ខាពណ៌ខៀវស្រងាត់មើលទៅត្រជាក់ភ្នែកនារដូវវស្សា។

ប្រាសាទនេះ មានទីតាំងនៅក្នុងព្រៃ ខាងជើងប្រាសាទតាព្រហ្ម និងខាងកើតប្រាសាទតាកែវឆ្ពោះទៅខាងជើងប្រហែល ៨០០ម៉ែត្រ។ ប្រាសាទតានៃកសាងឡើងក្នុងសតវត្សទី១២ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ដើម្បីឧទ្ទិសដល់ព្រះពុទ្ធសាសនាមហាយាន។

សាធារណជនទាំងអស់ គួរចំណាយពេលទៅទស្សនាប្រាសាទតានៃ ព្រោះថា មិនត្រឹមតែមានទេសភាពស្រស់ស្អាតក្នុងរស្សន្តរដូវនេះទេ ថែមទាំងមានសភាពស្ងប់ស្ងាត់ស័ក្តិសមជាទីសក្ការៈដ៏មានបារមី សម្រាប់អ្នកមានជំនឿផងដែរ។

ដើម្បីរមណីយដ្ឋានអង្គរមានភាពស្រស់បំព្រង

ផ្សាយនៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០២១

ការថែទាំ និងសម្អាតអនាម័យពីសំណាក់ក្រុមការងារសម្អាតប្រាសាទ បានធ្វើឱ្យតំបន់រមណីយដ្ឋានអង្គរ មានភាពស្រស់បំព្រងទាំងរដូវប្រាំង និងរដូវវស្សា។

ជារៀងរាល់ថ្ងៃក្រុមការងារពួកគាត់បានបែងចែកជាក្រុមៗ ខ្លះបោសស្លឹកឈើបោសដីស្រោចស្មៅកាត់រុក្ខជាតិទាំងតូចទាំងធំ ក្នុងនិងក្រៅប្រាសាទ មួយទៀតនោះគឺបារស្លែ និងរុក្ខជាតិក្នុងទឹកជាដើម។ សកម្មភាពទាំងនេះ គឺជាការរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឱ្យ តំបន់ប្រាសាទមានសោភ័ណភាពស្អាត ក្រៅពីកិច្ចការអភិរក្សដែលអាជ្ញាធរជាតិអប្សរា បាននិងកំពុងធ្វើជាប្រចាំ ហើយកិច្ចការទាំងនេះ មិនអាចខ្វះបានចូលរួមពីសាធារណជន ក៏ដូចជាភ្ញៀវទេសចរបានទេ។

យើងទាំងអស់គ្នា ត្រូវមានស្មារតីតែមួយក្នុងការធ្វើឱ្យបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរមានភាពស្រស់ស្អាត ទាក់ទាញភ្ញៀវទេសចរ ពិសេសស័ក្តិសមជាមួយគុណតម្លៃមិនអាចកាត់ថ្លៃបាន នៃរមណីយដ្ឋានអង្គរ៕

អាជ្ញាធរជាតិអប្សរា ចុះពិនិត្យទីតាំងស្នើសុំសាងសង់ផ្លូវលើខ្នងភ្នំគូលែន

ផ្សាយនៅថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០២១

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងសហការី ព្រមទាំងមានការចូលរួមពីក្រុមប្រឹក្សាឃុំ មេភូមិ ឧទ្យានុរក្សនៃក្រសួងបរិស្ថាន បានចុះពិនិត្យទីតាំងស្នើសុំសាងសង់ផ្លូវគម្រោងអភិវឌ្ឍន៍ឃុំខ្នងភ្នំ ដែលមានទីតាំង នៅលើឧទ្យានជាតិភ្នំគូលែន។

ការចុះពិនិត្យមើលទិដ្ឋភាពជាក់ស្តែង និងផ្ទៀងផ្ទាត់ជាមួយផែនទីបុរាណដ្ឋាន ដើម្បីរកលទ្ធភាព និងដំណោះស្រាយសមស្របបញ្ចៀសផលប៉ះពាល់ណាមួយដល់បុរាណដ្ឋាន និងបុរាណវិទ្យាក្រោមដី។ បន្ទាប់ពីនោះ លោក អ៊ឹម សុខរិទ្ធី ក៏បានចុះពិនិត្យតាមបុរាណដ្ឋានមួយចំនួន និងបានសំណេះសំណាលសួរសុខទុក្ខភ្នាក់ងារអភិរក្សប្រាសាទដែលប្រចាំការនៅទីនោះផងដែរ៕

សកម្មភាពដ៏មមាញឹកនៃការស្តារពើកនៅកសិន្ធុខាងលិចនៃក្រុងអង្គរធំ របស់មន្ត្រីជំនាញអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០២១

ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា កំពុងបង្ហាញសកម្មភាពដ៏មមាញឹកក្នុងការងារស្តារពើកស្មៅដ៏ក្រាស់ៗ ដែលកកើតឡើងដោយសាររុក្ខជាតិតូចៗក្នុងទឹក ដូចជា៖កំប្លោក ស្លែរ កកនៅក្នុងទឹករយៈពេលយូរនៅក្នុងកសិន្ធុខាងលិចក្រុងអង្គរធំ។

មុនពេលមានសកម្មភាពស្តារពើកស្មៅនេះ ស្ថានភាពទឹកកសិន្ធុខាងលិចនៃក្រុងអង្គរធំ មើលទៅស្ទើតែមិនឃើញផ្ទៃទឹកសោះ ដោយសារមានពើកស្មៅដ៏ក្រាស់ៗដុះជុំជិតនៅទីនោះ តែពេលនេះប្រែមកជាស្រស់ស្អាតឡើងវិញបណ្តើៗហើយ ព្រោះតែការយកចិត្តទុកដាក់ថែទាំរបស់អាជ្ញាធរជាតិអប្សរា។

លោក ញ៉ែម រស្មី មន្ត្រីបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានឲ្យដឹងថា ចាប់តាំងពីថ្ងៃអនុវត្ត

ការងារស្តារពើកជំហានដំបូង កាលពីថ្ងៃទី២៦ ខែមេសា រហូតមកដល់បច្ចុប្បន្ននេះ ក្រុមការងាបានធ្វើការងារស្តារពើកស្មៅបានចំនួនជាង១៥០០០ម៉ែត្រក្រឡា ពោលគឺអាចបញ្ចប់នារយៈពេល៣ខែខាងមុខ បើសិនជាមិនមានបញ្ហារាំងស្ទះណាមួយកើតឡើង។

ការងារនេះមិនអាចធ្វើលឿនទៅបាន ដោយសារពើកមានសភាពក្រាស់ ធ្ងន់ និង មានសត្វអាសិរពិស និងសត្វឈ្លើងនៅក្នុងពើកដែលជាបញ្ហាប្រឈមខ្លះៗសម្រាប់ក្រុមការងារចុះកាប់ពើក។

លោកបន្តទៀតថា ក្រោយពេលការងារស្តារពើកស្មៅដ៏ក្រាសនេះ រួចរាល់ រំពឹងថាបរិស្ថាន និងសោភ័ណ្ឌភាពនៅបរិវេនកសិន្ធុខាងលិចនៃក្រុងអង្គរធំ នឹងប្រែជាស្រស់ស្អាតឡើងវិញ ហើយក៏ជាទីទាកទាញ់ភ្ញៀវទេសចរមកកម្សាន្តនៅទីនោះ។

សូមជម្រាបផងដែរថា ការងារស្តារពើកជាជំហានដំបូងនេះធ្វើឡើងដោយអាជ្ញាធរជាតិអប្សរា ក្រោមគំនិតផ្តួចផ្តើមនិងជួយឧបត្ថម្ភ ដោយលោក **ជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច **លោកជំទាវ ភឿង សកុណា** ប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ **លោក ជំទាវ ឧកញ៉ា នាងធំសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភក៍ កិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ និងសប្បុរសជនមួយចំនួនទៀត៕



អាជ្ញាធរជាតិអប្សរាបញ្ចប់គម្រោងជួសជុលបណ្ណាល័យខាងត្បូងប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០២១

បណ្ណាល័យខាងត្បូងនៃប្រាសាទព្រះខ័ន បានបញ្ចប់ការជួសជុលនៅក្នុងខែឧសភា ឆ្នាំ២០២១។ លោក ជា សារិទ្ធ បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងជាប្រធានគម្រោងបានឱ្យដឹងថា បណ្ណាល័យនេះមានសភាពទ្រុឌទ្រោម ហើយទ្រេតខ្លាំងទៅជ្រុងខាងត្បូងដោយសារគ្រឹះចុះខ្សោយ និងដើមស្ពង់ធំដុះពីលើដំបូលធ្វើឱ្យប្រេះស្រាំ បើកចំហរធំចាប់ពីផ្នែកដំបូលរហូតដល់ខឿនដែលអាចប្រឈមនឹងការដួលរលំ។

បុរាណវិទូរូបនេះបញ្ជាក់ថា ចាប់តាំងពីខែសីហា ឆ្នាំ២០២០ រហូតដល់ខែឧសភា ឆ្នាំ២០២១នេះ អាជ្ញាធរជាតិអប្សរា បានសហការជាមួយអង្គការមូលនិធិប្រាសាទពិភពលោក World Monuments Fund (WMF) ធ្វើសម្រង់ប្លង់និងសិក្សាយ៉ាងម៉ត់ចត់ពីស្ថានភាពគ្រោះថ្នាក់ រួមទាំងការធ្វើកំណាយបុរាណវិទ្យា ដើម្បីពិនិត្យស្ថានភាពគ្រឹះរបស់ប្រាសាទ។ គម្រោង នេះប្រើរយៈពេលប្រហែល១៥ខែ ត្រូវ

រុះរើថ្មជួសជុលពង្រឹងគ្រឹះ និងរៀបផ្គុំតាមផ្នែកដែលខូចខាតឡើងវិញ។

ក្រោយពេលបញ្ចប់ការជួសជុលបណ្ណាល័យខាងត្បូងនៃប្រាសាទព្រះខ័នរួចរាល់ អាជ្ញាធរជាតិអប្សរា មានផែនការជួសជុលខ្លោងទ្វារខាងកើតនៃអាគារព្រះឥសូរ និងជួសជុលកំពង់ទឹកនៅខាងកើតព្រះខ័ន។

ក្រៅពីនោះអាជ្ញាធរជាតិអប្សរាសហការជាមួយអង្គការមូលនិធិប្រាសាទពិភពលោកលើគម្រោងធ្វើផែនទីហានិភ័យ ដើម្បីកំណត់ទីតាំងដែលប្រឈមនឹងគ្រោះថ្នាក់ និងកំណត់គោលដៅជួសជុលនៅកន្លែងអាទិភាព៕

អាជ្ញាធរជាតិអប្សរាចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនប្រេងឥន្ធនៈ Total Cambodge លើការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០២១

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក **ជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាជ្ញាធរជាតិអប្សរា បានចុះកិច្ចព្រមព្រៀងជាមួយនឹងក្រុមហ៊ុន Total Cambodge ដែលពិធីនេះធ្វើឡើងរវាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងលោក Asif IQBAL នាយកគ្រប់គ្រងទូទៅក្រុមហ៊ុន Total Cambodge ប្រចាំប្រទេសកម្ពុជា ស្តីពីការដាំដើមឈើនៅក្នុងរមណីយដ្ឋានអង្គរ។ ពិធីនេះ ក៏មានការចូលរួមពីឯកឧត្តមរដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយក ឯកឧត្តមអគ្គនាយករង និងថ្នាក់ដឹកនាំនៃស្ថាប័នទាំងពីរផងដែរ។

ក្នុងឱកាសនោះ លោកជំទាវបណ្ឌិតសភាចារ្យក៏បានសម្តែងអំណរគុណ និងកោតសរសើរពីការចូលរួមចំណែករបស់ក្រុមហ៊ុន Total Cambodge ប្រចាំប្រទេសកម្ពុជា ដែលបានចូលរួមចំណែកទៅលើសកម្មភាពជាច្រើនក្នុងប្រទេសកម្ពុជា នាពេលកន្លងមក ក៏ដូចជាបច្ចុប្បន្ន។ ជាក់ស្តែង ការចុះកិច្ចព្រមព្រៀងក្នុងការដាំដើមឈើនៅក្នុងរមណីយដ្ឋានអង្គរនាពេលនេះ គឺជាការឆ្លុះបញ្ចាំងពីការទទួលខុសត្រូវ និងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកស្ទួយទេសភាព បរិស្ថាន ធម្មជាតិ និងប្រាសាទ ក៏ដូចជាកាត់បន្ថយឧស្ម័នពុលនៅក្នុងរមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញ៕

អាជ្ញាធរជាតិអប្សរា ចុះពិនិត្យការងារនៅតំបន់ប្រាសាទបេងមាលា

ផ្សាយនៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទ និងបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ និងតាមដានការងារនៅតំបន់ប្រាសាទបេងមាលា ស្ថិតនៅភូមិបេងមាលា ស្រុកស្វាយលើ។

ក្នុងដំណើរចុះពិនិត្យការងារនៅតំបន់ក្រៅឧទ្យានអង្គរនេះ រួមមានការកែលម្អស្ពានដើរទស្សនាខាងក្នុងប្រាសាទបេងមាលា។ រៀបចំ និងសម្រួលផ្លូវដើរទស្សនាក្នុងប្រាសាទ រួមទាំងជុំវិញប្រាសាទដើម្បីឱ្យភ្ញៀវទេសចរបានស្វែងយល់កាន់តែច្រើនអំពីសិល្បៈប្រាសាទខ្មែរ។ ពន្យល់អំពីសារសំខាន់ការចូលរួមសហការការងាររបស់ភ្នាក់ងារនៅតាមប្រាសាទ អាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសប្រជាជនក្នុងតំបន់ ព្រោះជាសម្បត្តិបេតិកភណ្ឌទាំងអស់គ្នា ដែលជាកិច្ចការងារមួយជួយលើកតម្លៃតំបន់ប្រាសាទ

បេងមាលា ឱ្យទទួលស្គាល់ជាលក្ខណៈសកលដែលជាជំហានមួយឆ្ពោះទៅការចុះបញ្ជី ជាសម្បត្តិបេតិកភណ្ឌពិភពលោក។

លើសពីនេះ លោកក៏បានពាំនាំនូវការព្រួយបារម្ភ និងផ្តាំផ្ញើសុខទុក្ខពីថ្នាក់ដឹកនាំរបស់អាជ្ញាធរជាតិអប្សរា ដល់មន្ត្រីគ្រប់គ្រង ប្រធានភ្នាក់ងារ និងពលករកំពុងបំពេញការងារនៅតំបន់ប្រាសាទបេងមាលា។ ពិសេស ពង្រឹងការរក្សាសុខភាព និងអនាម័យ ដោយអនុវត្តគោលការណ៍ ៣កុំ ៣ការពាររបស់រាជរដ្ឋាភិបាលឱ្យបានខ្ជាប់ខ្ជួន ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ទាំងអស់គ្នា។

ក្នុងឱកាសនោះដែរ លោក សុខរិទ្ធី ក៏បានចុះទៅពិនិត្យ និងសិក្សាបន្ថែមនូវចម្លាក់សត្វម្ករ បុរាណដ្ឋាននានា មានក្នុងបញ្ជីបុរាណដ្ឋាន និងមិនទាន់ចុះក្នុងបញ្ជី ដែលមានទីតាំងនៅជុំវិញតំបន់ប្រាសាទបេងមាលា ដើម្បីរាយការណ៍ និងសុំគោលការណ៍អនុវត្តគម្រោងផ្សេងៗពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា៕

កូនឈើចម្រុះជាង៦ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយពីថ្ងៃទី៥ ដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២១

ផ្សាយនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២១

កូនឈើចម្រុះសរុបចំនួន ៦,២៩០ ដើមទៀត ត្រូវបានចែកចាយដល់សាធារណជនដែលបានដាក់ពាក្យស្នើសុំមកកាន់អាជ្ញាធរជាតិអប្សរា។ ដើមឈើទាំងនោះ ត្រូវបានស្នើសុំដើម្បីយកទៅដាំនៅតាមដីគម្របព្រៃឈើ ស្ថាប័ន ដីចម្ការ និងដីផ្ទះរបស់ប្រជាពលរដ្ឋទាំងក្នុងនិងក្រៅខេត្តសៀមរាប។ ការចែកចាយ ឬផ្តល់កូនឈើទាំងនោះរួមមាន៖

- ផ្តល់កូនឈើជូនលោក ទិត ឌីរ៉ា ចៅសង្កាត់គោកចក ចំនួន១,៥០០ដើម ដើម្បីយកទៅដាំអមតាមដងផ្លូវនានាក្នុងភូមិសាស្ត្រសង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គគីរ៣០០ដើម លឿងរាជ២០០ដើម ក្រោកធំ២០០ដើម ក្រោកតូច២០០ដើម ត្របែកព្រៃ២០០ដើម ចាមរី២០០ដើម និងខ្នារ២០០ដើម។
- ផ្តល់កូនឈើជូនតំណាង **ឯកឧត្តម ឧត្តមសេនីយ៍ឯក កែវ ឌី** មេបញ្ជាការកងពលធំអន្តរាគមន៍លេខ២ ចំនួន ២,០០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីបញ្ជាការដ្ឋានកងពលធំអន្តរាគមន៍លេខ២ ស្ថិតក្នុងភូមិស្រះខ្វាវ ឃុំតាំ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម ប្រេស៥០០ដើម ឈើទាល៥០០ដើម និងគគីរ៥០០ដើម។
- ផ្តល់កូនឈើជូនលោក ស៊ន់ កាន់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំតាមជើងភ្នំគូលែន ស្ថិតក្នុងភូមិថ្មដល់ ឃុំតាំ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។កូនឈើទាំងនោះរួមមានរំដួល១០០ដើម ក្រោក១០០ដើម ត្របែកព្រៃ១០០ដើម និងអង្គារបុស្ស ២០០ដើម។
- ផ្តល់កូនឈើជូនលោក ទូច សេដ្ឋា បុគ្គលិកក្រុមហ៊ុន HEINEKEN CAMBODIA ចំនួន២០០ដើម ដើម្បីយកទៅដាំនៅដីផ្ទាល់ខ្លួន ស្ថិតក្នុងភូមិរោងគោ ឃុំថ្មបាំង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ កូនឈើទាំងនោះរួមមាន គ្រញូង២០ដើម បេង២០ដើម ធ្នង់២០ដើម ប្រេស២០ដើម ត្របែកព្រៃ២០ដើម រំដួល២០ដើម ផ្ចឹរ២០ដើម គុយ២០ដើម និងគូលែន៤០ដើម។
- ផ្តល់កូនឈើជូនលោក ជា សណ្តាប់ ចំនួន១០០ដើម ដើម្បីយកទៅដាំនៅតាមបរិវេណសាលារៀនក្នុងភូមិកំភេម ឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ឈើទាល៥០ដើម និងត្រាច៥០ដើម។
- ផ្តល់កូនឈើជូនលោក អ៊ូច ឆត្រា ដើម្បីយកទៅដាំនៅខេត្តពោធិ៍សាត់ ចំនួន២០០ដើមមាន គ្រញូង៥០ដើម បេង៥០ដើម ធ្នង់៥០ដើម និងប្រេស៥០ដើម។
- ផ្តល់កូនឈើជូនលោក ធន់ ចាន់ថា ចំនួន២៥០ដើម ដើម្បីយកទៅដាំនៅរាជធានីភ្នំពេញ។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម បេង៥០ដើម ធ្នង់៥០ដើម និងប្រេស៥០ដើម ។
- ផ្តល់កូនឈើជូនតំណាងនាយកដ្ឋានសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ចំនួន១,០៤០ដើម ដើម្បីយកទៅដាំនៅតាមបរិវេណដីទំនេរជុំវិញប្រាសាទ និងទីធ្លាសាធារណៈនានាក្នុងឧទ្យានអង្គរ។ កូនឈើទាំងនោះរួមមាន ឈើទាល២០០ដើម គគីរ២០០ដើម កកោះ៣០ដើម រំដួល១០០ដើម អង្កាញ់១៥០ដើម គ្រញូង៣០ដើម បេង៨០ដើម ធ្នង់១០០ដើម និងប្រេស១៥០ដើម ។
- ប្រគេនកូនឈើជូនព្រះអង្គ ព្រេង សារិទ្ធ គង់នៅវត្តព្រះឥន្ទកោសីយ៍ខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តផែនដីដំរីសរើល ស្ថិតក្នុងឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ។ កូនឈើទាំងនោះរួមមាន ឈើទាល១០០ដើម គគីរ១០០ដើម សំរោង១០០ដើម គ្រញូង១០០ដើម បេង៥០ដើម និងធ្នង់៥០ដើម៕

អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលស្រុកបន្ទាយស្រីចុះពិនិត្យឡកុលាលភាជន៍បុរាណនៅជើងភ្នំគូលែន

ផ្សាយនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១

នៅថ្ងៃទី១៤ និង១៥ ខែមិថុនា ឆ្នាំ២០២១ មន្ត្រីសណ្តាប់ធ្នាប់និងមន្ត្រីជំនាញនៃអាជ្ញាធរជាតិអប្សរា សហការជាមួយរដ្ឋបាលស្រុកបន្ទាយស្រីនិងអាជ្ញាធរភូមិឃុំ បានចុះពិនិត្យទីតាំងឡផលិតកុលាលភាជន៍បុរាណនៅភូមិថ្មដល់ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលទទួលរងការឈូសឆាយពីប្រជាពលរដ្ឋនៅទីនោះដើម្បីពូនថ្នល់ចូលដីរបស់ខ្លួន។

អាជ្ញាធរជាតិអប្សរា និងដៃគូស្រាវជ្រាវអន្តរជាតិធ្លាប់បានសិក្សាបុរាណវិទ្យាលើស្ថានីយ ឡដុតកុលាលភាជន៍នេះកន្លងមក និងទើបបានចុះក្នុងបញ្ជីបុរាណដ្ឋានរួចហើយដែរ។ ស្ថានីយនេះជាអតីតកន្លែងផលិតកុលាលភាជន៍បុរាណដើមសម័យអង្គរ ប្រភេទស្រទាប់រលោងពណ៌បៃតងដែលផ្តើមផលិតនៅរវាងសតវត្សទី៩-១០នៃគ.ស។ កុលាលភាជន៍ប្រភេទនេះធ្លាប់ប្រទះឃើញតាមស្ថានីយកំណាយផ្សេងៗ ក្នុងខេត្តសៀមរាប តំបន់ផ្សេងៗ និងនៅភាគខាងត្បូងប្រទេសវៀតណាមសព្វថ្ងៃ។

ថ្មីៗនេះមានការឈូសឆាយធ្វើថ្នល់ចូលសហគមន៍របស់អ្នកស្រុកក្នុងតំបន់ ដោយកាត់តាមជើងនៃទីទួលឡមួយផ្នែក ដោយបានប៉ះពាល់ជើងទួលផ្នែកខាងលិចមួយចំហៀង។ តាមការពិនិត្យជាក់ស្តែង ការឈូសឆាយធ្វើផ្លូវនៅផ្នែកខាងលិច បានយកដីមួយផ្នែកនាជើងទួល មិនទាន់បានប៉ះពាល់ដល់រចនាសម្ពន្ធនិងគ្រឿងបង្គុំឡទេ។ ប៉ុន្តែបានប៉ះពាល់ដល់គំនរអំបែងភាជន៍និងសំណល់ដែលសល់ពីឡចាស់ ដែលបានកាយមកទុកនៅជើងទួល។

វិធានការណ៍បន្ទាន់មួយ ត្រូវបានដាក់ចេញដោយមន្ត្រីសណ្តាប់ធ្នាប់ សហការជាមួយអាជ្ញាធរមូលដ្ឋាន គឺបានដាក់របាំងការពារ និងហាមឃាត់ការឈូសឆាយបន្តនិងអប់រំណែនាំប្រជាជនរស់នៅក្បែរស្ថានីយឱ្យជួយអភិរក្សស្ថានីយនេះ។ វិធានការបន្ទាប់ ដោយមានការឯកភាពពីរដ្ឋបាលស្រុក គឺស្នើឱ្យអាជ្ញាធរមូលដ្ឋានកាយប្រមូលដីដែលបានយកពីជើងទួល ពូនកន្លែងខូចខាតឡើងវិញ និងថ្នល់ថ្មីត្រូវរក្សាគម្លាតទីទួលបុរាណនេះ។ ក្នុងពេលខ្លីខាងមុខ អាជ្ញាធរជាតិអប្សរា នឹងរៀបចំបោះបង្គោលព្រំការពារបុរាណដ្ឋានទាំងនេះ ដោយសហការជាមួយរដ្ឋបាលស្រុកដើម្បីបញ្ចៀសការឈូសឆាយ ដើម្បីអភិរក្សនិងលើកតម្លៃស្ថានីយនេះឱ្យបានគង់វង្ស។

បន្ថែមលើនេះ ស្ថាប័នទាំងពីរនឹងរៀបចំឲ្យមានវេទិកាអប់រំដល់ប្រជាពលរដ្ឋមូលដ្ឋានអំពីសារសំខាន់ លក្ខណៈពិសេស និងតម្លៃប្រវត្តិសាស្ត្ររបស់តំបន់ ដើម្បីឱ្យសហគមន៍មូលដ្ឋានចូលរួមថែរក្សាការពារសម្បត្តិបេតិកណ្ឌរួមគ្នា៕

អាជ្ញាធរជាតិអប្សរា កំពុងកាត់ក្រី និងដកហូតដើមឈើមានហានិភ័យខ្ពស់ នៅតាមដងផ្លូវជាតិលេខ៦ ចាប់ពីព្រំប្រទល់ក្រុងសៀមរាប ដល់ឃុំខ្នាត ស្រុកពួក

ផ្សាយនៅថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១

មន្ត្រីបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយអាជ្ញាធរមូលដ្ឋានឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប បានចុះពិនិត្យស្ថានភាពដើមឈើដែលមានហានិភ័យខ្ពស់ ដុះនៅតាមដងផ្លូវជាតិលេខ៦ ចាប់ពីព្រំប្រទល់ក្រុងសៀមរាប ភូមិគោកស្នួល ដល់ភូមិទឹកថ្លា ឃុំខ្នាត ស្រុកពួក និងកំពុងអនុវត្តវិធានការបន្ទាន់ចំពោះដើមឈើទាំងនោះ ដើម្បីបង្ការ និងបញ្ចៀសគ្រោះថ្នាក់ទុកជាមុន កុំឲ្យប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋនិងយានយន្តគ្រប់ប្រភេទដែលឆ្លងកាត់។

ដើមឈើកំពុងដកហូតចេញមានចំនួន២ដើមរួមមាន ដើមស្វាយ និងដើមឈើទាល ដែលដើមឈើទាំង២នេះ ដុះជាប់ផ្លូវ និងកៀកស្ពាន បណ្តាលឲ្យមានគ្រោះថ្នាក់ជាញឹកញាប់។ ចំណែកឯដើមឈើដែលកំពុងកាត់ក្រីមែកមានចំនួន១០០

ដើមរួមមាន៖ ឈើទាល គគីរ ចាមរី ព្រីង អាកាស្យា ទ្រៀក អង្កាញ់ អំពិលទឹក ក្រសាំង ស្នួល ស្វាយ ប្រេងខ្យល់ ត្រាច ត្រចៀកដំរី ពោធិ៍ និងជ្រៃ ដែលត្រូវកាត់ក្រីមែកចេញចំនួន ៣០០មែក ដើម្បីសម្រាលតួដើមកុំឲ្យដួលរលំ ឬបាក់ធ្លាក់មែកមកលើផ្លូវជាតិ៕

រូបភាពប្រចាំថ្ងៃ៖ ភាពស្រស់ស្អាតនៃប្រាសាទតុបខាងលិច

ផ្សាយនៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០២១

ប្រាសាទតុបខាងលិច ស្ថិតនៅក្នុងរាជធានីអង្គរធំ ឬនៅខាងលិចប្រាសាទបាយ័ន្ត ចន្លោះប្រាសាទបាយ័ន្តនិងខ្លោងទ្វារតាកាវ។ ប្រាសាទតូចមួយនេះ មានភាពស្រស់ស្អាតនិងទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិជាច្រើនចូលមកទស្សនានិងផ្តិតយករូបភាពប្រាសាទបុរាណនិងធម្មជាតិក្នុងបរិវេណនេះ។

ប្រាសាទតុបខាងលិច កសាងឡើងក្នុងរវាងសតវត្សទី១០ ដែលមានរចនាប័ទ្មបន្ទាយស្រី ឧទ្ទិសចំពោះព្រហ្មញ្ញសាសនា។ ចាប់ពីសតវត្សទី១៣ដល់ទី១៧ ប្រាសាទនេះត្រូវបានកែបន្ថែមខ្លះៗ ដែលគេឃើញដល់សព្វថ្ងៃដូចជាការកសាងប្រាង្គពីរអមសងខាង ព្រមទាំងខឿនថ្មមួយខាងមុខប្រាសាទបន្ថែមទៀត ឱ្យក្លាយជាឧបោសថាគារ ជាទីសក្ការៈរបស់ព្រះពុទ្ធសាសនាថេរវាទជាដើម។

វិទ្យាស្ថាន ណារ៉ា របស់ប្រទេសជប៉ុន សហការជាមួយអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមគម្រោងអភិរក្សជួសជុលប្រាសាទតុបពីឆ្នាំ២០១១មក។ ជំហានដំបូង ក្រុមការងារបានជួសជុលប្រាង្គខាងត្បូងរួចរាល់ ហើយបន្តជួសជុលប្រាង្គខាងជើង និងជួសជុលប្រាង្គកណ្តាលនៃប្រាសាទ ដែលបានបញ្ចប់នៅឆ្នាំ២០២០៕

សោភ័ណភាពពណ៌ខៀវស្រងាត់ចាប់ផ្ដើមលេចមុខបណ្ដើរៗនៅបរិវេណមុខព្រះលានជល់ដំរី

ផ្សាយនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២១

បច្ចុប្បន្នបរិវេណមុខព្រះលានជល់ដំរី បាននិងកំពុងចាប់ផ្ដើមប្រែមុខមាត់ថ្មី បន្ទាប់ពីអាជ្ញាធរជាតិអប្សរា កំពុងដំណើរការរៀបចំក្រាលថ្មបាយក្រៀមសម្រាប់ផ្លូវថ្មើរជើង សួនស្មៅ ដាំដើមឈើ។ ការកែលម្អនេះ គឺឱ្យស្របទៅលំនាំប្រាសាទបុរាណដើម្បីលើកតម្លៃវប្បធម៌ ធ្វើយ៉ាងណាឱ្យខាងមុខព្រះលានជល់ដំរីនេះមានទេសភាពល្អ និងសោភ័ណភាពបែតងទាក់ទាញអ្នកទេសចរជាតិ និងអន្តរជាតិទៅទស្សនាក្រោយបញ្ចប់ជំងឺកូវីដ-១៩នាពេលខាងមុខ។

ការរៀបចំ លែងឱ្យមានចរាចរណ៍យានយន្តលើគន្លងផ្លូវចាស់ដោយជំនួសផ្លូវវាងថ្មីនេះបានរួមចំណែកសំខាន់ក្នុងការបញ្ចៀសកុំឱ្យប៉ះពាល់ដល់ប្រាសាទបុរាណ ដោយសារតែភាពរំញ័រនៃគ្រឿងយន្ត ហេតុដូច្នេះទើបអាជ្ញាធរជាតិអប្សរា

កែលម្អឡើងវិញ ដោយធ្វើផ្លូវថ្មើរជើងសម្រាប់ដើរទស្សនាប្រាសាទ និងដើម្បីលើកតម្កើង ថែរក្សា អភិរក្សវប្បធម៌ជាតិ។ លោកអ្នកអាចឃើញនូវទស្សនីយភាពថ្មី ប្លែកភ្នែក ពេលមកទស្សនាក្រុងអង្គរធំ ក្រោយពីទីតាំងនេះមានការអភិវឌ្ឍន៍ជាបន្តបន្ទាប់ពីសំណាក់អាជ្ញាធរជាតិអប្សរា។

សូមអញ្ជើញទស្សនា ទិដ្ឋភាពនៅជុំវិញបរិវេណខាងមុខព្រះលានជល់ដំរី ដែលបានរៀបចំរចនាសម្ព័ន្ធផ្លូវថ្មើរជើង សួនស្មៅ និងដាំដើមឈើ ដើមផ្កាលម្អយ៉ាងស្រស់ស្អាត៕

សកម្មភាពថែទាំ និងសម្អាតប្រាង្គប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០២១

ប្រាង្គប្រាសាទជាច្រើននៅក្នុងរមណីយដ្ឋានអង្គរ គ្រប់គោលដៅទាំងអស់សុទ្ធតែមាន ភ្នាក់ងារសណ្តាប់ធ្នាប់ ភ្នាក់ងារទេសចរណ៍ដែលប្រចាំការជាប្រចាំ ដើម្បីចាំសម្រួលហេតុការណ៍ផ្សេងៗដល់ភ្ញៀវទេសចរដែលមកទស្សនាអង្គរ។

ក្រៅពីកិច្ចការខាងលើ ក្រុមការងារដែលប្រចាំការតាមប្រាសាទនីមួយៗ ក៏មិនភ្លេចរួមចំណែកថែទាំប្រាសាទនោះដែរ។ ក្រុមការងារបានបង្កើនសកម្មភាពថែទាំ សម្អាតបរិស្ថាន ដកស្មៅ កាត់កូនឈើតូចៗ និងរុក្ខជាតិផ្សេងៗដែលដុះនៅលើប្រាសាទ។

តាមរយៈសកម្មភាពនេះបញ្ជាក់ឱ្យឃើញថា អាជ្ញាធរជាតិអប្សរា ពិតជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការថែទាំ និងលើកតម្លៃប្រាង្គប្រាសាទ ដែលជាមរតកដូចតាយើងជាប្រចាំ និងគ្រប់កាលៈទេសៈទាំងអស់៕

ឆមាសទី១ ឆ្នាំ២០២១ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន៨៦៥ករណី

ផ្សាយនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២១

លទ្ធផលការងាររបស់ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំឆមាសទី១ ក្នុងឆ្នាំ២០២១ ដែលបានចុះផ្សព្វផ្សាយអប់រំ និងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសាងសង់តូចតាចទាំង៥គោលដៅស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរបានចំនួន១៣៩៩សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន៨៦៥សំណើ។

ករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន១១៩ករណី ស្រុកអង្គរធំបានចំនួន២១៣ករណី ស្រុកពួកបានចំនួន១២០ករណី ក្រុងសៀមរាបបានចំនួន១៩១ករណី និងស្រុកបន្ទាយស្រីបានចំនួន១៩៣ករណី រួមទាំងក្រុមការងារក្រៅឧទ្យានអង្គរចំនួន២៩សំណើ សរុបចំនួន៨៦៥សំណើ។

លើសពីនេះ ក្រុមការងារសហគមន៍បានចូលរួមក្នុងការងារមនុស្សធម៌ និងកិច្ចការសាសនាដូចជា ជួយឧបត្ថម្ភថវិកា និងសម្ភារប្រើប្រាស់ដល់ចាស់ជរា ជនពិការ កុមារមានជំងឺគ្រួសារខ្វះខាតមួយចំនួន និងចូលរួមក្នុងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ រួមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ និងក្រៅតំបន់អង្គរ។

គោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកំពុងចាប់ផ្តើមដំណើរការ គម្រោងជួសជុលខ្លោងទ្វារតាកាវ

ផ្សាយនៅថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០២១

ខ្លោងទ្វារតាកាវជាខ្លោងទ្វារមួយក្នុងចំណោមខ្លោងទ្វារទាំង៥នៃក្រុងអង្គរធំដែលស្ថិតនៅទិសខាងលិចនៃប្រាសាទបាយ័ន្ត។ ខ្លោងទ្វារនេះសង់អំពីថ្មភក់ និងថ្មបាយក្រៀមដែលមានកំពូលរូបព្រហ្មមុខបួនចំនួន៣ នៅពីលើ កំពូលកណ្តាលមានកម្ពស់រហូតដល់២៣ម៉ែត្រ។ រីឯតាមចំណុចកែងនៃខ្លោងទ្វារ មានរូបព្រះឥន្ទគង់លើដំរីក្បាលបី ហើយនៅខាងលិចមានស្ពានហាលដែលមានលម្អដោយរូបទេវតានិងយក្សទាញព្រ័ត។

ដោយសារកត្តាអាយុកាល អាកាសធាតុ និងសង្គ្រាម បានធ្វើឱ្យដើមឈើដុះលើនិងក្បែរ បានបណ្តាលឱ្យរូបចម្លាក់បង្កាន់ដៃយក្សនិងទេវតាដួលរលំស្ទើរអស់គ្មានសល់ ហើយបានធ្វើឱ្យរចនាសម្ពន្ធរបស់ខ្លោងទ្វារមួយភាគធំ បានរងនូវការខូចខាតជាខ្លាំងដោយរូបចម្លាក់ព្រះឥន្ទគង់លើដំរីក្បាលបីបានរលុះធ្លាក់ដី ដំបូលរលុះនិងផ្នែកនៅសលបានហែកញែករកកលនឹងរលុះធ្លាក់មកដី។

កញ្ញា ហាន សុច្ចរី ស្ថាបត្យករ និងជាអ្នកទទួលបន្ទុកលើការងារជួសជុលបង្កាន់ដៃរូបទេវតានិងអសុរាបានឱ្យដឹងថា ដំណើរការជួសជុលនេះ គឺមានកិច្ចការងារចម្បងៗចំនួនបីដែលត្រូវធ្វើជាចាំបាច់ ០១) ការងាររៀបន្ទារទល់ទ្រពង្រឹងរចនាសម្ពន្ធប្រាង្គខ្លោងទ្វារទាំងមូល ដើម្បីការពារសុវត្ថិភាពក្នុងកំឡុងពេលធ្វើការនិងផ្តល់លទ្ធភាពសម្រាប់អ្នកបច្ចេកទេសសិក្សាបច្ចេកទេសរួមក្នុងការជួសជុល ០២) ការងារជួសជុលពង្រឹងជើងខឿនជ្រុងពាយ័ព្យ ហើយនិងដំរីអាទិទេព ០៣) ការងារជួសជុលស្ពានប្រវែង១០ម៉ែត្រ។ ចំពោះការងារជួសជុលខាងលើនឹងត្រូវអនុវត្តទន្ទឹមគ្នា គ្រោងនឹងដំណើរការដំណាលគ្នា។

ចំពោះបញ្ហាដែលក្រុមការងារជួបប្រទះមានដូចជា ស្ពានភាពរូបចម្លាក់អមសងខាងស្ពានមានភាពទ្រុឌទ្រោមស្ទើរតែរាបដល់ដី ថ្មចម្លាក់មាននៅលាយឡំគ្នា និងខ្លះទៀតបានបាត់បង់ធ្វើឱ្យក្រុមការងារពិបាកក្នុងការស្វែងរកថ្មមករៀបចំផ្គុំឡើងវិញ និងការសិក្សាកំណត់យកអ័ក្សរួមនៃថ្មកម្រាលចម្លាក់ លើរចនាសម្ពន្ធស្ពាន ដោយសារថ្មជញ្ជាំងគ្រឹះមួយចំនួនធំបានងាកចេញពីទីតាំងដើម។

សូមជម្រាបជូនថា ខ្លោងទ្វារតាកាវ ត្រូវបានប្រារព្ធពិធីប្រុងពលី ដើម្បីដំណើរការជួសជុលកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោក ជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច **លោកជំទាវ ភឿង សកុំណា** ប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រោមគំនិតផ្តួចផ្តើមនិងជួយឧបត្ថម្ភដោយលោក **ជំទាវឧកញ៉ា នាងទិសាខា អគ្គមហាឧបាសិកា ពុទ្ធសាសនូបត្ថម្ភកិត្តិបណ្ឌិត សៀង ចាន់ហេង** អគ្គនាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍ អនុវត្តផ្ទាល់ដោយអាជ្ញាធរជាតិអប្សរា៕

លេខាធិការដ្ឋានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ រៀបចំការចុះពិនិត្យការដ្ឋានជួសជុលប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០២១

ដោយសារវិបត្តិជំងឺកូវីដជាសកល ចាប់ពីឆ្នាំ២០២០ គណៈកម្មាធិការអាយស៊ីស៊ី-អង្គរ បានខកខានរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់និងពេញលេញនោះទេ។ ការណ៍នេះបណ្តាលឱ្យមានការរៀបចំកិច្ចប្រជុំតាមរយៈ ប្រព័ន្ធអេឡិចត្រូនិច ហើយអ្នកជំនាញការចំពោះកិច្ចនៃគណៈកម្មាធិការនេះ បានត្រឹមតែពិនិត្យ វាយតម្លៃអំពីការវិវត្តនៃគម្រោងដែលកំពុងអនុវត្តពីចម្ងាយប៉ុណ្ណោះ។

ដូចគ្នាដែរ នៅឆ្នាំ២០២១នេះ លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ បានប្រើយន្តការបន្ថែមទៀតដើម្បីជួយដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខ ទាក់ទងនឹងកិច្ចការមួយចំនួនដែលកំពុងប្រឈមនឹងគ្រោះថ្នាក់។ជំនួសឱ្យមានអ្នកជំនាញការចំពោះកិច្ចដែលមានមូលដ្ឋាននៅក្រៅប្រទេសកម្ពុជា លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ បានអញ្ជើញអ្នកជំនាញការបរទេសដែលកំពុងជួសជុលនៅតាមការដ្ឋានប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ ឱ្យជួយផ្តល់យោបល់ទៅវិញទៅមកជាមួយអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរា ដែលកំពុងបំពេញភារកិច្ចនៅតាមការដ្ឋាននានាជាច្រើនក្នុងរយៈពេលចុងក្រោយនេះ។

សូមបញ្ជាក់ថា លេខាធិការដ្ឋានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នឹងចុះពិនិត្យការដ្ឋានក្នុងតំបន់រមណីយដ្ឋានអង្គរ រយៈពេល២ថ្ងៃ គឺថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ២០២១។ ក្រោយពីការចុះពិនិត្យរួចរាល់ លេខាធិការដ្ឋានគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ នឹងត្រូវធ្វើរបាយការណ៍រួមដើម្បីដាក់ជូនទៅគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍បន្ត៕

កូនឈើចម្រុះជិត៨ពាន់ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរា ចែកចាយពីថ្ងៃទី១៤ ដល់ថ្ងៃទី២២ ខែមិថុនា

ផ្សាយនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២១

កូនឈើចម្រុះសរុបចំនួន ៧,៨៥០ ដើមទៀត ត្រូវបានចែកចាយដល់សាធារណជនដែលបានដាក់ពាក្យស្នើសុំមកកាន់អាជ្ញាធរជាតិអប្សរា។ ដើមឈើទាំងនោះ ត្រូវបានស្នើសុំដើម្បីយកទៅដាំនៅតាមដីគម្រប់ព្រៃឈើ ស្ថាប័ន ដីចម្ការ និងដីផ្ទះរបស់ប្រជាពលរដ្ឋទាំងក្នុងនិងក្រៅខេត្តសៀមរាប។
ការចែកចាយ ឬផ្តល់កូនឈើទាំងនោះរួមមាន៖

- ផ្តល់កូនឈើជូនតំណាង **ឧត្តមសនីយ៍ត្រី ចៅ វណ្ណានិត** មេបញ្ជាការកងរាជអាវុធហត្ថខេត្តសៀមរាប ចំនួន១,៧០០ដើម ដើម្បីយកទៅដាំតាមអង្គភាពមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ក្នុងខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង៥០០ដើម ធ្នង់៣០០ដើម ចាមរី៥០០ដើម ក្ងោក ៣០០ដើម និងអូញម៉ូញ១០០ដើម។
- ផ្តល់កូនរំដួលជូនតំណាងនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនៃអាជ្ញាធរជាតិអប្សរាចំនួន៣០ដើមដើម្បីយកទៅដាំក្នុងបរិវេណប្រាសាទបន្ទាយក្តី។
- ផ្តល់កូនឈើជូនលោក ស្វាយ ហុង មេឃុំដូនកែវ ចំនួន ១,៨៣០ដើម ដើម្បីយកទៅដាំតាមដងផ្លូវនានាក្នុងឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ។ កូនឈើទាំងនោះរួមមាន គគីរ៥០០ដើម ក្ងោក៣០០ដើម រំដួល២០០ដើម ខ្នារ២០០ដើម ត្របែកព្រៃ៣០០ដើម និងលឿងរាជ៣៣០ដើម។
- ផ្តល់កូនឈើជូនលោក ស៊ន់ កាន់ ប្រជាពលរដ្ឋរស់នៅខេត្តសៀមរាប ចំនួន៥០០ដើម ដើម្បីយកទៅដាំតាមជើងភ្នំគូលែន ស្ថិតក្នុងភូមិថ្មដល់ ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គគីរ១០០ដើម ឈើទាល១០០ដើម កកោះ១០០ដើម សំរោង១០០ដើម និងផ្ចឿក១០០ដើម។
- ផ្តល់កូនឈើជូនតំណាង **ឯកឧត្តម មេធាវី ឈិត បូរ៉ាវុធ** ចំនួន៦០០ដើម ដើម្បីយកទៅដាំតាមបរិវេណវត្តអារាមនានានៅស្រុកកំណើត។ កូនឈើទាំងនោះរួមមាន គ្រញូង ១០០ដើម បេង៥០ដើម ធ្នង់៥០ដើម ប្រេស៥០ដើម ក្ងោក ២០០ដើម អូញម៉ូញ៥០ដើម និងគគីរ១០០ដើម។
- ប្រគេនកូនឈើជូនព្រះវិជិតមេធា អ៊ាន សុឃា ព្រះចៅអធិការវត្តពោធិវនារាម ចំនួន៧៥០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីធ្លាវត្តពោធិវនារាម ហៅវត្តស្លឹ និងវត្តជ័យមុនីវនារាម ហៅវត្តជយោ ស្ថិតក្នុងស្រុកចំការលើ ខេត្តកំពង់ចាម។ កូនឈើទាំងនោះរួមមាន គ្រញូង១០០ដើម បេង ៣០ដើម ធ្នង់៣០ដើម ប្រេស៣០ដើម ឈើទាល៥០ដើម គគីរ៣០ដើម កកោះ៥០ដើម ផ្ចឿក៨០ដើម សំរោង៣០ដើម ចំបក់១០ដើម ពពេល៣០ដើម ត្របែកព្រៃ៥០ដើម ផ្ចៀវ១០០ដើម ថ្កុល៥០ដើម រំដួល៥០ដើម។
- ផ្តល់កូនឈើជូនតំណាងលោក ស៊ីន ចាន់ថុល អភិបាលស្រុកពួក ចំនួន៨០០ដើម ដើម្បីយកទៅដាំនៅតាមទីធ្លាសាលារៀន និងវត្តអារាមនានាក្នុងស្រុកពួក ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន ឈើទាល២៥០ដើម កកោះ២០០ដើម បេង១៥០ដើម និងគ្រញូង២០០ដើម។
- ផ្តល់កូនឈើជូនលោកស្រី អ៊ុន សេរីរ័ត្ន នាយិកាសាលាបឋមសិក្សា ហ៊ុន សែន អញ្ចាញ ក្រុងសៀមរាប ចំនួន១០ដើម ដើម្បីយកទៅដាំនៅមុខទីធ្លាសាលារៀន។ កូនឈើទាំងនោះរួមមាន រំដួល៤ដើម ត្របែកព្រៃ៣ដើម និងអង្កាញ់៣ដើម។
- ផ្តល់កូនឈើជូនលោក ប៉ុន ព្យុះ មន្ត្រីរាជការ ចំនួន៣០ដើម ដើម្បីយកទៅដាំលើផ្ទាល់ខ្លួនក្នុងភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប។ កូនឈើទាំងនោះរួមមាន ធ្នង់១៥ដើម បេង៥ដើម និងក្ងោក១០ដើម។
- ផ្តល់កូនឈើជូនលោក ច័ន្ទ រស្មី អ្នកសារព័ត៌មានកោះសន្តិភាពចំនួន១០០ដើមដើម្បីយកទៅដាំលើផ្ទាល់ខ្លួនក្នុងភូមិព្រៃគុយ ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ កូនឈើទាំងនោះរួមមាន គ្រញូង៣០ដើម ធ្នង់២០ដើម បេង២០ដើម និងប្រេស៣០ដើម។
- ផ្តល់កូនឈើជូនតំណាងលោកស្រី ម៉ននី រង្សី អភិបាលស្រុកក្រឡាញ់ ចំនួន១,៥០០ដើម ដើម្បីយកទៅដាំនៅតាម បណ្តោយផ្លូវជាតិលេខ៦រហូតដល់ព្រំប្រទល់ស្រុកពួក និងផ្លូវជាតិលេខ៦៨ដល់ស្រុកស្រីស្នំ និងដាំនៅព្រៃលិចទឹកផង។ កូនឈើទាំងនោះរួមមាន ត្របែកព្រៃ៣០០ដើម ក្ងោក ៥០០ដើម ឥន្ទនេល៣០០ដើម ខ្នារ២០០ដើម និងចាមរី ២០០ដើម៕

អាជ្ញាធរជាតិអប្សរាដំណើរការលើកថ្មប្រាសាទដែលធ្លាក់រាយប៉ាយ ក្នុងកសិន្ធុប្រាសាទបាយ័ននៅរក្សាទុក

ផ្សាយនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២១

ក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា ដំណើរការលើកថ្មប្រាសាទដែលធ្លាក់រាយប៉ាយក្នុងកសិន្ធុខាងត្បូងឆៀងខាងលិចប្រាសាទបាយ័នទៅរក្សាទុកនៅទីតាំងសុវត្ថិភាព។

លោក ស៊ឹម ថន អនុប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ដែលជាអ្នកទទួលខុសត្រូវការដ្ឋានលើកថ្មនេះបានឱ្យដឹងថា ថ្មប្រាសាទដែលស្ថិតនៅរាយប៉ាយក្នុងកសិន្ធុប្រាសាទបាយ័នរាប់រយឆ្នាំមក ហើយនោះមានចំនួនជិត៣០០០ដុំមួយផ្នែករលុះបាក់ធ្លាក់ពីតួប្រាសាទក្បែរនោះនិងមួយផ្នែកទៀតត្រូវគេជញ្ជូនយកទៅដាក់ក្នុងពេលដែលបារាំងធ្វើការជួសជុលប្រាសាទបាយ័ន (ប្រហែលចន្លោះឆ្នាំ១៩១៣-១៩២៩)។

ថ្មដែលអ្នកជំនាញស្រង់បានមកភាគច្រើនជាប្រភេទថ្មភក់ មានដូចជា ថ្មដំបូល ធ្នឹម សសរ ខឿន ថ្មកម្រាល បូករួមទាំងថ្មមានក្បាច់ចម្លាក់ជាដើម។ លោកបន្តទៀតថា គោលបំណងលើកថ្មនេះ គឺដើម្បីរៀបចំទុកដាក់ឱ្យមានសណ្ដាប់ធ្នាប់ល្អ ដើម្បីថែរក្សាទុកត្រៀមបម្រុង សម្រាប់ធ្វើការជួសជុលប្រាសាទឡើងវិញ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ

ផ្សាយនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០២១

ក្នុងសប្តាហ៍ទី៤នៃខែមិថុនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៥គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបាគង បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិដូនន់ ឃុំមានជ័យ ភូមិរលួសខាងលិច ភូមិកញ្ជរ ភូមិចំបក់ ភូមិដូនទាវ ភូមិមមាញ ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិតាត្រៃ ភូមិថ្នល់បណ្តោយ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

ក្រុមការងារប្រចាំស្រុកពួក បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិព្រៃធ្លក ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិដូនឪ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

ក្រុមការងារប្រចាំក្រុងសៀមរាប បានចុះពិនិត្យនិងដោះស្រាយស្ថិតនៅក្នុងភូមិថ្នល់ សង្កាត់ស្រង៉ែ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។

សរុបមក នៅក្នុងសប្តាហ៍ទី៤នៃខែមិថុនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ទាំង៥គោលដៅ បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកំពុងស្ដារប្រព័ន្ធប្រឡាយបុរាណ២ខ្សែ ប្រវែងជាង៣ពាន់ម៉ែត្រ

ផ្សាយនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងទឹក ក៏ដូចជាការបញ្ចៀសទឹកជំនន់នៅក្នុងតំបន់អង្គរ និងក្រុងសៀមរាប ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹក នៃអាជ្ញាធរជាតិអប្សរា បាននិងកំពុងធ្វើការស្ដារឡើងវិញនូវប្រព័ន្ធប្រឡាយបុរាណចំនួន២ខ្សែ ដែលមានប្រវែងសរុប ៣,៣០០ម៉ែត្រ។

ប្រព័ន្ធប្រឡាយដែលបាននិងកំពុងស្ដាររួមមាន ខ្សែទី១ មានប្រវែង២០០០ម៉ែត្រ ស្ថិតនៅផ្នែកខាងលិចស្ទឹងសៀមរាប ដែលមានទីតាំងចាប់ភូមិក្លូង់ ឃុំលាងដៃ ស្រុកអង្គរធំ រហូតដល់ភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប។ ខ្សែទី២ ផ្នែកខាងកើតស្ទឹងសៀមរាប មានប្រវែង ១៣០០ម៉ែត្រ ស្ថិតនៅក្នុងភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី។

ប្រឡាយទាំង២ខ្សែនេះ ជាផ្នែកមួយយ៉ាងសំខាន់នៃប្រឡាយរំដោះទឹកជំនន់ពីស្ទឹងសៀមរាប ទៅស្ទឹងពួក ស្ទឹងព្រះស្រុក និងស្ទឹងរលួស ហើយក៏ជាប្រឡាយនាំទឹកដ៏សំខាន់ ចូលទៅក្នុងកសិន្ទុប្រាសាទអង្គរធំ អង្គរវត្ត បារាយណ៍ខាងជើង បារាយណ៍ខាងលិច និងអាងស្តុកទឹកនានាក្នុងតំបន់អង្គរ អាងស្តុកទឹកភ្នំបូកផងដែរ។ លើសពីនេះទៅទៀត ការងារស្តាប្រឡាយខាងលើនេះ ក៏ផ្តល់ជាប្រយោជន៍ក្នុងការរក្សាទឹកសម្រាប់ការអភិរក្សប្រាសាទ ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ ប្រើប្រាស់ប្រចាំថ្ងៃ និងស្រោចស្រពផងដែរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកអង្គរធំ បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

ក្រុមការងារប្រចាំស្រុកបន្ទាយស្រី បានចុះពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលសំណង់ តូចតាចបានចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមកម្មវិធីជិះកង់ បាទីក្រម៉ា ជាមួយស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ី

ផ្សាយនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២១

នៅព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ នេះ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ដែលមាន **ឯកឧត្តម ឡុង កុសល** អគ្គនាយករងអាជ្ញាធរជាតិអប្សរា និងដោយមានការចូលរួមជាអធិបតីភាពពី **ឯកឧត្តម ប៉ាក់ សុខុម** រដ្ឋលេខាធិការក្រសួងទេសចរណ៍ និង **ឯកឧត្តម ស៊ូឌើរម៉ាន់ ហាសាំង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌូនេស៊ីប្រចាំកម្ពុជា បានចូលរួមកម្មវិធីជិះកង់ផ្សារភ្ជាប់វប្បធម៌ បាទីក្រម៉ា (Batik Kroma) ដែលជាកម្មវិធីធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងស្ថានទូតសាធារណរដ្ឋឥណ្ឌូនេស៊ី។ កម្មវិធីនេះ ធ្វើឡើងក្នុងបំណងបង្កើតទំនាក់ទំនងរវាងប្រទេសទាំងពីរ ក៏ដូចជាបង្កើនការផ្សព្វផ្សាយផ្នែកវប្បធម៌ និងទេសចរណ៍ផងដែរ។

ឯកឧត្តម ស៊ូឌើរម៉ាន់ ហាសាំង (Sudirman Haseng) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌូនេស៊ីប្រចាំកម្ពុជា មានប្រសាសន៍ថា ព្រឹត្តិការណ៍ជិះកង់នេះធ្វើឡើងក្នុងបំណងរក្សាក៏ដូចជាបង្កើនទំនាក់ទំនងរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ។ ជាមួយគ្នានោះ ការជិះកង់នេះក៏ដើម្បីបង្កើនការផ្សព្វផ្សាយផ្នែកវប្បធម៌ និងទេសចរណ៍ពីគ្នាទៅវិញទៅមកផងដែរ។

បន្ថែមពីនេះ ឯកឧត្តមឯកអគ្គរដ្ឋទូតមានសុទិដ្ឋិនិយមថា ព្រឹត្តិការណ៍ជិះកង់នេះនឹងក្លាយជាគំរូមួយដ៏ល្អប្រសើរ ដើម្បីជាការចាប់ផ្តើមនៃការក្រោកឈរឡើងវិញ ប្រយុទ្ធប្រឆាំងនឹងស្ថានការណ៍ដ៏លំបាកក្នុងវិបត្តិជំងឺកូវីដ១៩នេះផងដែរ។

ឯកឧត្តម ប៉ាក់ សុខុម រដ្ឋលេខាធិការក្រសួងទេសចរណ៍ បានកោតសរសើរចំពោះកម្មវិធីនេះ ថាបានបង្ហាញពីអតីតកាលរបស់ប្រទេសកម្ពុជា ក៏ដូចជាការបង្ហាញភាពប្រហាក់ប្រហែលគ្នា នៃផ្នែកវប្បធម៌ និងអារ្យធម៌រវាងប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី។ ការរៀបចំកម្មវិធីជិះកង់នៅក្នុងខេត្តសៀមរាបនេះ មិនមែនជារឿងចៃដន្យទេ ខណៈដែលខេត្តនេះត្រូវបានចាត់ទុកជាទីក្រុងវប្បធម៌នៃប្រទេសអាស៊ាន សម្រាប់ឆ្នាំ២០២១-២០២២៕

លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរប្រជុំដើម្បីសុំយោបល់បច្ចេកទេសអំពីគម្រោងអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២១

លេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ បានចាប់ផ្តើមកិច្ចប្រជុំរបស់ខ្លួនតាមប្រព័ន្ធអេឡិចត្រូនិច (Zoom) រយៈពេល២ថ្ងៃ គឺថ្ងៃទី២៨-២៩ ខែមិថុនា ដើម្បីសុំយោបល់បច្ចេកទេសពីអ្នកជំនាញការចំពោះកិច្ចនៃគណៈកម្មាធិការអាយស៊ីស៊ី-អង្គរ ដោះស្រាយបញ្ហាបន្ទាន់មួយចំនួនទៅលើការងារជួសជុស អភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព។

នេះជាឆ្នាំទី២ហើយ ដែលអ្នកជំនាញការចំពោះកិច្ចដែលមានមូលដ្ឋាននៅបរទេសខកខានធ្វើដំណើរមកប្រជុំដោយផ្ទាល់នៅកម្ពុជាបាន។

កិច្ចការពារបេតិកភណ្ឌវប្បធម៌ជាភារកិច្ចរបស់កូនខ្មែរគ្រប់ៗរូប

ទីស្នាក់ការអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្តល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្តាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្តោយផ្លូវហ្សាលដឺហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានផ្សព្វផ្សាយ
ឆ្នាំ២០២២